មាតិកា

I.ខុទ្ទកាល័យព្រះមហាក្សត្រ

១.ព្រះរាជក្រម

២៣-៦-២០០៦ -ព្រះរាជក្រម នស/រកម/០៦០៦/០១៧ ស្ដីពីការប្រកាសឱ្យប្រើច្បាប់ស្ដីពីការអនុម័តយល់ព្រមលើផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០០៦-២០១០ ***(ត មកពីរាជកិច្ចលេខ ៥១)*** ៤៨៥៣

២៧-៦-២០០៦ -ព្រះរាជក្រម នស/រកម/០៦០៦/០១៩ ស្ដីពីការប្រកាសឱ្យប្រើច្បាប់ស្ដីពីវិសោធនកម្មមាត្រា ១៣ ថ្មី នៃច្បាប់ស្ដីពីវិសោធនកម្ម ច្បាប់ស្ដីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ៤៩២៨

២.ព្រះរាជក្រឹត្យ

២៩-៦-២០០៦ -ព្រះរាជក្រឹត្យ នស/រកត/០៦០៦/២៧៩ ស្ដីពីការតែងតាំងលោក **យ៉េត ចរិយា** បច្ចុប្បន្នព្រះរាជអាជ្ញារង នៃអយ្យការអមតុលាការខេត្តបន្ទាយមានជ័យ ជាព្រះរាជអាជ្ញារង នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ៤៩៣១

២៩-៦-២០០៦ -ព្រះរាជក្រឹត្យ នស/រកត/០៦០៦/២៨០ ស្ដីពីការប្រោសព្រះរាជទាន ចំពោះឯកឧត្តមបណ្ឌិត **ចំន្ទ សារុន** នូវគ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេនា ៤៩៣២

០២-៧-២០០៦ -ព្រះរាជក្រឹត្យ នស/រកត/០៧០៦/២៨២ ស្ដីពីការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស **មេដាយការពារជាតិ** តាមលំដាប់ថ្នាក់ ជូនមន្ត្រីពន្ធនាគារ នៃក្រសួងមហាផ្ទៃ ចំនួន ១២៩ រូប ដែលមានស្នាដៃល្អ និងស្មារតីទទួលខុសត្រូវខ្ពស់ ក្នុងការបំពេញភារកិច្ចបំរើជាតិមាតុភូមិ ៤៩៣៣

០២-៧-២០០៦ -ព្រះរាជក្រឹត្យ នស/រកត/០៧០៦/២៨៣ ស្ដីពីការតម្លើងឋានន្តរស័ក្តិថ្នាក់ ឧត្តមសេនីយ៍ត្រី ជូននាយទាហានជាន់ខ្ពស់ នៃកងយោធពលខេមរភូមិន្ទ ចំនួន ០២ រូប ៤៩៣៨

០៦-៧-២០០៦ -ព្រះរាជក្រឹត្យនស/រកត/០៧០៦/២៨៨ស្ដីពីការតែងតាំងមន្ត្រីរាជការ ៤៩៣៩

០៦-៧-២០០៦ -ព្រះរាជក្រឹត្យ នស/រកត/០៧០៦/២៨៩ ស្ដីពីការតម្លើងឋានន្តរស័ក្តិថ្នាក់ ឧត្តមសេនីយ៍ត្រី ជូននាយនគរបាលជាតិជាន់ខ្ពស់ នៃក្រសួងមហាផ្ទៃ ចំនួន ០៤ រូប ៤៩៤០

០៧-៧-២០០៦ -ព្រះរាជក្រឹត្យ នស/រកត/០៧០៦/២៩០ស្ដីពីការប្រគល់ភារកិច្ចជូនឯកឧត្តម **គាន់ ផវិន្ទ** អោយបំពេញមុខងារជា អគ្គនាយក នៃអគ្គនាយកដ្ឋានអាស៊ាន នៃក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ៤៩៤១

II. រាជរដ្ឋាភិបាល

១. អនុក្រឹត្យ

១២-៧-២០០៦ -អនុក្រឹត្យលេខ ៦៤ អនក្រ.បក ស្តីពីការអនុញ្ញាតច្បាប់ស្តីពីម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់ ៤៩៤២

១៣-៧-២០០៦ -អនុក្រឹត្យលេខ ៤៨៤ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៤៩៦២

១៣-៧-២០០៦ -អនុក្រឹត្យលេខ ៤៨៥ អនក្រ.តត ស្តីពីការជូនមេដាយការងារ ៤៩៦៣

១៣-៧-២០០៦ -អនុក្រឹត្យលេខ ៤៨៦ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៤៩៦៤

១៤-៧-២០០៦ -អនុក្រឹត្យលេខ ៤៨៧ អនក្រ.តត ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ ៤៩៦៥

២. សេចក្តីសម្រេច

១៣-៧-២០០៦ - សេចក្តីសម្រេចលេខ ២៨ សសរ ស្តីពីការកែសំរួលសមាសភាពនៃ គណៈកម្មាធិការជាតិ និងលេខាធិការដ្ឋានគណៈកម្មាធិការជាតិដឹកនាំ បញ្ហាការប្រយុទ្ធ ប្រឆាំង និងទប់ស្កាត់អំពើភេរវកម្ម ៤៩៦៦

១៥-៧-២០០៦ - សេចក្តីសម្រេចលេខ ២៩ សសរ ស្តីពីការផ្ទេរសិទ្ធការងាររបស់រាជរដ្ឋាភិបាល ៤៩៧២

III. ការងារបណ្តាក្រសួង

១. ទីស្តីការរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

២៩-៦-២០០៦ -ប្រកាសលេខ ៧០៦ ឧរថ.កឧ.ប្រក ស្តីពីនីតិវិធីផ្តល់ប្រកាសនីយបត្រតក្កកម្ម និងវិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ ៤៩៧៣

០៥-៧-២០០៦ -ប្រកាសលេខ ៧១៨ ឧរថ.កឧ.ប្រក ស្តីពីការអនុញ្ញាតឱ្យក្រុមហ៊ុន **ជានថេសសា ហ្គាមេន (ខេមបូឌា)** បង្កើតរោងចក្រ "កាត់ដេរសម្លៀកបំពាក់" ដែលមានឈ្មោះថា " ជានថេសសា ហ្គាមេន (ខេមបូឌា)" ៥០០៧

០៥-៧-២០០៦ -ប្រកាសលេខ ៧១៩ ឧរថ.កឧ.ប្រក ស្តីពីការអនុញ្ញាតឱ្យក្រុមហ៊ុន **អ៊ីយ៉ុន (ខេមបូឌា) ហ្គាមេន** បង្កើតរោងចក្រ "កាត់ដេរសម្លៀកបំពាក់" ដែលមានឈ្មោះ ថា " អ៊ីយ៉ុន (ខេមបូឌា) ហ្គាមេន" ៥០០៩

០៥-៧-២០០៦ -ប្រកាសលេខ៧២០ឧរថ.កឧ.ប្រកស្តីពីការអនុញ្ញាតឱ្យក្រុមហ៊ុន **ហ្សន់ជីន (ខេមបូឌា) ខប** បង្កើតរោងចក្រ "កាត់ដេរសម្លៀកបំពាក់" ដែលមានឈ្មោះ ថា " ហ្សន់ជីន (ខេមបូឌា) ខប" ៥០១១

០៥-៧-២០០៦ -ប្រកាសលេខ ៧២១ ឧរថ.កឧ.ប្រក ស្ដីពីការអនុញ្ញាតឱ្យក្រុមហ៊ុន **អ៊ីរូហ្គេត ហ្គាមេន** បង្កើតរោងចក្រ "កាត់ដេរសម្លៀកបំពាក់" ដែលមានឈ្មោះ ថា "អ៊ីរូហ្គេត ហ្គាមេន" ៥០១៣

០៥-៧-២០០៦ -ប្រកាសលេខ ៧២២ ឧរថ.កឧ.ប្រក ស្ដីពីការអនុញ្ញាតឱ្យក្រុមហ៊ុន **ញូ មីងដា (ខេមបូឌា)** បង្កើតរោងចក្រ "កាត់ដេរសម្លៀកបំពាក់" ដែលមានឈ្មោះថា "ញូ មីងដា (ខេមបូឌា)" ៥០១៥

០៥-៧-២០០៦ -ប្រកាសលេខ ៧២៣ ឧរថ.កឧ.ប្រក ស្ដីពីការអនុញ្ញាតឱ្យក្រុមហ៊ុន **យ៉ាកជីន (ខេមបូឌា) អ៊ីន** បង្កើតរោងចក្រ "កាត់ដេរសម្លៀកបំពាក់" ដែលមានឈ្មោះ ថា "យ៉ាកជីន (ខេមបូឌា) អ៊ីន" ៥០១៧

នស/រកម/០៦០៦/០១៧

ព្រះរាជក្រម

យើង

ព្រះករុណាព្រះបាទសម្ដេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងផែនការ
- បានទ្រង់យល់សេចក្ដីក្រាបបង្គំទូលថ្វាយ របស់សម្ដេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា និងរបស់ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងផែនការ

ប្រកាសឱ្យប្រើ

ច្បាប់ស្ដីពីការអនុម័តយល់ព្រមលើផែនការយុទ្ធសាស្ត្រអភិវឌ្ឍជាតិ ២០០៦-២០១០ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី ០៩ ខែ ឧសភា ឆ្នាំ ២០០៦ នាសម័យប្រជុំរដ្ឋសភាលើកទី ៤ នីតិកាលទី ៣ និងដែលព្រឹទ្ធសភាបានពិនិត្យ និងផ្ដល់យោបល់យល់ស្របលើទម្រង់ និងគតិច្បាប់ព្រមទាំងលើខ្លឹមសារនៃអត្ថបទច្បាប់នេះទាំងស្រុងដោយគ្មានការកែប្រែអ្វីឡើយ កាលពីថ្ងៃទី ០៩ ខែមិថុនា ឆ្នាំ ២០០៦ នាសម័យប្រជុំពេញអង្គលើកទី១នីតិកាលទី២ ហើយដែលមានសេចក្ដីទាំងស្រុងដូចតទៅនេះ :

ច្បាប់
ស្តីពី
ការអនុម័តយល់ព្រមលើ
ផែនការយុទ្ធសាស្ត្រអភិវឌ្ឍជាតិ ២០០៦-២០១០

មាត្រា ១.-

អនុម័តយល់ព្រមលើផែនការយុទ្ធសាស្ត្រអភិវឌ្ឍជាតិ ២០០៦-២០១០ ដូចមានអត្ថបទទាំងស្រុងភ្ជាប់មកជាមួយនេះ ។

មាត្រា ២.-

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបន្តអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍជាតិ ២០០៦-២០១០ នេះ ។

ធ្វើនៅព្រះបរមរាជវាំងរាជធានីភ្នំពេញថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ ២០០៦

នស/រកម.០៦០៦.២៩១ **ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

នរោត្តម សីហមុនី

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

នាយករដ្ឋមន្ត្រី

ហត្ថលេខា

ហ៊ុន សែន

បានជម្រាបជូនសម្តេចនាយករដ្ឋមន្ត្រី

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងផែនការ

ហត្ថលេខា

ឆាយ ថន

លេខ: ៧៦៤ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ មិថុនា ឆ្នាំ២០០៦

អគ្គលេខាធិការរងរាជរដ្ឋាភិបាល

ឃន ជិនកេន

(ត មកពីរាជកិច្ចលេខ ៥១)



ជំពូក ៥

ចំណាយ មូលធន

និងការរៀបចំកម្មវិធី

ជំពូក ៥

ចំណាយ ធនធាន និងការរៀបចំកម្មវិធី

៥.០១ ការអនុវត្តប្រកបដោយជោគជ័យ និងទាន់ពេលវេលានៃយុទ្ធសាស្ត្រ និងសមិទ្ធផលនៃចំណុចដៅ[១] *ផយអជ* អំពាវនាវរកការវិនិយោគបន្ថែមដែលត្រឹមត្រូវនិងចំទិសដៅ និងការប្រើប្រាស់ដោយផ្តោតចំបញ្ហានិងប្រកបដោយប្រសិទ្ធភាព ។ ការវិនិយោគទាំងនេះ នឹងត្រូវប្រព្រឹត្តទៅ ទាំងក្នុងវិស័យឯកជនដើម្បីធ្វើឱ្យមានចីរភាពនិងបង្កើនសកម្មភាពសេដ្ឋកិច្ច ទាំងក្នុងវិស័យសាធារណៈដើម្បីផ្តល់កម្លាំងជំរុញកំណើននិងការកាត់បន្ថយភាពក្រីក្រ ។ ជំពូកនេះ ផ្តោតជាសំខាន់លើវិស័យសាធារណៈ ដែលទាក់ទងនឹង :

- កម្រិតនៃការវិនិយោគសាធារណៈ ដែលត្រូវការចាំបាច់ក្នុងរយៈពេលនៃការអនុវត្ត *ផយអជ* (២០០៦-២០១០) ដោយគិតពិចារណាផងដែរនូវរាល់ឧបសគ្គនានា ដែលបណ្តាលមកពីសមត្ថភាពស្រូបយកនៃប្រព័ន្ធរដ្ឋបាលសាធារណៈ ។
- ប្រភពផ្សេងៗនៃមូលនិធិសម្រាប់ការវិនិយោគ ។
- របៀបរបប និតិវិធី និងវិធីសាស្ត្ររៀបចំកម្មវិធី និងប្រតិបត្តិការនៃការវិនិយោគ ។

៥.០២ ការព្យាករណ៍ម៉ាក្រូសេដ្ឋកិច្ចដែលមានការឯកភាពពីមូលនិធិរូបិយវត្ថុអន្តរជាតិ បានគ្រោងទុកជាមុននូវកំណើន *ផសស* ថេរមួយស្មើ ៦,០ភាគរយ ក្នុងរយៈពេលប្រាំឆ្នាំនៃ *ផយអជ* (២០០៦-២០១០) ដោយបានថ្លឹងថ្លែងអំពីកត្តាខាងក្រៅនិងខាងក្នុងដែលអាចប៉ាន់ស្មានបាន (ឧបសម្ព័ន្ធ២.១) ។ ដើម្បី សម្រេចបានកម្រិតកំណើននេះ វិស័យនីមួយៗត្រូវឱ្យមានអត្រាកំណើនប្រចាំឆ្នាំដែលអាចព្យាករណ៍បាន ដែលអាចធ្វើបានពិតប្រាកដ ដូចដែលមានក្នុងឧបសម្ព័ន្ធ២.១ ។ ដើម្បីសម្រេចបានកម្រិតនានាដូចដែលបានព្យាករណ៍នៃកំណើនតាមវិស័យ កម្រិតអប្បបរមាពិតប្រាកដនៃ "ការវិនិយោគពិតប្រាកដ" គឺជាការចាំបាច់នៅក្នុងវិស័យផ្សេងៗ (ឧបសម្ព័ន្ធ ២.២) ។

---

[១] ជំពូក៣ និង ៤

តារាង៥.១ : កម្រិតវិនិយោគដែលចាំបាច់

២០០៦-២០១០ (លានដុល្លារអាមេរិក)

[illegible]	[illegible]
ក្នុងនោះ វិនិយោគសាធារណៈ :	២.៣៨៤.៦០
-ហិរញ្ញប្បទានក្នុងស្រុក	៧៨៣.៣០
-ហិរញ្ញប្បទានក្រៅប្រទេស	១.៦០១.៣០
វិនិយោគឯកជន :	៤.០១៦.៥០
-ហិរញ្ញប្បទានក្នុងស្រុក	២.៧៥៨.៥០
-ហិរញ្ញប្បទានក្រៅប្រទេស	១.២៥៨.០០
ហិរញ្ញប្បទានក្នុងស្រុកសរុប	៣.៥៤១.៨០
ហិរញ្ញប្បទានក្រៅស្រុកសរុប	២.៨៥៩.៣០

ប្រភព: ឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ និងឧបសម្ព័ន្ធ ២.២

៥.០៣ ការវិនិយោគក្នុងវិស័យឯកជនរួមមានពីរផ្នែក ការវិនិយោគក្នុងប្រទេស និងការវិនិយោគផ្ទាល់ពីក្រៅប្រទេស ។ ការព្យាករណ៍ម៉ាក្រូសេដ្ឋកិច្ច បានប៉ាន់ប្រមាណថា ការវិនិយោគផ្ទាល់ពីក្រៅប្រទេស ដែលបច្ចុប្បន្នភាគច្រើនស្ថិតនៅក្នុងផ្នែកឧស្សាហកម្មសំលៀកបំពាក់ និងវិស័យទេសចរណ៍ អាចនឹងលើសពី ១.២៥៨លានដុល្លារអាមេរិក ក្នុងរយៈពេលផែនការនេះ ។ រាជរដ្ឋាភិបាលកម្ពុជាមានជំនឿថា ការវិនិយោគផ្ទាល់ពីក្រៅប្រទេសអាចកើនទៅដល់កម្រិតមួយខ្ពស់ជាងច្រើន ក្នុងអំឡុងពេលនៃ*ផយអជ*[១] ហើយអាចនឹងធ្វើឱ្យមានសកម្មភាពខ្លាំងក្លា និងចម្រុះប្រភេទ ដើម្បីគ្របដណ្តប់យ៉ាងទូលំទូលាយ និងស៊ីជម្រៅទៅលើផ្នែកអន្តរវិស័យជាច្រើន និងបែងចែកតាមតំបន់ភូមិសាស្ត្រនានា ហើយនិងប្រកបដោយចីរភាពក្នុងរយៈពេលវែង ។ រាជរដ្ឋាភិបាលនឹងធានាថា ប្រការនេះអាចសម្រេចបានតាមរយៈ កំណែទម្រង់ផ្នែករដ្ឋបាលច្បាប់ និងហិរញ្ញវត្ថុ ដូចដែលបានបញ្ជាក់រួចមកហើយនៅក្នុងជំពូក៤ ដើម្បីបង្កើតបាននូវបរិយាកាសមួយប្រកបដោយភាពងាយស្រួលនិងមានការប្រកួតប្រជែង ហេតុដូចនេះ កម្ពុជានឹងក្លាយទៅជាប្រទេសដែលមានការលួតលាស់ និងប្រកបដោយសុវត្ថិភាព អាចព្យាករណ៍បាន និងមានផលចំណេញសម្រាប់រយៈពេលវែងចំពោះការវិនិយោគផ្ទាល់ពីក្រៅប្រទេសទាំងឡាយ ។

៥.០៤ វិស័យហិរញ្ញវត្ថុ (ធនាគារនិងការធានារ៉ាប់រង) មិនទាន់ក្លាយជាដៃគូសំខាន់មួយក្នុងការវិនិយោគក្នុងប្រទេសនៅឡើយ ទោះបីជាធនាគារផ្តល់គណនីផ្សេងៗជាច្រើន រួមមានគណនីជនបទក៏ដោយ ។ អត្រាការប្រាក់កម្ចីខ្ពស់ បានធ្វើឱ្យការខ្ចីប្រាក់ពុំមានការកើនឡើង ។ កម្រិតការខ្ចីប្រាក់ពីស្ថាប័នហិរញ្ញវត្ថុសម្រាប់ការវិនិយោគរយៈពេលវែងនៅតែមានកំរិតទាបខ្លាំង ។ ប្រាក់ដុល្លារអាមេរិកមួយចំនួនធំ ដែលបាន[illegible]

[១] ការប៉ាន់ស្មានដែលបានធ្វើការកែសម្រួលនៅខែធ្នូ ឆ្នាំ២០០៥ បានដាក់បញ្ចូលតួលេខនេះក្នុងកម្រិត ១.៣៨៤លានដុល្លារ (សូមមើល[illegible] ឧបសម្ព័ន្ធ២.១ ។

ក្នុងប្រទេសកម្ពុជា មិនទាន់បានយកទៅប្រើប្រាស់ឱ្យបានពេញលេញសម្រាប់ការវិនិយោគក្នុងប្រទេសនៅឡើយ ហើយប្រាក់មួយចំនួនបែរជាត្រូវយកទៅវិនិយោគនៅទីកន្លែងផ្សេងទៅវិញ[១] ។ ដូច្នេះ ការជំរុញឱ្យធនាគារផ្តល់មូលនិធិបម្រើការងារសម្រាប់កំណើនសេដ្ឋកិច្ចកម្ពុជា គឺជាអាទិភាពដ៏សំខាន់មួយ នឹងអាចធ្វើទៅបានតាមរយៈការបង្កើនតម្រូវការសម្រាប់ការវិនិយោគនានាក្នុងប្រទេស ។

៥.០៥ *ជំពូកនេះស្តីពី ការវិនិយោគសាធារណៈ ឬការវិនិយោគវិស័យសាធារណៈ*[២] ។ ថវិកាចំនួន ២.៣៨៤.៦០ លានដុល្លារអាមេរិកក្នុងតារាង៥.១ សម្រាប់ការវិនិយោគសាធារណៈ ផ្តោតជាសំខាន់លើ "*ការវិនិយោគមូលធន*" ឬ "*ការវិនិយោគពិត*" ។ ការវិនិយោគនេះ បង្ហាញពី "*លទ្ធភាពអាចធ្វើទៅបាន*" ប៉ុន្តែមិនបានយកមកពិចារណាពេញលេញនូវរាល់ "*តម្រូវការ*" ចាំបាច់ក្នុងការចំណាយសម្រាប់វិស័យសង្គមកិច្ច និងវិស័យផ្សេងៗទៀត ដើម្បីសម្រេចបាន *គអសក* និងគោលដៅរួមនានាដែលបានលើកឡើងក្នុងជំពូក៣[៣] ព្រមទាំងការចំណាយចរន្តបន្ថែមដែលមានកើតឡើងដោយសារការវិនិយោគថ្មីៗ និងការកើនឡើងនៃការចំណាយផ្សេងៗ ។ "*តម្រូវការ*" នាពេលអនាគតក្នុងវិស័យសាធារណៈ ដែលហួសនិងខ្ពស់ជាងចំនួនដែលត្រូវចំណាយ ដូចជាចំណាយចរន្តថែងក្នុងថវិកាប្រចាំឆ្នាំ (ដែលភាគច្រើនឆ្ពោះទៅរកការចំណាយសង្គមនិងចំណាយជាអាទិភាពផ្សេងទៀត ហើយដាច់ដោយឡែកពីចំណាយលើផ្នែកការពារជាតិនិងសន្តិសុខ) រួមមានដូចខាងក្រោម :

- ការវិនិយោគមូលធនថ្មី និងចំណាយបន្ថែមលើការវិនិយោគដែលកំពុងដំណើរការ ។
- ការចំណាយចរន្តបន្ថែម ដែលកើនហួសនិងខ្ពស់ជាងការកើនឡើងជាធម្មតានៃមុខចំណាយដែលមានស្រាប់ (ដូចជា បៀវត្សរ៍មន្ត្រីរាជការស៊ីវិល) រួមបញ្ចូលទាំងចំណាយថែទាំបន្ថែមលើការវិនិយោគថ្មីៗ ។
- ការចំណាយបន្ថែមទៅលើមុខចំណាយមិនមែនមូលធន ដូចជា ការឧបត្ថម្ភបន្ថែមនិងអាហារូបករណ៍ថ្មី ឬបន្ថែម ។
- ការចំណាយទៅលើជំនួយបច្ចេកទេសក្រៅប្រទេស ទោះបីស្ថិតនៅក្នុងកម្រិតត្រូវកាត់បន្ថយយ៉ាងឆាប់រហ័សក៏ដោយ ។

៥.០៦ ដើម្បីសម្រុះសម្រួលដល់ការចំណាយដែលចាំបាច់ទាំងអស់សម្រាប់ធ្វើឱ្យសម្រេចគោលដៅនិងចំណុចដៅទាំងឡាយ (ជាពិសេស *គអសក*) បរិមាណចំណាយហិរញ្ញវត្ថុសរុបក្នុងអំឡុងពេល *ផយអជ* (២០០៦-២០១០) ចាំបាច់ត្រូវមាន (គិតជាលានដុល្លារអាមេរិក) :

[១] ដូចនៅពាក់កណ្តាលឆ្នាំ២០០៥ ប្រាក់បញ្ញើជាដុល្លារអាមេរិកនៅធនាគារពាណិជ្ជមាន ៨៥៧លាន ដែលត្រូវបានបញ្ចេញឱ្យខ្ចី [illegible] វិញចំនួនផ្សេងទៀត ត្រូវបាននាំចេញទៅក្រៅប្រទេស ។

[២] ការវិនិយោគទាំងនេះត្រូវបានកំណត់លើវិស័យ និងសកម្មភាពទាំងឡាយដែលផ្នែកឯកជនពុំមានបំណង ឬមាន [illegible] ប៉ុន្តែជាការវិនិយោគដែលត្រូវការចាំបាច់សម្រាប់ការអភិវឌ្ឍប្រទេស ។

[៣] ជំពូក ៣ : តារាង ៣.២

▪ ការវិនិយោគវិស័យសាធារណៈតាមចំណោលម៉ាក្រូសេដ្ឋកិច្ច[១]	២.៣៨៤,៦០
▪ បន្ថែម : វិស័យសង្គមកិច្ចបន្ថែម និងចំណាយអភិបាលកិច្ច	៣០០,០០
ជំនួយបច្ចេកទេស ការបណ្ដុះបណ្ដាល និងអង្កេត	៥០០,០០
ចំណាយចរន្តបន្ថែម	៣០០,០០
ទុនបម្រុងសម្រាប់វិស័យផលិត	១៥,៤០
ចំណាយសរុប[២]	**៣.៥០០,០០**

៥.០៧ សូចនាករដែលគួរឱ្យជឿបានផ្សេងទៀតនៃចំណាយ "*ចាំបាច់*" គឺ សេចក្ដីលម្អិតនៃកម្មវិធី និងសកម្មភាពនានាទៅតាមការប៉ាន់ស្មានចំណាយដែលមានចែងក្នុងកម្មវិធីវិនិយោគសាធារណៈ៣ឆ្នាំរំកិល *(កវស)* ដែលមិនគ្រាន់តែឆ្លុះបញ្ចាំងនូវសំណើរបស់បណ្ដាក្រសួង និងស្ថាប័ននានាទេ ប៉ុន្តែក៏ឆ្លុះបញ្ចាំងពីសមត្ថភាពដែលស្រូបបានរបស់គេដែរ ។ តាមរយៈការធ្វើចំណោលលើចំនួនសរុប ១.៩៣៧,៥៩ លានដុល្លារអាមេរិកដែលប៉ាន់ប្រមាណក្នុងកម្មវិធីវិនិយោគសាធារណៈ ឆ្នាំ២០០៥-២០០៧[៣] តាមរយៈនិងការគិតគូរពិចារណាអំពីតម្រូវការសម្រាប់គំនិតផ្ដួចផ្ដើមសំខាន់ៗ ក្នុងការជំរុញល្បឿនរីកចម្រើនដើម្បីឈានទៅទៅសម្រេចបានគោលដៅ និងចំណុចដៅនៅឆ្នាំ២០១០ ចំណាយហិរញ្ញវត្ថុសរុប នៃ *ផយអជ* អាចត្រូវការថវិកាចំនួន ១៥.២២៥ពាន់លានរៀល ស្មើនឹង ៣.៥០០លានដុល្លារអាមេរិក[៤] ដោយមានកម្រិតដូចគ្នាដោយចៃដន្យ ជាមួយនឹងចំនួនដែលបានមកពីក្របខ័ណ្ឌម៉ាក្រូសេដ្ឋកិច្ចនៃកថាខ័ណ្ឌ ៥.០៦ ខាងលើ ។ បរិមាណនេះអាចមានប្រហែល ៧០០លានដុល្លារ ជាមធ្យមក្នុងមួយឆ្នាំ ដែលកាន់តែកើនឡើងជាលំដាប់ពីឆ្នាំ២០០៦ ។

៥.០៨ នៅពេលរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ[៥] កម្មវិធី និងគម្រោងលម្អិតដែលបានស្នើឡើងមិនទាន់ត្រូវបានរៀបចំពេញលេញ សម្រាប់បញ្ហាតាមវិស័យនីមួយៗ និងបញ្ហាអន្តរវិស័យ ។ ដូចបានលម្អិតក្នុងជំពូកមុនៗ រួចមកហើយ[៦] កម្មវិធីនិងគម្រោងទាំងនោះ នឹងត្រូវរៀបចំឡើងនៅដើមឆ្នាំ២០០៦ ចាប់ផ្ដើមគិតគូរដោយពេញលេញនូវអាទិភាពពិតប្រាកដ ដូចមាននៅក្នុងកថាខ័ណ្ឌ ៤.០៥ នៃជំពូក៤ ។ ដូច្នេះ នៅដំណាក់កាលនេះ មិនអាច ឬចាំបាច់ធ្វើការកំណត់នូវការចំណាយផ្សេងៗសម្រាប់សកម្មភាពនានាក្នុងកម្រិតជាក់លាក់ពិតប្រាកដមួយនោះឡើយ ។

---

[១] ឧបសម្ព័ន្ធ ២.២ ។

[២] បរិមាណសរុប ៣.៥០០លានដុល្លារ គឺជាចំណាយសរុបសម្រាប់វិស័យសាធារណៈ ដែលបានបញ្ជាក់នៅ កថាខ័ណ្ឌ ៥.០៥ ដែលបរិមាណវិនិយោគសរុប ៣.៥៤០.៨លានដុល្លារ ដែលបានមកពី "ប្រភពហិរញ្ញវត្ថុក្នុងស្រុក" ក្នុងតារាង ៥.១ គឺជាទុនសុទ្ធ ដែលចំណាយទាំងសម្រាប់វិស័យសាធារណៈ ៧៨៣.៣ លានដុល្លារ និងវិស័យឯកជន ២.៧៥៨.៥០លានដុល្លារ នេះជាតួលេខពីរប្រហាក់ប្រហែលគ្នា ។

[៣] សូមអានទំព័រ ១១៤ (ឯកសារភាសាអង់គ្លេស) នៃការអនុវត្តយុទ្ធសាស្ត្រចតុកោណ និងតម្រូវការជំនួយអភិវឌ្ឍន៍ ខែវិច្ឆិកា ឆ្នាំ២០០៤ ដែលបានដាក់ជូន ក្នុងកិច្ចប្រជុំពិគ្រោះយោបល់ឆ្នាំ២០០៤ ។

[៤] ឧបសម្ព័ន្ធ ២.២ ។

[៥] ខែវិច្ឆិកា ឆ្នាំ២០០៥ : កវស សម្រាប់ឆ្នាំ២០០៦-២០០៨ នឹងត្រូវរួចរាល់នៅខែធ្នូ ឆ្នាំ២០០៥

[៦] ជំពូកទី ១: កថាខ័ណ្ឌ ១.១១ ជំពូក ៣: កថាខ័ណ្ឌ ៣.១៣ ជំពូក ៤: កថាខ័ណ្ឌ ៤.០៥

ក្នុងករណីខ្លះ ការចំណាយបែបនេះ ត្រូវបានគណនាក្នុងលក្ខណៈលម្អិតបន្ថែមទៀត នៅពេលណាដែលកម្មវិធីនិងសកម្មភាពទាំងនោះ ត្រូវបានគ្រោងរៀបចំ ហើយអាចមានលទ្ធភាពធនធាន ហើយនឹងត្រូវយកទៅបង្ហាញជាបន្តបន្ទាប់នៅក្នុងកម្មវិធីវិនិយោគសាធារណៈបីឆ្នាំរំកិល ។

៥.០៥ *ការធ្វើវិភាជន៍ការចំណាយទូទៅ* : គប្បីផ្តល់លទ្ធភាពធនធានឱ្យបានគ្រប់គ្រាន់ ចំពោះវិស័យទាំងឡាយដើម្បីអាចសម្រេចបានគោលដៅនិងចំណុចដៅជាអាទិភាព ក្នុងស្មារតីរក្សាតុល្យភាព ដែលផ្តោតឱ្យចំទិសដៅ និងឆ្ពោះទៅរកអ្វីមួយច្បាស់លាស់ ដូចបានពិភាក្សារួចមកហើយក្នុងជំពូក៣ និងជំពូក៤ ។ ដូចបានលើកឡើងនៅផ្នែកខាងដើមរួចមកហើយ គោលដៅចម្បង គឺកាត់បន្ថយភាពក្រីក្រ ដែលការងារនេះទាមទារបង្កើនការវិនិយោគនៅតំបន់ជនបទ និងតំបន់ដាច់ស្រយាល ដែលមានប្រជាជនក្រីក្រជាង៩០ភាគរយរស់នៅ ដោយផ្តោតជាសំខាន់ទៅលើកំណើនកសិកម្ម ។ វិស័យផលិតកម្មទាំងអស់ដែលនាំឱ្យមានកំណើន ចាំបាច់ត្រូវធានាឱ្យមានធនធានតាមតម្រូវការ ។ ដូចគ្នានេះដែរ វិស័យសង្គមកិច្ចជាអាទិភាព ដែលជួយជំរុញប្រមូលផ្តុំ និងធានាចីរភាពនៃធនធានមនុស្ស (ដែលរួមចំណែកផងដែរចំពោះកំណើនសម្រាប់រយៈពេលវែង) ត្រូវទទួលបាននូវការផ្គត់ផ្គង់ធនធានដែលត្រូវការចាំបាច់ ។ ដោយផ្អែក តាមសេចក្តីត្រូវការជាមុនទាំងនេះ និងដោយសារតែពុំមានការណែនាំណាដែលគួរឱ្យជឿទុកចិត្តបានក្នុងការវិនិយោគកន្លងមក[7] ការធ្វើវិភាជន៍ដ៏ល្អប្រសើរបំផុតនូវធនធានទាំងអស់ នឹងត្រូវធ្វើឡើង ដោយផ្តោតលើកំណើនជាអាទិភាព និងផ្នែកអភិវឌ្ឍន៍ធនធានមនុស្ស ដើម្បីបង្កើនល្បឿនអភិវឌ្ឍន៍ និងសម្រេចបាននូវការកាត់បន្ថយ ភាពក្រីក្រព្រមទាំងចំណុចដៅនានានៅក្នុងគោលដៅសហស្សវត្សរ៍កម្ពុជា ។ ដោយហេតុនេះហើយ រាជរដ្ឋាភិបាលកម្ពុជា បានសម្រេចថា ចំណាយសរុបចំនួន ១៥.២២៥ពាន់លានរៀល ស្មើនឹង ៣.៥០០លានដុល្លារអាមេរិក ដែលគ្រោងសម្រាប់វិស័យសាធារណៈតែមួយសម្រាប់រយៈពេល (២០០៦-២០១០) នឹងត្រូវបែងចែក ដូចមាន បង្ហាញក្នុងតារាង ៥.២ ។ ទិដ្ឋភាពសំខាន់ៗមួយចំនួន នៅក្នុងតារាងមានដូចតទៅ :

- ការធ្វើវិភាជន៍ការចំណាយលើវិស័យសាធារណៈ ត្រូវស្របជាមួយការព្យាករណ៍ម៉ាក្រូសេដ្ឋកិច្ច ។

[7] ទំព័រ៤៣នៃឯកសាររបាយការណ៍ស្តីពីកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ឆ្នាំ២០០២និងឆ្នាំ២០០៣ (តុលា២០០៤) របស់ កអក/គជអ បង្ហាញពីតួលេខចំណាយរបស់ដៃគូអភិវឌ្ឍន៍ក្រៅប្រទេសសម្រាប់ឆ្នាំ១៩៩២-២០០៣ ។ តួលេខទាំងនោះ មិនមានភាពជាក់លាក់សម្រាប់ធ្វើការប្រៀបធៀបឡើយ ដោយសារ (ក) ចំណាត់ថ្នាក់មិនស៊ីគ្នាទៅនឹងតារាង៥.២ (ដែលតារាងនេះមានទម្រង់ដូចគ្នានឹងតារាងនៅក្នុងទំព័រ១១៤ នៃឯកសារកអក/គជអ ខែវិច្ឆិកា ឆ្នាំ២០០៤ ដែលបានបង្ហាញនៅក្នុងកិច្ចប្រជុំពិគ្រោះយោបល់នាខែធ្នូ ឆ្នាំ២០០៤) (ខ) ចំណាយអភិវឌ្ឍន៍កន្លងមក ដែលភាគច្រើនបំផុតបានមកពីដៃគូអភិវឌ្ឍន៍ក្រៅប្រទេស ពុំបានតម្រង់ទិសច្បាស់លាស់ស្របទៅតាមទិសដៅរបស់ផែនការអភិវឌ្ឍន៍សេដ្ឋកិច្ច-សង្គមកិច្ចលើកទី១និងទី២ទេ ប៉ុន្តែបានផ្អែកទៅលើអាទិភាពនិងការជ្រើសរើសរបស់ដៃគូអភិវឌ្ឍន៍ក្រៅប្រទេសផ្ទាល់ ទោះជាដូចនេះក្តី ការចំណាយបែបនេះ ពិតជាបានរួមចំណែកធ្វើឱ្យមានកំណើន ដោយហេតុថា ការចំណាយណាមួយ អាចត្រូវបានធ្វើឡើង នៅក្នុងពេលដែលប្រទេសមួយចាប់ផ្តើមស្តារពីចំណុចសូន្យ ដូចដែលកម្ពុជាបានឆ្លងកាត់រួចមកហើយ ។ ហេតុនេះ *ផសអជ* ធ្វើការវិភាជន៍ធនធានដែលមានលក្ខណៈប្រសើរជាងមុន ស្របទៅតាមទិសដៅអាទិភាពនានា ។

- ការធ្វើវិភាជន៍ទាំងនេះ ត្រូវតែជាក់ស្តែង ដែលទាក់ទងទៅនឹងលទ្ធភាពធនធានដែលមាន ឧទាហរណ៍ ៣.៥០០លានដុល្លារអាមេរិក (ប្រសិនបើធនធានពីដៃគូអភិវឌ្ឍន៍ក្រៅប្រទេសទាំងអស់មានភាពរលូនត្រឹមត្រូវទៅនឹង *ផយអជ*) ។
- ការធ្វើវិភាជន៍ចំពោះវិស័យសាធារណៈ ត្រូវផ្តោតទៅលើ និងក្នុងរង្វង់វិស័យនិងសកម្មភាពទាំងឡាយដែលមិនមានវិសាលភាពក្នុងការទាក់ទាញវិនិយោគ ឬការចូលរួមពីវិស័យឯកជន ។
- ដោយសារការកាត់បន្ថយភាពក្រីក្រជាអាទិភាពខ្ពស់បំផុត ហើយកម្រិតភាពក្រីក្រខ្ពស់នៅតំបន់ជនបទ វិស័យសាធារណៈ ត្រូវផ្តោតការយកចិត្តទុកដាក់ជាពិសេសទៅលើតំបន់ជនបទ ដែលជាង៦០ភាគរយនៃធនធាន នឹងត្រូវផ្តល់ផលប្រយោជន៍ចំពោះតំបន់ជនបទ ។
- សកម្មភាពជាអាទិភាពនានា ផ្សារភ្ជាប់ជាមួយវិស័យសេដ្ឋកិច្ច-សង្គមកិច្ច នឹងមានផលឥទ្ធិពលភ្លាមៗចំពោះការកាត់បន្ថយភាពក្រីក្រ ការសម្រេចបាននូវ *គអសក* និងចំណុចដៅនៃកំណើនសេដ្ឋកិច្ច ។
- បរិមាណទឹកប្រាក់៣.៥០០លានដុល្លារ គឺមានរាប់បញ្ចូលនូវការចំណាយក្នុងវិស័យសាធារណៈ (កថាខ័ណ្ឌ ៥.០៥) ដែលបានមកពីគ្រប់ប្រភពទាំងអស់ ដូចបានរៀបរាប់នៅក្នុងកថាខ័ណ្ឌ៥.១១ (ដែលភាគច្រើនពុំស្ថិតក្នុងថវិកាជាតិបច្ចុប្បន្ន) ។ បរិមាណនេះ មិនរាប់បញ្ចូលការវិនិយោគ ឬការចូលរួមរបស់ផ្នែកឯកជនទេ ទោះជាផ្នែកមួយ ឬផ្នែកទាំងអស់ដែលបានវិនិយោគទៅលើហេដ្ឋារចនាសម្ព័ន្ធសាធារណៈ ឬក៏សកម្មភាពវិស័យសាធារណៈផ្សេងៗ តាមរយៈ *សាងសង់-ដំណើរការ-ផ្ទេរ* ឬតាមការរៀបចំស្រដៀងៗគ្នានេះ ក៏ពុំមានរាប់បញ្ចូលដែរ ។
- ការធ្វើវិភាជន៍ទៅគ្រប់វិស័យទាំងអស់ ត្រូវបានផ្អែកទៅលើការប៉ាន់ស្មានពីតម្រូវការ ហើយទ្រទ្រង់ដល់កំណើនដែលបានរំពឹងទុកជាមុន ដើម្បីឆ្ពោះទៅកាត់បន្ថយភាពក្រីក្រ និងសម្រេចគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា ។
- ការពន្យល់លម្អិតមានផ្តល់ជូនជាកំណត់សម្គាល់នៅផ្នែកខាងក្រោមនៃតារាង ។

៥.១០ រាជរដ្ឋាភិបាលកត់សម្គាល់ថា មានកម្មវិធី និងគម្រោងនានាកំពុងដំណើរការ ជាពិសេស កម្មវិធីនិងគម្រោងដែលគាំទ្រដោយដៃគូអភិវឌ្ឍន៍ក្រៅប្រទេស ដែលស្រូបយកផ្នែកខ្លះនៃធនធានដែលអាចរកបាន ។ រាជរដ្ឋាភិបាលនឹងពិនិត្យឡើងវិញ (តាមរយៈយន្តការក្រុមការងារបច្ចេកទេស ជាឧទាហរណ៍) ដើម្បីឱ្យដឹងថាកម្មវិធី និងគម្រោង ទាំងអស់នេះស្ថិតនៅក្នុងព្រំដែននៃអាទិភាពនានាដែលបានគ្រោងឡើងក្នុងឯកសារនេះ ។ លើសពីនេះទៀត តាមរយៈការពិនិត្យឡើងវិញរបៀបនេះ រាជរដ្ឋាភិបាលនឹងខិតខំប្រឹងប្រែង ក្នុងការធានាថា ធនធានដែលប្រើប្រាស់ ចំពោះការចំណាយគ្មានអាទិភាព នឹងត្រូវបានតម្រង់ទិសសារជាថ្មី ដើម្បីឱ្យវិស័យអាទិភាពអាចទទួលបានចំណែក តាមតម្រូវការនៅក្នុងការវិភាជន៍ចុងក្រោយ ដូចមានក្នុងតារាង៥.២ ។

ផែនការលម្អិត នឹងត្រូវបង្កើតឡើង ដើម្បីប្រើប្រាស់ថវិកាវិភាជន៍ ដោយមានការពិគ្រោះយោបល់យ៉ាងជិតស្និទ្ធជាមួយបណ្ដាក្រសួង និងស្ថាប័នពាក់ព័ន្ធនានា[១] ។

ធនធានដែលអាចរកបានសម្រាប់វិស័យសាធារណៈ

៥.១១ រាជរដ្ឋាភិបាលកម្ពុជាជឿជាក់ថា ការចំណាយដែលបានប៉ាន់ស្មានសរុប ចំនួន៣.៥០០លានដុល្លារសម្រាប់វិស័យសាធារណៈក្នុងកំឡុងពេល *ផយអជ* ២០០៦-២០១០ អាចទទួលបានពីប្រភពមូលនិធិ ដូចខាងក្រោម :

- អតិរេក (សម្រាប់មូលធនវិនិយោគ) នៅក្នុងថវិកាប្រចាំឆ្នាំរបស់រដ្ឋាភិបាល (ចំណូលសរុបគិតទាំងចំណូលចរន្តនិងចំណូលជាទុន ដកចេញនូវជំនួយដោយមានការជួយផ្គត់ផ្គង់តិចតួចពីដៃគូអភិវឌ្ឍន៍ក្រៅប្រទេស ចំណាយចរន្ត ដោយរួមបញ្ចូលទាំងសេវាកម្ម បំណុល និងសំណង) ។
- ជំនួយឥតសំណងពីដៃគូអភិវឌ្ឍន៍ក្រៅប្រទេស (ទ្វេភាគី ពហុភាគី និងអង្គការក្រៅរដ្ឋាភិបាលនានា)[២] ។
- ប្រាក់កម្ចីសម្បទានពីដៃគូអភិវឌ្ឍន៍ក្រៅប្រទេស (សំខាន់ពីស្ថាប័នហិរញ្ញវត្ថុពហុភាគី) ។
- ប្រភពធនធានមិនមែនប្រពៃណី រួមទាំងដៃគូអភិវឌ្ឍន៍ក្រៅប្រទេសដែលមិនមែនជាប្រពៃណី (មានទាំងជំនួយឥតសំណង និងកម្ចីពាក់កណ្ដាលសម្បទាន[៣]) ។
- ការបន្ធូរបន្ថយបំណុលទំនងជាអាចប្រព្រឹត្តទៅបាន ពីព្រោះតែស្ថានភាពកម្ពុជាជាប្រទេសមានចំណូលតិច ដូច្នេះនឹងមានការបញ្ចេញមូលនិធិពីសេវាកម្មបំណុល ដើម្បីសម្រេចបានចំណុចដៅដ៏សំខាន់នៃគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា ។

៥.១២ ផ្អែកលើលំហូរចូលនៃមូលនិធិពីដៃគូអភិវឌ្ឍន៍ក្រៅប្រទេសកន្លងមក និងអតិរេកថវិកាប្រចាំឆ្នាំដែលបានព្យាករណ៍ លទ្ធភាពធនធានប៉ាន់ស្មានសម្រាប់ការអនុវត្ត *ផយអជ* រយៈពេលប្រាំឆ្នាំ២០០៦-២០១០ មានដូចខាងក្រោម :

- ថវិកាប្រមាណ ៣.៣៧០លានរៀល ស្មើនឹង ៧៧៥លានដុល្លារ[១] ឬប្រហែល ១៥៥លានដុល្លារក្នុងមួយឆ្នាំ បានមកពីអតិរេកថវិការបស់រាជរដ្ឋាភិបាល (គោលដៅជាគន្លឹះរបស់រាជរដ្ឋាភិបាល គឺត្រូវកៀរគរប្រភពធនធានក្នុងស្រុកឱ្យបានច្រើនថែមទៀត) ។

---

[១] ដូចដែលបានលើកឡើងពីខាងដើម អតិក្រមគ្រប់គ្រងទូទាំងវិស័យជាលម្អិត និងផែនការផ្សេងៗទៀត នឹងត្រូវរៀបចំឡើង ដើម្បីបំបែកជាលម្អិត ពង្រីករៀបចំជាកម្មវិធី នូវអនុគោលដៅនិងអនុចំណុចដៅជាតិ នៅក្នុងត្រីមាសដំបូងនៃឆ្នាំ២០០៦ (សូមមើលជំពូក៤) ។

[២] ទោះបីជាជំនួយឥតសំណងនេះគឺជាប្រភពដ៏សំខាន់នៃការគាំទ្រដ៏គួរជាទីចង់បានក៏ដោយ ក៏ការចង្អុលបង្ហាញថ្មីៗ ជាពិសេស ពីស្ថាប័ន[illegible] បង្ហាញថា ជំនួយបែបនេះមិនត្រូវបានលើកទឹកចិត្តទេ ។ ម្យ៉ាង ស្ថាប័នហិរញ្ញវត្ថុពហុភាគី បានសម្រេចផ្ដល់ការគាំទ្រ[illegible] "ជំនួយឥតសំណង" ដែលជំនួសឱ្យកម្ចីសម្បទាន ប៉ុន្តែម្យ៉ាងទៀត ស្ថាប័នហិរញ្ញវត្ថុពហុភាគីក៏បានសម្រេច (ក) កាត់បន្ថយ[illegible] មានលក្ខខណ្ឌថ្មី ដែលជាហេតុនាំឱ្យរាំងស្ទះដល់ការផ្ដល់មូលនិធិ ។

[៣] រួមបញ្ចូលទាំងជំនួយឥតសំណងនិងកម្ចីពាក់កណ្ដាលសម្បទាន ពីធនាគារពិភពលោកនិងធនាគារអភិវឌ្ឍន៍អាស៊ី ។

- ទឹកប្រាក់ចំនួន ២.៥០០លានដុល្លារ ប្រហែលជា ៥០០លានដុល្លារក្នុងមួយឆ្នាំ បានពីដៃគូអភិវឌ្ឍន៍ក្រៅប្រទេសជាប្រពៃណី មានទាំងប្រាក់កម្ចី ទាំងជំនួយឥតសំណង ដែលរួមបញ្ចូលចំណាយផ្ទាល់ទាំងអស់ដោយដៃគូអភិវឌ្ឍន៍ក្រៅប្រទេសនានា នៅក្នុងគណនេយ្យរបស់កម្ពុជា ។

៥.១៣ ដូច្នេះ ទឹកប្រាក់សរុបចំនួន ៣.២៧៥លានដុល្លារ ត្រូវបានប៉ាន់ស្មានថា អាចមានសម្រាប់គ្រប់សកម្មភាពនៃវិស័យសាធារណៈរបស់ *ផយអជ* ក្នុងរយៈពេល៥ឆ្នាំ (២០០៦-២០១០) ហើយបើធៀបទៅនឹងតម្រូវការប្រមាណចំនួន ៣.៥០០លានដុល្លារ គឺនៅខ្វះប្រហែលតែ ២២៥លានដុល្លារ ប៉ុណ្ណោះ ។ កង្វះនេះអាចកើនឡើងច្រើនថែមទៀត ប្រសិនបើថវិកាវិភាជន៍ និងការប្រើប្រាស់ថវិកា ជាពិសេសពីដៃគូអភិវឌ្ឍន៍ក្រៅប្រទេសមិនបានបន្ស៊ីពេញលេញជាមួយនិងសកម្មភាពជាអាទិភាពនានារបស់ *ផយអជ* ហើយម្យ៉ាងទៀត ប្រសិនបើថវិកាមួយចំនួនបានប្រើប្រាស់ទៅលើមុខចំណាយមិនអាទិភាព ដែលជ្រើសរើសដោយដៃគូអភិវឌ្ឍន៍ក្រៅប្រទេស[២] ។

៥.១៤ ប្រសិនបើការចំណាយដែលបានព្យាករណ៍ទុកចំនួន ៣.៥០០លានដុល្លារ នៅក្នុងវិស័យសាធារណៈ ក្នុងកំឡុងពេលនៃ *ផយអជ* កើតមានដូចដែលបានព្យាករណ៍ទុក រាជរដ្ឋាភិបាលមានសង្ឃឹមយ៉ាងខ្លាំងថា គោលដៅនិងចំណុចដៅនៃ *ផយអជ* (ការកាត់បន្ថយភាពក្រីក្រ *គអសក* កំណើនសេដ្ឋកិច្ចឆាប់រហ័យ) អាចសម្រេចបាន ។ <u>*មានវិធីពីរ (សេណារីយោ)*</u> តាមរយៈករណីនេះអាចត្រូវបានបង្ហាញ ។ <u>*សេណារីយោទី១*</u> គឺថា ចំនួនមូលនិធិសរុប ៣.៥០០លានដុល្លារអាមេរិក គឺអាចរកបានដោយផ្អែកតាមអាទិភាពនៃតារាង៥.២ និងជំនួយបច្ចេកទេសជាចំៗគ្នា ត្រូវបានកម្រិតមិនឱ្យច្រើនជាង ៥០០លានដុល្លារអាមេរិក ។ នេះជាអប្បបរមាដែលត្រូវការ និងដែលអាចមាន ។

៥.១៥ <u>*សេណារីយោទី២*</u> គឺជាបញ្ហាដែលធនធានពីដៃគូអភិវឌ្ឍន៍ក្រៅប្រទេសទាំងអស់មិនអាចរកបានពេញលេញសម្រាប់គោលបំណងដែលជាអាទិភាពនៅក្នុង *ផយអជ* ។ បញ្ហានេះ អាចបកស្រាយបានម្យ៉ាងទៀតថា :

- ការប្រើប្រាស់ជំនួយបច្ចេកទេសជាចំៗគ្នាធ្លាប់មានច្រើនជាង ៥០០លានដុល្លារអាមេរិក ជាឧទាហរណ៍ ដោយផ្អែកតាមរបាយការណ៍សហប្រតិបត្តិការអភិវឌ្ឍន៍ឆ្នាំ២០០២ និងឆ្នាំ២០០៣ (ទំព័រទី២០ នៃរបាយការណ៍គោល) ចំនួន ៤៤.១ភាគរយ នៃមូលនិធិដៃគូអភិវឌ្ឍន៍ក្រៅប្រទេស សម្រាប់ក្នុងកំឡុងពេលឆ្នាំ ១៩៩៩-២០០៣ ត្រូវបានចំណាយលើសហប្រតិបត្តិការបច្ចេកទេសជាចំៗគ្នា ។ បើយកសមាមាត្រខាងលើនេះ ធៀបជាមួយនឹងជំនួយ ២.៥ពាន់លានដុល្លារ ដែលរំពឹងថានឹងអាចទទួលបានពីដៃគូអភិវឌ្ឍន៍

---

[១] តាមការព្យាករណ៍របស់មូលនិធិរូបិយវត្ថុអន្តរជាតិ (ឧបសម្ព័ន្ធ២.១) ខែតុលា ឆ្នាំ២០០៥ គឺជាការព្យាករណ៍ដែលយកចេញពីទឹកប្រាក់ចំនួន ៣.៥០០ លានដុល្លារអាមេរិក ។ ឱនភាពធនធានអាចមានប្រមាណ ៤៥លានដុល្លារអាមេរិកក្នុងមួយឆ្នាំ (ឬ ២២៥លានដុល្លារអាមេរិកសម្រាប់រយៈពេលប្រាំឆ្នាំ ២០០៦-២០១០) ។ ម្យ៉ាងវិញទៀត អតិរេកថវិកា (ចំណូលសរុបដកចំណាយចរន្ត) អាចមានប្រមាណ ៧៧៥លានដុល្លារ ដែលជាតួលេខស្មើនឹង ៧៨៣.៣លានដុល្លារអាមេរិក ដែលជា "ហិរញ្ញប្បទានដោយធនធានក្នុងស្រុក" ដូចនៅក្នុងតារាង ៥.១ ។

[២] កន្លងមក មួយផ្នែកធំនៃធនធានដែលបានកំណត់ដោយដៃគូអភិវឌ្ឍន៍ក្រៅប្រទេសសម្រាប់កម្ពុជា ត្រូវបានចំណាយដោយផ្ទាល់ដោយដៃគូអភិវឌ្ឍន៍ទាំងនោះ ទៅលើកម្មវិធីនានាដែលជាជម្រើសរបស់ពួកគេ ដោយមិនធ្វើឡើងតាមរយៈថវិកាជាតិ ។

ក្រៅប្រទេសសម្រាប់ដំណាក់កាលរបស់ *ផយអជ* នោះជំនួយបច្ចេកទេសដាច់ៗគ្នាអាចនឹងមានដល់ ១.១ពាន់លានដុល្លារ គឺលើស ៦០០លានដុល្លារ ពីការគិតគូនៅក្នុង *ផយអជ* ដែលមានប្រមាណ ៥០០លានដុល្លារ ។

- កម្មវិធីនិងគម្រោងមួយចំនួនដែលអនុវត្តដោយដៃគូអភិវឌ្ឍន៍ក្រៅប្រទេស មិនត្រូវបានដាក់បញ្ចូលនៅក្នុងអាទិភាពនៃ *ផយអជ* ទេ ។

៥.១៦ ដើម្បីអនុវត្ត *ផយអជ* ប្រកបដោយជោគជ័យនិងមានប្រសិទ្ធភាព ត្រូវការថវិកាចំនួន ៣.៥០០លានដុល្លារ ដើម្បីចំណាយតាមរបៀបដែលបានគ្រោងនៅក្នុងតារាង៥.២ ការចំណាយលើសខ្លះទៀតជាង ៥០០លានដុល្លារ ទៅលើជំនួយបច្ចេកទេសក្រៅប្រទេស និងចំនួនបានចំណាយទៅលើគម្រោងជំនួយបច្ចេកទេសក្រៅប្រទេសដែលមិនស្ថិតក្នុងការកំណត់នៃ *ផយអជ* នឹងកាត់បន្ថយធនធានជំនួយបច្ចេកទេសក្រៅប្រទេសដែលលើសទាំងនោះដែលអាចរកបានសម្រាប់ *ផយអជ* ។ ការកាត់បន្ថយរបៀបនេះ នឹងបង្កើនគម្លាតហិរញ្ញវត្ថុ ហើយករណីនេះ នឹង (ក) ឬមួយត្រូវបំពេញដោយធនធានបន្ថែម[១] ឬមួយ (ខ) ការសម្រេចបាននៃចំណុចដៅ *ផយអជ* នឹងត្រូវជួបការលំបាកដោយសារគម្លាតហិរញ្ញវត្ថុនេះ ។

៥.១៧ ការឯកភាពគ្នាជាសាកលលើភាពជាដៃគូក្នុងកម្រិតខ្ពស់ ត្រូវបានផ្តួចផ្តើមឡើងដើម្បីជួយបណ្តាប្រទេសក្រីក្រឱ្យសម្រេចបាន *គអសក* និងផ្តល់មូលនិធិដែលចាំបាច់សម្រាប់គោលបំណង ។ ក្នុងស្មារតីនេះ រាជរដ្ឋាភិបាលកម្ពុជានឹងខិតខំប្រឹងប្រែង ដើម្បីធានាកិច្ចសហប្រតិបត្តិការយ៉ាងជិតស្និទ្ធជាមួយបណ្តាដៃគូអភិវឌ្ឍន៍ក្រៅប្រទេសដែលធនធានក្រៅប្រទេសត្រូវតម្រឹមឱ្យបានពេញលេញទៅនឹងគោលដៅនិងចំណុចដៅរបស់ *ផយអជ* តាមរយៈការតម្រង់ទិសឡើងវិញនូវមូលនិធិពីបណ្តាវិស័យដែលមានអាទិភាពតិចតួច ដែលទទួលបានពីដៃគូអភិវឌ្ឍន៍ក្រៅប្រទេសនាពេលបច្ចុប្បន្ន រួមមាន ការកាត់បន្ថយឱ្យបានច្រើនក្នុងជំនួយបច្ចេកទេសដាច់ៗគ្នា ហេតុដូចនេះ *"ការផ្ទេរដុលពិត"* នៃមូលនិធិអាចកើតឡើងសម្រាប់ការវិនិយោគដែលគ្រោងទុកក្នុង *ផយអជ* ។ របៀបដែលប្រសើរបំផុត ដើម្បីទទួលបានចំណែកសំខាន់នៃជំនួយអភិវឌ្ឍន៍ តាមរយៈ "ការគាំទ្រគម្រោងថវិកា" ដែលទាក់ទងទៅនឹងការអនុវត្តបែបគុណភាព និងបរិមាណដែលអាចវាស់បានក្នុងវិស័យនីមួយៗដែលបានជ្រើសរើស ។ ដូច្នេះ ការគាំទ្រគម្រោងថវិកាអាចជួយបានតាមមធ្យោបាយបី គឺ (ក) លើកកម្ពស់ភាពជាម្ចាស់និងភាពជាអ្នកដឹកនាំរបស់រាជរដ្ឋាភិបាលនៃអាទិភាពគោលនយោបាយ និងកម្មវិធីអភិវឌ្ឍន៍នានា (ខ) ការងារគណនេយ្យដែលមានការតាមដាននិងតម្លាភាពត្រឹមត្រូវជាងមុន នៃជំនួយក្រៅប្រទេស (គ) ការតាមដានមើល និងគណនេយ្យភាពក្នុងប្រទេស តាមរយៈស្ថាប័នប្រជាធិបតេយ្យនានា សម្រាប់ការទទួលនិងប្រើប្រាស់មូលនិធិក្រៅប្រទេស ។ រាជរដ្ឋាភិបាលកម្ពុជានឹងខិតខំ

---

[១] ប្រសិនបើគេសន្មតថា ជំនួយបច្ចេកទេសដាច់ៗគ្នាបន្ថែមមានចំនួន ៦០០លានដុល្លារ ហើយគម្រោងមិនមែនអាទិភាពដែលផ្តល់ហិរញ្ញប្បទានដោយដៃគូអភិវឌ្ឍន៍ក្រៅប្រទេសក្នុងទឹកប្រាក់ប្រមាណ ២០០លានដុល្លារ នោះ គម្លាតនឹងកើនឡើងដល់ ៨០០លានដុល្លារ ។ ធនធានបន្ថែមដែលត្រូវរកឱ្យបានដើម្បីបំពេញគម្លាតដែលធ្វើឱ្យកើនឡើងនូវការចំណាយសរុបក្នុងវិស័យសាធារណៈក្នុងអំឡុងពេលនៃ *ផយអជ* នឹងកើនដល់ ៤,៧០០លានដុល្លារ ។

ស្វែងរកកិច្ចសហប្រតិបត្តិការរបស់ដៃគូអភិវឌ្ឍន៍ក្រៅប្រទេសនានា ដើម្បីឈានឆ្ពោះទៅរក "*ការគាំទ្រគម្រោងថវិកា*" ដែលជាយន្តការដ៏ប្រសើរបំផុតសម្រាប់ការផ្តល់ការគាំទ្រពីខាងក្រៅ ប៉ុន្តែត្រូវទទួលស្គាល់ថា ដំណើរការនេះអាចត្រូវប្រើពេលវេលាយូរឆ្នាំ ដើម្បីរៀបចំនិងធ្វើឱ្យមានវឌ្ឍនភាព ។ ដើម្បីចាប់ផ្តើមការងារនេះ រាជរាជរដ្ឋាភិបាលត្រូវធ្វើសុខដុមនីយកម្មកម្មវិធីជំនួយ តាមរយៈវិធីសាស្ត្រនានា ដូចជា អភិក្រមគ្រប់គ្រងទូទាំងតាមវិស័យ ដើម្បី សម្រេចបានភាពរលូននិងភាពជុំគ្នា ហើយចៀសវាងបាននូវការត្រួតគ្នានិងការធ្វើសារឡើងវិញ ។ ការងារនេះគួរដំណើរការតាមរយៈបណ្តាក្រុមការងារបច្ចេកទេស ។

៥.១៨ គម្លាតប្រមាណ ២២៥លានដុល្លារ ស្មើនឹង ៦,៤៣ភាគរយនៃការចំណាយសរុបដែលបានប៉ាន់ស្មាន ចំនួន ៣.៥០០លានដុល្លារ បានគ្រោងដោយ *ផយអជ* ។ គម្លាតនេះអាចកើនឡើងច្រើន ប្រហែល ១.០២៥លានដុល្លារ ប្រសិនបើសេណារីយោដែលមានក្នុងកថាខ័ណ្ឌ៥.១៥ (មើលកំណត់សម្គាល់នៅទំព័រ១១២) ទទួលជោគជ័យ ។ រាជ-រដ្ឋាភិបាលជឿជាក់ថា បញ្ហានេះអាចសម្រេចបាន តាមរយៈ :

- ចំណូលបន្ថែមរបស់រាជរដ្ឋាភិបាល ដែលអាចកើនឡើងពីការខិតខំប្រឹងប្រែងគៀរគរចំណូលក្នុងស្រុក និងលទ្ធភាពការធ្វើអាជីវកម្មប្រេង និងឧស្ម័នបម្រុងរបស់ប្រទេសបានជោគជ័យ ។
- ចំពោះស្ថានភាពប្រទេសដែលមានការអភិវឌ្ឍតិចតួច ហើយស្ថានភាពរបស់កម្ពុជា ដែលជាប្រទេសសាកល្បងសម្រាប់ភាពរលូននិងសុខដុមនីយកម្ម មូលនិធិបន្ថែមពិសេសពីបណ្តាដៃគូអភិវឌ្ឍន៍ក្រៅប្រទេស ជាផ្នែកនៃការប្តេជ្ញាចិត្តរបស់ពួកគេក្នុងការសម្រេចគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ ដោយការបង្កើនបណ្តាចំណុចដៅជំនួយអភិវឌ្ឍន៍ឱ្យខិតទៅជិត ០,៧ភាគរយនៃ ផសស (សេចក្តីប្រកាសនៅទីក្រុងម៉ុងតេរេ ឆ្នាំ២០០២) ជាពិសេស ដោយគិតចំពោះស្ថានភាពរបស់កម្ពុជា ទាំងជាប្រទេសអភិវឌ្ឍន៍តិចតួច ទាំងជាប្រទេសសាកល្បងសម្រាប់សុខដុមនីយកម្ម និងការតម្រឹមតម្រង់ ។
- ធនធានដែលបានពីដៃគូអភិវឌ្ឍន៍ក្រៅប្រទេសមិនមែនជាប្រពៃណី ។
- មូលនិធិដែលបានបន្ធូរបន្ថយ តាមរយៈការបន្ធូរបន្ថយបំណុលដែលអាចធ្វើបាន ។

៥.១៩ កម្ពុជាទទួលជំនួយក្រៅប្រទេស ទាំងប្រាក់កម្ចី និងជំនួយឥតសំណង ប៉ុន្តែជាប្រទេសមានការអភិវឌ្ឍតិចតួច មិនអាចទ្រទ្រង់នឹងបន្ទុកប្រាក់កម្ចី ទោះជាដូចនេះក្តី កម្ពុជាអាចទទួលបានសម្បទាន ព្រោះថា ប្រជាជនជំនាន់ក្រោយមិនអាចទទួលបន្ទុកសងបំណុលនេះបាន ។ ដូច្នេះ រាជរដ្ឋាភិបាលកម្ពុជាមានបំណង :

- ទទួលជំនួយពីក្រៅប្រទេសភាគច្រើនក្នុងទម្រង់ជំនួយឥតសំណងឱ្យបានច្រើនតាមដែលអាចធ្វើបាន ដែលត្រូវប្រើប្រាស់សម្រាប់វិស័យសង្គមកិច្ចទាំងអស់ និងផ្តល់មូលនិធិដោយផ្ទាល់ដល់ថ្នាក់មូលដ្ឋាន ។ ដោយធ្វើការកាត់បន្ថយកម្រិតនៃជំនួយបច្ចេកទេស ការធ្វើអង្កេត និងការងារប្រហាក់ប្រហែលផ្សេងៗទៀត [១]

[១] សូមមើល កថាខ័ណ្ឌ ៤.០៥

- ទុនបម្រុងការប្រើប្រាស់កម្ចីក្នុងទម្រង់សម្បទានឬពាក់កណ្តាលសម្បទាន ឱ្យបានច្រើនតាមអាចធ្វើបាន ក្រោយមកក្នុងលក្ខណៈប្រុងប្រយ័ត្នតែលើចំណាយមូលធនសំខាន់ៗ ក្នុងការកសាងហេដ្ឋារចនាសម្ព័ន្ធ ឬអាទិភាពខ្ពស់ អាចវាស់វែងបាន មានចំណូលច្បាស់លាស់ ឬកម្មវិធីនានាដែលបង្កើតទិន្នផលឬចំណូល ។

កម្មវិធី : ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ កម្មវិធីវិនិយោគសាធារណៈ និងថវិកាប្រចាំឆ្នាំ

៥.២០ វិភាជន៍ហិរញ្ញវត្ថុដែលបានធ្វើឡើងសម្រាប់វិស័យផ្សេងៗនៅក្នុង *ផយអជ* (តារាង ៥.២) មានទិសដៅ ឬការតម្រង់ទិសទូលំទូលាយឆ្ពោះទៅមុខ ។ ដើម្បីឱ្យក្លាយទៅជាប្រតិបត្តិការវិភាជន៍ហិរញ្ញវត្ថុដែលត្រូវបញ្ចប់នៅពេលមានគម្រោងសំណើច្បាស់លាស់សម្រាប់ទុនជាក់ស្តែង និងចំណាយចរន្តលើមូលដ្ឋានប្រចាំឆ្នាំ ។ ដើម្បីសម្រេចគោលបំណងនេះ យន្តការកម្មវិធីវិនិយោគសាធារណៈបីឆ្នាំរំកិលដែលមានស្រាប់ នឹងត្រូវបានប្រើប្រាស់សម្រាប់កំណត់ផែនការ ដំណាក់កាល និងចំណាយប៉ាន់ស្មានលើសកម្មភាពជាក់លាក់ក្នុងឆ្នាំនីមួយៗ សម្រាប់រយៈពេល ៣ឆ្នាំបន្ទាប់ ។ ធ្វើដូច្នេះ វិស័យនីមួយៗ ឬថ្នាក់ក្រោមជាតិ នឹងចងចាំកាន់តែច្បាស់នូវគោលដៅរួមនានាដែលត្រូវសម្រេច និងចំណុចដៅច្បាស់លាស់ដែលនៅកំណត់ក្នុង *ផយអជ* ។ ក្នុងការរៀបចំផែនការវិនិយោគសម្រាប់ឆ្នាំនីមួយៗ ដោយផ្អែកលើទុន ឬមធ្យោបាយរបស់វិស័យនីមួយៗ និងថ្នាក់ក្រោមជាតិ ស្ថាប័នកណ្តាលនានា[១] នឹងធានាថា *កវស* ត្រូវអនុវត្តតាមទិសដៅ តាមការគូសបញ្ជាក់ និងតាមការចង្អុលបង្ហាញក្នុងន័យចំណាយវិនិយោគដែលមាននៅក្នុង *ផយអជ* ដែលត្រូវពិនិត្យនិងកែសម្រួលឡើងវិញពីពេលមួយទៅពេលមួយ ។ សំណើ ឬគម្រោងនានាដែលមិនអនុលោមទៅតាម ឬមិនសមស្របទៅនឹង *ផយអជ* នឹងមិនអាចត្រូវបានចាត់ជាអាទិភាពក្នុង *កវស* ទេ ។

៥.២១ ដូចបានពិចារណាខាងដើម ដៃគូអភិវឌ្ឍន៍ក្រៅប្រទេសបានជំរុញយ៉ាងខ្លាំងក្លានិងបន្ទាន់ដើម្បីធានាថា បញ្ឈប់ការគាំទ្ររបស់ខ្លួនលើកម្មវិធី ឬគម្រោងដែលគ្មានអាទិភាពក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ។ បញ្ហានេះ នឹងត្រូវបានធានាដោយការលើកទឹកចិត្តដៃគូអភិវឌ្ឍន៍ក្រៅប្រទេស អនុវត្តផ្សារភ្ជាប់ទៅនឹងសេចក្តីណែនាំ និងបែបបទ ដែលបានចែងក្នុងក្របខ័ណ្ឌការគ្រប់គ្រងសហប្រតិបត្តិការអភិវឌ្ឍន៍ថ្មី ដែលនឹងបញ្ចប់ក្នុងពេលឆាប់ៗខាងមុខ ។ ទោះជាយ៉ាងនេះ កម្មវិធី និងគម្រោងនានាដែលត្រូវបានទទួលស្គាល់ថាបានចាប់ផ្តើមរួចហើយ ត្រូវបន្តដំណើរការតាមដំណើរ ។ ប៉ុន្តែទោះក្នុងករណីទាំងនោះ រាល់ការប្រឹងប្រែងត្រូវតែប្តូរទិសកម្មវិធី ឬគម្រោងឆ្ពោះទៅអាទិភាពនៃ *ផយអជ*[២] ។

---

[១] ក្រសួងផែនការ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឧត្តមក្រុមប្រឹក្សាជាតិសេដ្ឋកិច្ច និងគណៈកម្មាធិការទីតិសម្បទានិងអភិវឌ្ឍន៍នៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ។

[២] ការងារនេះត្រូវអនុវត្តតាមរយៈក្រុមការងារបច្ចេកទេសនានា ។

៥.២២ រាជរដ្ឋាភិបាលកម្ពុជានឹងធានាថា ក្របខ័ណ្ឌចំណាយរយៈពេលមធ្យម និងវិភាជន៍ចំណាយថវិកាប្រចាំឆ្នាំ ត្រូវបានបង្កើតឡើងក្នុងពេលជាមួយគ្នានឹងវិភាជន៍គោលដៅ និងចំណុចដៅព្រមទាំងក្របខ័ណ្ឌ *កវម* (ដែលគោលបំណង គឺធ្វើឱ្យស្របជាមួយនឹងវិភាជន៍ និងចំណុចដៅរបស់ *ផយអជ*)។ ដូច្នេះពីជំហានមូលដ្ឋានមួយទៅជំហានមូលដ្ឋានមួយ គោលដៅ ចំណុចដៅ និងវិភាជន៍ទូទៅរបស់ *ផយអជ* ដូចខណៈដែលពិនិត្យកែលម្អពីពេលមួយទៅពេលមួយ បានណែនាំ ដឹកនាំ និងមានឥទ្ធិពលដល់ *កវម* និងថវិកាប្រចាំឆ្នាំ ។

៥.២៣ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ នឹងរៀបចំ និងបញ្ចប់ជាស្ថាពរនៅចុងឆ្នាំ២០០៥ ។ ដោយកិច្ចប្រជុំជាមួយដៃគូអភិវឌ្ឍន៍ក្រៅប្រទេស ស្តីពីការកៀរគរជំនួយនៅពេលខាងមុខ នឹងប្រព្រឹត្តទៅតែមួយលើកនៅ ខែមីនា ឆ្នាំ២០០៦ ការបង្ហាញកម្មវិធីវិនិយោគសាធារណៈឆ្នាំ២០០៦-២០០៨ នាពេលប្រជុំនោះនឹងត្រូវធ្វើឱ្យមានភាពស៊ីសង្វាក់ជាមួយនឹងអាទិភាពដែលបានកំណត់នៅក្នុង *ផយអជ* នេះ។ ទោះយ៉ាងនេះក្តី ថវិកាប្រចាំឆ្នាំសម្រាប់ឆ្នាំ ២០០៦ ត្រូវបានរៀបចំរួចរាល់ជាស្ថាពរនៅខែធ្នូ ឆ្នាំ២០០៥ ដោយគ្មានបន្ទល់ពេលវេលាសម្រាប់សម្រេចបានទំនាក់ទំនងច្បាស់លាស់ជាមួយ *ផយអជ* និង *កវម* ។ ប៉ុន្តែ ជាគម្រោងចំណាយថវិកាដែលត្រូវបានទទួលស្គាល់ជាទូទៅទំនងមានក្នុងទិសដៅលើកឡើងក្នុង *ផយអជ* ប្រសិនជាមានការខុសគ្នា នោះក៏ស្ថិតក្នុងកម្រិតបន្តិចបន្តួច ។ ដំណើរការនៃប្រតិបត្តិការក្នុងពេលតែមួយរវាង *ផយអជ កវម* និងគម្រោងថវិកាប្រចាំឆ្នាំមានភាពរលូនពេញទំហឹងនឹងត្រូវបានធានាច្បាស់លាស់ពីពាក់កណ្តាលឆ្នាំ២០០៦ តទៅ[១] ។ ស្ថាប័នកណ្តាលសំខាន់បួនរបស់រាជរដ្ឋាភិបាល[២] ដែលមានទំនាក់ទំនងគ្នាទៀងទាត់នឹងធានាថា កិច្ចព្រមព្រៀងនេះសម្រេចបានទាន់ពេលវេលា ។ ធ្វើយ៉ាងដូច្នេះ ស្ថាប័នទាំងបួន អាចពិនិត្យទៅលើទិដ្ឋភាពទាំងមូលសម្រាប់វិស័យនីមួយៗ និងការប្រើប្រាស់ចំណាយថវិកា ដូចដែលវិភាជន៍មិននៅឈរតែឯកឯង ប៉ុន្តែដូចជាការបំពេញបន្ថែមគោលនយោបាយទៅក្នុងកម្មវិធីគាំទ្រពីខាងក្រៅប្រទេស[៣] ។

៥.២៤ *ផយអជ* អមដោយ *កវម* សម្រាប់ឆ្នាំ២០០៦-២០០៨ នឹងត្រូវតែជាឯកសារផែនការរបស់រាជរដ្ឋាភិបាលក្នុងការកៀរគរជំនួយ នាកិច្ចប្រជុំពិគ្រោះយោបល់ ក្នុងខែមីនា ឆ្នាំ២០០៦ ។ នៅបណ្តាឆ្នាំក្រោយៗមកទៀត

---

[១] បែបបទដែលបានគ្រោងក្នុងជំពូក ៦ ។

[២] ក្រសួងផែនការ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ឧត្តមក្រុមប្រឹក្សាជាតិសេដ្ឋកិច្ច និងគណៈកម្មាធិការនីតិសម្បទានិងអភិវឌ្ឍន៍កម្ពុជា/ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ។

[៣] ប្រសិនបើការចំណាយលើជំនួយទាំងអស់មិនបានធ្វើឡើងតាមរយៈការគាំទ្រថវិកា (តាមរយៈថវិកាប្រចាំឆ្នាំរបស់រាជរដ្ឋាភិបាលកម្ពុជា) នោះការចំណាយទាំងឡាយនៅក្នុងថវិកាដែលគ្រាន់តែជាផ្នែកមួយនៃការចំណាយសាធារណៈសរុបសម្រាប់វិស័យនីមួយៗ និងមិនបានឆ្លុះបញ្ចាំងយ៉ាងពិតប្រាកដអំពីនៃការបែងចែកនៅក្នុងវិស័យនីមួយៗ ក្នុងការចំណាយសាធារណៈសរុបទេ ។ ដូច្នេះ រូបភាពរួមគួរតែត្រូវបានពិនិត្យមើល ដើម្បីធ្វើការវាយតម្លៃ នៃចំណែករបស់វិស័យនីមួយៗក្នុងការចំណាយសាធារណៈ ហើយមិនត្រូវពិនិត្យមើលតែចំណែកនៅក្នុងថវិកា ដែលគ្រាន់តែជាប្រភពតែមួយគត់នៃការផ្តល់ថវិកាសម្រាប់វិស័យសាធារណៈប៉ុណ្ណោះទេ ។

របាយការណ៍វឌ្ឍនភាពនៃការអនុវត្ត *ផយអជ* ប្រចាំឆ្នាំ[១] និងការកែលម្អ *ករស* នឹងជាឯកសារគោលរបស់រាជរដ្ឋាភិបាលសម្រាប់បណ្តាកិច្ចប្រជុំក្បៀរគរជំនួយ ។

៥.២៥ តាមរយៈសេចក្តីប្រកាសអន្តរជាតិកម្រិតខ្ពស់នៅទីក្រុងរ៉ូម និងទីក្រុងប៉ារីស[២] នោះ ដៃគូអភិវឌ្ឍន៍ក្រៅប្រទេសទាំងអស់បានប្តេជ្ញាក្នុងការបន្ស៊ីគ្រប់កម្មវិធីជំនួយទាំងអស់ ទៅនឹងអាទិភាព និងបណ្តាផែនការអភិវឌ្ឍន៍ទាំងអស់ក្រោមការដឹកនាំ និងភាពជាម្ចាស់របស់បណ្តាប្រទេសអ្នកទទួលជំនួយ ។ ដើម្បីចាប់ផ្តើមដំណើរការបន្ស៊ីសម្រាប់រយៈពេលនេះ រាជរដ្ឋាភិបាលនឹងសំណូមពរដល់ដៃគូអភិវឌ្ឍន៍ក្រៅប្រទេស[៣] ដោយធ្វើការចាប់ផ្តើមពីកិច្ចប្រជុំក្បៀរគរជំនួយនៅខែមីនា ឆ្នាំ២០០៦ ដោយមិនត្រឹមតែបង្ហាញពីចំនួនសរុបដែលជាជំនួយនឹងផ្តល់ជូនកម្ពុជាក៏ប៉ុន្តែត្រូវធ្វើការបញ្ជាក់ច្បាស់ផងដែរ ស្តីពី (ក) បរិមាណទឹកប្រាក់ដែលនឹងផ្តល់ជូនតាមវិស័យនីមួយៗ ក្នុងលក្ខណៈស្រដៀងគ្នាជាមួយនឹងវិភាជន៍ *ផយអជ* (ខ) លទ្ធភាពបន្តនូវប្រភេទកម្មវិធីឬគម្រោងនានា ដែលផ្តល់ការគាំទ្រស្របជាមួយនិងការវិភាជន៍ហិរញ្ញវត្ថុសម្រាប់វិស័យនីមួយៗ (គ) បរិមាណទឹកប្រាក់ដែលត្រូវចំណាយសម្រាប់បណ្តាកម្មវិធីឬគម្រោងនានាកំពុងដំណើរការ (ឃ) មានឱកាសសម្រាប់គម្រោងថ្មីៗ (ង) ដោយពុំគិតបញ្ចូលនូវជំនួយបច្ចេកទេសទៅនឹងបរិមាណសរុប ។

៥.២៦ ដូចបានបញ្ជាក់ជូនរួចមកហើយ *ផយអជ* គឺជាឯកសាររស់ និងអាចកែសម្រួលបាន និងជាឧបករណ៍ណែនាំមានការប្រែប្រួល មានសមត្ថភាពសម្រួល និងកាត់តម្រឹមទៅតាមទិន្នន័យដែលបានរួមបញ្ចូលគ្នា និងតាមកាលៈទេសៈ ។ ដូច្នេះ លទ្ធផលនិងផលប្រយោជន៍ចុងក្រោយស្តីពីគោលដៅនិងចំណុចដៅសំខាន់ៗ នឹងត្រូវតាមដានត្រួតពិនិត្យនិងវាយតម្លៃយ៉ាងទៀងទាត់ ដើម្បីពិភាក្សាក្នុងការកែតម្រូវប្រចាំឆ្នាំក្នុង *ផយអជ* ។ វិធីសាស្ត្រនិងនីតិវិធីនានា សម្រាប់ការកែតម្រូវប្រចាំឆ្នាំទាំងនោះ នឹងត្រូវពន្យល់បកស្រាយក្នុងជំពូក៦ ។

---

[១] សូមមើលជំពូក ៦ សម្រាប់ការលម្អិតបន្ថែម

[២] សូមមើលជំពូក ៤ កថាខ័ណ្ឌ ៤.២៥

[៣] ជាពិសេស ដោយសារតែកម្ពុជាគឺជាប្រទេសសាកល្បងមួយសម្រាប់កិច្ចខិតខំប្រឹងប្រែងនេះ ។

តារាង៥.២ : វិភាជន៍របស់ *ផយអជ* តាមវិស័យ ២០០៦-២០១០

(គិតជាលានដុល្លារអាមេរិក)

[illegible]	[illegible]	[illegible]	[illegible]	[illegible]	[illegible]	[illegible]	[illegible]	[illegible]
								១
វិស័យសង្គមកិច្ច								
អប់រំ: អប់រំមូលដ្ឋាន ៦០%	៥៥០		១៥,៧១	៣៣០	៦០	២២០	៤០	២
សុខាភិបាល	៦០០		១៧,១៤	៤២០	៧០	១៨០	៣០	
សរុប		**១.១៥០**	**៣២.៨៦**					
វិស័យសេដ្ឋកិច្ច								
កសិកម្មនិងការគ្រប់គ្រងដីធ្លី:ផ្សេងពីចញ្ចជាតិ	១៥០		៤.២៩	១៤៣	៩៥	៨	៥	៣
ចញ្ចជាតិតាមរដូវ: ស្រូវ និងផ្សេងៗ	២០០		៥.៧១	២០០	១០០	០		
អភិវឌ្ឍន៍ជនបទ	៣៥០		១០.០០	៣៥០	១០០	០		៤
កម្មន្តសាល រ៉ែ និងពាណិជ្ជកម្ម	៨០		២.២៩	១២	១៥	៦៨	៨៥	៥
សរុប		**៧៨០**	**២២.២៩**					
ហេដ្ឋារចនាសម្ព័ន្ធ								
ដឹកជញ្ជូន (ផ្លូវថ្នល់ កំពង់ផែ ផ្លូវដែក អាកាស	៥៥០		១៥,៧១	២៧៥	៥០	២៧៥	៥០	៦
ទឹក និងអនាម័យ (មិនគិតជនបទ)	១៥០		៤.២៩	១៥	១០	១៣៥	៩០	៧
ថាមពល និងអគ្គិសនី	១២០		៣.៤៣	៦០	៥០	៦០	៥០	៨
ប្រៃសណីយ៍ និងទូរគមនាគមន៍	៦០		១,៧១	៣០	៥០	៣០	៥០	៩
សរុប		**៨៨០**	**២៥.១៤**					
សេវាកម្ម និងកម្មវិធីអន្តរវិស័យ								
ការបញ្ជ្រាបយេនឌ័រ	៣០		០.៨៦	៥	៣០	២១	៧០	១០
ទេសចរណ៍	៣០		០.៨៦	៨	២៥	២៣	៧៥	
បរិស្ថាន និងអភិរក្ស	១០០		២.៨៦	៩០	៩០	១០	១០	១១
សហគមន៍ និងសេវាកម្មសង្គម	៨០		២.២៩	៦០	៧៥	២០	២៥	
វប្បធម៌ និងសិល្បៈ	៣០		០.៨៦	១៥	៥០	១៥	៥០	
អភិបាលកិច្ច និងរដ្ឋបាល	២២០		៦,២៩	៤៤	២០	១៧៦	៨០	១២
សរុប		**៤៩០**	**១៤,០០**					
មិនទាន់បែងចែក		២០០	៥.៧១	១០០	៥០	១០០	៥០	១៣
សរុបរួម		**៣.៥០០**	**១០០**	**២.១៦០**	**៦២%**	**១.៣៤០**	**៣៨%**	**១៤**

កំណត់ពន្យល់ :

១. ក. បរិមាណតាមវិស័យនីមួយៗរួមមាន : ធនធានដែលបានមកពីគ្រប់ប្រភពទាំងអស់ : រាជរដ្ឋាភិបាលកម្ពុជា និងដៃគូអភិវឌ្ឍន៍ ក្រៅប្រទេស (ចំណាយផ្ទាល់ឬតាមរយៈរាជរដ្ឋាភិបាលកម្ពុជា) ។

ខ. ចំណាយមូលធន ចំណាយចរន្តបន្ថែម ជំនួយបច្ចេកទេស ចំណាយក្នុងការតាមដានត្រួតពិនិត្យ ប្រមូលទិន្នន័យ ការថែរក្សាគេហទំព័រ ។

គ. តួលេខជនបទ-ទីប្រជុំជន ត្រូវបានចង្អុលបង្ហាញ និងគប្បីរួមបញ្ចូលគ្នា ។

ឃ. បរិមាណទាំងនេះ ក៏រួមទាំងការផ្តល់ប្រាក់ជំនួយទាំងអស់ទៅថ្នាក់ខេត្ត ស្រុក និងឃុំ សម្រាប់អនុវត្តដោយផ្ទាល់ ។

២. ក. រួមទាំង យុវជន និងកីឡា ។

ខ. ៦០ភាគរយ នៃចំនួនសរុប នឹងត្រូវបែងចែកសម្រាប់ការអប់រំមូលដ្ឋាន ។

៣. រួមទាំង ការនេសាទ ការបោសសម្អាតមីន និងសកម្មភាពផ្សេងៗក្រៅពីដំណាំតាមរដូវ មិនរាប់បញ្ចូលរុក្ខាប្រមាញ់ដែលបានបង្ហាញនៅក្នុងផ្នែកបរិស្ថាន និងអភិរក្ស ។

៤. ការអភិវឌ្ឍជនបទ : រួមទាំង កម្មវិធីសីលា ផ្លូវជនបទ ទីផ្សារ គម្រោងប្រព័ន្ធធារាសាស្ត្រ ការផ្គត់ផ្គង់ទឹកនិងអនាម័យ វិមជ្ឈការនិងវិសហមជ្ឈការ អភិបាលកិច្ចមូលដ្ឋាន ។

៥. រួមបញ្ចូលនូវ : ការបង្កើតការងារ និងបញ្ហាកម្លាំងពលកម្ម ។

៦. មិនរាប់បញ្ចូល ផ្លូវជនបទ ។ ផ្លូវជាតិនិងផ្លូវខេត្ត មានផលប្រយោជន៍ដល់តំបន់ជនបទ ដូច្នេះផ្លូវទាំងពីរប្រភេទនេះមានសមាមាត្រ ៥០ភាគរយ ។ ត្រូវមានការចូលរួមពីផ្នែកឯកជន ។ រួមបញ្ចូលទាំង ចំណាយបន្ថែមលើការថែទាំ ។

៧. មិនរាប់បញ្ចូលសកម្មភាពនៅតំបន់ជនបទ ដែលបានកំណត់នៅក្នុងការអភិវឌ្ឍជនបទ ។

៨. ការវិនិយោគក្នុងវិស័យនេះ គប្បីត្រូវជំរុញលើកទឹកចិត្តឱ្យមានការចូលរួមពីវិស័យឯកជន ។

៩. ការវិនិយោគក្នុងវិស័យនេះ គប្បីត្រូវជំរុញលើកទឹកចិត្តឱ្យមានការចូលរួមពីវិស័យឯកជន ។

១០ សម្រាប់បង្កើតការយល់ដឹង និងការបញ្ជ្រាប ។ វិស័យដទៃទៀតនឹងបញ្ចូលសកម្មភាពនានាក្នុងការងាររបស់គេ ។

១១ រួមទាំងរុក្ខាប្រមាញ់ ។

១២ រួមទាំង :

ក. កំណែទម្រង់ទាំងអស់ ដូចជា កំណែទម្រង់ច្បាប់និងប្រព័ន្ធតុលាការ កំណែទម្រង់រដ្ឋបាលសាធារណៈ កំណែទម្រង់ម៉ាក្រូសេដ្ឋកិច្ច កំណែទម្រង់សារពើពន្ធ និងកំណែទម្រង់ផ្សេងៗទៀត ។

ខ. ការសិក្សានិងការអង្កេតរបស់វិទ្យាស្ថានជាតិស្ថិតិ ដូចជា ជំរឿនប្រជាជនឆ្នាំ២០០៨ ការវាយតម្លៃភាពក្រីក្រ អង្កេតសេដ្ឋកិច្ច-សង្គមកិច្ចកម្ពុជា ការតាមដានត្រួតពិនិត្យការអនុវត្ត *ផយអជ* ។ល។

គ. ការគ្រប់គ្រងកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ ។ល។

ឃ. ការបោះឆ្នោតនានា ។

ង. សកម្មភាពរដ្ឋបាលសាធារណៈផ្សេងៗទៀត ។

១៣. ទុនបម្រុងសម្រាប់ការបំបែរទិសដៅប្រើប្រាស់ប្រភពធនធាន បើសិនជាចាំបាច់ ។

១៤. ភាពខុសគ្នាបន្តិចបន្តួចក្នុងតួលេខសរុបនានា (ជនបទ ទីប្រជុំជន) និងតួលេខសរុបរួម អាស្រ័យទៅនឹងការតម្រឹមលេខទសភាគ ។

ជំពូក ៦

ការតាមដានត្រួតពិនិត្យ និងការវាយតម្លៃ

៦.០១ ដើម្បីធានាថា ការអនុវត្ត *ផយអជ* មានដំណើរការស្របទៅនឹងជំហានដែលចង់បាន ឱ្យសម្រេចគោលដៅនិងចំណុចដៅនានារបស់ *ផយអជ* ការតាមដានត្រួតពិនិត្យ និងការវាយតម្លៃវឌ្ឍនភាពជាប្រចាំទាមទារធ្វើការកែតម្រូវពាក់កណ្តាលអណត្តិជាចាំបាច់ ដោយប្រើប្រាស់លទ្ធផលដែលរកឃើញ និងទិន្នន័យផ្សេងៗទៀត ដែលអាចកើតមាន ។ ប្រព័ន្ធតាមដានត្រួតពិនិត្យ និងវាយតម្លៃមួយដែលមានប្រសិទ្ធភាពដែលអាចមានលទ្ធភាព វាយតម្លៃពីវឌ្ឍនភាព និងការផ្តល់ទុនទាន់ពេលវេលា ការឆ្លើយតបប្រចាំឆ្នាំចំពោះអ្នករៀបចំគោលនយោបាយ គឺជាសមាសភាគទាំងមូលនៃផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ។

៦.០២ ប្រព័ន្ធតាមដានត្រួតពិនិត្យ និងវាយតម្លៃ *ផយអជ* នឹងមានក្នុងផ្នែកនៃការអនុវត្តសូចនាករ លទ្ធផលដែលទទួលបានពីក្របខ័ណ្ឌ និងអាទិភាពនៃ *ផយអជ* ស្របជាមួយនឹងយន្តការដែលមាន ប្រសិទ្ធិភាពសម្រាប់តាមដានវឌ្ឍនភាព ។ គោលបំណង ត្រូវធានាការតាមដានត្រួតពិនិត្យ និងការវាយតម្លៃវឌ្ឍនភាពជាប្រចាំ និងទៀងទាត់ពេលកំណត់ ដោយផ្អែកទៅនឹងធាតុចូល លទ្ធផល និងសមិទ្ធផលនៃយុទ្ធសាស្ត្រ និងសកម្មភាពផ្សេងៗនៅក្នុង *ផយអជ* ។

៦.០៣ ដើម្បីចាប់ផ្តើមអនុវត្តការតាមដានត្រួតពិនិត្យ និងការវាយតម្លៃនេះ *ផយអជ* ទាំងមូល នឹងត្រូវធ្វើការកែសម្រួលឡើងវិញនៅខែមិថុនា ឆ្នាំ២០០៦[១] ដើម្បីពិចារណាពីធាតុចូលនិងទិន្នន័យបន្ថែមថ្មីនានា ពីគ្រប់វិស័យ និងក្រោមថ្នាក់ជាតិទាំងអស់ ។ បន្ទាប់មក ដោយផ្អែកលើការពិគ្រោះយោបល់ជាមួយមានចំណែកអ្នកពាក់ព័ន្ធទាំងអស់នៅដើមឆ្នាំ២០០៦ ផែនការលម្អិតតាមវិស័យ និងក្រោមថ្នាក់ជាតិ នឹងត្រូវរៀបចំឡើងឱ្យស្របគ្នាជាមួយនឹងគោលដៅ ចំណុចដៅ និងតម្លៃដែលបានបំបែកចេញ ក៏ដូចជាមធ្យោបាយលម្អិតបន្ថែមទៅលើរបៀបវិភាជន៍ធនធាន នឹងត្រូវប្រើប្រាស់តាមវិធីដែលអាចធ្វើឱ្យបានប្រសើរបំផុត[២] ។ របាយការណ៍ស្តីពីលទ្ធផលដែលទទួលបានពីការងារខាងលើ នឹងត្រូវធ្វើការតិតគូរនៅក្នុង "ការពិនិត្យដំបូង" នៃការអនុវត្ត *ផយអជ* ។ របាយការណ៍

---

[១] ក្រុមការងារបច្ចេកទេសទាំងអស់នឹងចូលរួមនៅគ្រប់ការតាមដានត្រួតពិនិត្យ និងវាយតម្លៃ និងរៀបចំរបាយការណ៍វឌ្ឍនភាពប្រចាំឆ្នាំនៃការអនុវត្ត *ផយអជ* ។

[២] ដូចបានបង្ហាញក្នុងជំពូក១ ដោយផ្អែកលើគោលដៅនិងចំណុចដៅអាទិភាពជាតិ ក៏ដូចជាការបែងចែកសូចនាករតាមវិស័យដែលបានផ្តល់ក្នុង *ផយអជ* ក្រសួង/ស្ថាប័ននីមួយៗនឹងរៀបចំផែនការលម្អិតតាមផ្នែករបស់ខ្លួននៅខែមិថុនា ឆ្នាំ២០០៦ ក្នុងការពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធទាំងអស់ ដូចគ្នា នេះ ក្រោមថ្នាក់ជាតិ (ខេត្ត ស្រុក និងឃុំ) នឹងធ្វើការពិគ្រោះយោបល់ពីខែមករា-មេសា ឆ្នាំ២០០៦ ដើម្បីរៀបចំផែនការវិនិយោគរបស់ខ្លួនទៅតាមតម្លៃដែលសមស្រប ។

នេះនឹងជះឥទ្ធិពលដោយផ្ទាល់ ហើយនឹងត្រូវគិតគូរក្នុងការរៀបចំ *ករស* ឆ្នាំ២០០៧-២០០៩ ក្របខ័ណ្ឌចំណាយរយៈពេលមធ្យមឆ្នាំ២០០៧-២០១១ និងថវិកាប្រចាំឆ្នាំ២០០៧ ។

៦.០៤ *វឌ្ឍនភាពនៃការអនុវត្ត* *ផយអជ* នឹងត្រូវធ្វើការតាមដានត្រួតពិនិត្យនិងវាយតម្លៃប្រចាំឆ្នាំ ហើយរបាយការណ៍នឹងត្រូវរៀបចំដោយផ្អែកតាមការរកឃើញ និងសកម្មភាព កែសម្រួលដែលបានលើកឡើង ។ ការវាយតម្លៃដូចនោះនឹងធ្វើរៀងរាល់ដើមឆ្នាំនីមួយៗ ហេតុដូចនេះ ការតម្រង់ទិសឡើងវិញ និង/ឬការកែតម្រូវដែលអាចធ្វើបាន អាចត្រូវធ្វើតាមរយៈការពិនិត្យប្រចាំឆ្នាំ ។ ដូច្នេះ ការងារការវាយតម្លៃ លើកដំបូងនឹងត្រូវអនុវត្តក្នុងកំឡុងពីខែមករា ដល់ខែមីនា ឆ្នាំ២០០៧ ហើយរបាយការណ៍វឌ្ឍនភាពនឹងត្រូវរៀបចំនៅខែមិថុនា ឆ្នាំ២០០៧ ។ ពេលវេលាដែលបានកំណត់ដូចគ្នានេះដែរ នឹងត្រូវធ្វើការសង្កេតសម្រាប់ការរៀបចំរបាយការណ៍វឌ្ឍនភាពនៅក្នុងឆ្នាំនីមួយៗ ដែលទទួលបានជោគជ័យ ។ របាយការណ៍វឌ្ឍនភាពនឹងត្រូវផ្សព្វផ្សាយយ៉ាងទូលំទូលាយ ហើយនឹង (១) បង្កើតមូលដ្ឋានសម្រាប់ការកែតម្រូវ និងការតម្រង់ទិសឡើងវិញ នៃសកម្មភាពសម្រាប់ឆ្នាំបន្ទាប់ (២) ប្រើប្រាស់ស្របជាមួយនឹង *ករស* ជារបាយការណ៍របស់រាជរដ្ឋាភិបាល ដើម្បីការងារការកៀរគរជំនួយប្រចាំឆ្នាំ (ឧទាហរណ៍ ការប្រជុំក្រុមពិគ្រោះយោបល់ជាដើម) ។ ឯកសារ *ផយអជ* ស្របជាមួយនឹង *ករស* ឆ្នាំ២០០៦-២០០៨ (ស្របគ្នាទាំងស្រុងជាមួយនឹង *ផយអជ*) នឹងជាឯកសារចម្បងរបស់រាជរដ្ឋាភិបាលសម្រាប់ការណែនាំការពិភាក្សានៅឯកិច្ចប្រជុំការកៀរគរជំនួយនាខែមីនា ឆ្នាំ២០០៦ ។

៦.០៥ ក្របខ័ណ្ឌតាមដានត្រួតពិនិត្យ និងវាយតម្លៃរួមនៃ *ផយអជ* នឹងត្រូវរៀបចំ ដើម្បីអនុវត្តការងារសំខាន់ៗពីរ ។ ទី១ *ផយអជ* នឹងធ្វើការតាមដានត្រួតពិនិត្យប្រចាំឆ្នាំ វឌ្ឍនភាពនៃការអនុវត្តគោលនយោបាយ កម្មវិធី និងការសម្រេចបានគោលដៅ ចំណុចដៅ តាមរយៈការកំណត់ពីរ (១) ធាតុចូល និងលទ្ធផល និង (២) លទ្ធផលនៃការអភិវឌ្ឍ ។ ទី២ *ផយអជ* នឹងគាំទ្រការវាយតម្លៃគោលនយោបាយ កម្មវិធី តាមរយៈការប្រើប្រាស់សូចនាករជាមូលដ្ឋាន ទាំងការពិនិត្យឡើងវិញជាប្រចាំនូវវឌ្ឍនភាពនៃការអនុវត្តគោលនយោបាយ កម្មវិធីនៃ *ផយអជ* និងការវាយតម្លៃពីទំនាក់ទំនងរវាងការអនុវត្តសកម្មភាព និងការផ្លាស់ប្តូរក្នុងលទ្ធផលដែលគ្រោងទុក ។

៦.០៦ ទិន្នន័យពីសូចនាករធាតុចូលនិងលទ្ធផល ភាគច្រើននឹងត្រូវប្រមូលតាមរយៈប្រព័ន្ធរដ្ឋបាល ។ សម្រាប់គោលបំណងនេះ អាទិភាពដ៏សំខាន់មួយរបស់ *ផយអជ* នឹងត្រូវដាក់ឱ្យដំណើរការនូវប្រព័ន្ធព័ត៌មានរដ្ឋបាលដែលសមហេតុផល និងដែលអាចជឿទុកចិត្តបាន ។ ផ្ទុយមកវិញ ការវាយតម្លៃគោលនយោបាយឬកម្មវិធី នឹងពាក់ព័ន្ធភាគច្រើនបំផុតជាមួយនឹងសូចនាករលទ្ធផលដែលមានការប្រែប្រួលយឺត ។ សម្រាប់កាតវាយតម្លៃនេះ ប្រភពព័ត៌មានចម្បងគឺ ការធ្វើអង្កេតនានាទៅតាមកាលវេលាកំណត់ ។

៦.០៧ ក្នុងទស្សនៈសំខាន់បំផុត នៃការតាមដានត្រួតពិនិត្យ និងការវាយតម្លៃជាប្រចាំ ពីការអនុវត្ត *ផយអជ* រចនាសម្ព័ន្ធមួយដែលមានពីរកម្រិត នឹងត្រូវអនុម័តជាក្របខ័ណ្ឌនៃកិច្ចប្រតិបត្តិការរបស់វា នៅថ្នាក់ជាតិ

ចំនួន"សូចនាករសំខាន់ៗ" ដែលបានកំណត់ និងអាចគ្រប់គ្រងបាន នឹងត្រូវប្រើប្រាស់ដើម្បីត្រួតពិនិត្យទំហំសំខាន់ៗ នៃវឌ្ឍនភាពប្រចាំឆ្នាំនៃ *ផយអជ* ដែលផ្អែកលើមូលដ្ឋាននេះ របាយការណ៍វឌ្ឍនភាពប្រចាំឆ្នាំនេះ នឹងត្រូវធ្វើការ រៀបចំឡើង ។ កម្រិតទី២នៃរចនាសម្ព័ន្ធ នឹងត្រូវប្រើប្រាស់នៅតាមក្រសួង-ស្ថាប័ន ។ ក្រសួង-ស្ថាប័នពាក់ព័ន្ធ នីមួយៗ នឹងរៀបចំបញ្ជីសូចនាកររបស់ខ្លួន ដោយផ្អែកលើ *ផយអជ* សូចនាករនៃ *គអសក* ស្ថិតក្រោមសមត្ថកិច្ច និងសូចនាករផ្សេងៗទៀត ដែលទាក់ទងនឹងគោលបំណងសម្រាប់ការតាមដានត្រួតពិនិត្យតាមវិស័យ ។ គោល បំណងនៃការតាមដានត្រួតពិនិត្យនិងការវាយតម្លៃ នឹងត្រូវធ្វើឱ្យបានស៊ីជម្រៅ និងលម្អិតបន្ថែម នៅថ្នាក់ក្រសួង-ស្ថាប័ន ដើម្បីគាំទ្រការវិភាគ និងការតាមដានត្រួតពិនិត្យលម្អិតពីគោលនយោបាយ កម្មវិធី និងធ្វើការតម្រង់ទិស ឡើងវិញ ។

៦.០៨ គម្រោងនៃក្របខ័ណ្ឌតាមដានត្រួតពិនិត្យ និងវាយតម្លៃ *ផយអជ* នឹងត្រូវបញ្ចប់នៅខែមិថុនា ឆ្នាំ២០០៦ ដែលជាពេលវេលាសម្រាប់ក្រសួងផែនការ ដាក់ឱ្យដំណើរការក្របខ័ណ្ឌនិងស្ថាប័នដែលចាំបាច់ ដើម្បីធានា លទ្ធផលនៃរបាយការណ៍តាមដានត្រួតពិនិត្យ និងវាយតម្លៃ *ផយអជ* ប្រចាំឆ្នាំ ដោយប្រើប្រាស់សូចនាករសំខាន់ៗ និងព័ត៌មានពាក់ព័ន្ធ ។ សូចនាករដែលមានក្នុងតារាង៣.២ (ជំពូក៣) នឹងត្រូវប្រើប្រាស់ជាសូចនាការសំខាន់ៗ នេះ ។ ដូចគ្នានេះដែរ ក្រសួង-ស្ថាប័នពាក់ព័ន្ធនីមួយៗ នឹងបង្កើតក្របខ័ណ្ឌប្រតិបត្តិចាំបាច់នៅខែមិថុនា ឆ្នាំ ២០០៦ ដើម្បីធានាការតាមដានត្រួតពិនិត្យជាប្រចាំនៃសូចនាករដែលបានកំណត់ ។ ក្នុងការជ្រើសរើសសូចនាករ ក្រសួង-ស្ថាប័ននីមួយៗ នឹងអនុវត្តតាមការណែនាំរួមខ្លះៗ ដើម្បីធានាការដាក់ បញ្ចូលសូចនាករដែល :

- សម្របសម្រួលការធ្វើសេចក្តីសម្រេចចិត្តដែលបានកំណត់ និងជួយដល់ការកំណត់ឡើងវិញនៃអាទិភាព និង គោលនយោបាយ ។
- លើកកម្ពស់តម្លាភាព និងគណនេយ្យភាព តាមរយៈការកែលម្អការចែករំលែកព័ត៌មាន ។
- ជំរុញឱ្យមានការយោគយល់គ្នាកាន់តែប្រសើរឡើងនៃទំនាក់ទំនងរវាងការអនុវត្ត *ផយអជ* និងផល ប៉ះពាល់នៃលទ្ធភាព ។
- មានទស្សនៈច្បាស់លាស់ ដើម្បីបញ្ចូលទៅក្នុងការបង្កើតប្រព័ន្ធទិន្នន័យ ។

ក្រសួងផែនការនឹងបង្កើតទម្រង់របាយការណ៍រួមមួយ និងអនុម័តតារាងពេលវេលា ដើម្បីកំណត់មាតិកា ភាពជាប់ លាប់និងពេលវេលាកំណត់នៃការរាយការណ៍របស់ក្រសួង/ស្ថាប័ន តាមរយៈការពិភាក្សាគ្នា ។ ទម្រង់របាយ ការណ៍នេះ នឹងត្រូវបញ្ចប់នៅខែមិថុនា ឆ្នាំ២០០៦ ។

៦.០៩ វិទ្យាស្ថានជាតិស្ថិតិ (*វជស*) នៃក្រសួងផែនការ គឺជាស្ថាប័នដែលបានចាត់តាំង និងមានសិទ្ធិអំណាចខាង បច្ចេកទេស ដើម្បីប្រមូល ដំណើរការ និងបង្ហាញទិន្នន័យផ្សេងៗ ដែលទាក់ទងនឹង[illegible] ច្បាប់ស្ថិតិបានអនុម័ត នៅខែមីនា ឆ្នាំ២០០៥ អនុញ្ញាតឱ្យ *វជស* ទទួលខុសត្រូវគ្រប់សកម្មភាព[illegible]ទាំងអស់ ដើម្បី

ទាក់ទងនឹងស្ថិតិ និងការបង្កើតព័ត៌មានផ្សេងៗនៅក្នុងប្រទេស ។ ដូច្នេះ *វជស* នឹងដើរតួនាទីយ៉ាងសំខាន់ក្នុងការធានាឱ្យមានទិន្នន័យជាប្រចាំអំពីសូចនាករ *ផយអជ* សម្រាប់គោលបំណងការតាមដានត្រួតពិនិត្យ និងការវាយតម្លៃ ។ *វជស* ទើបបានបញ្ចប់នាពេលថ្មីៗ អំពីផែនការមេស្តីពីស្ថិតិ[១] សម្រាប់កម្ពុជា ដែលបង្កើតឡើងជាផែនការអាទិភាព សម្រាប់រយៈពេលវែង សម្រាប់ប្រព័ន្ធស្ថិតិជាតិរបស់ប្រទេស ដែលរួមមាន *វជស* អង្គភាពស្ថិតិនៅតាមបណ្តាក្រសួងពាក់ព័ន្ធ និងធនាគារជាតិនៃកម្ពុជា ។ ផែនការមេស្តីពីស្ថិតិផ្តល់ទស្សនៈ យុទ្ធសាស្ត្ររយៈពេលវែង និងផែនការហិរញ្ញប្បទានសម្រាប់សកម្មភាពស្ថិតិ សម្រាប់រយៈពេលពីឆ្នាំ២០០៦-២០១៥ ហើយផែនការមេនេះ ក៏បានគ្រោងផងដែរនូវកម្មវិធីការងារ និងស្ថិតិហេដ្ឋារចនាសម្ព័ន្ធជាអាទិភាព ដែលរួមមានលទ្ធផលស្ថិតិសំខាន់ៗ ដែលត្រូវអនុវត្តក្នុងអំឡុងពេលនោះ ។ ក្នុងក្របខ័ណ្ឌនេះ ផែនការការងាររយៈពេលមធ្យម (២០០៦-២០១០) នឹងត្រូវបញ្ចូលសម្រាប់ការបង្កើតទិន្នន័យស្ថិតិ អំពីសូចនាកររបស់ *ផយអជ* តាមកម្រិតស្មើៗគ្នាតាមតម្រូវការ ។ ដូចគ្នានេះដែរ *វជស* នឹងប្រើប្រាស់កាំអ៊ិនហ្វូ (ប្រព័ន្ធព័ត៌មានរបស់វា) ដើម្បីគាំទ្រការតាមដានត្រួតពិនិត្យ និងការផ្សព្វផ្សាយ ។ ចំពោះសកម្មភាពទាំងអស់ខាងលើសមត្ថភាពរបស់ *វជស* និងស្ថាប័នពាក់ព័ន្ធរបស់ប្រព័ន្ធស្ថិតិជាតិ នឹងត្រូវកែសម្រួលជាបន្តបន្ទាប់ ទាំងផ្នែកជំនាញមនុស្ស និងលទ្ធភាពបច្ចេកទេស ។

៦.១០ សម្រាប់ការត្រួតពិនិត្យជាប្រចាំនៃដំណើរការ *ផយអជ* លើមូលដ្ឋានប្រចាំឆ្នាំ ផែនការការងាររយៈពេលមធ្យមរបស់ផែនការមេស្តីពីស្ថិតិ អាចបង្កើតយន្តការ ដើម្បីអង្កេតតាមដានប្រចាំឆ្នាំ ឬកំណត់ចន្លោះពេលស្មើៗគ្នា ឬក៏ជំរឿនឬអង្កេតចន្លោះពេលស្មើៗគ្នាវែងជាងនេះ ដូចជា ជំរឿនប្រជាជន ជំរឿនកសិកម្ម ជំរឿនសហគ្រាស អង្កេត សេដ្ឋកិច្ច-សង្គមកិច្ច អង្កេតប្រជាសាស្ត្រនិងសុខភាព និងអង្កេតផ្សេងៗទៀត ។ ទិន្នន័យតាមតំបន់តូចៗ និងទិន្នន័យរបាយការណ៍រដ្ឋបាលជាប្រចាំ ក៏មានសារៈសំខាន់ណាស់ដែរ សម្រាប់គោលបំណងការរៀបចំផែនការដែលបានដៅ និងកម្មវិធីសកម្មភាពនានា ហើយនិងជាការបំពេញបន្ថែមដ៏មានសារៈសំខាន់ចំពោះព័ត៌មានដែលបានពីសកម្មភាពតាមដានត្រួតពិនិត្យ និងវាយតម្លៃ ដូចជាអង្កេតគំរូជាតិ ជាដើម ។ ហេតុដូចនេះ ទិន្នន័យមូលដ្ឋានឃុំដែលមាន ត្រូវដើរតួនាទីយ៉ាងសំខាន់ ក្នុងយន្តការតាមដានត្រួតពិនិត្យ និងវាយតម្លៃ *ផយអជ* ។ ចំពោះបញ្ហាទាំងនេះ នឹង ត្រូវទាមទារការកែលម្អបន្ថែមក្នុងទិន្នន័យមូលដ្ឋាន និងទំនាក់ទំនងទិន្នន័យ រវាង *វជស* ជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធ និងជាមួយក្រោមថ្នាក់ជាតិ ។ ក្រសួងផែនការ នឹងធ្វើការពិគ្រោះយោបល់ជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធរបស់រាជរដ្ឋាភិបាល និងរៀបចំក្របខ័ណ្ឌអនុវត្តជាក់ស្តែងមួយ និងវិធីសាស្ត្រក្រោមផែនការការងាររយៈពេលមធ្យម ដើម្បីតាមដានវឌ្ឍនភាព អំពីសូចនាករសំខាន់ៗរបស់ *ផយអជ* នៅខែមីនា ឆ្នាំ២០០៦ ។ កម្មវិធីនេះ នឹងបង្កើតផ្នែកនៃរបាយការណ៍វឌ្ឍនភាពដំបូងអំពី *ផយអជ* ដែលនឹងត្រូវធ្វើឱ្យរួចរាល់នៅខែមិថុនា ឆ្នាំ២០០៦ ។

---

[១] ផែនការមេស្ថិតិសម្រាប់កម្ពុជា វិទ្យាស្ថានជាតិស្ថិតិ ក្រសួងផែនការ ខែកញ្ញា ឆ្នាំ២០០៥

៦.១១ សម្រាប់ការតាមដានត្រួតពិនិត្យ និងការវាយតម្លៃនៅថ្នាក់ក្រសួង-ស្ថាប័ន ប្រភពព័ត៌មានសំខាន់ៗ គឺជាប្រព័ន្ធទំនាក់ទំនងរដ្ឋបាលនិងរបាយការណ៍របស់ស្ថាប័នទាំងនោះ ។ នាពេលបច្ចុប្បន្ននេះ ក្រសួង-ស្ថាប័នពាក់ព័ន្ធ រក្សាទិន្នន័យមូលដ្ឋាន និងព័ត៌មានស្ថិតិរបស់ខ្លួនផ្ទាល់ ប៉ុន្តែសមត្ថភាពរបស់ពួកគេ គឺមិនទាន់ស្មើគ្នានៅឡើយ ។ ទស្សនៈសំខាន់ៗនៃការតាមដានត្រួតពិនិត្យ និងការវាយតម្លៃនៅថ្នាក់ក្រសួង-ស្ថាប័នក្រោមក្របខ័ណ្ឌ *ផយអជ* គ្រប់ក្រសួង-ស្ថាប័នទាំងអស់ ត្រូវការកែតម្រូវឱ្យមានលក្ខណៈជាប្រព័ន្ធនូវសមត្ថភាពការប្រមូល និងដំណើរការទិន្នន័យ ជាពិសេស ទំហំសូចនាកររបស់ *ផយអជ* ដែលបានអនុម័ត និងដែលបានលើកឡើងដោយក្រសួង-ស្ថាប័ននានា ។ ការគាំទ្រចាំបាច់នឹងត្រូវផ្តល់ ដើម្បីបង្កើតនិងថែរក្សាគេហទំព័រផ្ទាល់របស់ក្រសួង-ស្ថាប័ននីមួយៗ ដើម្បីធ្វើការកែសម្រួលរៀងរាល់៦ខែម្តង ដែលពួកគេនឹងផ្តល់និន្នន័យពាក់ព័ន្ធអំពីសូចនាករសម្រាប់ប្រើប្រាស់ តាមរយៈប្រព័ន្ធគ្រប់គ្រងផ្ទាល់របស់ពួកគេ ក៏ដូចជាសម្រាប់ផ្ទៃក្នុងរាជរដ្ឋាភិបាល និងការប្រើប្រាស់ជាសាធារណៈ ។

៦.១២ ជាក់ស្តែង ការអនុម័តក្របខ័ណ្ឌទូលំទូលាយមួយសម្រាប់ការតាមដានត្រួតពិនិត្យ និងការវាយតម្លៃ *ផយអជ* មិនបានរារាំងតម្រូវការដើម្បីអនុវត្តវិធីសាស្ត្រតាមវិស័យ និងវិធីសាស្ត្រចូលរួម ក្នុងការតាមដានត្រួតពិនិត្យ និងការវាយតម្លៃ *ផយអជ* ។ ទាំងអស់នេះ នឹងត្រូវប្រើប្រាស់ជាប្រភពសក្តានុពលដ៏សំខាន់នៃការតាមដានត្រួតពិនិត្យ និងការវាយតម្លៃ ដែលផ្តោតលើបញ្ហាដែលបានកំណត់ចំៗ និងទាន់ពេលវេលា ។ បញ្ហាទាំងនេះនឹងត្រូវបញ្ចូលផងដែរ នូវដំណើរការអនុវត្តន៍ *ផយអជ* ។ ដូចគ្នានេះដែរ ឧបករណ៍ថ្មីៗនិងទាន់សម័យ (ឧទាហរណ៍ ការដាក់ពិន្ទុរបស់ប្រជាពលរដ្ឋ ទាក់ទងនឹងទស្សនៈនៃការផ្លាស់ប្តូរ និងការពេញចិត្តជាមួយនឹងបរិមាណនិងគុណភាពនៃសេវាសាធារណៈផ្សេងៗ) នឹងត្រូវប្រើប្រាស់ ដើម្បីលើកកម្ពស់សមាសភាពចូលរួម និងសម្លេងប្រជាជននៅមូលដ្ឋាន ដើម្បីបញ្ចូលទៅក្នុងការតាមដានត្រួតពិនិត្យនិងការវាយតម្លៃ *ផយអជ* ។



ជំពូក ៧

សេចក្តីសន្និដ្ឋាន



ជំពូក ៧

សេចក្តីសន្និដ្ឋាន

៧.០១ ការយកចិត្តទុកដាក់យ៉ាងពេញលេញក្នុងការធ្វើឱ្យមានវឌ្ឍនភាពរហូតមកដល់ឆ្នាំ២០០៥ និងការទទួលបានជោគជ័យនៃស្ថានភាពសេដ្ឋកិច្ច-សង្គមកិច្ច ឯកសារនេះត្រូវបានច្របាច់និងរួមបញ្ចូលគ្នារវាង *គអសក* និង *យុទ្ធសាស្ត្រជាតិកាត់បន្ថយភាពក្រីក្រ* និង :

- បង្ហាញយ៉ាងច្បាស់ពី ការកំណត់គ្រប់ជ្រុងជ្រោយនៃគោលដៅម៉ាក្រូទាំងឡាយ ដែលនឹងត្រូវសម្រេចឱ្យបាននៅក្នុងរយៈពេល ៥ឆ្នាំខាងមុខ (២០០៦-២០១០) តាមរយៈការអនុវត្តយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល ។
- ធ្វើឱ្យងាយយល់យុទ្ធសាស្ត្រនិងសកម្មភាពសំខាន់ៗ ដែលនឹងត្រូវសម្រេចឱ្យបានដោយវិស័យនីមួយៗ និងដោយយកចិត្តទុកដាក់លើបញ្ហាអន្តរវិស័យ ។
- ចង្អុលបង្ហាញការចំណាយហិរញ្ញវត្ថុរួមចាំបាច់សម្រាប់រយៈពេលនោះ និងបានជ្រើសរើសការបែងចែកចំណាយនេះតាមវិស័យ ។
- កំណត់និងបង្ហាញច្បាស់ ពីគ្រប់ធនធានដែលមាន ។
- បង្ហាញពីគម្រោងដែលបានបញ្ចប់និងកំពុងដំណើរការរបស់ *ផយអជ* ទាក់ទងជាមួយ *ករស* និងដំណើរការថវិកាប្រចាំឆ្នាំ ។
- លម្អិតសេចក្តីត្រូវការសម្រាប់ការតាមដានត្រួតពិនិត្យឱ្យបានជិតដល់ពីវឌ្ឍនភាពនៃការអនុវត្ត *ផយអជ* ក៏ដូចជា វិធីសាស្ត្រដែលនឹងត្រូវរៀបចំឡើងសម្រាប់គោលដៅខាងលើ ។
- បង្ហាញម្តងហើយម្តងទៀតថា ឯកសារផែនការនេះជាឯកសារមួយរស់ ប្រែប្រួលតាមកាលៈទេសៈ និងមានលក្ខណៈឌីណាមិច ហើយនឹងត្រូវបានកែសម្រួលដោយរួមច្របាច់បញ្ចូលទិន្នន័យជាច្រើនទៀត និងផ្អែកលើការរកឃើញនៅពេលរៀបចំការពិនិត្យមើលឡើងវិញប្រចាំឆ្នាំ និងរបាយការណ៍ពីវឌ្ឍនភាពនៃការអនុវត្ត ។

៧.០២ ឯកសារនេះកំណត់ខ្លួនឯងដើម្បីធ្វើការកំណត់ជារួមលើ កម្រិតជាតិ បណ្តាគោលដៅជាយុទ្ធសាស្ត្រនិងអាទិភាព បណ្តាចំណុចដៅឬសូចនាករ និងការវិភាជន៍ធនធាន ។ គោលដៅនិងចំណុចដៅទាំងនេះនឹងត្រូវបំប្លែង និងលម្អិតបន្ថែមទៀតនៅតាមវិស័យនិងថ្នាក់ក្រោមជាតិ សម្រាប់ការធ្វើកិច្ចពិគ្រោះយោបល់យ៉ាងទូលំទូលាយ ដែលនឹងធ្វើឡើងនៅក្នុងអំឡុងពេលពីរ-បីខែ ដើមឆ្នាំ២០០៦ ។ កិច្ចពិគ្រោះយោបល់នេះនឹងត្រូវធ្វើឡើងនៅ

សម្រួលដោយក្រសួងផែនការ ធ្វើការសហការជាមួយនឹងស្ថាប័នសំខាន់ៗមួយចំនួន[១] ទៀតដែលទទួលខុសត្រូវក្នុងការកែសម្រួលនិងធ្វើបច្ចុប្បន្នភាព *ផយអជ* ។

៧.០៣ កត្តាមួយចំនួនដែលមិនអាចថ្លឹងថ្លែងបាន និងមិនអាចប៉ាន់ស្មានទុកមុន ឬមានហានិភ័យ ដែលអាចមានផលប៉ះពាល់លើការអនុវត្ត និងវឌ្ឍនភាពរបស់ *ផយអជ* នោះគឺ :

- ធនធានដែលបានរំពឹងទុកនឹងមិនត្រូវបានទទួល ជាពិសេសពីដៃគូអភិវឌ្ឍន៍ក្រៅប្រទេស ។
- ថ្លៃឡើងខ្ពស់នៃប្រេងឥន្ធនៈនិងឧស្ម័នលើពិភពលោក នៅតែបន្តឡើងរហូតដល់កម្រិតមិនអាចស្មានដល់ (ជាងពីរដងនៃថ្លៃនៅឆ្នាំ២០០៤) ដែលនឹងជំរុញឱ្យមានអតិផរណាដល់កម្រិតខ្ពស់ ។
- ស្ថានភាពខាងនយោបាយ សន្តិសុខ និងសង្គមក្នុងតំបន់ និងពិភពលោក ដោយសារសកម្មភាពនៃភេរវកម្ម ។
- ឧបសគ្គពាណិជ្ជកម្ម អន្តរជាតិមិនត្រូវបានធ្លាក់ចុះតាមជំហានដែលបានរំពឹងទុក ។
- ការរីករាលដាលនៃជម្ងឺនានាដូចជា ជម្ងឺផ្តាសាយបក្សី និងជម្ងឺថ្មីៗផ្សេងទៀត ។
- គ្រោះធម្មជាតិ កើតចេញមកខុសពីកម្រិតធម្មតា ដូចជា ការសារចុះសារឡើងនៃគ្រោះរាំងស្ងួត ឬគ្រោះទឹកជំនន់ ដែលមានឥទ្ធិពលលើផលិតផលដំណាំ និងបំផ្លិចបំផ្លាញហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត និងទ្រព្យសម្បត្តិ ។

៧.០៤ មាគ៌ាដែលត្រូវធ្វើដំណើរទៅមុខ មានការប្រឈមនិងការលំបាក ។ ទោះជាដូចនេះក្តី រាជរដ្ឋាភិបាលកម្ពុជាជឿជាក់ថា អាចអនុវត្ត *ផយអជ* ក្នុងគ្រប់ប្រធានបទទាំងអស់ ដើម្បីយកចិត្តទុកដាក់ធ្វើការផ្លាស់ប្តូរទៅរកភាពប្រាកដនិយមពីមួយឆ្នាំទៅមួយឆ្នាំ ហើយគ្រប់ធនធានដែលត្រូវការទាំងអស់នឹងមានគ្រប់គ្រាន់ ។ រាជរដ្ឋាភិបាលកម្ពុជាសង្ឃឹមថា នឹងទទួលបានកិច្ចសហការយ៉ាងពេញលេញពីគ្រប់អ្នករួមចំណែកទាំងអស់ (ដៃគូអភិវឌ្ឍន៍ក្រៅប្រទេស សង្គមស៊ីវិល និងគ្រប់ក្រសួង/ស្ថាប័នរដ្ឋាភិបាល) ក្នុងការធ្វើឱ្យមានភាពប្រាកដនិយមបណ្តាគោលដៅរបស់ *ផយអជ* ដើម្បីធ្វើឱ្យប្រសើរឡើងការរស់នៅរបស់ប្រជាជនកម្ពុជា ជាពិសេស កាត់បន្ថយឱ្យបាននាប់រហ័សនូវកម្រិតនៃភាពក្រីក្រ ។

---

[១] ក្រសួងផែនការ ឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

ឧបសម្ព័ន្ធ ១.១

សូចនាករនិងចំណុចដៅនៃគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា

សំគាល់ : ១. ឆ្នាំជាមូលដ្ឋាន និងគោលដៅសម្រាប់ឆ្នាំ ២០០៥, ឆ្នាំ២០១០ និងឆ្នាំ២០១៥ ដែលយកពីរបាយការណ៍គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា ឆ្នាំ២០០៣ ។

២. ការសម្រេចបាននៅឆ្នាំ២០០៥ ដែលយកពីការកែលម្អគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា នាខែកញ្ញា ឆ្នាំ២០០៥ ។

៣. ស្ថានភាព ពីការកែលម្អគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា នាខែកញ្ញា ឆ្នាំ២០០៥ :

- ក : ដំណើរការងារបច្ចុប្បន្នត្រូវតាមចំណុចដៅ និងនៅឆ្នាំ២០១៥ បានសម្រេចលើសការរំពឹងទុក ។
- ខ : ដំណើរការងារបច្ចុប្បន្នត្រូវតាមចំណុចដៅ និងអាចសម្រេចបានតាមចំណុចដៅនៅឆ្នាំ២០១៥ ។
- គ : ដំណើរការងារបច្ចុប្បន្នមិនត្រូវតាមចំណុចដៅ ប៉ុន្តែស្ថានភាពមានភាពប្រសើរជាងឆ្នាំជាមូលដ្ឋាន និន្នាការនេះ ចំណុចដៅនៅឆ្នាំ ២០១៥ ហាក់ដូចជាពុំអាចសម្រេចបាន ។
- ឃ : ដំណើរការងារបច្ចុប្បន្នមិនត្រូវតាមចំណុចដៅ ហើយស្ថានភាពពុំមានភាពប្រសើរជាងឆ្នាំជាមូលដ្ឋាន និន្នាការនេះ ចំណុចដៅនៅឆ្នាំ២០១៥ ហាក់ដូចជាពុំអាចសម្រេចបាន ។
- ង : ដំណើរការងារបច្ចុប្បន្នមិនត្រូវតាមចំណុចដៅ ហើយស្ថានភាពកាន់តែអាក្រក់ជាងឆ្នាំជាមូលដ្ឋាន និន្នាការនេះ ចំណុចដៅនៅឆ្នាំ២០១៥ ហាក់ដូចជាពុំអាចសម្រេចបាន ។

	[illegible]	[illegible]	[illegible]	[illegible]	[illegible]	[illegible]	[illegible]	[illegible]
	គអសក១: លុបបំបាត់ភាពក្រីក្រខ្លាំងធ្ងរ និងភាពអត់ឃ្លាន							
	១. កាត់បន្ថយឱ្យបានពាក់កណ្តាលរវាងឆ្នាំ១៩៩៣ និង២០១៥ នូវសមាមាត្រប្រជាជនដែលមានចំណូលទាបជាងខ្សែបន្ទាត់ភាពក្រីក្រថ្នាក់ជាតិ							
១.១	កាត់បន្ថយសមាមាត្រប្រជាជនដែលមានប្រាក់ចំណូលទាបជាងខ្សែបន្ទាត់ភាពក្រីក្រថ្នាក់ជាតិ (%)	(៣៩)	១៩៩៣	៣១	៣៤.៧[១] (២៨.០)	២៥	១៩.៥	ក
១.២	បង្កើនសមាសភាគប្រជាជនដែលក្រជាងគេបំផុតក្នុងការចំណាយថ្នាក់ជាតិ (%)	៧.៤	១៩៩៣	៩		១០	១១	ង
	ប្រៀបធៀបការប៉ាន់ស្មាននៅឆ្នាំ ២០០៤	(៨.៥)			(៧)			
១.៣	កាត់បន្ថយសមាមាត្រកុមារធ្វើការងារដែលមានអាយុពី ៥ ដល់ ១៧ឆ្នាំ (%)	១៦.៥	១៩៩៩	១៣	២២.៣	១០.៦	៨	ង
	២. កាត់បន្ថយឱ្យបានពាក់កណ្តាលរវាងឆ្នាំ ១៩៩៣ និង ២០១៥ នូវសមាមាត្រប្រជាជនដែលទទួលរងនូវការអត់ឃ្លាន							
១.៤	កាត់បន្ថយអត្រាប្រេវ៉ាឡង់នៃកុមារមិនគ្រប់ទម្ងន់ (ទម្ងន់ធៀបនឹងអាយុ <2 SD) ដែលមានអាយុក្រោម ៥ឆ្នាំ (%)	៤៥.២	២០០០	៣៦	ពុំមានតួលេខ	២៩	២២	
១.៥	កាត់បន្ថយសមាមាត្រប្រជាជនដែលរស់នៅក្រោមខ្សែបន្ទាត់ម្ហូបអាហារ (%)	(២០)	១៩៩៣	១៦	១៩.៧[២] (១៨.២)	១៣	១០	ក

[១] ទិន្នន័យសម្រាប់ ១.១ និង ១.៥ បង្ហាញពីសភាពការនៅក្នុងតំបន់ (៩៦ភាគរយ នៃបណ្តាភូមិនៅជនបទ និង ៩៦ភាគរយនៃចំនួនគ្រួសារដែលបានអង្កេតនៅឆ្នាំ១៩៩៣ ដែលតំបន់ផ្សេងទៀតនាពេលនោះមានបញ្ហាសន្តិសុខ ។

[២] ដូចគ្នានិងចំណុចខាងលើដែរ ។

១.៦	កាត់បន្ថយប្រេវ៉ាឡង់នៃកុមារគ្រិន (កម្ពស់ធៀបនឹងអាយុ <2SD) ដែលមានអាយុក្រោម ៥ឆ្នាំ (%)	៤៤.៦	២០០០	៣៥	ពុំមានតួលេខ	២៨	២២	
១.៧	កាត់បន្ថយប្រេវ៉ាឡង់នៃកុមារស្គម (ទម្ងន់ធៀបនឹងកម្ពស់ <2SD) ដែលមានអាយុក្រោម ៥ឆ្នាំ (%)	១៥	២០០០	១៣	ពុំមានតួលេខ	១០		
១.៨	សមាមាត្រគ្រួសារប្រើប្រាស់អំបិលអ៊ីយ៉ូត (%)	១៤	២០០០	៨០	៣១.៥	៩០	៩០	គ
	គោលដៅ២: សម្រេចឱ្យបានជាទូទៅនូវការអប់រំមូលដ្ឋានរយៈពេល ៩ឆ្នាំ							
	៣. ធានាឱ្យកុមារទាំងអស់បានបញ្ចប់ការសិក្សាកំរិតបឋមនៅមុនដំណាច់ឆ្នាំ ២០១០ និងការសិក្សាកំរិតមូលដ្ឋានរយៈពេល ៩ឆ្នាំ នៅមុនដំណាច់ឆ្នាំ២០១៥							
២.១	អត្រាពិតចូលរៀនថ្មី	៨១	២០០១	៩៥	៨១.០	១០០	១០០	ឃ
២.២	អត្រាពិតនៃការសិក្សានៅបឋមសិក្សា	៨៧	២០០១	៩៥	៩១.៩	១០០	១០០	គ
២.៣	អត្រាពិតនៃការសិក្សានៅមធ្យមសិក្សាបឋមភូមិ	១៩	២០០១	៥០	២៦.១	៧៥	១០០	គ
២.៤	កាត់បន្ថយសមាមាត្រកុមារអាយុ ពី ៦ ដល់ ១៤ឆ្នាំ ដែលមិនបានចូលរៀន (%)	៣៥	១៩៩៩	២២	១៨.៧	១១	០	ក
២.៥	អត្រាគង់វង្សនៃសិស្សដែលបានចូលរៀនពីថ្នាក់ទី១ ដល់ទី៥	៥៨	២០០១	៧៧	៥៩.២	១០០	១០០	ឃ
២.៦	អត្រាគង់វង្សនៃសិស្សដែលបានចូលរៀនពីថ្នាក់ទី១ ដល់ទី៦ (ថ្នាក់ចុងក្រោយនៃការសិក្សាបឋមសិក្សា)	៥១	២០០១	៧៣	៥៣.១	១០០	១០០	ឃ
២.៧	អត្រាគង់វង្សនៃសិស្សដែលបានចូលរៀនពីថ្នាក់ទី១ ដល់ទី៩ (ថ្នាក់ចុងក្រោយនៃការសិក្សាកម្រិតមូលដ្ឋាន)	៣៣	២០០១	៥២	៣០.១៨	៧៦	១០០	ង
២.៨	អត្រាអក្ខរកម្មនៃអ្នកដែលមានអាយុពី ១៥ ដល់ ២៤ឆ្នាំ	៨២	១៩៩៩	៩០	៨៣.៤	៩៥	១០០	ឃ
	៤. លុបបំបាត់វិសមភាពយេនឌ័រក្នុងការអប់រំកម្រិតមូលដ្ឋានរយៈពេល ៩ឆ្នាំ							
២.៩	ផលធៀបសិស្សស្រី/ប្រុសនៅបឋមសិក្សា (%)	៨៧	២០០១	៩៨	៨៩.៥	១០០	១០០	គ
២.១០	ផលធៀបសិស្សស្រី/ប្រុសនៅមធ្យមសិក្សាបឋមភូមិ (%)	៦៣	២០០១	៩៦	៧៧	១០០	១០០	គ
	គោលដៅ៣: លើកកម្ពស់សមភាពយេនឌ័រ និងផ្តល់សិទ្ធអំណាចដល់ស្ត្រី							
	៥. កាត់បន្ថយគម្លាតយេនឌ័រនៅកម្រិតមធ្យមសិក្សាទុតិយភូមិ និងឧត្តមសិក្សា							
៣.១	បង្កើនផលធៀបរវាងសិស្សស្រី និងសិស្សប្រុសនៅកម្រិតមធ្យមសិក្សាទុតិយភូមិ (%)	៤៨	២០០១	៥៥	៥៩.៩	៨០	១០០	ខ
៣.២	បង្កើនផលធៀបរវាងនិស្សិតស្រី និងនិស្សិតប្រុសនៅកម្រិតឧត្តមសិក្សា (%)	៣៨	២០០១	៥០	៤៥.៦	៧០	៨៥	គ
៣.៣	បង្កើនផលធៀបរវាងអក្ខរកម្មស្ត្រី និងបុរសអាយុពី ១៥ ដល់ ២៤ឆ្នាំ (%)	៨៧	១៩៩៨	៩៥	៩០.០			គ

[illegible]	[illegible]	[illegible]	[illegible]	[illegible]	[illegible]	[illegible]	[illegible]	[illegible]
៣.៤	បង្កើនផលធៀបរវាងអក្ខរកម្មស្ត្រី និងបុរសអាយុពី ២៥ ដល់ ៤៤ឆ្នាំ (%)	៧៨	១៩៩៨	៨៥	៨០.០	១០០	១០០	គ
	៦. លុបបំបាត់គម្លាតយេនឌ័រ សម្រាប់ការងារមានប្រាក់ឈ្នួលនៅគ្រប់វិស័យសេដ្ឋកិច្ច							
៣.៥	បង្កើនសមាមាត្រស្ត្រីធ្វើការងារមានប្រាក់ឈ្នួលក្នុងវិស័យកសិកម្ម (%)	៣៥	១៩៩៨	៥០	៥២.៥	៥០	៥០	ក
៣.៦	បង្កើនសមាមាត្រស្ត្រីធ្វើការងារមានប្រាក់ឈ្នួលក្នុងវិស័យឧស្សាហកម្ម (%)	៤៤	១៩៩៨	៥០	៥៣.៥	៥០	៥០	ក
៣.៧	បង្កើនសមាមាត្រស្ត្រីធ្វើការងារមានប្រាក់ឈ្នួលក្នុងវិស័យសេវាកម្ម (%)	២១	១៩៩៨	៣០	២៧	៣៧	៥០	គ
	៧. លុបបំបាត់គម្លាតយេនឌ័រនៅក្នុងស្ថាប័នសាធារណៈ							
៣.៨	បង្កើនសមាមាត្រនៃអសនៈរបស់ស្ត្រីនៅក្នុងសភាជាតិ (%)	១២	២០០៣	១៧	១៧.១	២៤	៣០	ខ
៣.៩	បង្កើនសមាមាត្រនៃអសនៈរបស់ស្ត្រីនៅក្នុងព្រឹទ្ធសភា (%)	១៣	២០០៣	១៧	១៤	១៤	៣០	គ
៣.១០	បង្កើនសមាមាត្រស្ត្រីជារដ្ឋមន្ត្រី (%)	៨	២០០៣	៩	៧.១	១២	១៥	ង
៣.១១	បង្កើនសមាមាត្រស្ត្រីជារដ្ឋលេខាធិការ (%)	៦	២០០៣	៨	៧.១	១៥	១៨	គ
៣.១២	បង្កើនសមាមាត្រស្ត្រីជាអនុរដ្ឋលេខាធិការ (%)	៥	២០០៣	៨	១១.៩	១៧	២០	ក
៣.១៣	បង្កើនសមាមាត្រស្ត្រីជាអភិបាលខេត្ត (%)	០	២០០៣	៣	០	៦	១០	ង
៣.១៤	បង្កើនសមាមាត្រស្ត្រីជាអភិបាលរងខេត្ត (%)	១	២០០៣	៤	១.៧	៨	១៥	ឃ
៣.១៥	បង្កើនសមាមាត្រស្ត្រីជាសមាជិកក្រុមប្រឹក្សាឃុំ-សង្កាត់ (%)	៨	២០០៣	៧	៨.៧	១៥	២៥	ក
	៨. កាត់បន្ថយរាល់គ្រប់ទម្រង់នៃអំពើហិង្សាចំពោះស្ត្រី និងកុមារ							
៣.១៦	បង្កើនអត្រានៃប្រជាជនដែលដឹងថាអំពើហិង្សាចំពោះស្ត្រីគឺជាអាកប្បកិរិយាខុសឆ្គង និងជាអំពើឧក្រិដ្ឋ (%)	ពុំមានតួលេខ		២៥	៤.៥	៥០	១០០	ង
៣.១៧	បង្កើនអត្រានៃករណីអំពើហិង្សាក្នុងគ្រួសារ ដែលត្រូវបានពិគ្រោះយោបល់ដោយបុគ្គលិកដែលមានជំនាញ (%)	ពុំមានតួលេខ		២០		៥០	១០០	
៣.១៨	ច្បាប់ប្រឆាំងអំពើហិង្សាចំពោះស្ត្រី និងកុមារត្រូវបានតាក់តែងឡើង និងអនុវត្តដោយអនុលោមទៅតាមនិយាមអន្តរជាតិ (ឆ្នាំ)			២០០៥				
៣.១៩	ប្រមូលទិន្នន័យស្ថិតិប្រចាំឆ្នាំ ដើម្បីត្រួតពិនិត្យអំពើហិង្សាចំពោះស្ត្រី (ឆ្នាំ)			២០០៥				
៣.២០	តាក់តែងឡើង និងអនុវត្តផែនការទប់ស្កាត់អំពើហិង្សា (ឆ្នាំ)			២០០៥				
	គោលដៅ៤: កាត់បន្ថយអត្រាមរណភាពកុមារ							
	៩. បន្ថយអត្រាមរណភាពកុមារអាយុក្រោម ៥ ឆ្នាំ							

[illegible]	[illegible]	[illegible]	[illegible]	[illegible]	[illegible]	[illegible]	[illegible]	[illegible]
៤.១	កាត់បន្ថយអត្រាមរណភាពកុមារអាយុក្រោម ៥ឆ្នាំ ក្នុង ១.០០០កំណើតរស់	១២៤	១៩៩៨	១០៥	៨២	៨៥	៦៥	ក
៤.២	កាត់បន្ថយអត្រាមរណភាពទារក ក្នុង ១.០០០កំណើតរស់	៩៥	១៩៩៨	៧៥	៦៦	៦០	៥០	ក
៤.៣	បង្កើនសមាមាត្រកុមារអាយុក្រោម ១ឆ្នាំ បានទទួលការចាក់ថ្នាំការពារជំងឺកញ្ជ្រិល (%)	៤១.៤	២០០០	៨០	៨០	៨៥	៩០	ខ
៤.៤	បង្កើនសមាមាត្រកុមារអាយុក្រោម ៦-៥៩ ខែ បានទទួលថ្នាំវីតាមីន អា (%)	២៨	២០០០	៧០	ពុំមានតួលេខ	៨០	៩០	
៤.៥	បង្កើនសមាមាត្រកុមារអាយុក្រោម ១ឆ្នាំ បានទទួលចាក់ថ្នាំការពារជំងឺខាន់ស្លាក់ ក្អកមាន់ និងតេតាណូស (%)	៤៣	២០០០	៨០	៨៣	៨៥	៩០	ក
៤.៦	បង្កើនសមាមាត្រទារកត្រូវបានបំបៅដោះដល់អាយុ ៦ខែ (%)	១១.៤	២០០០	២០	ពុំមានតួលេខ	៣៤	៤០	
៤.៧	បង្កើនសមាមាត្រនៃម្តាយដែលចាប់ផ្តើមបំបៅដោះទារកទើបនឹងកើតក្នុងរយៈពេលមួយម៉ោងនៃកំណើត (%)	១១	២០០០	២៨	២៥.៣	៤៥	៦២	ក
	គោលដៅទី៥: លើកកម្ពស់សុខភាពមាតា							
	១០. បន្ថយផលធៀបមរណភាពមាតា							
៥.១	កាត់បន្ថយផលធៀបមរណភាពមាតា ក្នុង ១០០.០០០ កំណើតកូន	៤៣៧	១៩៩៧	៣៤៣	ពុំមានតួលេខ	២៤៣	១៤០	
៥.២	កាត់បន្ថយអត្រាលទ្ធភាពផ្តល់កំណើតសរុប	៤	១៩៩៨	៣.៨	៣.៣	៣.៤	៣.០	ក
៥.៣	បង្កើនសមាមាត្រនៃការសម្រាលកូន ដោយបុគ្គលិកសុខាភិបាលដែលមានជំនាញ (%)	៣២	២០០០	៦០	ពុំមានតួលេខ	៧០	៨០	
៥.៤	បង្កើនសមាមាត្រនៃស្ត្រីរៀបការដែលប្រើប្រាស់វិធីពន្យារកំណើតទំនើប (%)	១៨.៥	២០០០	៣០		៤៤	៦០	ក
	តែក្នុងវិស័យសាធារណៈ (%)	(១១.៥)			(២០.១)			
៥.៥	បង្កើនសមាមាត្រនៃស្ត្រីមានផ្ទៃពោះ ដែលទទួលការពិគ្រោះមុនពេលសម្រាលកូនបានពីរដង ឬច្រើនជាងជាមួយបុគ្គលិកសុខាភិបាលដែលមានជំនាញ (%)	៣០.៥	២០០០	៦០		៧៥	៩០	ក
	តែក្នុងវិស័យសាធារណៈ (%)	(២៥.៤)			(៤៧)			
៥.៦	កាត់បន្ថយសមាមាត្រស្ត្រីមានផ្ទៃពោះ ដែលមានជំងឺស្លេកស្លាំងខ្វះជាតិដែក (%)	៦៦	២០០០	៥០	ពុំមានតួលេខ	៣៥	៣៣	
៥.៧	កាត់បន្ថយសមាមាត្រស្ត្រីអាយុ ១៥ ដល់ ៤៩ឆ្នាំ ដែលមានផលធៀបទម្ងន់នឹងកម្ពស់ក្រោម ១៨.៥ គក/ម៉ែតការ៉េ (%)	២១	២០០០	១៧	ពុំមានតួលេខ			
៥.៨	កាត់បន្ថយសមាមាត្រស្ត្រីអាយុ ១៥ ដល់ ៤៩ឆ្នាំ ដែលមានជំងឺស្លេកស្លាំងខ្វះជាតិដែក (%)	៥៨	២០០០	៤៥	ពុំមានតួលេខ			

[illegible]	[illegible]	[illegible]	ឆ្នាំ	២០០៥		២០១០	[illegible]	[illegible]
				[illegible]	[illegible]			
៥.៩	បង្កើនសមាមាត្រនៃស្ត្រីមានផ្ទៃពោះ ដែលសម្រាលកូនដោយការវះកាត់ (%)	០.៨	២០០០	២	០.៨	៣	៤	ឃ
	គោលដៅ៦: ប្រយុទ្ធប្រឆាំងនឹងមេរោគអេដស៍/ ជម្ងឺអេដស៍ គ្រុនចាញ់ និងជម្ងឺដទៃទៀត							
	១១. បន្ថយការរីករាលដាលនៃមេរោគអេដស៍/ ជំងឺអេដស៍							
៦.១	កាត់បន្ថយអត្រាប្រេវ៉ាឡង់ មេរោគអេដស៍ក្នុងចំណោមមនុស្សពេញវ័យអាយុពី ១៥ ដល់ ៤៩ឆ្នាំ (%)	៣.០	១៩៩៧	២.៣	១.៩	២	១.៨	ក
៦.២	កាត់បន្ថយអត្រាប្រេវ៉ាឡង់ មេរោគអេដស៍ក្នុងចំណោមស្ត្រីមានផ្ទៃពោះអាយុពី ១៥ ដល់ ២៤ឆ្នាំ បានពិនិត្យផ្ទៃពោះមុនសម្រាល (%)	២.៥	១៩៩៨	២.៤	២.១	២.០	១.៥	ក
៦.៣	បង្កើនសមាមាត្រប្រើប្រាស់ស្រោមអនាម័យក្នុងចំណោមស្ត្រីរកស៊ីផ្លូវភេទ ក្នុងពេលរួមភេទចុងក្រោយ (%)	៩១	២០០២	៩៨	៩៦.៧	៩៨	៩៨	ង
៦.៤	បង្កើនសមាមាត្រនៃយុវជនអាយុពី ១៥ ដល់ ២៤ឆ្នាំ ដែលបានរាយការណ៍ពីការប្រើប្រាស់ស្រោមអនាម័យក្នុងពេលរួមភេទជាមួយដៃគូមិនទៀងទាត់ (%)	៨២	២០០២	៨៥	ពុំមានលេខ	៩០	៩៥	
៦.៥	បង្កើនសមាមាត្រនៃការប្រើប្រាស់ស្រោមអនាម័យដែលបានរាយការណ៍ដោយស្ត្រីរៀបការ ដែលដឹងខ្លួនថាស្ថិតក្នុងស្ថានភាពគ្រោះថ្នាក់ (%)	១	២០០០	២	ពុំមានលេខ	៥	១០	
៦.៦	បង្កើនសមាមាត្រនៃស្ត្រីពិនិត្យផ្ទៃពោះមុនសម្រាលដែលមានផ្ទុកមេរោគអេដស៍ ហើយបានចូលរួមក្នុងកម្មវិធីបង្ការការឆ្លងពីម្តាយទៅកូន (%)	២.៧	២០០២	១០	៣.៨	៣៥	៥០	ង
៦.៧	បង្កើនសមាមាត្រនៃអ្នកជម្ងឺអេដស៍ ដែលបានទទួលថ្នាំប្រឆាំងការឆ្លងមេរោគអេដស៍ (%)	៣	២០០២	២៥	៤៥	៦០	៧៥	ក
	១២. បន្ថយការរីករាលដាលនៃជំងឺគ្រុនចាញ់ ជម្ងឺគ្រុនឈាម និងជម្ងឺរបេង							
៦.៨	កាត់បន្ថយអត្រាការស្លាប់ដោយសារជម្ងឺគ្រុនចាញ់ ដែលបានរាយការណ៍ដោយមណ្ឌលសុខភាពសាធារណៈ (%)	០.៤	២០០០	០.៣	០.៣៦	០.២៥	០.១	ង
៦.៩	បង្កើនសមាមាត្រនៃប្រជាជននៅតំបន់មានជម្ងឺគ្រុនចាញ់ខ្ពស់ ដែលប្រើមុងជ្រលក់ថ្នាំកាលពីយប់កន្លងមក (%)	២៤	២០០០	៨០	៤៩	៩៥	៩៨	ង
៦.១០	កាត់បន្ថយចំនួនអ្នកជម្ងឺគ្រុនចាញ់ ដែលទទួលបានការព្យាបាលនៅមណ្ឌលសុខភាពសាធារណៈ ក្នុងប្រជាជន ១.០០០នាក់	១១.៤	២០០០	៩	៧.៣	៧	៤	ក
៦.១១	បង្កើនសមាមាត្រនៃសេវាសុខភាពសាធារណៈ ដែលអាចបញ្ជាក់ពីរោគវិនិច្ឆ័យជម្ងឺគ្រុនចាញ់បានជាក់លាក់ ៩៥% តាមរូបមន្តជាតិ (%)	៦០	២០០២	៧០	ពុំមានលេខ	[illegible]	[illegible]	[illegible]

	[illegible]	[illegible]	[illegible]	[illegible]		[illegible]	[illegible]	[illegible]
				[illegible]	[illegible]			
៦.១២	កាត់បន្ថយចំនួនអ្នកជម្ងឺគ្រុនឈាម ដែលទទួលបានការព្យាបាលនៅក្នុងមណ្ឌលសុខភាពសាធារណៈ ក្នុងប្រជាជន ១.០០០នាក់	១	២០០១	០.៨	០.៨៤	០.៦	០.៤	ឥ
៦.១៣	កាត់បន្ថយអត្រាស្លាប់ដោយជម្ងឺគ្រុនឈាម ដែលបានរាយការណ៍ដោយបណ្ឌលសុខភាពសាធារណៈ (%)	១.៥	២០០៣	១	០.៧៤	០.៥	០.៣	ក
៦.១៤	កាត់បន្ថយអត្រាប្រេវ៉ាឡង់នៃជម្ងឺរបេងសួតវិជ្ជមាន ក្នុងចំណោមប្រជាជន ១០០.០០០នាក់	៤២៨	១៩៩៧	៣២១	ពុំមានតួលេខ	២១៤	១៣៥	
៦.១៥	កាត់បន្ថយអត្រាស្លាប់ដោយជម្ងឺរបេង ក្នុងចំណោមប្រជាជន ១០០.០០០នាក់	៩០	១៩៩៧	៦៨	ពុំមានតួលេខ	៤៥	៣២	
៦.១៦	បង្កើនសមាមាត្រនៃអ្នកដែលបានប៉ាន់ស្មានថាមានករណីរបេងសួតវិជ្ជមានថ្មី បានរកឃើញក្រោមការព្យាបាលដោយមានការត្រួតពិនិត្យផ្ទាល់ (%)	៥៧	២០០២	៧០	៦១	>៧០	>៧០	ឥ
៦.១៧	រក្សាសមាមាត្រនៃអ្នកជម្ងឺរបេងសួតវិជ្ជមាន ដែលបានកត់ត្រា ហើយបានព្យាបាលប្រកបដោយជោគជ័យក្រោមការព្យាបាលដោយមានការត្រួតពិនិត្យផ្ទាល់ (%)	៨៩	២០០២	>៨៥		៨៥	៨៥	
	គអសកគ៧: ធានានិរភាពបរិស្ថាន							
	១៣. បញ្ចូលគោលការណ៍អភិវឌ្ឍន៍ចីរភាព ទៅក្នុងគោលនយោបាយ និងកម្មវិធីជាតិ និងបង្កើនធនធានបរិស្ថាន							
៧.១	រក្សានូវផ្ទៃដីគ្របដណ្តប់ដោយព្រៃឈើ (% នៃផ្ទៃដីសរុប)	៦០	២០០២[១]	៦០	៥៨	៦០	៦០	
៧.២	រក្សានូវផ្ទៃដីតំបន់ការពារធម្មជាតិចំនួន ២៣កន្លែង (លានហត)	៣.៣	១៩៩៣	៣.៣	ពុំមានតួលេខ	៣.៣	៣.៣	
៧.៣	រក្សានូវតំបន់អភិរក្សព្រៃឈើថ្មីទាំង ៦ (លានហត)	១.៣៥	១៩៩៦	១.៣៥	ពុំមានតួលេខ	១.៣៥	១.៣៥	
៧.៤	បង្កើនចំនួនអ្នកអភិរក្សតំបន់ការពារធម្មជាតិ	៦០០	២០០១	៧៧២	ពុំមានតួលេខ	៩៨៧	១.២០០	
៧.៥	រក្សាចំនួនអ្នកអភិរក្សតំបន់ព្រៃឈើ	៥០០	២០០១	៥០០	ពុំមានតួលេខ	៥០០	៥០០	
៧.៦	បង្កើនសមាមាត្រឡូត៍នេសាទដែលប្រគល់ជូនសហគមន៍មូលដ្ឋាន (%)	៥៦	១៩៩៨	៥៨	៥៦.៤៦	៦០	៦០	ឥ
៧.៧	បង្កើនចំនួនសហគមន៍ឡូត៍នេសាទមូលដ្ឋាន	២៦៤	២០០០	៣៦៤	៣៧៥	៤៦៤	៥៨៩	ក
៧.៨	បង្កើនផ្ទៃទីជម្រកសុវត្ថិភាពមច្ឆា (ពាន់ហត)	២៦៤	២០០០	៥៨១	ពុំមានតួលេខ	៥៨១	៥៨១	
៧.៩	កាត់បន្ថយការប្រើអុសដុតរបស់គ្រួសារ (%)	៩២	១៩៩៣	៧០	៨៣.៩	៦១	៥២	ឥ
	១៤. កាត់បន្ថយអោយបានពាក់កណ្តាល សមាមាត្រប្រជាជនដែលគ្មានលទ្ធភាពប្រើប្រាស់ទឹកស្អាតជាប្រចាំនៅដំណាច់ឆ្នាំ ២០១៥							
៧.១០	បង្កើនសមាមាត្រប្រជាជន ជនបទដែលមានលទ្ធភាពប្រើប្រាស់ប្រភពទឹកស្អាត (%)	២៤	១៩៩៨	៣០	៤១.៦	៤០	៥០	

[១] ផ្ទៃដីព្រៃ គឺជាតម្លៃមធ្យមក្នុងរយៈកំឡុងពេល ឆ្នាំ១៩៩២-២០០២

[illegible]	[illegible]	[illegible]	[illegible]	[illegible]		[illegible]	[illegible]	[illegible]
				[illegible]	[illegible]			
៧.១១	បង្កើនសមាមាត្រប្រជាជន ទីប្រជុំជនដែលមានលទ្ធភាពប្រើប្រាស់ប្រភពទឹកស្អាត (%)	៦០	១៩៩៨	៦៨	៧៥.៨	៧៤	៨០	ក
	១៥. កាត់បន្ថយអោយបានពាក់កណ្តាល សមាមាត្រប្រជាជនដែលគ្មានលទ្ធភាពប្រើប្រាស់អនាម័យប្រសើរជាងមុនជាប្រចាំនៅដំណាច់ឆ្នាំ ២០១៥							
៧.១២	បង្កើនសមាមាត្រប្រជាជនជនបទ ដែលមានលទ្ធភាពទទួលបានប្រព័ន្ធអនាម័យប្រសើរឡើង (%)	៨.៦	១៩៩៦	១២	១៦.៤	២០	៣០	ក
៧.១៣	បង្កើនសមាមាត្រប្រជាជនទីក្រុង/ទីប្រជុំជន ដែលមានលទ្ធ-ភាពទទួលបានប្រព័ន្ធអនាម័យ ប្រសើរឡើង (%)	៤៩	១៩៩៨	៥៩	៥៥	៦៧	៧៤	ក
	១៦. បង្កើនអត្រាប្រជាជនមានប័ណ្ណកម្មសិទ្ធិដីធ្លីទូទាំងប្រទេស ទាំងទីក្រុង និងជនបទ នៅមុនដំណាច់ឆ្នាំ ២០១៥							
៧.១៤	បង្កើនអត្រាប្រជាជនមានប័ណ្ណកម្មសិទ្ធិដីធ្លីទូទាំងប្រទេស ទាំងទីក្រុង និងជនបទ នៅមុនដំណាច់ឆ្នាំ២០១៥ (%)	១៥	២០០០	១៦	១៦	៣២	៦៥	
	គអសកម៨: បង្កើតភាពជាដៃគូជាសកលសម្រាប់កិច្ចអភិវឌ្ឍន៍			ពុំមានចំណុចដៅច្បាស់លាស់				
	ពីចំណុចដៅរូមទី ១៧ ដល់ ២៣ សម្រាប់ដៃគូអភិវឌ្ឍន៍ក្រៅប្រទេសមានភាពទូលំទូលាយ សម្រាប់ក្នុងប្រទេសពុំមានចំណុចដៅច្បាស់លាស់							
	គអសកម៩: ការជោះមីន យុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ និងការសង្គ្រោះជនរងគ្រោះ							
	២៤. ឆ្ពោះទៅរកអត្រាគ្រោះថ្នាក់សូន្យដោយសារមីន និងគ្រាប់មិនទាន់ផ្ទុះ							
៩.១	កាត់បន្ថយចំនួនជនរងគ្រោះដោយសារមីនអោយដល់សូន្យនៅត្រឹមឆ្នាំ ២០១២	១.៦៩១	១៩៩៣	៥០០	៧៩៧	២០០	០	ក
៩.២	បោសសំអាតតំបន់ដែលសង្ស័យថាមានមីនអោយអស់ (%)	១០	១៩៩៩	៥១	៥០.៣	៧៧	១០០	ខ
	២៥. លុបបំបាត់ផលប៉ះពាល់ជាវិជ្ជមានដល់មនុស្សជាតិ និងសេដ្ឋកិច្ច សង្គមកិច្ច ដោយសារមីន និងគ្រាប់មិនទាន់ផ្ទុះនៅឆ្នាំ២០១៥							
៩.៣	បង្កើតក្របខ័ណ្ឌការងារជំនួយទូលំទូលាយមួយដល់ជនរងគ្រោះមុនឆ្នាំ២០០៥					២០០៧		
៩.៤	បង្កើតកញ្ចប់ជំនួយ និងធ្វើសមាហរណកម្មទៅក្នុងសង្គមដល់ជនរងគ្រោះដោយសារគ្រាប់មីន និងគ្រាប់មិនទាន់ផ្ទុះ	ពុំមានតួលេខ			កំណត់នៅពេលក្រោយ			

ឧបសម្ព័ន្ធ ១.២
ការសម្រេចគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា
ដកស្រង់ចេញពីការសម្រួលឆ្នាំ២០០៥[១]

១. គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជាមាន ៩គោលដៅ ២៥ចំណុចដៅរួម និង ១០៦ចំណុចដៅ ដែលបានផ្ដោតលើ (ក) ភាពក្រីក្រនិងភាពអត់ឃ្លានធ្ងន់ធ្ងរ (ខ) សកលកម្មការអប់រំមូលដ្ឋានចំនួន ៩ឆ្នាំ (គ) សមភាពយេនឌ័រនិងការផ្ដល់សិទ្ធិអំណាចដល់ស្ត្រី (ឃ) មរណភាពកុមារ (ង) មរណភាពមាតា (ច) មេរោគហ៊ីវ/ជម្ងឺអេដស៍ ជម្ងឺគ្រុនចាញ់ និងជម្ងឺដទៃទៀត (ឆ) ចីរភាពបរិស្ថាន (ជ) បង្កើតភាពជាដៃគូជាសកលសម្រាប់កិច្ចអភិវឌ្ឍ និង (ឈ) ការដោះមីន យុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ និងការសង្គ្រោះជនរងគ្រោះដោយសារមីន ។ នៅក្នុងសូចនាករជាក់លាក់នៃ *គអសក* នីមួយៗដែលបានលើកឡើង ចំណុចដៅរយៈពេលខ្លី មធ្យម និងវែង ដែលនឹងត្រូវធ្វើឱ្យសម្រេចក្នុងអំឡុងពេល ឆ្នាំ២០០៥-២០១០ និងឆ្នាំ២០១៥ ត្រូវបានកំណត់ឡើង ។

២. ទន្ទឹមនឹងមានវឌ្ឍនភាពគួរឱ្យកត់សម្គាល់ជាងមួយទសវត្សរ៍កន្លងទៅ ក្នុងការអនុវត្តគោលនយោបាយគាំទ្រអ្នកក្រ និងកំណែទម្រង់យ៉ាងទូលំទូលាយ ដែលមានគោលបំណងពង្រឹងប្រជាធិបតេយ្យ ការគោរពច្បាប់ និងអភិបាលកិច្ចល្អ ការប្រឈមមុខដ៏ចម្បងរបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងការអភិវឌ្ឍនាពេលបច្ចុប្បន្នគឺ សម្រេចឱ្យបានចំណុចដៅទាំងឡាយដែលបានកំណត់នៅក្នុង *គអសក* ។

លុបបំបាត់ភាពក្រីក្រ និងភាពអត់ឃ្លានធ្ងន់ធ្ងរ

៣. ការប៉ាន់ស្មានពីវឌ្ឍនភាពនៃគោលដៅនេះដោយប្រើប្រាស់ទិន្នន័យមូលដ្ឋានឆ្នាំ១៩៩៣-១៩៩៤ នៅមានចន្លោះខ្វះខាត ព្រោះថា ទិន្នន័យមូលដ្ឋាននេះប្រមូលមកតាមរយៈការធ្វើអង្កេតដែលមិនបានគ្របដណ្ដប់ទូទាំងប្រទេសទេ ដោយមូលហេតុសន្តិសុខនៅពេលនោះ ។ ទោះជាដូចនេះក្ដី តាមរយៈការប៉ាន់ស្មានដែលមាន បានបង្ហាញថា អត្រាភាពក្រីក្របានថយចុះគួរឱ្យកត់សម្គាល់នៅក្នុងតំបន់ទីប្រជុំជននិងតំបន់ជនបទមួយចំនួនដែលបានគ្របដណ្ដប់ដោយអង្កេតឆ្នាំ១៩៩៣-១៩៩៤ ប៉ុន្តែ បច្ចុប្បន្ននេះ អត្រាភាពក្រីក្រនៅតំបន់ជនបទភាគច្រើនដែលអង្កេតឆ្នាំ១៩៩៣-១៩៩៤ មិនបានគ្របដណ្ដប់ និងនៅតំបន់ដែលពិបាកទៅដល់ មានកម្រិតខ្ពស់ជាងច្រើន ។

៤. តាមរយៈការប៉ាន់ស្មានដោយប្រើប្រាស់ទិន្នន័យដែលប្រមូលបានដោយប្រើប្រាស់វិធីសាស្ត្រខល អត្រាប្រជាជនកម្ពុជាដែលរស់នៅក្រោមខ្សែបន្ទាត់ភាពក្រីក្រមាន ៣៤,៧ភាគរយនៅឆ្នាំ២០០៤ ។ ដោយគ្មានការប៉ាន់ស្មានដែលអាចប្រៀបធៀបគ្នាបាន សម្រាប់ប្រជាជនសរុបក្នុងឆ្នាំ១៩៩៣-១៩៩៤ ទេ ការវាយតម្លៃការប្រែប្រួលនៃភាពក្រីក្រសម្រាប់ទូទាំងប្រទេស មានការលំបាក ។ ទោះជាដូចនេះក្ដី ការប្រែប្រួលនៃអត្រាភាពក្រីក្រសម្រាប់

---

[១] ការសម្រេច *គអសក* លៃសម្រួលឆ្នាំ២០០៥ ក្រសួងផែនការ រាជរដ្ឋាភិបាលកម្ពុជា

ប្រជាជនដែលរស់នៅក្នុងតំបន់ដែលមានស្ថានភាពភូមិសាស្ត្រដូចគ្នានឹងតំបន់ ដែលគ្របដណ្តប់ដោយការអង្កេតសេដ្ឋកិច្ច-សង្គមកិច្ចកម្ពុជាឆ្នាំ១៩៩៣-១៩៩៤ ត្រូវបានធ្វើការប៉ាន់ស្មាន ។ ការអង្កេតនេះបានគ្របដណ្តប់តែ ៥៩ភាគរយ នៃតំបន់ភូមិសាស្ត្រទូទាំងប្រទេសកម្ពុជា ហើយបានសាកសួរគ្រួសារតែប្រមាណ ៦៨ភាគរយនៃចំនួនគ្រួសារសរុបប៉ុណ្ណោះ ដោយមិនបានបញ្ចូលនូវអ្នកក្រីក្រជាច្រើន និងតំបន់មួយចំនួនដែលមិនបានគ្របដណ្តប់ដោយអង្កេត ដោយហេតុផលអសន្តិសុខនៅតំបន់នោះ នាពេលនោះ ។ ការប៉ាន់ស្មានដោយផ្អែកលើសំណាកគំរូដែលមានលក្ខណៈអាចប្រៀបធៀបបាន ក្នុងតំបន់ដែលគ្របដណ្តប់ដោយអង្កេតឆ្នាំ១៩៩៣-១៩៩៤ បានបង្ហាញពីការធ្លាក់ចុះយ៉ាងខ្លាំងនៃអត្រាភាពក្រីក្រពី ៣៩ភាគរយនៅឆ្នាំ១៩៩៣-១៩៩៤ មកត្រឹម ២៨ភាគរយនៅឆ្នាំ២០០៤ ។

៥. ប្របហាក់ប្រហែលគ្នានេះដែរ អត្រាប្រជាជនរស់នៅក្រោមខ្សែបន្ទាត់ភាពក្រីក្រម្ហូបអាហារ សម្រាប់ទូទាំងប្រទេសគឺ ១៩,៧ភាគរយនៅឆ្នាំ២០០៤ ប៉ុន្តែពុំមានតួលេខបង្ហាញសម្រាប់ទូទាំងប្រទេសនៅមុនឆ្នាំនេះឡើយ ។ ទោះជាដូចនេះក្តី តាមរយៈការប៉ាន់ស្មានដោយប្រើប្រាស់សំណាកគំរូដូចខាងដើម បង្ហាញថា សមាមាត្រប្រជាជនដែលរស់នៅក្រោមខ្សែបន្ទាត់ភាពក្រីក្រម្ហូបអាហារ ក៏ធ្លាក់ចុះច្រើនដែរពី ២០ភាគរយនៅឆ្នាំ១៩៩៣-១៩៩៤ មក ១៤,៦ភាគរយនៅឆ្នាំ២០០៤ ក្នុងតំបន់ដែលគ្របដណ្តប់ដោយអង្កេត១៩៩៣-១៩៩៤ ។

៦. អត្រាភាពក្រីក្រនៅតំបន់ដែលមិនបានគ្របដណ្តប់ដោយអង្កេតឆ្នាំ១៩៩៣-១៩៩៤ ដែលបានគណនាពីទិន្នន័យដែលមានគឺ ៤៥,៦ភាគរយក្នុងឆ្នាំ២០០៤ គឺមានកម្រិតខ្ពស់ជាងអត្រាភាពក្រីក្រនៅក្នុងតំបន់ដែលបានគ្របដណ្តប់ដោយអង្កេត១៩៩៣-១៩៩៤ ដែលមានកម្រិតតែ ២៨ភាគរយប៉ុណ្ណោះ ។ ប្រហាក់ប្រហែលគ្នានេះដែរ សន្ទស្សន៍ភាពក្រីក្រម្ហូបអាហារត្រូវបានប៉ាន់ស្មានថាមានកម្រិត ២៨,៧ភាគរយ នៅតំបន់ដែលមិនបានគ្របដណ្តប់ដោយអង្កេតឆ្នាំ១៩៩៣-១៩៩៤ គឺខ្ពស់ជាងពីរដងកម្រិតនៅក្នុងតំបន់ដែលបានគ្របដណ្តប់ដោយអង្កេតខាងលើ ដែលមានតែ ១៤,២ភាគរយប៉ុណ្ណោះ ។

៧. នៅពេលដែលភាពជោគជ័យរបស់កម្ពុជាក្នុងការកាត់បន្ថយភាពក្រីក្រនៅតំបន់ទីប្រជុំជន និងតំបន់ដែលអាចទៅដល់ជាច្រើនទៀត ត្រូវបានទទួលការកោតសរសើរ បញ្ហាប្រឈមមុខដ៏ធំនៅក្នុងទសវត្សរ៍ខាងមុខ គឺត្រូវកាត់បន្ថយភាពក្រីក្រដែលមានកម្រិតខ្ពស់ នៅតំបន់ជនបទដែលមិនបានគ្របដណ្តប់ដោយអង្កេតសេដ្ឋកិច្ច-សង្គមកិច្ចឆ្នាំ១៩៩៣-១៩៩៤ ។ ដើម្បីសម្រេចបានការកាត់បន្ថយភាពក្រីក្រនៅតំបន់ដែលមិនបានគ្របដណ្តប់នេះ និងដើម្បីសម្រេចបានពាក់កណ្តាលចំណុចដៅនៃអត្រាភាពក្រីក្រសម្រាប់ទូទាំងប្រទេសដែលបានកំណត់ក្នុង *គអសក* ពីកម្រិតដែលមានក្នុងឆ្នាំ១៩៩៣-១៩៩៤ កម្ពុជាត្រូវតែបង្កើនល្បឿនកំណើនសេដ្ឋកិច្ច និងរួមចំណែកគាំទ្រអ្នកក្រីក្របានច្រើនបន្ថែមទៀត ក្នុងអំឡុងពេល ១០ឆ្នាំខាងមុខ ។ លក្ខខណ្ឌដំបូងបង្អស់និងសំខាន់មួយសម្រាប់ធ្វើឱ្យសម្រេចបានការកាត់បន្ថយភាពក្រីក្រនៅតំបន់ដែលមិនបានគ្របដណ្តប់នេះគឺ ត្រូវផ្តោតការទៅលើគោលបំណង យុទ្ធសាស្ត្រនិងសកម្មភាពទាំងឡាយដែលបានផ្តោតនិងកំណត់រួចហើយ ដើម្បីជំរុញការអនុវត្ត

ភាពក្រីក្រនៅតំបន់ជនបទ ជាពិសេស នៅតំបន់ដែលរងគ្រោះដោយមានភាពក្រីក្រកម្រិតខ្ពស់ និងដែលមិនបានគ្របដណ្ដប់ដោយអង្កេតសេដ្ឋកិច្ច-សង្គមកិច្ចឆ្នាំ១៩៩៣-១៩៩៤ ។

៨. ទោះបីជាមានភស្តុតាងបង្ហាញពីវឌ្ឍនភាពក្នុងការកាត់បន្ថយភាពក្រីក្រក៏ដោយ ក៏ហាក់ដូចជាមានការកើនឡើងនូវការរងទុកលំបាកក្នុងចំណោមប្រជាជនមួយផ្នែក ជាពិសេសស្ត្រីនិងកុមារ ។ ដូចជាបញ្ហា នៅតំបន់ជនបទដែរគឺ បញ្ហាវិសមភាពមានការកើនឡើង ហើយធ្វើឱ្យមានផលប៉ះពាល់ដល់កុមារធ្វើការងារ ដែលជាមូលដ្ឋានសម្រាប់អភិវឌ្ឍន៍ធនធានមនុស្សរបស់កម្ពុជានៅជំនាន់បន្ទាប់ទៀត ។

សកលកម្មនៃការអប់រំមូលដ្ឋានចំនួន ៩ឆ្នាំ

៩. កម្ពុជាបានធ្វើឱ្យមានវឌ្ឍនភាពគួរឱ្យកត់សម្គាល់ នៅក្នុងការបង្កើនភាពទទួលបានសេវាអប់រំមូលដ្ឋាន ប៉ុន្តែប្រទេសជាតិមានការងារជាច្រើនទៀតដែលត្រូវបំពេញ ដើម្បីសម្រេចឱ្យបានចំណុចដៅទាំងឡាយដែលបានកំណត់នៅក្នុង *គអសក* ។ តាមការប៉ាន់ស្មានបង្ហាញថា សូចនាករមួយក្នុងចំណោមសូចនាករទាំងដប់ក្នុងផ្នែកនេះមានស្ថានភាពកាន់តែអាក្រក់ នៅពេលដែលសូចនាករបួនផ្សេងទៀតត្រូវបានបង្ហាញថាមានវឌ្ឍនភាពតែបន្តិចបន្តួចប៉ុណ្ណោះ ។ ឯក្នុងចំណោមសូចនាករដែលនៅសល់ប្រាំទៀត បួនមិនបានបង្ហាញពីភាពជឿនលឿនគ្រប់គ្រាន់ដើម្បីឱ្យសម្រេចចំណុចដៅនៅឆ្នាំ២០០៥ទេ ស្របពេលដែលសូចនាករមួយដែលនៅសល់ (សមាមាត្រកុមារពី ៦-១៤ឆ្នាំមិនបានចូលរៀន) ត្រូវបានបង្ហាញថាបានអនុវត្តលើសចំណុចដៅឆ្នាំ២០០៥ ។

១០. អត្រាពិតនៃការចូលរៀនថ្មី (ប្រៀបធៀបនឹងសក្ដានុពលជាក់ស្ដែងនៃការចូលរៀនថ្មីនៅថ្នាក់ទី១) ស្ថិតនៅកម្រិតដដែលគឺ ៨១ភាគរយ នៅឆ្នាំ២០០១ និង២០០៥ ដែលចំណុចដៅសម្រាប់ឆ្នាំ២០០៥គឺ ៩៥ភាគរយ ។ អត្រាគង់វង្ស (សមាមាត្រសិស្សដែលបានរៀនដល់ថ្នាក់ចុងក្រោយនៃភូមិសិក្សាណាមួយ) ពីថ្នាក់ទី១ដល់ថ្នាក់ទី៩ បានធ្លាក់ចុះពី ៣៣ភាគរយនៅឆ្នាំ២០០១ ដល់ ៣០,១៨ភាគរយ នៅឆ្នាំ២០០៥ ដែលចំណុចដៅសម្រាប់ឆ្នាំ២០០៥គឺ ៥២ភាគរយ ។ អត្រាគង់វង្សផ្សេងទៀត (ពីថ្នាក់ទី១ ដល់ ថ្នាក់ទី៥ និង ពីថ្នាក់ទី១ ដល់ថ្នាក់ទី៦) ត្រូវបានបង្ហាញថា មានវឌ្ឍនភាពតិចតួចប៉ុណ្ណោះ ។ លទ្ធផលទាំងនេះ និងលទ្ធផលផ្សេងៗទៀត នៅតែមានគម្លាតឆ្ងាយពីចំណុចដៅទាំងឡាយ ដែលបានកំណត់ដើម្បីធ្វើឱ្យសម្រេចបានគោលដៅនៃសកលកម្មការអប់រំមូលដ្ឋានចំនួន ៩ឆ្នាំ ។ ការប៉ាន់ស្មានទាំងនេះ បញ្ជាក់ពីការមិនប្រែប្រួលនៃប្រសិទ្ធភាពកម្រិតទាបរបស់ប្រព័ន្ធអប់រំនៅកម្ពុជា ។

១១. នៅឆ្នាំ២០០៥ កុមារអាយុពី ៦-១៤ឆ្នាំ ប្រមាណ ១៨,៧ភាគរយ មិនបានចូលរៀន ដែលជាកម្រិតមួយល្អជាងចំណុចដៅដែលបានកំណត់ ២២ភាគរយសម្រាប់ឆ្នាំ២០០៥ និង ៣៥ភាគរយសម្រាប់ឆ្នាំ១៩៩៩ ទោះជាដូចនេះក្ដី តួលេខនេះចាំបាច់ត្រូវតែធ្វើការបរិយាយដោយប្រយ័ត្នប្រយែង នៅក្នុងបរិបទកម្ពុជា

សមាមាត្រកុមារធ្វើការងារអាយុពី ៥-១៧ឆ្នាំ មានការកើនឡើង ។ របាយការណ៍ជាច្រើន បង្ហាញថា មានកុមារជាច្រើនដែលមានអាយុលើសពី ១១ឆ្នាំ នៅរៀនក្នុងសាលាបឋមសិក្សា ដែលបង្កឱ្យឪពុកម្តាយមានភាពស្ទាក់ស្ទើរក្នុងចិត្តក្នុងការបញ្ជូនកូនទៅសាលារៀន ។ មូលហេតុផ្សេងៗទៀត ដែលបង្កឱ្យមានភាពស្ទាក់ស្ទើរក្នុងចិត្តនេះរួមមាន គុណភាពនៃការអប់រំមានកម្រិតទាប ខ្វះខាតគ្រូដែលបានឆ្លងកាត់ការបណ្តុះបណ្តាលគរុកោសល្យ ខ្វះខាតសៀវភៅនិងសម្ភារៈសិក្សា និងភាពក្រីក្ររបស់គ្រួសារផ្ទាល់ ។ ការប៉ាន់ស្មានពីប្រាក់បៀវត្សរ៍សមរម្យសម្រាប់ផ្តល់ដល់គ្រូបង្រៀន និងការបញ្ជូនគ្រូបង្រៀនដែលមានគុណភាពទៅតំបន់ជនបទ គួរតែត្រូវបានពិចារណា ។

១២. អត្រាអក្ខរភាពនៃក្រុមជនអាយុពី ១៥-២៤ឆ្នាំ ភាគច្រើននៅតែមិនមានការប្រែប្រួលទេ នៅក្នុងអំឡុងពេលថ្មីៗកន្លងទៅនេះ ។ នៅឆ្នាំ២០០៥ អត្រាអក្ខរភាពនេះមាន ៨៣ភាគរយ ធៀបនឹង៨២ភាគរយនៅឆ្នាំ១៩៩៩ ។ ចំណុចដៅនៃ *គអសក* បានកំណត់ថានឹងបង្កើនឱ្យដល់ ៩០ភាគរយនៅឆ្នាំ២០០៥ ។ បញ្ហាដ៏ចម្បងមួយផ្សេងទៀតគឺ ការលុបបំបាត់គម្លាតយេនឌ័រនៅក្នុងការអប់រំមូលដ្ឋាន ។ ការអនុវត្តនៅឆ្នាំ២០០៥ នេះបានបង្ហាញការមិនសម្រេចបានតាមចំណុចដៅដែលបានកំណត់ ជាពិសេស នៅកម្រិតមធ្យមសិក្សាបឋមភូមិ ។

លើកកម្ពស់សមភាពយេនឌ័រ និងការផ្តល់សិទ្ធិអំណាចដល់ស្ត្រី

១៣. កម្ពុជាបានធ្វើឱ្យមានវឌ្ឍនភាពច្រើនក្នុងការជំរុញឱ្យមានសមភាពយេនឌ័រ ហើយសូចនាករជាច្រើនត្រូវបានសម្រេចជិតស្មើនិងចំណុចដៅដែលបានកំណត់ ។ ទោះជាដូចនេះក្តី មានបញ្ហាធំៗជាច្រើន ជាពិសេស នៅក្នុងផ្នែកអំពើហិង្សាក្នុងគ្រួសារ ទើបតែត្រូវបានចាប់ផ្តើមយកចិត្តទុកដាក់ដោះស្រាយនៅក្នុងពេលថ្មីៗកន្លងទៅនេះ ។ លើសពីនេះទៀត ទោះបីជាមានការធ្វើឱ្យប្រសើរឡើងជាក់ស្តែងមួយចំនួនក៏ដោយ ក៏នៅមានបញ្ហាជាច្រើនទៀតដែរ ។

១៤. ជាច្រើនឆ្នាំមកហើយ វិសមភាពយេនឌ័រនៅមធ្យមសិក្សាទុតិយភូមិ និងឧត្តមសិក្សា មានការថយចុះហើយនៅឆ្នាំ២០០៥ អត្រាធៀបសិស្សប្រុសធៀបនឹងសិស្សស្រី ទាំងនៅមធ្យមសិក្សាទុតិយភូមិ និងឧត្តមសិក្សាមានកម្រិតជិតស្មើនឹងចំណុចដៅដែលបានកំណត់ក្នុង *គអសក* ។

១៥. អត្រាធៀបអក្ខរជនបុរសធៀបនឹងស្ត្រីក្នុងក្រុមអាយុ ១៥-២៤ឆ្នាំ មានកម្រិតទាបជាងចំណុចដៅ ដែលបានកំណត់សម្រាប់ឆ្នាំ២០០៥ ។ តាមការប៉ាន់ប្រមាណ អត្រានេះមានកម្រិត ៩០ភាគរយនៅឆ្នាំ២០០៥ ដែលសម្រាប់ឆ្នាំនេះ ចំណុចដៅត្រូវបានកំណត់ ៩៥ភាគរយ និងចំណុចដៅសម្រាប់ឆ្នាំ១៩៩៨ ត្រូវបានកំណត់ ៨៧ភាគរយ ។ ប្រហាក់ប្រហែលគ្នានេះដែរ អត្រាធៀបអក្ខរជនប្រុសធៀបនឹងស្ត្រីក្នុងក្រុមអាយុពី១៥-២៤ឆ្នាំ បានកើនឡើងបន្តិចបន្តួចដល់ ៨០ភាគរយនៅឆ្នាំ២០០៥ ដែលចំណុចដៅត្រូវបានកំណត់ ៨៥ភាគរយ ។

១៦. លក្ខណៈដែលគួរឱ្យកត់សម្គាល់បំផុតនៃអំណាចរបស់ស្ត្រីនោះគឺ ការកើនឡើងនៃការរួមចំណែករបស់ស្ត្រីក្នុងការងារទទួលកម្រៃនៅក្នុងវិស័យធំៗទាំងបី ព្រមទាំងការសម្រេចបានចំណុចដៅទាំងឡាយ ទាំងនៅក្នុងវិស័យកសិកម្មនិងឧស្សាហកម្ម ។ មានតែនៅក្នុងផ្នែកសេវាកម្មទេ ដែលកម្រិតនៃវឌ្ឍនភាពសម្រេចមិនបានតាមចំណុចដៅ ។ ការចូលរួមរបស់ស្ត្រីក្នុងការងារទទួលកម្រៃក្នុងផ្នែកសេវាកម្មមាន ២៧ភាគរយនៅឆ្នាំ២០០៥ ធៀបនឹងចំណុចដៅដែលត្រូវបានកំណត់ ៣០ភាគរយ ។ ទោះជាដូចនេះក្តី ត្រូវចងចាំថា ស្ត្រីភាគច្រើនបំផុតធ្វើការនៅក្នុងផ្នែកមិនរៀបរយ និងក្នុងការងារក្នុងគ្រួសារមិនទទួលកម្រៃ ។

១៧. ការផ្លាស់ប្តូរនៃស្ថានភាពរបស់ស្ត្រីក្នុងបរិយាកាសនយោបាយមានសភាពយឺតៗ ។ ស្ត្រីនៅតែមានតំណាងតិចតួចក្នុងផ្នែក នយោបាយ រដ្ឋបាល និងក្នុងផ្នែកផ្សេងទៀត ។ ការលើកលែងមួយដែលគួរឱ្យកត់សម្គាល់គឺឋានៈជាន់ខ្ពស់ក្នុងការងារមួយចំនួននៃសេវាកម្មសាធារណៈ ដូចជាអនុរដ្ឋលេខាធិការ ស្ត្រីបានចូលរួមច្រើនលើសពីចំណុចដៅសម្រាប់ឆ្នាំ២០០៥ ទោះបីជាមានកម្រិតទាបជាង ១២ភាគរយក៏ដោយ ។

១៨. មានភស្តុតាងបង្ហាញថា អំពើហិង្សាប្រឆាំងនឹងស្ត្រីមានកម្រិតខ្ពស់ ហើយជាទូទៅ វិសមភាពយេនឌ័រនៅតែជាបញ្ហាធ្ងន់ធ្ងរនៅកម្ពុជា ។ ការអនុម័តច្បាប់ថ្មីស្តីពីអំពើហិង្សាក្នុងគ្រួសារនាពេលថ្មីៗនេះ គឺជាការបង្ហាញឱ្យឃើញច្បាស់ពីការប្តេជ្ញាចិត្តរបស់រាជរដ្ឋាភិបាលក្នុងការកែលម្អស្ថានភាពនេះ ប៉ុន្តែការប្រឈមក្នុងផ្នែកនេះមានលក្ខណៈធំធេង ។

កាត់បន្ថយមរណភាពកុមារ

១៩. ការប៉ាន់ស្មានពីមរណភាពកុមារ បានបង្ហាញពីវឌ្ឍនភាពគួរឱ្យកត់សម្គាល់ នៅក្នុងគ្រប់វិស័យទាំងអស់ ។ ទោះជាដូចនេះក្តី ការប៉ាន់ស្មានពីមរណភាពកុមារនៅពេលបច្ចុប្បន្ននេះ គួរតែត្រូវបានគិតគូរឱ្យបានល្អិតល្អន់ ដោយហេតុថា នៅក្នុងការប្រមូលទិន្នន័យពីមរណភាពកុមារនេះ បច្ចេកវិទ្យានិងវិធីសាស្ត្រអង្កេតជាច្រើនត្រូវបានប្រើប្រាស់ខុសៗគ្នា ។ អត្រាមរណភាពកុមារអាយុក្រោម៥ឆ្នាំ ត្រូវបានប៉ាន់ប្រមាណថា មាន ៨២ ក្នុងចំណោម ១.០០០កំណើតរស់ នៅឆ្នាំ២០០៥ ធៀបនឹង ១២៤ នៅឆ្នាំ១៩៩៨ ។ ចំណុចដៅដែលបានកំណត់សម្រាប់ឆ្នាំ២០០៥ គឺ ១០៥ ក្នុងចំណោម ១.០០០កំណើតរស់ ។ ប្រហាក់ប្រហែលគ្នានេះដែរ អត្រាមរណភាពទារកត្រូវបានប៉ាន់ស្មានថាមាន ៦៦ ក្នុងចំណោម ១.០០០កំណើតរស់ នៅឆ្នាំ២០០៥ បើធៀបនឹងចំណុចដៅដែលបានកំណត់សម្រាប់ឆ្នាំ២០០៥ គឺ ៧៥ ហើយ ចំណុចដៅសម្រាប់ឆ្នាំ១៩៩៨ គឺ ៩៥ ក្នុងចំណោម ១.០០០កំណើតរស់ ។ និន្នាការដែលបានចង្អុលបង្ហាញនេះ មានភាពស៊ីសង្វាក់គ្នានឹងការធ្លាក់ចុះយ៉ាងឆាប់រហ័សនៃអត្រាបង្កើតកូនសរុប និងរបាយការណ៍ស្តីពីកំណើននៃការផ្តល់វ៉ាក់សាំងការពារ (ទាំងជម្ងឺកញ្ជ្រឹល និងជម្ងឺ DPT3) ។ ជាឧទាហរណ៍ សមាមាត្រកុមារក្រោមអាយុ ១ឆ្នាំដែលបានទទួលវ៉ាក់សាំងការពារជម្ងឺ DPT3 បានកើនឡើងពី ៤៣ភាគរយ នៅឆ្នាំ២០០០ ដល់ ៨៣ភាគរយនៅឆ្នាំ២០០៥ ដែលសម្រេចបានលើសពីចំណុចដៅដែលត្រូវបាន

កំណត់តែ ៨០ភាគរយប៉ុណ្ណោះ ។ ចំពោះចំណុចដៅនៃការផ្តល់វ៉ាក់សាំងការពារជម្ងឺកញ្ជ្រិល ក៏បានធ្វើឱ្យសម្រេចដែរ ដោយមាន ការកើនឡើងពី ៤១ភាគរយនៅឆ្នាំ២០០០ ដល់ ៨០ភាគរយនៅឆ្នាំ២០០៥ ។

២០. សមាមាត្រមាតាដែលបានបំបៅដោះកូនក្រោយពេលកើត ១ម៉ោង បានកើនឡើងដល់ជាង ២៥ភាគរយនៅឆ្នាំ២០០៥ គឺលើសពីចំណុចដៅដែលបានកំណត់ ។ ទោះជាដូចនេះក្តី មូលហេតុចម្បងនៃមរណភាពកុមារនៅកម្ពុជាគឺ ជម្ងឺរលាកផ្លូវដង្ហើមធ្ងន់ធ្ងរ និងជម្ងឺអាសន្នរោគ ដែលទាមទារឱ្យមានមធ្យោបាយមានប្រសិទ្ធភាពដើម្បីដោះស្រាយ ។

២១. ទោះជាដូចនេះក្តី ការធ្លាក់ចុះយ៉ាងឆាប់រហ័សពីដំបូងនៃអត្រាមរណភាពកុមារដែលបណ្តាលមកពីការថយចុះនៃភាពបង្កើតកូននិងកត្តាផ្សេងៗទៀត ហាក់ដូចជាមិនមានស្ថេរភាពទេ លុះត្រាតែកត្តាផ្សេងៗដែលបានលើកឡើងនិងជាមូលហេតុធ្វើឱ្យមានអត្រាមរណភាពកុមារខ្ពស់នៅកម្ពុជា ដូចជា ភាពក្រីក្រ កង្វះអាហារូបត្ថម្ភ និងអសន្តិសុខស្បៀង ការទទួលបានទឹកស្អាតនិងការកែលម្អអនាម័យមិនគ្រប់គ្រាន់ ផ្ទះទ្រុឌទ្រោម ចំណេះដឹងស្តីពីអនាម័យខ្លួនប្រាណនៅមានកំណត់ ការអនុវត្តអសុវត្ថិភាពសេវាសុខភាព និងភាពមិនគ្រប់គ្រាន់នៃប្រព័ន្ធថែទាំសុខភាពនិងកម្មវិធីត្រួតពិនិត្យជម្ងឺ ត្រូវបានដោះស្រាយ ។ សារថ្លែងដ៏សំខាន់មួយបង្ហាញឱ្យឃើញថា មរណភាពកុមារនៅកម្ពុជា នៅតែស្ថិតក្នុងចំណោមកម្រិតដែលខ្ពស់ជាងគេនៅក្នុងតំបន់ ដែលនេះគឺជា សក្តានុពលនៃកម្មវិធីទាំងឡាយសម្រាប់ត្រួតពិនិត្យជម្ងឺ ធ្វើឱ្យខិតទៅជិតគោលដៅដែលបានកំណត់ ដែលវឌ្ឍនភាពនៅពេលខាងមុខនឹងបង្កើនភាពពឹងផ្អែកលើភាពជោគជ័យក្នុងការបង្កើតសេវាសុខភាពសកម្ម ដែលវឌ្ឍនភាពនាពេលបច្ចុប្បន្ននេះមិនទាន់មានភាពគួរឱ្យពេញចិត្តនៅឡើយ ។

កែលម្អសុខភាពមាតា

២២. ព័ត៌មានថ្មីៗស្តីពីស្ថានភាពសុខភាពមាតាមានតិចតួចណាស់ ។ ទិន្នន័យស្តីពីសុខភាពមាតានេះ មានតែសូចនាករបួនប៉ុណ្ណោះ ក្នុងចំណោមសូចនាករដប់ ។ ជាពិសេស ពុំមានទិន្នន័យស្តីពីសូចនាករដ៏សំខាន់បំផុតមួយគឺអត្រាមរណភាពមាតាទេ ។ ប៉ុន្តែ ចំពោះទិន្នន័យទាំងឡាយណាដែលអាចរកបាន ព័ត៌មានស្តីពីស្ថានភាពសុខភាពមាតា មានលក្ខណៈមិនឯកភាពគ្នា ។

២៣. អត្រាបង្កើតកូនសរុបបានថយចុះពី ៤.០ ក្នុងឆ្នាំ១៩៩៨ មកត្រឹម ៣.៣ នៅឆ្នាំ២០០៥ គឺសម្រេចបានលើសចំណុចដៅ ដែលត្រូវបានកំណត់តែត្រឹម ៣.៨ ប៉ុណ្ណោះ ។ សមាមាត្រស្ត្រីរៀបការប្រើប្រាស់វិធីសាស្ត្រពន្យារកំណើតទំនើបតាមរយៈផ្នែកសាធារណៈបានកើនឡើងដល់ ២០.១ភាគរយ នៅឆ្នាំ២០០៥ ។ ទោះជាដូចនេះក្តី នៅមានស្ត្រីរៀបការហើយជាច្រើនទៀត ដែលបានទទួលសេវាពន្យារកំណើតនេះតាមរយៈប្រព័ន្ធទីផ្សារក្នុងសង្គម និងពីផ្នែកឯកជន ហើយបើគិតពីចំនួនសរុបនៃអ្នកដែលប្រើប្រាស់សេវាពន្យារកំណើតទំនើបនេះ ចំនួនពិត

ស្មើនឹង ៣០ភាគរយ ដែលជាចំណុចដៅដែលត្រូវបានកំណត់សម្រាប់ឆ្នាំ២០០៥ ។ ប្រហាក់ប្រហែលគ្នានេះ ភាគរយនៃស្ត្រីមានផ្ទៃពោះបានទទួលការពិគ្រោះយោបល់ពិនិត្យ ផ្ទៃពោះមុនពេលសម្រាលពីរដងយ៉ាងតិច ពីបុគ្គលិកសុខាភិបាលនៅផ្នែកសាធារណៈ បានកើនឡើងពី ២៥,៤ភាគរយ ដល់ ៤៧ភាគរយ ក្នុងរយៈពេលដូចគ្នា ។ អត្រាសរុប ដោយគិតបញ្ចូលទាំងការផ្តល់សេវាកម្មពិគ្រោះយោបល់នេះដោយផ្នែកឯកជន អាចនឹងជិតស្មើចំណុចដៅដែលបានកំណត់សម្រាប់ឆ្នាំ២០០៥ គឺ ៦០ភាគរយ ។ ការវិភាគដោយប្រើប្រាស់ ទិន្នន័យពីការធ្វើអង្កេតពាក់កណ្តាលជំរឿនកម្ពុជា២០០៤ បង្ហាញថា ជាងមួយភាគប្រាំនៃមូលហេតុទាក់ទងនឹង ជម្ងឺបណ្តាលឱ្យស្លាប់ស្ត្រីក្នុងក្រុមអាយុពី ១៥-៤៤ឆ្នាំ គឺដោយសារតែបញ្ហាស្មុគស្មាញទាក់ទងនឹងការមានផ្ទៃពោះ រួមទាំងនៅក្នុងពេលសម្រាលកូនផង ។ តួលេខយ៉ាងខ្ពស់ដូច្នេះ ទាមទារឱ្យមានការវាយតម្លៃដោយប្រុងប្រយ័ត្ន ពីស្ថានភាពនិងពិនិត្យមើលឡើងវិញលើអន្តរាគមន៍នានា ។

ប្រយុទ្ធប្រឆាំងនឹងមេរោគហ៊ីវ/ជម្ងឺអេដស៍ គ្រុនចាញ់ និងជម្ងឺផ្សេងទៀត

២៤. កម្ពុជាបានធ្វើឱ្យមានវឌ្ឍនភាពគួរឱ្យកត់សម្គាល់ ក្នុងការធ្វើឱ្យសម្រេចចំណុចដៅនានាក្នុងគោលដៅ ដែលត្រូវបានកំណត់សម្រាប់ឆ្នាំ២០០៥ ដោយប្រើមធ្យោបាយមានប្រសិទ្ធភាពនានាក្នុងការប្រយុទ្ធប្រឆាំងនឹងមេរោគហ៊ីវ/ជម្ងឺអេដស៍ ជម្ងឺគ្រុនចាញ់ ជម្ងឺគ្រុនសន្និ និងជម្ងឺធ្ងន់ធ្ងរផ្សេងទៀត ដូចជាជម្ងឺរបេងជាដើម ។ ស្របពេលដែលក្នុងគោលដៅនេះមានទិន្នន័យតែ ១២ ក្នុងចំណោម ១៩សូចនាករ នៅឆ្នាំ២០០៥ ភាគច្រើននៃសូចនាករនេះសុទ្ធតែសម្រេចបានលើសពីចំណុចដៅដែលបានកំណត់ ។

២៥. ក្នុងករណីនៃមេរោគហ៊ីវ/ជម្ងឺអេដស៍ អត្រារីករាលដាលក្នុងចំណោមមនុស្សពេញវ័យ អាយុ ១៥-៤៨ឆ្នាំ មានការថយចុះខ្លាំង ពី ៣,០ភាគរយនៅឆ្នាំ១៩៩៧ មកត្រឹម ១,៩ភាគរយនៅឆ្នាំ២០០៥ ដែលសម្រេចបានលើសពីចំណុចដៅដែលបានកំណត់សម្រាប់ឆ្នាំនោះ គឺ២,៣ភាគរយ[១] ។ អត្រារីករាលដាលនៃមេរោគហ៊ីវក្នុងចំណោមស្ត្រីមានផ្ទៃពោះ អាយុពី ១៥-២៤ឆ្នាំ ហើយបានទៅមជ្ឈមណ្ឌលទទួលការពិគ្រោះយោបល់ពិនិត្យផ្ទៃពោះមុនពេលសម្រាល ក៏មានការថយចុះពី ២,៥ភាគរយនៅឆ្នាំ១៩៩៨ ដល់២,១ភាគរយនៅឆ្នាំ២០០៥ ដែលសម្រេចលើសចំណុចដៅដែលត្រូវបានកំណត់តែត្រឹម ២,៤ភាគរយប៉ុណ្ណោះ ។ អត្រាប្រើប្រាស់ស្រោមអនាម័យរបស់ស្ត្រីរកស៊ីផ្លូវភេទ មានកម្រិតជិតស្មើ ៩៨ភាគរយ នៅឆ្នាំ២០០៥ គឺកើនឡើងពីកម្រិត ៩១ភាគរយនៅឆ្នាំ២០០១ ។ អត្រាប្រជាជនទទួលបានវិធីព្យាបាលរោគដោយប្រើប្រាស់ឱសថប្រឆាំងមេរោគអេដស៍ មាន៤៥ភាគរយ ដែលល្អជាងចំណុចដៅសម្រាប់ឆ្នាំ២០០៥ នេះ ដែលបានកំណត់តែ ២៥ភាគរយ ហើយការអនុវត្តនៅឆ្នាំ២០០២ សម្រេចបានតែ ៣ភាគរយប៉ុណ្ណោះ ។ ប្រជាជនជាង ៩.០០០នាក់ បានទទួលការព្យាបាលនេះ គិតត្រឹមត្រីមាសទី៣ នៃឆ្នាំ២០០៥ ។

---

[១] ការប៉ាន់ស្មានមួយចំនួនសម្រាប់បណ្តាឆ្នាំមូលដ្ឋាន ត្រូវបានកែសម្រួលឡើងវិញ ដោយសារតែវិធីសាស្ត្រមានការកែសម្រួល

២៦. អត្រាស្លាប់ដោយជម្ងឺគ្រុនចាញ់ដែលបានផ្តល់ព័ត៌មានដោយផ្នែកសុខភាពសាធារណៈ បានថយចុះពី ០,៤ ភាគរយ នៅឆ្នាំ២០០០ មកត្រឹម ០,៣៦ភាគរយនៅឆ្នាំ២០០៥ ទោះបីជាចំណុចដៅត្រូវបានកំណត់ឱ្យបញ្ចុះដល់ ០,៣ភាគរយក៏ដោយ ។ ក្នុងករណី ជម្ងឺគ្រុនសន្ធំ អត្រាស្លាប់បណ្តាលមកពីជម្ងឺនេះ មានការថយចុះគួរឱ្យកត់សម្គាល់ ពី ១,៥ភាគរយនៅឆ្នាំ២០០០ មកត្រឹម ០,៧៤ភាគរយនៅឆ្នាំ២០០៥ ល្អប្រសើរជាងចំណុចដៅដែលបានកំណត់ គឺ ១ភាគរយ ។

២៧. ទោះបីជាលទ្ធផលជាច្រើនមានលក្ខណៈគួរជាទីពេញចិត្តក៏ដោយ ក៏សេចក្តីអំណរពេញលេញមិនអាចកើតមានឡើងចំពោះជម្ងឺដ៏កាចសាហាវ ដូចជា មេរោគហ៊ីវ/ជម្ងឺអេដស៍ និងជម្ងឺរបេងទេ ។ ជម្ងឺទាំងនេះគឺជាមូលហេតុយ៉ាងចម្បងនៃការស្លាប់ ប្រជាជននៅគ្រប់ក្រុមអាយុទាំងអស់ ។ លើសពីនេះទៀត ការព្រួយបារម្ភពីករណីថ្មី១ទាក់ទងនឹងមេរោគហ៊ីវ/ជម្ងឺអេដស៍ដូចជា ការចម្លងពីឪពុកម្តាយទៅកូន និងពីប្តីទៅប្រពន្ធជាដើម ចាំបាច់ត្រូវតែធ្វើការដោះស្រាយ ។ ការរីករាលដាលដោយស្ងៀមស្ងាត់នៃមេរោគហ៊ីវ/ជម្ងឺអេដស៍ទៅតំបន់ជនបទក៏ជាបញ្ហាចម្បងមួយដែរ ។ យុទ្ធសាស្ត្រអន្តរាគមន៍នៃសាមញ្ញ ដើម្បីប្រយុទ្ធប្រឆាំងនឹងជម្ងឺអេដស៍ ដោយការផ្តោតការយកចិត្តទុកដាក់លើតំបន់ទីប្រជុំជននិងបណ្តាក្រុមជនដែលរងគ្រោះខ្លាំង ចាំបាច់ត្រូវតែបំពេញបន្ថែមដោយវិធីសាស្ត្រដែលអាចដោះស្រាយ នូវភាពងាយរងគ្រោះក្នុងជួរប្រជាជន និងទីកន្លែងដែលបានកំណត់ ។

ការធានានិរន្តរភាពបរិស្ថាន

២៨ ព័ត៌មានដែលអាចទទួលបាននៅក្នុងផ្នែកនេះ នៅមានគម្លាតយ៉ាងច្រើន ទិន្នន័យជាច្រើនដែលអាចយកមកធ្វើការវិភាគ គឺមានលក្ខណៈវិជ្ជមាន ។ ព័ត៌មានបច្ចុប្បន្នស្តីពីបញ្ហាសំខាន់នៃចីរភាពបរិស្ថាននៅកម្ពុជា (បញ្ហានៃវិសាលភាពព្រៃឈើនិងការគ្រប់គ្រង) គឺមិនអាចរកបាន ។ ប៉ុន្តែជាទូទៅទទួលស្គាល់ថា ដំណើរនៃការបំផ្លាញព្រៃឈើមិនត្រូវបានកាត់បន្ថយតាមផែនការនៅឡើយ ។ ដំណើរការថយចុះព្រៃឈើ គឺជាផ្នែកមួយបានឆ្លុះបញ្ចាំងពីការកើតឡើងខ្ពស់នៃការប្រើប្រាស់អុសជាថាមពល ។ នៅឆ្នាំ១៩៩៣ ៩២ភាគរយនៃគ្រួសារបានប្រើប្រាស់អុសជាថាមពល ។ ចំនួននេះបានធ្លាក់ចុះបន្តិចបន្តួច មកត្រឹមប្រហែល ៨៤ភាគរយនៅឆ្នាំ២០០៥ ចំណែកឯចំណុចដៅគឺត្រូវបានកំណត់ឱ្យនៅត្រឹម ៧០ភាគរយ ។ ចំណុចដៅទាំងអស់នោះនឹងនៅតែក្នុងការស្រមើស្រមៃ បើសិនជាការខិតខំប្រឹងប្រែងមិនបានយកទៅអនុវត្តនៅក្នុងផ្នែកទាំងពីរនៃព្រៃឈើ និងថាមពលនោះទេ ។

២៩ ក្នុងឆ្នាំ២០០៥ លទ្ធភាពទទួលបានប្រភពទឹកស្អាតក្នុងចំណោមប្រជាជននៅជនបទបានកើនឡើងដល់ ៤២ ភាគរយ និងទីប្រជុំជន បានកើនឡើងដល់ប្រហែល ៧៦ភាគរយ ។ លទ្ធភាពទទួលបានទឹកស្អាត លើសចំណុចដៅដែលកំណត់ត្រឹម ៣០ភាគរយ នៅជនបទ និង៦៨ភាគរយ នៅទីប្រជុំជន ។ ដូចគ្នានេះដែរ លទ្ធភាពទទួលបានអនាម័យល្អប្រសើរឡើងក្នុងចំណោមប្រជាជននៅជនបទ បានកើនឡើងដល់ ១៦ភាគរយ ធៀបនឹងចំណុចដៅ ១២ភាគរយ នៅឆ្នាំ២០០៥ ។ ក្នុងករណីប្រជាជននៅទីប្រជុំជន លទ្ធភាពទទួលបានអនាម័យប្រសើរឡើងកើន

៥៧ភាគរយ រីឯចំណុចដៅគឺ ៥៩ភាគរយនៅឆ្នាំ២០០៥ ។ បើប្រៀបធៀបជាមួយជោគជ័យដទៃទៀត ការធ្វើឱ្យបានសម្រេចចំណុចដៅដែលមានលក្ខណៈអន់ថយជាងនេះ មួយផ្នែកអាចពន្យល់បានតាមរយៈការហូរចូលយ៉ាងច្រើននៃអ្នកក្រជនបទ មកកាន់តំបន់ទីប្រជុំជន ។ នាពេលអនាគត ការខិតខំប្រឹងប្រែងផ្តោតទៅលើការលើកកម្ពស់ផលិតភាពកសិកម្ម ដើម្បីកាត់បន្ថយអត្រាការផ្លាស់ប្តូរទីលំនៅពីជនបទមកទីប្រជុំជន និងដើម្បីកែលម្អជីវភាពរស់នៅរបស់អ្នកក្រីក្រនៅទីប្រជុំជន ។

ការដោះមីន យុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ និងការសង្គ្រោះជនរងគ្រោះ

៣០ កម្ពុជាជាប្រទេសរងផលប៉ះពាល់ធ្ងន់ធ្ងរបំផុតដោយសារគ្រាប់មីន និងយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ ក្នុងចំណោមបណ្តាប្រទេសដែលមានផលប៉ះពាល់ទាំងឡាយ ។ កម្ពុជាបានអនុម័តចំណុចដៅសម្រាប់អនុវត្តនីការបោសសំអាតមីនឱ្យអស់នៅតំបន់ដែលមានគ្រាប់មីននៅត្រឹមឆ្នាំ២០១២ ។ ទោះបីមានវឌ្ឍនភាពសំខាន់ៗជាច្រើន ត្រូវបានធ្វើឡើងក៏ដោយ ក៏ចំណុចដៅនេះទំនងជាមិនអាចសម្រេចបានឡើយ ។ អាជ្ញាធរកម្ពុជាគ្រប់គ្រងសកម្មភាពមីន និងសង្គ្រោះជនពិការ ត្រូវបានរៀបចំឡើងវិញនឹងបញ្ចប់សកម្មភាពនៅឆ្នាំ២០១៥ ។

៣១ ប៉ុន្តែគម្លាតដ៏ធំ គឺទាក់ទងទៅនឹងក្នុងការកាត់បន្ថយចំនួនជនរងគ្រោះថ្នាក់ក្នុងមួយឆ្នាំៗ ។ ចំនួនអ្នកស្លាប់មានប្រមាណ ៨០០នាក់ នៅឆ្នាំ២០០៥ បើធៀបជាមួយនឹងចំណុចដៅដែលបានកំណត់គឺ ១.៦៩១នាក់ នៅឆ្នាំ១៩៩៣ ៥០០នាក់ នៅឆ្នាំ២០០៥ និង ២០០នាក់ នៅឆ្នាំ២០១០ ។ អត្រាស្លាប់ខ្ពស់នេះបានកើតឡើង ថ្វីបើការបោសសំអាតបានច្រើនជាង ៥០ភាគរយលើតំបន់ដែលមានគ្រាប់មីន ប្រៀបធៀបនឹងឆ្នាំ១៩៩៥ ដែលមានតែ ១០ភាគរយប៉ុណ្ណោះក៏ដោយ ។ មួយផ្នែកនៃមូលហេតុដែលបណ្តាលឱ្យស្លាប់នេះ គឺបណ្តាមកពីទីកន្លែងដែលបានបោសសម្អាតមីន និងលំនៅដ្ឋានរបស់ប្រជាជនមួយចំនួន ស្ថិតនៅជិតនឹងតំបន់ដែលគ្របដណ្តប់ដោយគ្រាប់មីន ដែលធ្វើឱ្យអត្រាស្លាប់នៅតែខ្ពស់ដដែល ។ មូលហេតុសំខាន់ៗដទៃទៀត គឺដោយសារការបំបកយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះដើម្បីយកលោហៈធាតុលក់ ។ បញ្ហាចុងក្រោយនេះ ចាំបាច់ក៏ត្រូវយកចិត្តទុកដាក់ជាបន្ទាន់ផងដែរ ។

ការសម្រេចគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា : បញ្ហាប្រឈមនាពេលអនាគត

៣២ ទោះបីជាកម្ពុជា កំពុងស្ថិតនៅផ្លូវ ដែលត្រូវសម្រេចចំណុចដៅនៃ *គអសក* ជាច្រើនក៏ដោយ ក៏កម្ពុជាមិនមែនស្ថិតនៅក្នុងដំណាក់កាលក្នុងវិស័យសំខាន់ៗជាច្រើនដែលទាក់ទងនឹងសន្តិសុខស្បៀង ការកាត់បន្ថយភាពក្រីក្រ ការអប់រំ និងការអភិវឌ្ឍសង្គមនិងសេដ្ឋកិច្ចប្រកបដោយចីរភាព ។ សមិទ្ធិផលសំខាន់ៗ និងគម្លាតជាច្រើនក្នុងការសម្រេចបាន *គអសក* ត្រូវបានសង្ខេបនៅក្នុងតារាង ១ ។

តារាង ១: សមិទ្ធផលសំខាន់ៗ និង ការសម្រេចមិនបានតាមចំណុចដៅរបស់ *គអសក* ឆ្នាំ២០០៥

[illegible]	[illegible]
• ការធ្វើឱ្យប្រសើរឡើងអត្រាភាពក្រីក្រនៅទីប្រជុំជន និងតំបន់ជនបទដែលមានលទ្ធភាពទៅដល់ ។ • ការពង្រីកការអប់រំបឋមសិក្សាដល់កុមារឱ្យបានច្រើនជាងមុន • ការកាត់បន្ថយបានច្រើននូវអត្រាមរណភាពទារក និងកុមារអាយុក្រោម៥ឆ្នាំ • ការធ្វើឱ្យប្រសើរឡើងនូវការចាក់ថ្នាំបង្ការជម្ងឺសំខាន់ៗដល់កុមារ • ការលើកកម្ពស់អត្រាបំបៅកូនដោយទឹកដោះម្តាយ • ការកាត់បន្ថយវិសមភាពយេនឌ័រ ក្នុងស្ទើរតែគ្រប់វិស័យទាំងអស់ ជាពិសេស ក្នុងការអប់រំបឋមសិក្សា អត្រាកម្មមនុស្សពេញវ័យនិងការងារដែលមានប្រាក់ឈ្នួលក្នុងផ្នែកកសិកម្ម និងឧស្សាហកម្ម • សមិទ្ធផលគួរឱ្យកត់សម្គាល់ក្នុងការកាត់បន្ថយជម្ងឺឆ្លង ជាពិសេស ហ៊ីវ/អេដស៍ • តំបន់ទីក្រុងទទួលបានទឹកស្អាត ហើយតំបន់ជនបទទទួលបាននូវអនាម័យប្រសើរជាងមុន	• អត្រាភាពក្រីក្រខ្ពស់នៅជនបទ • ភាពមិនជោគជ័យក្នុងការបង្កើនការសិក្សាពិតនៅកម្រិតខ្ពស់ជាងបឋមសិក្សា និងក្នុងការរក្សាឱ្យបានអត្រាគង់វង្សខ្ពស់នៅគ្រប់កម្រិតសិក្សា • ភាពយឺតយ៉ាវនៅមានកម្រិត ក្នុងការធ្វើឱ្យសម្រេចគោលដៅនៃសកលកម្មការអប់រំមូលដ្ឋាន៩ឆ្នាំ ជាពិសេសការអប់រំក្រោយបឋមសិក្សា • វិសមភាពយេនឌ័រនៅ មធ្យមសិក្សា និងឧត្តមសិក្សា • ការនៅតែបន្តកើតមាននូវអំពើហិង្សាកម្រិតខ្ពស់ក្នុងគ្រួសារទៅលើស្ត្រី • ការទទួលបាននូវសេវាសុខាភិបាល ដែលមានគុណភាព ជាពិសេស ក្នុងករណីសុខភាពស្ត្រី និងមាតា • ការរិចរិលនៃបរិស្ថាន ជាពិសេស ការរិចរិលព្រៃឈើ និងធនធានទឹក • ការបន្តមានជនរងគ្រោះដោយសារមីន និងយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ

៣៣ លទ្ធផលសម្រេចបានរបស់កម្ពុជានាពេលបច្ចុប្បន្ន ទាក់ទងទៅនឹង *គអសក* គឺមិនច្បាស់លាស់និងនៅមានកម្រិត ។ កម្ពុជានឹងមិនអាចសម្រេចបាន *គអសក* នៅឆ្នាំ២០១៥ ឡើយ ប្រសិនបើកិច្ចខិតខំ ប្រឹងប្រែងរបស់ជាតិទាំងមូលមិនត្រូវបានពង្រឹង និងបំពេញបន្ថែមដោយការគាំទ្រពីសហគមន៍អន្តរជាតិទេនោះ ។ បើសិនជាគ្មានការគាំទ្របែបនេះទេ កម្ពុជានឹងធ្លាក់ចុះទាបជាងបណ្តាប្រទេសកំពុងអភិវឌ្ឍន៍ថែមទៀត នៅក្នុងតំបន់អាស៊ី-ប៉ាស៊ីហ្វិក តាមរយៈនេះ គម្លាតផ្នែកសេដ្ឋកិច្ចនិងសង្គមក្នុងតំបន់កាន់តែមានទំហំខ្លាំងឡើង ។

៣៤ វឌ្ឍនភាពរបស់កម្ពុជាឆ្ពោះទៅរកគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា ត្រូវជួបឧបសគ្គជាច្រើន ដែលបញ្ហាសំខាន់ពីរគឺ ការខ្វះខាតមូលនិធិវិនិយោគ និងការទទួលបានសេវាទីផ្សារអន្តរជាតិមានកម្រិតទាបបំផុត ជាពិសេស ទៅកាន់ទីផ្សារនៅក្នុងបណ្តាប្រទេសអភិវឌ្ឍន៍ ទោះបីជាកម្ពុជាបានចូលជាសមាជិកពាណិជ្ជកម្មពិភពលោកក៏ដោយ ។ ការខ្វះខាតធនធានបែបនេះ ចាំបាច់ត្រូវដោះស្រាយឡើងវិញតាមរយៈលំហូរចូលជំនួយដ៏ច្រើន កាត់បន្ថយសេវាបំណុល និងបង្កើនលំហូរចូលនៃគណនេយ្យចរន្ត ដូចជា មានចែងក្នុងគោលដៅទី៨ នៃ*គអសក* ។ ជោគជ័យរបស់កម្ពុជានៅក្នុងទីផ្សារពាណិជ្ជកម្មសម្រាប់ការអភិវឌ្ឍ និងការឈានទៅសម្រេចបាន *គអសក* ទាមទារនូវការធ្វើពាណិជ្ជកម្មឱ្យកាន់តែច្រើនឡើងចូលទៅក្នុងទីផ្សារអន្តរជាតិ តាមរយៈការផ្លាស់ប្តូរផលិត-

គ្រោះទីផ្សារ លទ្ធភាពទទួលបានការនាំចេញផលិតផលជាច្រើន ដូចជា ការផ្តល់ឱ្យនូវកូតាមិនកំណត់ និងការលើកលែងពន្ធសម្រាប់គ្រប់ផលិតផលទំនិញដែលត្រូវបង់ពន្ធគយ នៅទីផ្សារក្នុងបណ្តាប្រទេសអភិវឌ្ឍន៍ ។ កម្ពុជាអាចសម្រេចបាន *គអសក* ប្រសិនបើគំនិតផ្តួចផ្តើមសំខាន់ៗត្រូវបានអនុវត្តដោយដៃគូអភិវឌ្ឍន៍ក្រៅប្រទេស និងសហគមន៍អន្តរជាតិ ដើម្បីបំពេញបន្ថែមលើយុទ្ធសាស្ត្រជាតិរួម ដែលមាននិន្នាការគាំទ្រ *គអសក* ។

ឧបសម្ព័ន្ធ ២.១

កម្ពុជា : សូចនាករសំខាន់ៗនៃម៉ាក្រូសេដ្ឋកិច្ច

ការប៉ាន់ស្មានពីឆ្នាំ ២០០៦-២០១០

[illegible]	[illegible]	[illegible]	[illegible]	[illegible]	[illegible]	[illegible]
	[illegible]	[illegible]				
***ផសស* (ថ្លៃថេរ) ពាន់លានរៀល**	**១៩,២៥៤**	**២០,៤៥២**	**២១,៦៧៩**	**២២,៩៣៦**	**២៤,២៩០**	**២៥,៧៤៧**
ផសស ជាក់ស្ដែង (% កំណើន)	៧.០	៦.០	៦.០	៥.៨	៥.៩	៦.០
អតិផរណាប្រាក់រៀល (%)	៦.២	៣.៥	៣.០	៣.០	៣.០	៣.០
វិនិយោគផ្ទាល់ពីបរទេស (លានដុល្លារ)	២១៦	២២៧	២៤៩	២៧៤	៣០២	៣៣២.០
សន្សំបរទេសសរុប (ចំនួនខែនៃការនាំចូល)	២.៥	២.៥	២.៥	២.៦	២.៨	៣.០
អត្រាប្ដូរប្រាក់ (រៀល/ដុល្លារ)	៤.១២៨	៤.២១៩	៤.២២៨	៤.២៧៨	៤.៣២៨	៤.៣៧៨
ការនាំចេញ (លានដុល្លារ)	២.៧០៧	២.៩៣១	៣.១៧២	៣.៣៩៥	៣.៦៤៣	៣.៩១៨
ការនាំចូល (លានដុល្លារ)	៣.៧៣៨	៤.១៦៩	៤.៥០៣	៤.៨២៧	៥.១៧២	៥.៥២៧
តុល្យភាពគណនេយ្យចរន្ត (% នៃ *ផសស* (រួមទាំងការផ្ទេរផ្លូវការ)	-៤.១	-៥.៤	-៤.៩	-៤.០	-៣.៣	-២.៦
វិស័យសារពើពន្ធ (% *ផសស*						
ចំណូលថវិកា	**១១.៨**	**១២.២**	**១២.៨**	**១៣.២**	**១៣.៥**	**១៣.៨**
ចំណូលពន្ធ-គយ	៨.៧	៩.៤	៩.៤	៩.៤	៩.៣	៩.២
ចំណូលមិនមែនពន្ធ-គយ	២.៥	២.៦	២.៦	២.៦	២.៧	២.៧
ចំណាយថវិកា	**១៤.៩**	**១៧.០**	**១៧.២**	**១៧.១**	**១៦.៩**	**១៦.៥**
ចំណាយមូលធន	៥.៣	៦.៦	៦.៦	៦.៣	៦.២	៥.៩
ចំណាយចរន្ត	៩.៦	១០.៥	១០.៧	១០.៧	១០.៧	១០.៨
តុល្យភាពចរន្ត	**១.៦**	**១.៥**	**២.០**	**២.៣**	**២.៦**	**២.៩**
[illegible]						
កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ	**៤.៥**	**៣.៤**	**៣.៧**	**៣.៧**	**៣.៨**	**៣.៨**
ស្រូវ	៨.០	៣.៥	៤.០	៤.០	៤.០	៤.០
បសុសត្វ និងបសុបក្សី	៤.០	៤.០	៤.៥	៤.៥	៥.០	៥.០
ការនេសាទ	០.០	៣.០	៣.០	៣.០	៣.០	៣.០
រុក្ខាប្រមាញ់ និងឈើមូល	០.០	២.០	២.០	២.០	២.០	២.០
ឧស្សាហកម្ម	**១០.៧**	**៩.១**	**៨.១**	[illegible]	[illegible]	**៧.៣**
រ៉ែ	៩.០	៩.០	៨.០	៨.០	៨.០	៨.០

[illegible]	[illegible]	[illegible]	[illegible]	[illegible]	[illegible]	[illegible]
កម្មន្តសាល	១០.២	៨.៦	៨.២	៦.៨	៦.៩	៧.១
ចំណីអាហារ ភេសជ្ជៈ និងថ្នាំជក់	២.០	៤.០	៤.១	៤.៥	៤.៥	៤.៥
វាយនភ័ណ្ឌ សំលៀកបំពាក់ និងស្បែកជើង	១៣.០	១០.០	៩.០	៧.០	៧.០	៧.០
ក្តារបន្ទះ ក្រដាស និងបោះពុម្ព	២.០	២.០	៣.០	៣.០	៤.០	៤.០
ផលិតផលជ័រកៅស៊ូ	(៥.០)	០.០	២.០	២.០	៣.០	៤.០
ផលិតផលផ្សេងៗទៀត	៣.០	៥.០	៨.០	៩.០	១០.០	១២.០
អគ្គិសនី ឧស្ម័ន និងទឹកស្អាត	៤.៥	៦.០	៧.០	៧.០	៧.០	៧.០
សំណង់	១៣.០	១១.០	៨.០	៨.០	៨.០	៨.០
សេវាកម្ម	**៦.៣**	**៦.០**	**៦.៦**	**៦.៨**	**៧.១**	**៧.១**
ពាណិជ្ជកម្ម	៥.០	៥.០	៥.០	៥.០	៦.០	៦.០
សណ្ឋាគារ និងភោជនីយដ្ឋាន	១៥.០	១០.០	១០.០	១០.០	១០.០	១០.០
ដឹកជញ្ជូន និងទូរគមនាគមន៍	៥.០	៦.០	៧.០	៧.០	៧.០	៧.០
ហិរញ្ញវត្ថុ	៦.០	៦.០	៦.០	៦.០	៦.០	៦.០
រដ្ឋបាលសាធារណៈ	៣.០	៣.០	៣.០	៣.០	៣.០	៣.០
ភ្នាក់ងារផ្តល់សេវាកម្ម និងអាជីវកម្ម	៤.០	៥.០	៦.០	៦.០	៦.០	៦.០
សេវាកម្មផ្សេងទៀត	៦.០	៦.០	៧.០	៨.០	៨.០	៨.០

ប្រភព៖ មូលនិធិរូបិយវត្ថុអន្តរជាតិ

ឧបសម្ព័ន្ធ ២.២

ប៉ាន់ស្មានពីការវិនិយោគ ឆ្នាំ២០០៦-២០១០

(លានដុល្លារ)

[illegible]	[illegible]	[illegible]	[illegible]	[illegible]	[illegible]	[illegible]
កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ	**១៦៨.៨**	**១៧៧.២**	**១៨៦.១**	**១៩៥.៤**	**២០៣.៥**	**៩៣១.០**
ដំណាំ	១៣៨.១	១៤៤.៩	១៥២.១	១៥៩.៧	១៦៥.៩	៧៦០.៧
បសុសត្វ និងបសុបក្សី	១០.៦	១១.២	១១.៩	១២.៧	១៣.៦	៦០.០
ការនេសាទ	១១.៤	១២.០	១២.៦	១៣.២	១៣.៨	៦៣.០
រុក្ខាប្រមាញ់ និងអាជីវឈើមូល	៨.៨	៩.១	៩.៤	៩.៨	១០.២	៤៧.៣
ឧស្សាហកម្ម	**៤៥៨.៧**	**៥១០.២**	**៥៧២.៩**	**៦៤៦.៩**	**៧៣៦.៣**	**២.៩២៥.០**
រ៉ែ	០.៦	០.៧	០.៨	០.៩	១.០	៤.០
កម្មន្តសាល	១៦០.០	១៧៧.១	១៩៨.៤	២២៥.៨	២៦២.៧	១.០២៤.០
ម្ហូបអាហារ ភេសជ្ជៈ និងថ្នាំជក់	១៤.៧	១៥.៤	១៦.២	១៧.២	១៨.៣	៨១.៨
វាយនភ័ណ្ឌ សំលៀកបំពាក់ និងស្បែកជើង	១១៧.១	១៣១.៥	១៤៩.៣	១៧២.២	២០៣.៤	៧៧៣.៥
ក្តារបន្ទះ ក្រដាស និងបោះពុម្ព	៥.៥	៥.៨	៦.៣	៦.៩	៧.៦	៣២.១
ផលិតផលកៅស៊ូ	៩.០	៩.៩	១១.១	១២.៨	១៥.២	៥៨.០
ផលិតផលផ្សេងៗទៀត	១៣.៦	១៤.៤	១៥.៥	១៦.៧	១៨.៣	៧៨.៥
អគ្គិសនី ឧស្ម័ន និងទឹកស្អាត	៨៦.២	៩៦.៥	១០៨.៥	១២២.១	១៣៧.៣	៥៥០.៦
សំណង់	២១១.៩	២៣៦.០	២៦៥.៣	២៨៨.២	៣៣៥.៣	១.៣៤៦.៧
សេវាកម្ម	**៤២៣.៣**	**៤៥៩.៩**	**៥០១.៩**	**៥៥០.៧**	**៦០៩.១**	**២.៥៤៤.៩**
ពាណិជ្ជកម្ម	៧០.០	៧៦.៣	៨១.៩	៨៧.៦	៩៣.៨	៤០៩.៦
សណ្ឋាគារ និងភោជនីយដ្ឋាន	៧៥.៤	៨៤.២	៩៥.៦	១១០.៥	១៣០.៧	៤៩៦.៤
ដឹកជញ្ជូន និងទូរគមនាគមន៍	៧៨.៨	៨៥.៧	៩៣.១	១០១.៣	១១០.១	៤៦៩.០
ហិរញ្ញវត្ថុ	៦.៧	៧.៣	៧.៩	៨.៥	៩.៣	៣៩.៧
រដ្ឋបាលសាធារណៈ	១១៣.២	១២០.១	១២៨.២	១៣៦.៩	១៤៦.២	៦៤៤.៦
ភ្នាក់ងារផ្តល់សេវាកម្ម និងអាជីវកម្ម	៥៥.៨	៦០.១	៦៦.០	៧៣.៤	៨៣.១	៣៣៨.៤
សេវាកម្មផ្សេងទៀត	២៣.៥	២៦.៤	២៩.២	៣២.៤	៣៦.០	១៤៧.៥
សរុប	**១.០៥០.៨**	**១.១៤៧.៣**	**១.២៦០.៩**	**១.៣៩៣.០**	**១.៥៤៨.៩**	**៦.៤០០.៩**
ការវិនិយោគមូលសរុប	១.០៥០.៨០	១.១៤៧.៤០	១.២៦០.៩០	១.៣៩៣.០០	១.៥៤៨.០០	៦.៤០១.១០
វិនិយោគសាធារណៈ	៤០៩.០០	៤៣២.១០	៤៧៣.០០	៥១៥.៣០	[illegible]	២.[illegible]៤.៦០

[illegible]	[illegible]	[illegible]	[illegible]	[illegible]	[illegible]	[illegible]
ហិរញ្ញប្បទានក្នុងស្រុក	៨៦.៦០	១១២.៦០	១៤៦.៤០	១៩០.៣០	២៤៧.៤០	៧៨៣.៣០
ហិរញ្ញប្បទានពីបរទេស	៣២២.៣០	៣១៥.៥០	៣២៦.៧០	៣២៥.០០	៣០៧.៨០	១.៦០១.៣០
វិនិយោគឯកជន	**៦៤១.៨០**	**៧១៥.៣០**	**៧៨៧.៥០**	**៨៧៧.៧០**	**៩៦៣.៨០**	**៤.០១៦.៥០**
ហិរញ្ញប្បទានក្នុងស្រុក	៤៥៦.៨០	៥១១.៣០	៥៥២.៥០	៥៩៥.៧០	៦៤១.៨០	២.៧៥៨.៥០
ហិរញ្ញប្បទានពីបរទេស	១៨៥.០០	២០៤.០០	២៣៥.០០	២៨២.០០	៣៥២.០០	១.២៥៨.០០
សរុបហិរញ្ញប្បទានក្នុងស្រុក	**៥៤៣.៤០**	**៦២៣.៥០**	**៦៩៩.៣០**	**៧៨៦.០០**	**៨៨៩.២០**	**៣.៥៤១.៨០**
សរុបហិរញ្ញប្បទានពីបរទេស	**៥០៧.៣០**	**៥២៣.៥០**	**៥៦១.៧០**	**៦០៧.០០**	**៦៥៩.៨០**	**២.៨៥៥.៣០**

ប្រភព: ឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ (ខែកញ្ញា ឆ្នាំ២០០៥)

វិនិយោគសាធារណៈ (មូលធន)			
ប៉ាន់ស្មានដោយឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ	២.៣៨៤.៦០	*កវិស* ប៉ាន់ស្មាន ២០០៥-២០០៧ : មូលធន	២.៣៧២.៦២
តម្រូវការថវិកាបន្ថែមសម្រាប់វិស័យសង្គមកិច្ច	៣០០.០០		
ជំនួយបច្ចេកទេស អង្កេត និងបណ្តុះបណ្តាល	៥០០.០០	: ជំនួយបច្ចេកទេសជាចំរុះគ្នា	៨៥៦.៦៨
ចំណាយចរន្តបន្ថែម	៣០០.០០	បូកបន្ថែមចំណាយចរន្ត	២៧០.៧០
ទុនបម្រុង (មិនធ្វើវិភាជន៍)	១៥.៤០		
សរុបចំណាយ *ផយអជ*	៣.៥០០.០០	សរុបចំណាយ *ផយអជ*	៣.៥០០.០០

ឧបសម្ព័ន្ធ ២.៣

ចំណាយថវិកា

ការបែងចែកតាមវិស័យ និងអាទិភាពក្រសួង

(គិតជាភាគរយនៃការចំណាយរបស់រដ្ឋាភិបាល)

[illegible]	[illegible]	[illegible]	[illegible]	[illegible]	[illegible]	[illegible]
រដ្ឋបាលទូទៅ	**១៤.០៣**	**១៣.៨៤**	**១៣.៨០**	**១៤.០០**	**១៤.០០**	**១៤.០០**
យុត្តិធម៌	០.៦៦	០.៦៧	០.៦៧	០.៦៧	០.៦៨	០.៦៨
រដ្ឋបាលទូទៅផ្សេងទៀត	១៣.៣៧	១៣.១៨	១៣.២៣	១៣.៣៣	១៣.៣២	១៣.៣២
ការពារជាតិ និងសន្តិសុខសង្គម	**២២.៨០**	**២០.៨៧**	**២១.៣០**	**២១.៣០**	**២១.១០**	**២០.៨០**
សេវាកម្មសង្គមកិច្ច	**៣៨.៤៣**	**៣៧.៣៦**	**៣៨.៤០**	**៣៨.៤៥**	**៣៨.៥០**	**៣៩.២០**
សុខាភិបាល	១២.០៤	១២.៧៤	១២.៧៥	១២.៧៥	១២.៧៥	១២.៨១
អប់រំ	១៨.៤៩	១៨.៤៩	១៨.៥០	១៨.៥០	១៨.៥០	១៨.៨១
កិច្ចការនារី	០.៥៦	០.៥៦	០.៥៦	០.៥៦	០.៥៦	០.៥៦
សេវាកម្មសង្គមកិច្ចផ្សេងទៀត	៧.៣៤	៥.៥៧	៦.៦០	៦.៦៥	៦.៧០	៦.៨៣
សេវាកម្មសេដ្ឋកិច្ច	**១០.០៨**	**១១.១០**	**១១.១១**	**១១.១១**	**១១.២០**	**១១.៣៥**
កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ	២.៥៣	២.៦៧	២.៦៧	២.៦៧	២.៧០	២.៧៥
អភិវឌ្ឍន៍ជនបទ	១.២៤	១.៣១	១.៣១	១.៣១	១.៣២	១.៣៣
សេវាកម្មសេដ្ឋកិច្ចផ្សេងទៀត	៦.៣១	៧.១៣	៧.១៣	៧.១៣	៧.១៨	៧.៣១
សន្សំ និងបំណុល	**១៤.៦៦**	**១៦.៨៤**	**១៥.២៩**	**១៥.១៤**	**១៥.២០**	**១៤.៦១**
ចំណាយចរន្តរបស់រដ្ឋាភិបាល (ពាន់លានរៀល)	**១.៩៨៣.៦០**	**២.៣៧៨.៩២**	**២.៧៦៩.០៤**	**៣.០៨៤.៧៣**	**៣.៣៧៣.៣៧**	**៣.៦១៤.២០**

ប្រភព: ឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ (ខែវិច្ឆិកា ឆ្នាំ២០០៥)

ឧបសម្ព័ន្ធ ៣

ទន្សានភាពក្នុងការកាត់បន្ថយភាពក្រីក្រ និងបញ្ហាប្រឈមក្នុង ៥យអ៥[1]

១. ការរាលដាលនៃភាពក្រីក្ររបស់កម្ពុជា ក្នុងបរិបទនៃសង្គ្រាមស៊ីវិលជាង ២ទសវត្សរ៍ និងទុក្ខវេទនា គឺជាបញ្ហាប្រឈមគន្លឹះមួយរបស់រាជរដ្ឋាភិបាល ។ ផែនការអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គមកិច្ច៥ឆ្នាំលើកទី១ ឆ្នាំ១៩៩៦-២000 បានចាប់ផ្តើមជាមួយនឹងការសន្មតថា "ការលុបបំបាត់ភាពក្រីក្រ គឺជាទិសដៅតែមួយគត់និងយូរអង្វែងរបស់រាជរដ្ឋាភិបាល ហើយការកាត់បន្ថយភាពក្រីក្រនេះគឺជាការនាំមុខស្នូលនៃផែនការឆ្នាំ១៩៩៦-២000" ។ ទិសដៅនេះត្រូវបានលើកឡើងជាថ្មីទៀត ក្នុងឯកសារគោលនយោបាយបន្តមកទៀត ដូចជា ផែនការអភិវឌ្ឍន៍សេដ្ឋកិច្ច-សង្គមកិច្ច៥ឆ្នាំលើទី២ ឆ្នាំ២០០១-២០០៥ និងយុទ្ធសាស្ត្រជាតិកាត់បន្ថយភាពក្រីក្រ ឆ្នាំ២០០៣-២០០៥ ។

២. ប៉ាន់ស្មានក្រីក្រសម្រាប់កម្ពុជាបានផ្អែកលើការអង្កេតសេដ្ឋកិច្ច-សង្គមកិច្ចកម្ពុជា[2] ។ ការអង្កេតចុងក្រោយនេះត្រូវបានធ្វើឡើងនៅឆ្នាំ២០០៤ ដែលបានប្រមូលទិន្នន័យស្តីពីការប្រើប្រាស់ប្រចាំថ្ងៃរបស់ប្រជាជនកម្ពុជា ដោយប្រើប្រាស់វិធីសាស្ត្រខល និងវិធីសាស្ត្រដាគី ។ តារាង១ ធ្វើការប្រៀបធៀបកម្រិតភាពក្រីក្រនៅកម្ពុជា ដែលបានមកពីការអង្កេតសេដ្ឋកិច្ច-សង្គមកិច្ចកម្ពុជាឆ្នាំ១៩៩៣-១៩៩៤ ដែលគ្របដណ្តប់បានតែ ៥៥ភាគរយនៃតំបន់ទូទាំងប្រទេសនិង ៦៨ភាគរយនៃគ្រួសារទាំងអស់ ដោយសារតែបញ្ហាសន្តិសុខនៅពេលនោះ ជាមួយនឹងកម្រិតភាពក្រីក្រដែលបានមកពីការអង្កេតសេដ្ឋកិច្ច-សង្គមកិច្ចឆ្នាំ២០០៤ ដែលបានគ្របដណ្តប់ទូទាំងប្រទេស[3] ។

តារាង១ : ផលធៀបការរាប់ចំនួនជនក្រីក្រនៅកម្ពុជា

(គិតជាភាគរយ)

[illegible]	[illegible]		[illegible]	
	១៩៩៣-៩៤	២០០៤	១៩៩៣-៩៤	២០០៤
ក) ទូទាំងកម្ពុជា				
ភ្នំពេញ	-	៤.៦	-	២.៦
តំបន់ទីប្រជុំជនផ្សេងទៀត	-	២៤.៦	-	១៤.២

---

[1] កំណត់សម្គាល់នេះរៀបចំដោយក្រសួងផែនការ ខែតុលា ឆ្នាំ២០០៥

[2] គួរបញ្ជាក់នៅទីនេះថា ការអង្កេតសេដ្ឋកិច្ច-សង្គមកិច្ចដែលបានដំណើរការរៀបចំនៅពេលវេលាខុសៗគ្នា តួលេខភាពក្រីក្រដែលទទួលបានមិនអាចធ្វើការប្រៀបធៀបបានទេ ដោយសារមានលក្ខណៈខុសគ្នាខាងបច្ចេកទេសអង្កេត ការគ្របដណ្តប់ ការប្រមូលទិន្នន័យ និងវិធីសាស្ត្រផ្សេងៗទៀត ។ ក្នុងការប្រៀបធៀបភាពក្រីក្រនៅគ្រប់ពេលទាំងអស់ត្រូវចងចាំការណែនាំនេះក្នុងគំនិតជានិច្ច ។

[3] តួលេខសម្រាប់ឆ្នាំ២០០៤ ត្រូវបានផ្អែកលើតួលេខចំណាយលើការប្រើប្រាស់ដែលទទួលបានពីការប្រមូលដោយវិធីសាស្ត្រខល [illegible] ១២ ខែនៃឆ្នាំ២០០៤ ។ ចំណុចដៅថ្មីនិងការប៉ាន់ស្មានភាពក្រីក្រសម្រាប់ឆ្នាំ២០០៤ ដោយប្រើប្រាស់តួលេខដែលបានប្រមូល [illegible] នៅមិនទាន់មាននៅឡើយ ។ តួលេខភាពក្រីក្រសម្រាប់ឆ្នាំ១៩៩៣-១៩៩៤ បានផ្អែកលើតួលេខដែលបានប្រមូលដោយប្រើប្រាស់វិធីសាស្ត្រខល ។

[illegible]	[illegible]			
	[illegible]	[illegible]	[illegible]	[illegible]
តំបន់ជនបទ	-	៣៩.២	-	២២.២
កម្ពុជា	-	៣៤.៧	-	១៩.៧
ខ) តំបន់ភូមិសាស្ត្រដែលបានគ្របដណ្តប់ដោយអង្កេតសេដ្ឋកិច្ច-សង្គមកិច្ច ឆ្នាំ១៩៩៣-៩៤				
ភ្នំពេញ	១១.៤	៤.៦	៦.២	២.៦
តំបន់ប្រជុំជនផ្សេងទៀត	៣៦.៦	២០.៥	១៩.៦	១២.៥
តំបន់ជនបទ	៤៣.១	៣៣.៧	២២.០	១៦.៧
កម្ពុជា	៣៩.០	២៨.០	២០.០	១៤.២
គ) តំបន់ភូមិសាស្ត្រដែលបានបានគ្របដណ្តប់ដោយអង្កេតសេដ្ឋកិច្ច-សង្គមកិច្ច ១៩៩៣/១៩៤	...	៤៩.៦	...	២៨.៧

ចំណាំ : "..." មានន័យថា ពុំទាន់មានទិន្នន័យបញ្ជាក់ ។ ខ្សែបន្ទាត់ភាពក្រីក្រផ្អែកលើខ្សែបន្ទាត់ភាពក្រីក្រម្ហូបអាហារ (ដែលផ្តល់ ២.១០០កាឡូរី សម្រាប់មនុស្សម្នាក់ក្នុងមួយថ្ងៃ) និងការចំណាយមិនមែនម្ហូបអាហារក្នុងកម្រិតអប្បបរមា ។

៣. លទ្ធផលបង្ហាញថាសន្ទស្សន៍នៃភាពក្រីក្រសម្រាប់ទូទាំងកម្ពុជាគឺ ៣៤.៧ភាគរយក្នុងឆ្នាំ២០០៤ ។ ពុំមានការប៉ាន់ស្មានអាចប្រៀបធៀបជាមួយភាពក្រីក្រសម្រាប់ទូទាំងនៅឆ្នាំ១៩៩៣-៩៤ ទេ ដោយសារតំបន់ភូមិ-សាស្ត្រដែលគ្របដណ្តប់ដោយការអង្កេតឆ្នាំ១៩៩៣-១៩៩៤ មានចំនួនតិចពេក ។ ទោះជាដូចនេះក្តី ការប៉ាន់ស្មាននៅឆ្នាំ២០០៤ ពីសំណាកគំរូ ដែលបានគ្របដណ្តប់លើតំបន់ភូមិសាស្ត្រដូចគ្នាក្នុងការអង្កេតសេដ្ឋកិច្ច-សង្គមកិច្ច ឆ្នាំ១៩៩៣-១៩៩៤ បានបង្ហាញថា អត្រាភាពក្រីក្រនៅកម្ពុជាមានការថយចុះយ៉ាងខ្លាំង ពី ៣៩ភាគរយក្នុងឆ្នាំ ១៩៩៣-១៩៩៤ មក ២៨ភាគរយក្នុងឆ្នាំ២០០៤ ។ និន្នាការនេះបង្ហាញពីការធ្លាក់ចុះនៃភាពក្រីក្រ ប្រហែល ១១ភាគរយ ដែលក្នុងរយៈពេលនោះ គឺប្រហែលថយចុះជាមធ្យម ១ភាគរយ ក្នុងមួយឆ្នាំ ។

៤. ដូចគ្នាដែរ ប្រជាជនដែលរស់នៅក្រោមបន្ទាត់ភាពក្រីក្រម្ហូបអាហារ សម្រាប់ទូទាំងប្រទេសគឺ ១៩.៧ភាគរយក្នុងឆ្នាំ២០០៤ ដែលក្នុងនោះ នៅតំបន់ភូមិសាស្ត្រដែលជាសំណាកគំរូអាចប្រៀបធៀបបាន សន្ទស្សន៍ភាពក្រីក្រម្ហូបអាហារបានធ្លាក់ចុះពី ២០ភាគរយ ទៅ ១៤.២ភាគរយក្នុងរយៈពេលដូចគ្នា គឺពីឆ្នាំ១៩៩៣-១៩៩៤ ទៅឆ្នាំ២០០៤ ។ ភាពក្រីក្រដែលបានវាស់វែងតាមរយៈសន្ទស្សន៍ទាំងពីនេះ បានថយចុះនៅក្នុងតំបន់ទាំង៣នៃប្រទេស សម្រាប់តំបន់ភូមិសាស្ត្រដែលជាសំណាកគំរូអាចប្រៀបធៀបបាន ទោះបីជានៅតំបន់ជនបទនៅតែមានអត្រាភាពក្រីក្រខ្ពស់ខ្លាំងក៏ដោយ ។

៥. ក្នុងរយៈពេលដូចគ្នា ការប្រែប្រួលភាពក្រីក្រដែលមានការពាក់ព័ន្ធ ដូចជាសន្ទស្សន៍គម្លាតភាពក្រីក្រ (P1) និងស្វ័យគុណនៃសន្ទស្សន៍គម្លាតភាពក្រីក្រ (P2) ឆ្លុះបញ្ចាំងជាទូទៅពីការប្រែប្រួលដែល[illegible]

ផលធៀបរាប់ចំនួនមនុស្ស ដូចដែលបានរៀបរាប់ខាងលើ ។ តាមរៈសន្ទស្សន៍ភាពក្រីក្រដែលបានធ្លាក់ចុះស្របគ្នា ក្នុងតំបន់ទាំង៣ សម្រាប់តំបន់ភូមិសាស្ត្រដែលជាសំណាកគំរូអាចប្រៀបធៀបបាន ទាំងនេះ បានបង្ហាញថា មួយផ្នែកធំនៃប្រជាជនក្រីក្រ កំពុងស្ថិតនៅជិតបន្ទាត់ភាពក្រីក្រជាងក្នុងពេលឆ្នាំ១៩៩៣/១៩៩៤[១] ។

៦. ក្នុងឆ្នាំ២០០៤ អត្រាភាពក្រីក្រដែលខ្ពស់ជាងគេនៅទូទាំងប្រទេសកម្ពុជា ដែលបានប្រៀបធៀបទៅនឹងតំបន់ដែលបានគ្របដណ្តប់ដោយអង្កេតសេដ្ឋកិច្ច-សង្គមកិច្ចឆ្នាំ១៩៩៣-១៩៩៤ គឺជាតំបន់ដែលមិនបានគ្របដណ្តប់ដោយអង្កេតឆ្នាំ១៩៩៣-១៩៩៤ (៤៤ភាគរយនៃតំបន់សរុបទូទាំងប្រទេស) ។ តាមការគណនាដ៏សាមញ្ញមួយ បង្ហាញថា ផលធៀបរាប់ចំនួនមនុស្សក្នុងតំបន់ដែលមិនបានគ្របដណ្តប់ដោយអង្កេតឆ្នាំ១៩៩៣-១៩៩៤ នេះ មាន ៤៥.៦ភាគរយក្នុងឆ្នាំ២០០៤ (ប្រៀបធៀបទៅនឹង ២៨ភាគរយក្នុងតំបន់ដែលបានគ្របដណ្តប់ដោយអង្កេតឆ្នាំ ១៩៩៣-១៩៩៤) ដែលជាមួយគ្នានោះ សន្ទស្សន៍ភាពក្រីក្រម្ហូបអាហារគឺ ២៨.៧ភាគរយ (ប្រៀបធៀបទៅនឹង ១៤.២ភាគរយ ក្នុង តំបន់ដែលបានគ្របដណ្តប់ដោយអង្កេតឆ្នាំ ១៩៩៣-១៩៩៤)[២] ។

៧. ជាង ៩០ភាគរយនៃប្រជាជនក្រីក្ររស់នៅក្នុងតំបន់ជនបទ នេះបង្ហាញឱ្យឃើញថា ភាពក្រីក្រនៅកម្ពុជាភាគច្រើនមានឫសគល់នៅក្នុងវិស័យកសិកម្ម ដែលមានផលិតភាពនិងកំណើនទាប ប៉ុន្តែបានផ្តល់ជីវិតរស់នៅដល់ប្រជាជនភាគច្រើននៅក្នុងប្រទេស ។ ជាមួយគ្នានឹងភាពខុសគ្នាយ៉ាងខ្លាំងនៃអត្រាភាពក្រីក្រ ភាពខុសគ្នារវាងចំណែកនៃប្រជាជនក្រីក្រនៅជនបទ និងចំណែកនៃប្រជាជនក្រីក្រនៅទីប្រជុំជន ក៏កើនឡើងកាន់តែខ្លាំងដែរ ដែលក្នុងរយៈពេលនោះ ចំណែកនៃប្រជាជនក្រីក្រនៅជនបទមានការកើនឡើង បើប្រៀបធៀបទៅនឹងប្រជាជនក្រីក្រទាំងអស់នៅក្នុងប្រទេស (ពី ៨៧ភាគរយក្នុងឆ្នាំ១៩៩៣/៩៤ ទៅ ៩១ភាគរយក្នុងឆ្នាំ២០០៤) ហើយ ចំណែកនៃប្រជាជនក្រីក្រនៅទីក្រុងភ្នំពេញបានធ្លាក់ចុះ បើប្រៀបធៀបទៅនឹងប្រជាជនក្រីក្រទាំងអស់នៅក្នុងប្រទេស (ពី ៣ភាគរយ ទៅ ១ភាគរយ) និងនៅក្នុងតំបន់ទីប្រជុំជនផ្សេងទៀត អត្រានេះបានថយចុះ ពី ១០ភាគរយ ទៅ ៨ភាគរយ ។

៨. ស្ថានភាពនៃជនក្រីក្រកម្ពុជា គឺពុំមានភាពខុសគ្នាខ្លាំងពីប្រជាជនក្រីក្រក្នុងប្រទេសក្រីក្រផ្សេងទៀតទេ ។ ភាពក្រីក្រទូទៅ ក៏ដូចជាភាពក្រីក្រម្ហូបអាហារនៅក្រុងភ្នំពេញ មានកម្រិតខ្ពស់ជាងខ្លាំងនៅក្នុងតំបន់ជនបទ និងតំបន់ទីប្រជុំជនផ្សេងទៀត ។ ក្រៅពីការរស់នៅនៅតំបន់ជនបទ ប្រជាជនក្រីក្រតែងតែមានកម្រិតអប់រំទាប លទ្ធភាព

---

[១] លំដាប់ទី១ នៃភាពលើសលុបនៃការបូកបន្ថែមបន្តការបែងចែកចំណាយពិតសម្រាប់មនុស្សម្នាក់ ក្នុងឆ្នាំ២០០៤ លើការបែងចែកឆ្នាំ១៩៩៣-១៩៩៤ នៅកម្ពុជា បង្ហាញថា និន្នាការនៃភាពក្រីក្រក្នុងរយៈពេលនោះ អាចដូចគ្នាលើផ្ទៃនៃបន្ទាត់ភាពក្រីក្រដែលអាចមានជាក់ស្តែងទាំងអស់ ។

[២] ជាមួយចំណែកនៃប្រជាជនដែលបានចាំនស្មានប្រហែល ៣៨ ភាគរយក្នុងតំបន់ដែលមិនបានគ្របដណ្តប់ដោយអង្កេតឆ្នាំ១៩៩[illegible] x គឺជាសន្ទស្សន៍ភាពក្រីក្រក្នុងតំបន់ដែលមិនបានគ្របដណ្តប់ក្នុងការអង្កេតសេដ្ឋកិច្ចសង្គមកិច្ចឆ្នាំ១៩៩៣-១៩៩៤ សម្រាប់[illegible] $0.៦២ \times ២៧.៩៧ + 0.៣៨ \times X = ៣៤.៦៨$ ដែលអាចទទួលបាន $X = ៤៥.៦៣\%$ ដូចគ្នានេះដែរសម្រាប់សន្ទស្សន៍ភា[illegible] $0.៦២ \times ១៤.១៨ + 0.៣៨ \times X' = ១៩.៦៨$ ដែលអាចទទួលបាន $X = ២៨.៦៥\%$ ។

មានកំរិតក្នុងការទទួលបានដីនិងទ្រព្យសកម្មផ្សេងទៀត និងប្រមូលផ្តុំច្រើននៅក្នុងការងារដែលទទួលបានកំរៃទាប ការងារដែលប្រើប្រាស់កម្លាំងពលកម្ម និងការងារដែលសង្គមមិនសូវចាប់អារម្មណ៍ ។ ទាំងនៅក្នុងតំបន់ទីក្រុង និងតំបន់ជនបទ អ្នកក្រីក្រទទួលបានសេវាកម្ម និងភាពទំនើកម្មតិចតួច ។ ប្រជាជនក្រីក្រទាំងនោះរស់នៅក្នុងផ្ទះដែលមានគុណភាពទាប ជាមួយការមិនទទួលបានមានកម្រិតនូវសេវាមូលដ្ឋាន ដូចជាទឹកស្អាត និងការធ្វើឱ្យប្រសើរឡើងអនាម័យ ។ ប្រជាជនក្រីក្រតែងតែរស់នៅក្នុងគ្រួសារដែលមានសមាជិកច្រើន មានកូនច្រើន និងមានមេគ្រួសារដែលមានការអប់រំតិចតួច ។ ប្រជាជនទាំងនោះក៏មានលទ្ធភាពតិចតួចក្នុងការទទួលបានតិចតួចនូវសេវាសាធារណៈ ។

៩. ជាការពិតនៅកម្ពុជា ភាពក្រីក្រនៅតំបន់ជនបទបានធ្លាក់ចុះក្នុងអត្រាមួយយឺតៗ ជាងភាពក្រីក្រនៅភ្នំពេញ ឬតំបន់ទីប្រជុំជនផ្សេងទៀត ។ ការធ្លាក់ចុះខ្លាំងនៃភាពក្រីក្រក្នុងតំបន់នេះ (ជាទូទៅនៅក្នុងតំបន់ដែលបានគ្របដណ្តប់ដោយអង្កេតសេដ្ឋកិច្ច-សង្គមកិច្ចឆ្នាំ១៩៩៣-១៩៩៤) គឺដោយសារឥទ្ធិពលនៃកំណើនដ៏ខ្លាំងនៅតំបន់ទីប្រជុំជន និងការប្រមូលផ្តុំវិនិយោគសាធារណៈក្នុងតំបន់ទាំងនោះ ។ នេះឆ្លុះបញ្ចាំងឱ្យឃើញពី "លទ្ធផលនៃសន្តិភាព" ដែលកម្ពុជាបានទទួល តាមរយៈការបញ្ចប់នូវជម្លោះនិងភាពឯកកោរជាងពីរទសវត្សរ៍កន្លងមក ដែលធ្វើឱ្យមានការកើនឡើងនូវការវិនិយោគនិងកំណើនសេដ្ឋកិច្ច ហើយជាលទ្ធផលធ្វើឱ្យមានការកាត់បន្ថយភាពក្រីក្រ[៣] ។ ទោះជាដូចនេះក្តី ជាទូទៅកំណើននេះមិនមានតុល្យភាពទេ ដោយបានប្រមូលផ្តុំច្រើននៅទីក្រុងភ្នំពេញនិងទីប្រជុំជននានា មានមូលដ្ឋានតិចតួច និងនាំមុខដោយសកម្មភាពដូចជា ឧស្សាហកម្មកាត់ដេរ សំណង់ និងទេសចរណ៍ ។

១០. ផ្ទុយទៅវិញ កំណើននៃសកម្មភាពនៅជនបទ ដែលជាចម្បងផ្អែកលើកសិកម្ម បានបង្ហាញពីគម្លាតច្រើននិងដែលអាចប្រែប្រួលនៅពីក្រោយសេដ្ឋកិច្ច ។ លើសពីនេះទៀត កំណើនក្នុងវិស័យកសិកម្មនៅពេលអំឡុងពេលនោះ ត្រូវបានកំណត់ភាគច្រើននៅក្នុងតំបន់ជនបទមួយចំនួនដែលមានអំណោយផលច្រើន ។ ភាពខុសគ្នាយ៉ាងខ្លាំងនៃកម្រិតភាពក្រីក្រ រវាងតំបន់ដែលបានគ្របដណ្តប់ និងមិនបានគ្របដណ្តប់ដោយអង្កេតសេដ្ឋកិច្ច-សង្គមកិច្ចឆ្នាំ១៩៩៣-១៩៩៤ គឺជាលទ្ធផលនៃកត្តាទាំងនោះ ។

១១. ប្រសិនបើកំណើននៅតែបន្តនៅទីប្រជុំជន ភាពក្រីក្រនៅជនបទនឹងនៅតែមានកម្រិតខ្ពស់ ជាពិសេសនៅពេលដែលទំហំនៃភាពក្រីក្រកាន់តែធំឡើងនៅតំបន់ជនបទ ។ នៅក្នុងស្ថានភាពបែបនេះ ការកាត់បន្ថយភាពក្រីក្រ ដែលទទួលបានពី *ផយអជ* នឹងមានកម្រិតតិចតួចបំផុត ។ បញ្ហានេះ នឹងធ្វើឱ្យរាំងស្ទះដល់ការសម្រេចបានចំណុចដៅទាំងឡាយរបស់ *ផយអជ* នាឆ្នាំ២០១០ និង *គអសក* នាឆ្នាំ២០១៥ ។ ដូច្នេះ បញ្ហាប្រឈមចម្បងរបស់

---

[៣] ក្នុងរយៈពេលនោះដែរ កម្ពុជាបានទទួលផលចំណេញពីលក្ខខណ្ឌអំណោយផលសំខាន់១ ដូចជា ក្រសួងការបរទេស និងស្ថាប័ន[illegible] ពីចុងឆ្នាំ១៩៩០ ទៅ២០០៥ និងបន្តនៅក្នុងបញ្ជីសុវត្ថិភាពរបស់សហរដ្ឋអាមេរិករហូតដល់ឆ្នាំ២០០៨។

ផយអជ គឺអនុម័តនូវយុទ្ធសាស្ត្រនិងសកម្មភាពដែលបានកំណត់រួចហើយ ដើម្បីជំរុញការកាត់បន្ថយភាពក្រីក្រនៅតំបន់ជនបទ ជាពិសេស នៅតំបន់ដែលមានភាពក្រីក្រខ្ពស់ និងតំបន់ដែលមិនបានគ្របដណ្តប់ដោយអង្កេតសេដ្ឋកិច្ច-សង្គមកិច្ចឆ្នាំ១៩៩៣/៩៤ ។ លើសពីនេះ បញ្ហាប្រឈមនៃ *ផយអជ* នឹងត្រូវពង្រឹងថែមទៀតនូវសមិទ្ធផលនៃការកាត់បន្ថយភាពក្រីក្រ ដែលបានមកពីវឌ្ឍនភាពនៃសមាសភាគសំខាន់ពីរនៃយុទ្ធសាស្ត្រចតុកោណ (សន្តិភាពនិងសន្តិសុខ សមាហរណកម្មទៅក្នុងតំបន់និងពិភពលោក) និងការផ្តួចផ្តើមឱ្យមានវឌ្ឍនភាព យ៉ាងឆាប់រហ័សដោយស្មើភាព នៅក្នុងមុំផ្សេងទៀតនៃយុទ្ធសាស្ត្រចតុកោណ រួមទាំងការបង្កើនល្បឿនកំណើនសេដ្ឋកិច្ច និងការអភិវឌ្ឍសង្គមនិងធនធានមនុស្ស ។

១២. ចំនួនភូមិទាំងឡាយដែលមិនបានគ្របដណ្តប់ដោយអង្កេតសេដ្ឋកិច្ច-សង្គមកិច្ចឆ្នាំ១៩៩៣/៩៤ តាមខេត្តត្រូវបានបង្ហាញក្នុងតារាង២ ។ ចំនួនភូមិទាំងអស់មាន ៥.០៩៣ភូមិនៅជនបទ និង ៩០ភូមិនៅទីប្រជុំជនដែលមិនបានគ្របដណ្តប់ដោយអង្កេតឆ្នាំ១៩៩៣-១៩៩៤ នេះ ដោយហេតុថាជាតំបន់ពិបាកធ្វើដំណើរទៅដល់ និងបញ្ហាសន្តិសុខ ។ អង្កេតនេះមិនបានគ្របដណ្តប់ទាំងស្រុងនូវខេត្ត៦ គឺខេត្តកោះកុង ក្រចេះ មណ្ឌលគិរី ព្រះវិហារ រតនគិរី និងស្ទឹងត្រែង ។

១៣. តារាងទី២នេះបង្ហាញថា ភូមិដែលមិនបានគ្របដណ្តប់ដោយអង្កេតសេដ្ឋកិច្ច-សង្គមកិច្ចឆ្នាំ១៩៩៣/៩៤ ភាគច្រើនស្ថិតនៅតំបន់ជនបទ ដែលភាពក្រីក្រមានកម្រិតខ្ពស់នៅក្នុងឆ្នាំ២០០៤ ។ នៅក្នុងបណ្តាឆ្នាំបន្ទាប់នេះ ទំនាក់ទំនងរវាងតំបន់ទីប្រជុំជន និងតំបន់ជនបទ (ដែលបានគ្របដណ្តប់ដោយអង្កេតឆ្នាំ១៩៩៣/៩៤) អាចមានភាពល្អប្រសើរជាងមុន និងបន្តរីកចម្រើន ហើយកម្រិតនៃភាពក្រីក្រក្នុងតំបន់ទាំងអស់នោះនឹងថយចុះ ទន្ទឹមនឹងកំណើនសេដ្ឋកិច្ចទូទៅរបស់កម្ពុជាមានជាមធ្យមប្រហែល ៦ភាគរយក្នុងអំឡុងទសវត្សរ៍ចុងក្រោយនេះ ។ ម្យ៉ាងវិញទៀត បន្ថែមលើវិធានការជំរុញល្បឿនកំណើននៅតំបន់ដែលមិនបានគ្របដណ្តប់ដោយអង្កេតសេដ្ឋកិច្ច-សង្គមកិច្ចឆ្នាំ១៩៩៣/៩៤ នឹងទាមទារឱ្យការយកចិត្តទុកដាក់ជាពិសេស និងធាតុចូលនិងការវិនិយោគដែលបានកំណត់ដើម្បីកាត់បន្ថយភាពក្រីក្រឱ្យថយចុះពីកម្រិតខ្ពស់ដែលមានស្រាប់ ។ ជាការពិតដែលថា បណ្តាឃុំនិងភូមិនៅតំបន់ផ្សេងទៀត នៅដាច់ស្រយាលនិងប្រមូលផ្តុំខ្ពស់នៃអ្នកក្រីក្រ ។ លើសពីនេះទៀត បណ្តាយុទ្ធសាស្ត្រនៃ *ផយអជ* គប្បីទទួលស្គាល់ថា ជាតម្រូវការជាក់លាក់នៃជនជាតិភាគតិច និងជនអន្តោប្រវេសន៍ក្រោមដែលមានទំនាក់ទំនងស្មុគស្មាញទៅនឹងបញ្ហាសេដ្ឋកិច្ច-សង្គមកិច្ច វប្បធម៌ ច្បាប់ នយោបាយ និងបញ្ហាដទៃទៀត ។

តារាង២ : តំបន់ក្រៅអង្កេតសេដ្ឋកិច្ច-សង្គមកិច្ចឆ្នាំ១៩៩៣/៩៤

[illegible]	[illegible]	
	[illegible]	[illegible]
បន្ទាយមានជ័យ	៧	[illegible]
បាត់ដំបង	...	[illegible]

ខេត្ត-ក្រុង	ចំនួនតំបន់ពុំបានអង្កេត	
	ទីប្រជុំជន	ជនបទ
កំពង់ចាម	...	៣៣៤
កំពង់ឆ្នាំង	...	២៦៨
ក្រុងព្រះសីហនុ	...	៥៩
កំពង់ស្ពឺ	...	៩៦៨
កំពង់ធំ	...	៦៦៣
កំពត	...	៣១៥
កណ្តាល	...	១០៩
កោះកុង	១០	១០៩
ក្រចេះ*	...	២៤៣
មណ្ឌលគិរី*	១៣	៧៤
ភ្នំពេញ	...	...
ព្រះវិហារ*	២៧	១៧០
ព្រៃវែង	...	...
ពោធិសាត់	...	៥១
រតនៈគិរី*	១៦	២២៧
សៀមរាប	...	៦៨៩
ស្ទឹងត្រែង*	១៧	១១២
ស្វាយរៀង	...	...
តាកែវ	...	៦៦
សរុប	**៩០**	**៥.០៩៣**

កំណត់ចំណាំ : ខេត្តដែលមានសញ្ញា (*) ជាខេត្តដែលនៅក្រៅអង្កេតទាំងស្រុង ។ ក្នុងសំណាកគំរូនៃអង្កេតសេដ្ឋកិច្ច-សង្គមកិច្ចឆ្នាំ ១៩៩៣/៩៤ ក្រុងកែប គឺស្ថិតនៅក្នុងខេត្តកំពត ឧត្តរមានជ័យស្ថិតនៅក្នុងខេត្តសៀមរាប និង ក្រុងប៉ៃលិនស្ថិតនៅក្នុងខេត្តបាត់ដំបង ។

១៤. សកម្មភាពពិសេសទាំងអស់នេះ នឹងរួមបញ្ចូល ការពឹងផ្អែកលើស្ថានភាពដែលមានស្រាប់ និងតម្រូវការជាក់លាក់នៅមូលដ្ឋាន ការថែទាំសុខភាពឱ្យបានកាន់តែច្រើននិងល្អប្រសើរឡើង ការពង្រីកប្រព័ន្ធអប់រំ ការបង្កើតសកម្មភាពកសិកម្មនិងមិនមែនកសិកម្មនៅជនបទ ការធ្វើឱ្យប្រសើរឡើងនូវហេដ្ឋារចនាសម្ព័ន្ធ ការបង្កើនជីវភាពរស់នៅប្រកបដោយនិរន្តរភាព និងសកម្មភាពប្រហាក់ប្រហែលដទៃទៀត ។ ជាមួយគ្នានេះ ការផ្តល់មូលនិធិច្រើនបន្ថែមទៀតទៅឱ្យតំបន់ដែលមិនបានគ្របដណ្តប់ដោយអង្កេតឆ្នាំ១៩៩៣-១៩៩៤ ទាំងនោះក្នុងអំឡុងពេល *ផយអជ* តាមរយៈមូលនិធិអភិវឌ្ឍន៍ឃុំ-សង្កាត់ ក៏ជាការចាំបាច់ណាស់ដែរ ។

១៥. បញ្ហាចម្បងផ្សេងទៀតសម្រាប់ *ផយអជ* ទាក់ទងនឹងការកាត់បន្ថយភាពក្រីក្រ គឺការកើនឡើងនៃនិន្នាការវិសមភាព ដោយសារតែផលប៉ះពាល់នៃកំណើនសេដ្ឋកិច្ចលើភាពក្រីក្រ ក៏អាស្រ័យផងដែរលើបញ្ហាដែលកើតមានឡើងចំពោះវិសមភាព[១] ។ ការកើនឡើងនៃវិសមភាពនៅកម្ពុជា ជាពិសេស នៅតំបន់ជនបទ បង្ហាញថា ទម្រង់នៃកំណើននៅតំបន់ជនបទកន្លងមកនៅកម្ពុជា មាននិន្នាការជាមូលដ្ឋានឆ្ពោះទៅរកការកើតឡើងវិសមភាពកាន់តែខ្ពស់ ។ ដើម្បីទប់ទល់នឹងនិន្នាការបែបនេះ ជាមួយនឹងការជំរុញផលិតភាពនិងផលទទួលបានឱ្យកាន់តែខ្ពស់ គោលនយោបាយនិងយុទ្ធសាស្ត្រកំណើននៃ *ផយអជ* ត្រូវតែដោះស្រាយប្រភពដែលនាំឱ្យមានការកើនឡើងនៃវិសមភាព ដូចជា ការពង្រាយមិនស្មើនៃកាលានុវត្តភាពសេដ្ឋកិច្ចនិងសង្គម ការចែកទុនហិរញ្ញវត្ថុនិងមូលធនមនុស្សមិនត្រឹមត្រូវ និងការកើនឡើងគម្លាតក្នុងផ្នែកដទៃនៃជីវិត ។ ថាមពលសម្រាប់ជំរុញកំណើនសេដ្ឋកិច្ចដែលបានមកទាំងពីសកម្មភាពកសិកម្មនិងពុំមែនកសិកម្ម ភាពចម្រុះមួយដែលចាំបាច់ក្នុងការគាំទ្រការកាត់បន្ថយភាពក្រីក្រក្នុងអំឡុងពេល *ផយអជ* និងពេលអនាគត ។

១៦. នៅក្នុងអំឡុងពេលនៃ *ផយអជ* កិច្ចខិតខំប្រឹងប្រែងដើម្បីបង្កើនចំណូលកសិកម្ម ចាំបាច់ត្រូវធ្វើឡើងនៅក្នុងវិស័យសំខាន់ៗជាច្រើន ដូចជា បង្កើនផលិតភាពដំណាំធញ្ញជាតិ (ជាពិសេសស្រូវ) តាមរយៈការប្រើប្រាស់ប្រភេទពូជនិងធាតុចូលដទៃទៀតឱ្យកាន់តែប្រសើរឡើង ការគ្រប់គ្រងជីនិងសត្វចង្រៃ និងការត្រួតពិនិត្យទឹកឱ្យបានល្អប្រសើរ ជាពិសេស តាមរយៈសំណង់ធារាសាស្ត្រខ្នាតតូច ។ ការបង្កើនផលិតកម្មបសុសត្វ និងនេសាទក៏សំខាន់ដែរ ហើយបញ្ហានេះតម្រូវឱ្យមានការកែលម្អសេវាកម្មបច្ចេកទេស សម្រាប់សុខភាពសត្វ សម្រាប់ការស្រាវជ្រាវអំពីជលផលនេសាទ អភិរក្ស និងការគ្រប់គ្រង ។ ការគាំទ្រ សម្រាប់ការពង្រីកលទ្ធភាពទទួលបានសេវាពីស្ថាប័នហិរញ្ញវត្ថុជនបទជាផ្លូវការ នឹងមានសារៈសំខាន់សម្រាប់កសិករ និងសហគ្រិននៅតំបន់ជនបទនានា ដើម្បីជួយឱ្យពួកគេពង្រីកកម្រិតប្រតិបត្តិការ និងទទួលបានប្រាក់ចំណេញច្រើននិងមានសកម្មភាពស្ថេរភាព ។ ដូចគ្នានេះដែរ ការកាត់បន្ថយបញ្ហាប្រឈមពីដីធ្លីនឹងទាមទារនូវការបង្កើនកិច្ចខិតខំប្រឹងប្រែងលើការផ្តល់កម្មសិទ្ធិដីធ្លី ដែលជាផ្នែកមួយនៃការបង្កើតនូវតម្លាភាព និងសុវត្ថិភាពទីផ្សារដីធ្លី ។

១៧. នៅកម្ពុជា សេដ្ឋកិច្ចជនបទមិនមែនកសិកម្មរួមមាន ពាណិជ្ជកម្ម ការដឹកជញ្ជូន ការកែច្នៃ កម្មន្តសាលខ្នាតតូច ការលក់រាយនិងសេវាកម្ម និងកត្តាប្រហាក់ប្រហែលផ្សេងទៀត គឺជាសក្តានុពលដ៏សំខាន់សម្រាប់កំណើនខ្លាំង និងការកាត់បន្ថយភាពក្រីក្រឆាប់រហ័ស ។ *ផយអជ* នឹងត្រូវកំណត់ដើមទុនសម្រាប់សក្តានុពលទាំង

---

[១] ទិន្នន័យអង្កេតសេដ្ឋកិច្ច-សង្គមកិច្ចបង្ហាញថា មេគុណហ្ស៊ីនីដែលត្រូវបានប៉ាន់ប្រមាណចំណាយប្រើប្រាស់ក្នុងម្នាក់សម្រាប់កម្ពុជានៅឆ្នាំ២០០៤ គឺ ០.៤០ ដោយមានកម្រិតខ្ពស់នៅតំបន់ទីប្រជុំជនដទៃទៀតគឺ ០.៤៤ នៅភ្នំពេញគឺ ០.៣៧ និងនៅតំបន់ជនបទគឺ ០.៣៤ បង្កើតនូវវិសមភាព[illegible]កម្ពុជា ក្នុងចំណោមបណ្តាប្រទេសដែលមានមេគុណនេះខ្ពស់បំផុតនៅភូមិភាគអាស៊ីបូព៌ា-ប៉ាស៊ីហ្វិក ។ សម្រាប់សំណាកគំរូប្រៀបធៀប[illegible] មេគុណហ្ស៊ីនីបានកើនឡើងពី ០.៣៥ ក្នុងឆ្នាំ១៩៩៣-១៩៩៤ ទៅ ០.៤០ ក្នុងឆ្នាំ២០០៤ សម្រាប់កម្ពុជា (មានការធ្លាក់ចុះពី ០.[illegible] ទៅ ០.[illegible] និងនៅស្ថិរតែថេរក្នុងកម្រិត ០.៤៤ នៅតំបន់ទីប្រជុំជនដទៃទៀត ប៉ុន្តែកើនឡើងខ្លាំងពី ០.៣៥ ទៅ ០.៤០ នៅតំបន់ជនបទ[illegible] ចំណូលមិនមាន គ្រប់គ្រាន់ទេ ប៉ុន្តែវិសមភាពចំណូលក៏មាន និន្នាការស្រដៀងគ្នាដែរ ។

អស់នេះ ។ គោលនយោបាយនានាបានតម្រង់ទៅរកការបង្កើនទ្រព្យរូបវន្តរបស់អ្នកក្រីក្រ ដូចជា ដី ឥណទាន និងហេដ្ឋារចនាសម្ព័ន្ធជនបទ នឹងក្លាយទៅជាផ្នែកទាំងមូលមួយនៃការជំរុញកំណើនដ៏ឆាប់រហ័សនៃ វិស័យជនបទ និងសេដ្ឋកិច្ចទាំងមូល ។

១៨. ដើម្បីធានានូវភាពជោគជ័យ និងនាំមកនូវលទ្ធផលយ៉ាងឆាប់រហ័យនិងប្រកបដោយប្រសិទ្ធភាព សកម្មភាពជាក់លាក់នានានៃ *ផយអជ* នឹងត្រូវបានរៀបចំឡើង ដោយឈរលើអ្វីដែលត្រូវបានសម្រេចកន្លងមក និងតាមរយៈការផ្លាស់ប្តូរការផ្តោតការយកចិត្តទុកដាក់ក្នុងការអនុវត្ត និងគោលនយោបាយទាំងអស់នេះនឹងធ្វើឱ្យផលចំណេញមានការកើនឡើងដល់អ្នកក្រីក្រនៅជនបទ ។ សកម្មភាពទាំងនេះក៏នឹងធានានូវសកម្មភាពមួយឆាប់រហ័សជាង និងប្រកបដោយចីរភាពថែមទៀត ឆ្ពោះទៅរកសមភាព និងយុត្តិធម៌ឱ្យកាន់តែប្រសើរឡើង ។

១៩. សមាសភាគដ៏សំខាន់របស់ *ផយអជ* នឹងធានាថា ជាមួយនឹងការអនុវត្តសេដ្ឋកិច្ចដែលមានកម្រិតខ្ពស់ជាងកំណើនត្រូវតែបានដល់អ្នកក្រីក្រ ហើយនិងបានពង្រីកកាលានុវត្តភាពរបស់ពួកគេ ។ ម៉្យាងវិញទៀត គោលនយោបាយនានានឹងត្រូវធានាថា អ្នកក្រីក្រមានធនធាន ពោលគឺមានការអប់រំ មានសុខភាពល្អ មានលទ្ធភាពទទួលបានដើមទុននិងទីផ្សារ សម្លេងនិងសិទ្ធិអំណាច និងការចូលរួមក្នុងការធ្វើសេចក្តីសម្រេចចិត្ត ក្នុងការប្រើប្រាស់ទុនលើការពង្រីកកាលានុវត្តភាពនៃកំណើន ។ ដូច្នេះ ការប្រែក្លាយយុទ្ធសាស្ត្រនៃ *ផយអជ* ទៅជាសកម្មភាពជាក់ស្តែងនិងមានប្រសិទ្ធភាពសម្រាប់ការកាត់បន្ថយភាពក្រីក្រ នឹងទាមទារឱ្យមានសេចក្តីសម្រេចចិត្ត និងប្រឹងប្រែងញាណ មិនគ្រាន់តែពីរាជរដ្ឋាភិបាលកម្ពុជានិងអ្នកមានចំណែកពាក់ព័ន្ធក្នុងស្រុកដទៃទៀតប៉ុណ្ណោះទេ តែក៏មានពីដៃគូអភិវឌ្ឍន៍ក្រៅប្រទេសផងដែរ ។

ឧបសម្ព័ន្ធ ៤
បញ្ជីឯកសារយោង

សមិទ្ធផលគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា ការកែតម្រូវសម្រាប់ឆ្នាំ២០០៥ (សេចក្តីព្រាង) ក្រសួងផែនការ ខែកញ្ញា ឆ្នាំ២០០៥ ។

ស្ថិតិកសិកម្ម ឆ្នាំ២០០៤-២០០៥ ក្រសួងកសិកម្ម ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០០៥ ។

កម្ពុជា : ស្ថិតិព្រៃឈើ ឆ្នាំ២០០៤ (រដ្ឋបាលព្រៃឈើ ក្រសួងកសិកម្ម រុក្ខាប្រម៉ាញ់ និងនេសាទ ខែឧសភា ឆ្នាំ២០០៥) ។

របាយការណ៍គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា ឆ្នាំ២០០៣ (ខែវិច្ឆិកា ឆ្នាំ២០០៣) ក្រសួងផែនការ ។

ការអង្កេតស្តីពីការវាយតម្លៃភាពក្រីក្រនៅកម្ពុជា ២០០៥ ។

កម្ពុជា : ការទទួលយកកាលានុវត្តភាពសកល : ការវាយតម្លៃបរិយាកាសវិនិយោគ និងយុទ្ធសាស្ត្រ កំណែទម្រង់ រៀបចំដោយក្រុមការងារធនាគារពិភពលោក ខែសីហា ឆ្នាំ២០០៤ ។

ការអង្កេតសេដ្ឋកិច្ច-សង្គមកិច្ចកម្ពុជា ឆ្នាំ២០០៣/០៤ ។

ក្របខ័ណ្ឌគ្រប់គ្រងកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ គណៈកម្មាធិការស្តារ និងអភិវឌ្ឍន៍កម្ពុជា/ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ខែតុលា ឆ្នាំ២០០៥ ។

ផែនការវិស័យហិរញ្ញវត្ថុ ឆ្នាំ២០០១-២០០៤ រាជរដ្ឋាភិបាលកម្ពុជា ខែសីហា ឆ្នាំ២០០១ ។

ផែនការសកម្មភាពអភិបាលកិច្ច ឆ្នាំ២០០១ ។

ការអនុវត្តន៍យុទ្ធសាស្ត្រចតុកោណនិងតម្រូវការជំនួយអភិវឌ្ឍន៍ : គណៈកម្មាធិការស្តារ និងអភិវឌ្ឍន៍កម្ពុជា/ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (រៀបចំសម្រាប់កិច្ចប្រជុំពិគ្រោះយោបល់ឆ្នាំ២០០៤) ។

សេរីភាពទូលំទូលាយ : ឆ្ពោះទៅការអភិវឌ្ឍ សន្តិសុខ និងសិទ្ធិមនុស្សសម្រាប់ទាំងអស់គ្នា : របាយការណ៍របស់អគ្គលេខាធិការអង្គការសហប្រជាជាតិសម្រាប់មហាសន្និបាតអង្គការសហប្រជាជាតិ ថ្ងៃទី២១ ខែមីនា ឆ្នាំ២០០៥ ។

គណនេយ្យជាតិកម្ពុជា ឆ្នាំ១៩៩៣-២០០៤ ព្រឹត្តិប័ត្រលេខ ៩ វិទ្យាស្ថានជាតិស្ថិតិ ខែមិថុនា ឆ្នាំ២០០៥ ។

យុទ្ធសាស្ត្រជាតិកាត់បន្ថយភាពក្រីក្រ : ឆ្នាំ២០០៣-២០០៥ ក្រុមប្រឹក្សាអភិវឌ្ឍន៍សង្គមកិច្ច រាជរដ្ឋាភិបាលកម្ពុជា ខែធ្នូ ឆ្នាំ២០០២ ។

យុទ្ធសាស្ត្រជាតិកាត់បន្ថយភាពក្រីក្រ : របាយការណ៍វឌ្ឍនភាព (ការកែតម្រូវ ថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៥ : ឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ ។

ចំណោលប្រជាជនកម្ពុជា ឆ្នាំ១៩៩៨-២០២០ : ការកែតម្រូវឡើងវិញលើកទីមួយ : វិទ្យាស្ថានជាតិស្ថិតិ ក្រសួងផែនការ និងមជ្ឈមណ្ឌលសិក្សាស្រាវជ្រាវពីប្រជាជន សកលវិទ្យាល័យភូមិន្ទភ្នំពេញ ខែមិថុនា ឆ្នាំ២០០៤ ។

ការវាយតម្លៃវិស័យឯកជនសម្រាប់ព្រះរាជាណាចក្រកម្ពុជា ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ខែធ្នូ ឆ្នាំ ២០០៣ ។

យុទ្ធសាស្ត្រចតុកោណ : សុន្ទរកថាសម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន ថ្លែងក្នុងសម័យប្រជុំគណៈរដ្ឋមន្ត្រី លើកទីមួយ ភ្នំពេញ ថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០០៤ (ផ្សព្វផ្សាយដោយទីស្តីការគណៈរដ្ឋមន្ត្រី) ។

ផែនការអភិវឌ្ឍន៍សេដ្ឋកិច្ច-សង្គមកិច្ច ៥ឆ្នាំលើកទី២ (២០០១-២០០៥) ក្រសួងផែនការ ។

ក្របខ័ណ្ឌអភិវឌ្ឍន៍សហគ្រាសធុនតូចនិងមធ្យម រាជរដ្ឋាភិបាលកម្ពុជា ថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០០៥ ។

កម្មវិធីអភិវឌ្ឍន៍អង្គការសហប្រជាជាតិ : របាយការណ៍អភិវឌ្ឍន៍មនុស្ស ឆ្នាំ២០០៥ ។

កម្មវិធីអភិវឌ្ឍន៍អង្គការសហប្រជាជាតិ : ការវិនិយោគរបស់កម្ពុជាក្នុងពេលអនាគត របាយការណ៍ប្រចាំ ឆ្នាំ ២០០៤ ។

ក្របខ័ណ្ឌជំនួយអភិវឌ្ឍន៍របស់អង្គការសហប្រជាជាតិ ឆ្នាំ២០០៦-២០១០ អ្នកសម្របសម្រួលរបស់អង្គការសហប្រជាជាតិប្រចាំនៅកម្ពុជាថ្ងៃទី៧ ខែមីនា ឆ្នាំ២០០៥ ។

រាជរដ្ឋាភិបាលកម្ពុជា : ក្របខ័ណ្ឌយុទ្ធសាស្ត្រស្តីពី កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ១៧មិថុនា ២០០៥ ។

ឧបសម្ព័ន្ធ ៥
ពាក្យអក្សរកាត់

កវិស	: កម្មវិធីវិនិយោគសាធារណៈ
កព	: កម្លាំងពលកម្ម
គអសក	: គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា
គម	: គីឡូម៉ែត្រ
គម^2	: គីឡូម៉ែត្រការ៉េ
គវម	: គីឡូវ៉ាត់ម៉ោង
ផយអជ	: ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ
ផសស	: ផលិតផលក្នុងស្រុកសរុប
ផសអ១	: ផែនការសកម្មភាពអភិបាលកិច្ច ១
ផសអ២	: ផែនការសកម្មភាពអភិបាលកិច្ច ២
ពក	: ពលកម្ម
ហត	: ហិកតា
វជស	: វិទ្យាស្ថានជាតិស្ថិតិ

ឧបសម្ព័ន្ធ ៦

ប្រកាស

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

****

ក្រសួងផែនការ

លេខ: ១១៩ ក្រ.ផក

ភ្នំពេញ, ថ្ងៃទី ០៤ ខែតុលា ឆ្នាំ ២០០៤

ប្រកាស
ស្តីពី
ការបង្កើតក្រុមការងាររៀបចំកសាងផែនការ
អភិវឌ្ឍន៍សេដ្ឋកិច្ច-សង្គមកិច្ច ៥ឆ្នាំ លើកទី៣ (២០០៦-២០១០)

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងផែនការ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងផែនការ
- បានឃើញអនុក្រឹត្យលេខ ៥៥ អនក្រ-បក ចុះថ្ងៃទី ២៣ ខែកញ្ញា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងផែនការ
- បានឃើញប្រកាសអន្តរក្រសួងមហាផ្ទៃ និងក្រសួងផែនការលេខ ០៩៨ ចុះថ្ងៃទី ៧ ខែកុម្ភៈ ឆ្នាំ២០០២ ស្តីពីការកសាងផែនការអភិវឌ្ឍន៍ ឃុំ-សង្កាត់
- យោងតាមសំណូមពរការងារចាំបាច់

សម្រេច

ប្រការ១ : បង្កើតក្រុមការងាររៀបចំកសាង ផែនការអភិវឌ្ឍន៍សេដ្ឋកិច្ច-សង្គមកិច្ច ៥ឆ្នាំ លើកទី ៣ (២០០៦-២០១០) នៅក្រសួងផែនការ។

ប្រការ២ : ក្រុមការងារនេះមានសមាសភាពដូចតទៅ:

១-លោក ទួន ថាវរៈ	អគ្គនាយកផែនការ ស្តីទី	ប្រធាន
២-លោកស្រី ហ៊ាង សៀកលី	អគ្គនាយករងផែនការ	អនុប្រធាន
៣-លោក នុត ចន្ទ័សុខា	អគ្គនាយករងផែនការ	អនុប្រធាន
៤-លោក សេង សឿន	នាយករងវិទ្យាស្ថានជាតិស្ថិតិ	អនុប្រធាន
៥-លោក ហ៊ីង ចន្ទ័មុន្នី	ប្រធាននាយកដ្ឋានផែនការវិនិយោគ	អនុប្រធាន
៦-លោក សួន សុឃីម	ប្រធាននាយកដ្ឋានទំនាក់ទំនងអន្តរជាតិ	សមាជិក
៧-លោក មឹម ម៉ារ៉ាឌី	ប្រធាននាយកដ្ឋានផែនការទូទៅ	សមាជិក

៨-លោកស្រី ខៀវ បូរី	ប្រធាននាយកដ្ឋានផែនការសង្គមកិច្ច	សមាជិក
៩-លោក សោម សេរីវុឌ្ឍន៍	ប្រធាននាយកដ្ឋានផែនការសេដ្ឋកិច្ច	សមាជិក
១០-លោក ហង្ស សុរិយា	អនុប្រធាននាយកដ្ឋានផែនការទូទៅ	សមាជិក
១១-លោក ប៊ូច សុវណ្ណឌី	អនុប្រធាននាយកដ្ឋានផែនការទូទៅ	សមាជិក
១២-លោក ជា ចាន់ទុំ	អនុប្រធាននាយកដ្ឋានផែនការទូទៅ	សមាជិក
១៣-លោក ផៃ បូរ	អនុប្រធាននាយកដ្ឋានផែនការទូទៅ	សមាជិក
១៤-លោក មាន ថាវរៈ	អនុប្រធាននាយកដ្ឋានផែនការទូទៅ	សមាជិក
១៥-លោក កែវ បុប្ផា	អនុប្រធាននាយកដ្ឋានផែនការទូទៅ	សមាជិក
១៦-លោក ស៊ិន សេដ្ឋា	អនុប្រធាននាយកដ្ឋានផែនការសង្គមកិច្ច	សមាជិក
១៧-លោក សាន សុខន	អនុប្រធាននាយកដ្ឋានផែនការសង្គមកិច្ច	សមាជិក
១៨-លោក មិត្ស សុវណ្ណ	អនុប្រធាននាយកដ្ឋានផែនការវិនិយោគ	សមាជិក
១៩-លោក ថេង បញ្ញាធន	អនុប្រធាននាយកដ្ឋានទំនាក់ទំនងអន្តរជាតិ	សមាជិក
២០-លោក ប៉ូ ម៉ៅ	អនុប្រធាននាយកដ្ឋានទំនាក់ទំនងអន្តរជាតិ	សមាជិក
២១-លោក ជឹង រដ្ឋា	អនុប្រធាននាយកដ្ឋានទំនាក់ទំនងអន្តរជាតិ	សមាជិក
២២-លោក ហួយ សិទ្ធិគុណ	អនុប្រធាននាយកដ្ឋានផែនការសេដ្ឋកិច្ច	សមាជិក
២៣-លោក ជួន នារិន	អនុប្រធាននាយកដ្ឋានផែនការសេដ្ឋកិច្ច	សមាជិក
២៤-លោក កង ស៊ីជាន់ណារ៉ា	ប្រធានការិយាល័យ ន.ដ្ឋានផែនការទូទៅ	សមាជិក
២៥-លោក ហ៊ែល គូនី	ប្រធានការិ.ន.ដ្ឋានផែនការវិនិយោគ	សមាជិក
២៦-លោក បិន ញាណរិទ្ធិ	ប្រធានការិ.ន.ដ្ឋានផែនការទូទៅ	សមាជិក

ប្រការ៣ : លោក ឱន ថាវរៈ ទទួលបន្ទុកដឹកនាំរួមក្នុងការងាររៀបចំកសាងផែនការ ៥ឆ្នាំលើកទី៣នេះ លោក លោកស្រី ជាអនុប្រធានទីមួយៗបំពេញកិច្ចការតាមភារៈកិច្ច ដែលប្រធានប្រគល់ជូន ។

ប្រការ៤ : ក្រុមការងារខាងលើនេះមានភារកិច្ចដូចតទៅ:

-រៀបចំរាល់លិខិតបទដ្ឋាន ឯកសារដែលពាក់ព័ន្ធដល់ការកសាងផែនការអភិវឌ្ឍន៍សេដ្ឋកិច្ច-សង្គមកិច្ច ៥ឆ្នាំ លើកទី៣

-ធ្វើជាដៃគូររួមធ្វើការងារជាមួយអ្នកជំនាញការនៃបណ្តាអង្គការអន្តរជាតិនានា ដែលមកជួយរៀបចំកសាង ផែនការអភិវឌ្ឍន៍សេដ្ឋកិច្ច-សង្គមកិច្ច ៥ឆ្នាំលើកទី៣

-ធ្វើការណែនាំផ្នែកបច្ចេកទេសដល់ក្រុមការងាររៀបចំកសាងផែនការអភិវឌ្ឍន៍សេដ្ឋកិច្ច-សង្គមកិច្ច ៥ឆ្នាំ លើកទី៣ (២០០៦-២០១០) នៅតាមបណ្តាក្រសួង និងស្ថាប័ន

-រៀបចំរាល់ការប្រជុំ និងសិក្ខាសាលានានា ក្នុងការរៀបចំកសាងផែនការអភិវឌ្ឍន៍សេដ្ឋកិច្ច-សង្គមកិច្ច ៥ឆ្នាំលើកទី៣

-រៀបចំសេចក្តីព្រាងផែនការអភិវឌ្ឍន៍សេដ្ឋកិច្ច-សង្គមកិច្ច ៥ឆ្នាំ លើកទី៣ ដាក់ជូនថ្នាក់ដឹកនាំក្រសួងផែនការ ពិនិត្យ និងដាក់ជូនបណ្តាសម័យប្រជុំអន្តរក្រសួង ស្ថាប័ន ពិនិត្យ មុននឹងបញ្ជូនទៅសុំការសំរេចពីគណៈរដ្ឋមន្ត្រី

-ធ្វើរបាយការណ៍ជារៀងរាល់សប្តាហ៍អំពីលទ្ធផលការងារ ជូនថ្នាក់ដឹកនាំក្រសួងផែនការ ។

ប្រការ៥ : ក្រុមការងារខាងលើនេះមានសិទ្ធិប្រើប្រាស់យន្តការនាយកដ្ឋាន ក្រោមឱវាទអគ្គនាយកដ្ឋានផែនការ និងវិទ្យាស្ថានជាតិស្ថិតិ និង គ្រប់អង្គភាពក្រោមឱវាទក្រសួងផែនការ ក្នុងករណីមានតម្រូវការ និង សំណូមពរចាំបាច់ក្នុងការងារ ។

ប្រការ៦ : ក្រុមការងារនេះគឺជាយន្តការសំរាប់ប្រើប្រាស់ នៅក្នុងការងារគាំទ្រ និងសំរបសំរួលដំណើរការកសាងផែនការអភិវឌ្ឍន៍ ឃុំ-សង្កាត់ និងកម្មវិធីវិនិយោគ ឃុំ-សង្កាត់ ខេត្ត-ក្រុង ៣ឆ្នាំរំកិលផងដែរ ។

ប្រការ៧ : សមាជិក សមាជិកានៃក្រុមការងារខាងលើនេះ ត្រូវចូលរួមប្រជុំការងារតាមការអញ្ជើញ និងដឹកនាំប្រជុំរបស់ ប្រធាន ឬអនុប្រធាន ក្នុងករណីអវត្តមានរបស់ប្រធាន ។

ប្រការ៨ : អស់លោក លោកស្រី ដែលមានរាយនាមក្នុងប្រការ២ខាងលើ និងគ្រប់ប្រធានអង្គភាព ក្រោមឱវាទក្រសួងផែនការ ត្រូវទទួលអនុវត្តតាមប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ឆាយ ថន

<u>ចម្លងជូន</u>

-ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ស ខេង
-ទីស្តីការគណៈរដ្ឋមន្ត្រី
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-គ្រប់ថ្នាក់ដឹកនាំ ក្រសួងផែនការ
-គ្រប់ក្រសួង-ស្ថាប័ន

"ដើម្បីជូនជ្រាបជាពត៌មាន"

-ដូចប្រការ៨ "ដើម្បីអនុវត្តន៍"
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
****

ក្រសួងផែនការ
លេខ: 0...៥៥៧...ផក

ភ្នំពេញ, ថ្ងៃទី១៧ ខែមិនា ឆ្នាំ ២០០៥

ប្រកាស
ស្តីពី
ការបង្កើតក្រុមការងារបច្ចេកទេសអន្តរស្ថាប័ន សំរាប់ការងាររៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ៥ ឆ្នាំលើកទីបី (២០០៦-២០១០)

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងផែនការ

- បានឃើញ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១១ ចុះថ្ងៃទី២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងផែនការ
- បានឃើញអនុក្រឹត្យលេខ ៥៥ អនក្រ.បក ចុះថ្ងៃទី២៣ ខែ កញ្ញា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងផែនការ
- បានឃើញ សារាចរលេខ ០១ សរ ចុះថ្ងៃទី ៣១ ខែ មករា ឆ្នាំ ២០០៥ ស្តីពីការរៀបចំកសាងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០០៦-២០១០
- យោងតាមសំណូមពរការងារចាំបាច់ ។

<u>សំរេច</u>

<u>ប្រការ ១</u> : បង្កើតក្រុមការងារបច្ចេកទេសអន្តរស្ថាប័ន (ហៅកាត់ថា ក្រ.ក.ប.អ [illegible] សំរាប់ការរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ៥ ឆ្នាំលើកទីបី (២០០៦-២០១០) ។

ប្រការ ២ : ក្រុមការងារបច្ចេកទេសអន្តរស្ថាប័ននេះ មានសមាសភាពដូចតទៅ :

១. ឯកឧត្តម អ៊ូ ឱហាត រដ្ឋលេខាធិការ ក្រសួងផែនការ ប្រធាន

២. ឯកឧត្តម ហ៊ុល លឹម រដ្ឋលេខាធិការ ក្រសួងផែនការ អនុប្រធាន

៣. ឯកឧត្តម ហង់ ជួន ណារ៉ុង អគ្គលេខាធិការ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជា អគ្គលេខាធិការឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ អនុប្រធាន

៤. ឯកឧត្តម ឆឹង ចំរើន រដ្ឋលេខាធិការ ក្រសួងផែនការ អនុប្រធាន

៥. ឯកឧត្តម ហ៊ូ តាំងអេង អនុរដ្ឋលេខាធិការ ក្រសួងផែនការ អនុប្រធានអចិន្ត្រៃយ៍

៦. ឯកឧត្តម ប្រាជ្ញ ស៊ុន រដ្ឋលេខាធិការ ក្រសួងបរិស្ថាន សមាជិក

៧. ឯកឧត្តម អេង ហ៊ួត រដ្ឋលេខាធិការ ក្រសួងសុខាភិបាល សមាជិក

៨. ឯកឧត្តម វេង សាខុន រដ្ឋលេខាធិការ ក្រសួងធនធានទឹក និងឧតុនិយម សមាជិក

៩. លោកជំទាវ ច័ន្ទ សូរិយ៍ រដ្ឋលេខាធិការ ក្រសួងកិច្ចការនារី សមាជិក

១០. ឯកឧត្តម ជា សុជារ៉ា រដ្ឋលេខាធិការ ក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ សមាជិក

១១. ឯកឧត្តម សួស គង់ រដ្ឋលេខាធិការ ក្រសួងអភិវឌ្ឍន៍ជនបទ សមាជិក

១២. ឯកឧត្តម សួង ហេង រដ្ឋលេខាធិការ ក្រសួងសាធារណការនិងដឹកជញ្ជូន សមាជិក

១៣. ឯកឧត្តម ភោគ សុវណ្ណរិទ្ធ រដ្ឋលេខាធិការ ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល សមាជិក

១៤. ឯកឧត្តម គឹម ស៊ីថន រដ្ឋលេខាធិការ ក្រសួងពាណិជ្ជកម្ម សមាជិក

១៥. ឯកឧត្តម សារ៉ាក់ ខាន់ រដ្ឋលេខាធិការ ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ សមាជិក

១៦. ឯកឧត្តម សយ ស៊ីផុន រដ្ឋលេខាធិការ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា សមាជិក

១៧. ឯកឧត្តម ជាច់ ផែន រដ្ឋលេខាធិការ ក្រសួងពត៌មាន សមាជិក

១៨. ឯកឧត្តម ទូត លុច រដ្ឋលេខាធិការ ក្រសួងយុត្តិធម៌ សមាជិក

១៩. ឯកឧត្តម ម៉ៅ សម្បត្តិ រដ្ឋលេខាធិការ ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច សមាជិក

២០. ឯកឧត្តម អ៊ិត ណូឌី អនុរដ្ឋលេខាធិការ ក្រសួងកសិកម្មរុក្ខាប្រមាញ់និងនេសាទ សមាជិក

២១. ឯកឧត្តម ណាត ប៊ុនធឿន អនុរដ្ឋលេខាធិការ ក្រសួងអប់រំ យុវជន និងកីឡា សមាជិក

២២. ឯកឧត្តម អ៊ុំ មាន អនុរដ្ឋលេខាធិការ ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ សមាជិក

៩

២៣. ឯកឧត្តម អៀម សារុំ	អនុរដ្ឋលេខាធិការ រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ	សមាជិក
២៤. ឯកឧត្តម ឆុង ទិន	អនុរដ្ឋលេខាធិការក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ	សមាជិក
២៥. ឯកឧត្តម យិន លូត	អនុរដ្ឋលេខាធិការ ក្រសួងធម្មការ និងកិច្ចការសាសនា	សមាជិក
២៦. ឯកឧត្តម ទា សុត្ថា	រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល	សមាជិក
២៧. ឯកឧត្តម រោង ឈុង	អគ្គលេខាធិការនៃគណៈកម្មាធិការជាតិប្រជាជននិងការអភិវឌ្ឍ	សមាជិក
២៨. ឯកឧត្តម ប៉ុន ណារិទ្ធិ	អគ្គលេខាធិការរងគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ	សមាជិក
២៩. ឯកឧត្តម ឡេង សុជា	អគ្គលេខាធិការរងអាជ្ញាធរកម្ពុជាគ្រប់គ្រងសកម្មភាពកំចាត់មីននិងសង្គ្រោះជនពិការដោយសារមីន	សមាជិក
៣០. តំណាងក្រសួងមហាផ្ទៃ		សមាជិក
៣១. លោក នាក់ សារិន	អនុប្រធាននាយកដ្ឋាន ធនាគារជាតិនៃកម្ពុជា	សមាជិក
៣២. លោកវេជ្ជ. តែង គន្ធី	អគ្គលេខាធិការរង អាជ្ញាធរប្រយុទ្ធនឹងជំងឺអេដស៍	សមាជិក
៣៣. ឯកឧត្តម ទូច ថាវរៈ	អគ្គនាយកផែនការ ក្រសួងផែនការ	លេខាធិការ

<u>ប្រការ ៣</u> : ក្រុមការងារបច្ចេកទេសអន្តរស្ថាប័ននេះ មានភារកិច្ចដូចតទៅ :

- ដឹកនាំ ណែនាំ អំពីទស្សនៈ យុទ្ធសាស្ត្រ កម្មវិធី និងគំរោងការងារ នៃផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ៥ឆ្នាំលើកទី៣(២០០៦-២០១០) ដល់ក្រុមការងាររៀបចំផែនការនៅ ក្រសួងផែនការ និងនៅបណ្តាក្រសួងស្ថាប័នពាក់ព័ន្ធ ។
- ទំនាក់ទំនង និងជាដៃគូការងារ ជាមួយសហគមន៍អ្នកផ្តល់ជំនួយ និងបណ្តាអង្គការមិនមែនរដ្ឋាភិបាល(NGOs) និងសង្គមស៊ីវិល ដើម្បីស្វែងរកការគាំទ្រទាំងថវិកា ទាំងបច្ចេកទេស សំរាប់ការកសាងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ៥ឆ្នាំ លើកទី៣ (២០០៦-២០១០) ។
- បូកសរុប និងធ្វើរបាយការណ៍អំពីលទ្ធផលការងារកសាងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ៥ឆ្នាំ លើកទី៣ (២០០៦-២០១០) ជូនក្រសួងផែនការ ។

<u>ប្រការ ៤</u> : ក្រុមការងារបច្ចេកទេសអន្តរស្ថាប័ននេះ មានក្រុមការងាររៀបចំកសាងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (២០០៦-២០១០) ដែលមានឯកឧត្តមអគ្គនាយកផែនការ នៃក្រសួងផែនការជាប្រធាន ជាសេនាធិការក្នុងដំណើរការការងាររបស់ខ្លួន ។

<u>ប្រការ ៥</u> : ក្រុមការងារបច្ចេកទេសអន្តរស្ថាប័ននេះ មានសិទ្ធអញ្ជើញតំណាងក្រសួងស្ថាប័ន ពាក់ព័ន្ធដទៃទៀតដែលមានការពាក់ព័ន្ធមករួមប្រជុំតាមការជាក់ស្តែង ។

<u>ប្រការ ៦</u> : ក្រុមការងារបច្ចេកទេសអន្តរស្ថាប័ននេះ មានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងផែនការ ក្នុងកិច្ចដំណើរការរបស់ខ្លួន ។

<u>ប្រការ ៧</u> : ប្រកាសនេះ មានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

<u>ប្រការ ៨</u> : ឯកឧត្តម លោកជំទាវ និងអស់លោក ដែលមានក្នុងប្រការ២ខាងលើ ត្រូវអនុវត្តប្រកាសនេះអោយមានប្រសិទ្ធភាព ។

<u>ប្រការ ៩</u> : រាល់លិខិតគតិយុត្តិដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍ ។

ឆាយ ថន

<u>ចម្លងជូន</u>
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យ ឯកឧត្តម សម្តេច ឧបនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័ន

"ដើម្បីជូនជ្រាប"
- ដូចប្រការ ២ "ដើម្បីអនុវត្ត"
- ឯកសារ — កាលប្បវត្តិ

លក្ខខ័ណ្ឌការងារ
ក្រុមការងារបច្ចេកទេសផែនការនិងការកាត់បន្ថយភាពក្រីក្រ

I. ប្រវត្តិដើម

១. ការកាត់បន្ថយភាពក្រីក្រ គឺជាការងារសំខាន់ក្នុងកម្មវិធីអភិវឌ្ឍន៍របស់រាជរដ្ឋាភិបាលកម្ពុជា។ ក្នុងទសវត្សកន្លងទៅ រាជរដ្ឋាភិបាលបានចាត់វិធានការក្នុងស្មារតីទទួលខុសត្រូវ ដើម្បីកំណត់អោយបានច្បាស់លាស់នូវវិធីសាស្ត្រក្នុងការកាត់បន្ថយភាពក្រីក្រ តាមរយៈឯកសារគោលនយោបាយជាច្រើន ដែលរួមមាន **ផែនការអភិវឌ្ឍន៍សេដ្ឋកិច្ច-សង្គមកិច្ចប្រាំឆ្នាំលើកទី១ (១៩៩៦-២០០០) និង ទី២ (២០០១-២០០៥)** និង **យុទ្ធសាស្ត្រជាតិកាត់បន្ថយភាពក្រីក្រ (២០០៣-២០០៥)** ។ អាទិភាពនិងយុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្ររបស់រាជរដ្ឋាភិបាល ត្រូវបានពង្រីកបន្ថែមតាមរយៈ **គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា** ដែលត្រូវបានកំណត់និងឯកភាពគ្នា នៅក្នុងឆ្នាំ ២០០៣ ។

២. រាជរដ្ឋាភិបាលកម្ពុជា បានសំរេចធ្វើការរៀបចំផែនការអភិវឌ្ឍន៍ជាតិតែមួយគត់ ដោយធ្វើការបញ្ចូលគ្នានូវផែនការអភិវឌ្ឍន៍សេដ្ឋកិច្ច-សង្គមកិច្ច៥ឆ្នាំនិងយុទ្ធសាស្ត្រជាតិកាត់បន្ថយភាពក្រីក្រ ដោយ ផ្សារភ្ជាប់ទៅនឹងគោលដៅអភិវឌ្ឍន៍សហស្សវត្សកម្ពុជា ដើម្បីអោយមានភាពស៊ីសង្វាក់គ្នាក្នុងការរៀបចំ និង ការអនុវត្តយុទ្ធសាស្ត្រនិងគោលនយោបាយអភិវឌ្ឍន៍ ។ ឯកសារនេះ មានឈ្មោះថា ***ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (ផយអជ) ២០០៦-២០១០*** គឺជាឯកសារគោលនយោបាយយុទ្ធសាស្ត្រ សំរាប់ការអនុវត្តទស្សនៈវិស័យអភិវឌ្ឍន៍របស់រាជរដ្ឋាភិបាល ដែលបានកំណត់យ៉ាងច្បាស់ក្នុង ***យុទ្ធសាស្ត្រចតុកោណ ដើម្បី កំណើន ការងារ សមធម៌ និង ប្រសិទ្ធភាព*** និងក្នុងកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាលអាណត្តិទី៣នៃរដ្ឋសភា (២០០៤-២០០៨)។ **ផយអជ** ក៏ជាឯកសារយុទ្ធសាស្ត្រដើម្បីបញ្ចូល **គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា** និង **គោលនយោបាយជាតិប្រជាជន** ទៅក្នុងក្របខ័ណ្ឌផែនការអភិវឌ្ឍន៍រយៈពេលមធ្យមផងដែរ ។

៣. **ក្រុមការងារបច្ចេកទេសទី១៨ សំរាប់ការងារផែនការនិងការកាត់បន្ថយភាពក្រីក្រ** ត្រូវបានបង្កើតឡើងជាយន្តការសំរាប់ការពិគ្រោះយោបល់និងការសំរបសំរួល ដើម្បីផ្តល់ការគាំទ្រដល់ការរៀបចំកសាងការអនុវត្តនិងការពិនិត្យតាមដាន **ផយអជ**។

៤. ក្រុមការងារបច្ចេកទេសសំរាប់ការងារផែនការនិងការកាត់បន្ថយភាពក្រីក្រ ត្រូវដឹកនាំដោយក្រសួងផែនការ ដែលដើរតួនាទីជាស្ថាប័នបង្គោល សំរាប់បញ្ចូលការកាត់បន្ថយភាពក្រីក្រ ជាមួយនឹងក្របខ័ណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ចនិងតាមវិស័យ ដំណើរការរៀបចំផែនការ រួមទាំង កម្មវិធីវិនិយោគសាធារណៈ ស៊ាំម៉ឺនសំរបសំរួលរួមគ្នា ខាងភ្នាក់ងារផ្តល់ជំនួយ គឺធនាគារពិភពលោកនិងប្រព័ន្ធសហប្រជាជាតិ ។

II. អាណត្តិរបស់ក្រុមការងារបច្ចេកទេសសំរាប់រៀបចំផែនការនិងការកាត់បន្ថយភាពក្រីក្រ

ទិសដៅរួមរបស់ក្រុមការងារបច្ចេកទេសសំរាប់រៀបចំផែនការ និងការកាត់បន្ថយភាពក្រីក្រ គឺដើម្បីគាំទ្ររាជរដ្ឋាភិបាល ក្នុងការជំរុញដំណើរការរៀបចំផែនការឱ្យកាន់តែមានប្រសិទ្ធភាព ដើម្បីសំរេចបានគោលដៅទាំងឡាយក្នុងការកាត់បន្ថយភាពក្រីក្រ ដែលបានកំណត់នៅក្នុងក្របខ័ណ្ឌនៃសេចក្តីប្រកាសសហស្សវត្សរ៍ និងគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា ។

បើពិនិត្យតាមចរិតអន្តរវិស័យនៃសកម្មភាពរបស់ខ្លួន ក្រុមការងារបច្ចេកទេសសំរាប់រៀបចំផែនការនិងការកាត់បន្ថយភាពក្រីក្រ នឹងធ្វើការសំរបសំរួលយ៉ាងជិតស្និទ្ធជាមួយក្រុមការងារផ្សេងៗ និងស្ថាប័នពាក់ព័ន្ធ ។

ស្របតាមការសំរេចនៃការប្រជុំក្រុមពិគ្រោះយោបល់ខែធ្នូ ឆ្នាំ២០០៤ ក្រុមការងារបច្ចេកទេស គឺជាស្ថាប័នឯករាជ្យដែលឧបត្ថម្ភគាំទ្រដោយ និងរួមចំណែកក្នុងយន្តការទាំងឡាយរបស់ក្រុមពិគ្រោះយោបល់ ។ ដូច្នេះ ក្រុមការងារនេះ នឹងត្រូវណែនាំដោយគោលការណ៍នៃការធានាការប្រើប្រាស់នូវធនធានដ៏ស្តួចស្តើងប្រកបដោយប្រសិទ្ធភាពតាមរយៈការជំរុញការសំរបសំរួល និងការកំណត់អាទិភាពប្រកបដោយប្រសិទ្ធភាព ។

III. ការទទួលខុសត្រូវ

- ផ្តល់វេទិកាមួយ ដើម្បីឈានទៅសំរេចបាន និងធានាឱ្យមានភាពរឹងមាំនៃ ការឯកភាពគ្នាលើអាទិភាពក្នុងការអភិវឌ្ឍន៍ជាតិ ដែលទាក់ទងនឹងគោលដៅទាំងឡាយក្នុងការកាត់បន្ថយភាពក្រីក្រ និងធានាឱ្យមានចំណងទាក់ទងរវាងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ នឹងគោលដៅទាំងនោះ ។
- កំណត់ពីតំរូវការសំរាប់ការរៀបចំកសាង ការអនុវត្ត និងការតាមដានផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ សំរបសំរួលការផ្តល់ធនធានសមស្រប ទាំងធនធានក្នុងស្រុកនិង ODA ដើម្បីដោះស្រាយនូវបញ្ហាទាំងនោះ ។
- ធានាការសំរបសំរួលនូវយុទ្ធសាស្ត្រតាមវិស័យ និងយុទ្ធសាស្ត្ររបស់អ្នកផ្តល់ជំនួយ ជាមួយនឹងបណ្តាអាទិភាពដែលបានឯកភាពគ្នារួចហើយ ដោយធ្វើការកំណត់និងសំរបសំរួល នូវចំណងទាក់ទងគ្នានិងការបំពេញគ្នាទៅវិញទៅមក រវាងសកម្មភាពទាំងឡាយ និងដោយធ្វើការជំរុញឱ្យមានវិធីសាស្ត្រជាយុទ្ធសាស្ត្រ សំរាប់ការអភិវឌ្ឍទូទាំងវិស័យ ។
- ដើរតួនាទីជាវេទិកាសំរាប់ផ្តល់និងផ្លាស់ប្តូរពត៌មាន សំរាប់អ្នករួមចំណែកទាំងអស់ ទាំងជាតិនិងអន្តរជាតិ ទាំងផ្នែករដ្ឋាភិបាលនិងមិនមែនរដ្ឋាភិបាល ។

IV. ការរៀបចំផ្នែកស្ថាប័ននិងផ្នែកប្រតិបត្តិការ

១. ក្រុមការងារបច្ចេកទេសសំរាប់រៀបចំផែនការនិងការកាត់បន្ថយភាពក្រីក្រ មានតំណាងក្រសួងផែនការ និងក្រសួង-ស្ថាប័នពាក់ព័ន្ធសំខាន់ៗរបស់រាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ រួមទាំងសង្គមស៊ីវិលផងដែរ ។

២. ក្រុមការងារបច្ចេកទេសសំរាប់រៀបចំផែនការនិងការកាត់បន្ថយភាពក្រីក្រ នឹងប្រតិបត្តិការលើមូលដ្ឋាននៃផែនការសកម្មភាពប្រចាំឆ្នាំ ជាមួយសមាជិកទាំងអស់ ដោយគិតដល់ការទទួលខុសត្រូវរួមគ្នា ក្នុងការអនុវត្តការងារតាមផែនការសកម្មភាព ។

៣. លេខាធិការដ្ឋានរបស់ក្រុមការងារស្ថិតនៅក្នុងក្រសួងផែនការ ត្រូវទទួលខុសត្រូវជារួម ក្នុងការសំរបសំរួលនិងការរៀបចំកសាងផែនការអភិវឌ្ឍន៍យុទ្ធសាស្ត្រជាតិ ដោយមានកិច្ចសហការជាមួយក្រុមការងារតាមក្រសួង-ស្ថាប័នពាក់ព័ន្ធ និងក្រុមការងារអ្នកផ្តល់ជំនួយ (សូមមើលដ្យាក្រាមភ្ជាប់ជាមួយ: *ក្របខ័ណ្ឌស្ថាប័នសំរាប់រៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ* ។ ប្រធាននៃលេខាធិការដ្ឋាននេះ ត្រូវរាយការណ៍ជូនក្រុមការងារបច្ចេកទេសសំរាប់រៀបចំផែនការនិងការកាត់បន្ថយភាពក្រីក្រ ស្តីពីការរីកចំរើនដែលបានធ្វើ ។

៤. ប្រសិនបើមានការចាំបាច់ ក្រុមការងារបច្ចេកទេសសំរាប់រៀបចំផែនការនិងការកាត់បន្ថយភាពក្រីក្រ អាចបង្កើតអនុក្រុមតាមការងារតាមប្រធានបទដោយឡែកៗ ដោយមានសមាជិក ដែលមានការយល់ព្រមទាំងសងខាង ។

៥. ក្រុមការងារបច្ចេកទេសសំរាប់រៀបចំផែនការនិងការកាត់បន្ថយភាពក្រីក្រ នឹងជួបប្រជុំជាប្រចាំ (រវាងពី ៤-៦ សប្តាហ៍ម្តង) ប្រសិនបើមានការចាំបាច់ ការប្រជុំអាចធ្វើក្នុងកំឡុងពេលចាប់ផ្តើម ដើម្បីគាំទ្រដល់ដំណើរការនៃការកសាង **ផយអជ** ដែលមានកំណត់ជាក់លាក់ ។ ការប្រជុំ ដែលនឹងត្រូវរៀបចំឡើង ដោយភ្ជាប់ជាមួយនឹងរបៀបវារៈនិងកំណត់ហេតុនៃការប្រជុំ នឹងត្រូវជូនដំណឹងទៅសមាជិកទាំងអស់ ។

៦. លក្ខខ័ណ្ឌការងាររបស់ក្រុមការងារបច្ចេកទេសសំរាប់រៀបចំផែនការនិងការកាត់បន្ថយភាពក្រីក្រ អាចកែប្រែដោយផ្អែកលើសំណើរបស់សមាជិក ដើម្បីឆ្លុះបញ្ចាំងពីភារកិច្ចអាទិភាពដែលត្រូវផ្លាស់ប្តូរឬបន្ថែម ដែលត្រូវបានចាត់ទុកថាចាំបាច់ដើម្បីសំរេចបាននូវទិសដៅរបស់ខ្លួន ។

ឧបសម្ព័ន្ធទី១

សមាជិក

សមាជិកទាំងប៉ុន្មានខាងក្រោមនេះ ត្រូវបានចាត់តាំងដោយស្ថាប័នសាមីរបស់គេ ដើម្បីចូលរួមក្រុមការងារបច្ចេកទេសសំរាប់រៀបចំផែនការនិងការកាត់បន្ថយភាពក្រីក្រ:

ក. ភាគីរដ្ឋាភិបាល:

ល.រ	ឈ្មោះ	មុខងារ និងស្ថាប័ន	
១	ឯកឧត្តម អ៊ូ ឱហាត	រដ្ឋលេខាធិការក្រសួងផែនការ	ប្រធាន
២	ឯកឧត្តម ហ៊ុល លីម	រដ្ឋលេខាធិការក្រសួងផែនការ	អនុប្រធាន
៣	ឯកឧត្តម ហង់ ជូន ណារ៉ុន	អគ្គលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាអគ្គលេខាធិការឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ	អនុប្រធាន
៤	ឯកឧត្តម ឆឹង ចំរើន	រដ្ឋលេខាធិការក្រសួងផែនការ	អនុប្រធាន
៥	ឯកឧត្តម ហ៊ូ តាំងអេង	អនុរដ្ឋលេខាធិការក្រសួងផែនការ	អនុប្រធានអចិន្ត្រៃយ៍
៦	ឯកឧត្តម ប្រាជ្ញ ស៊ុន	រដ្ឋលេខាធិការក្រសួងបរិស្ថាន	សមាជិក
៧	ឯកឧត្តម អេង ហ៊ួត	រដ្ឋលេខាធិការក្រសួងសុខាភិបាល	សមាជិក
៨	ឯកឧត្តម វេង សាខុន	រដ្ឋលេខាធិការក្រសួងធនធានទឹក និងឧតុនិយម	សមាជិក
៩	លោកជំទាវ ច័ន្ទ សូរីយ៍	រដ្ឋលេខាធិការក្រសួងកិច្ចការនារី	សមាជិក
១០	ឯកឧត្តម ជា សុផារ៉ា	រដ្ឋលេខាធិការក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់	សមាជិក
១១	ឯកឧត្តម សូស គង់	រដ្ឋលេខាធិការក្រសួងអភិវឌ្ឍន៍ជនបទ	សមាជិក
១២	ឯកឧត្តម សួង ហេង	រដ្ឋលេខាធិការក្រសួងសាធារណការ និងដឹកជញ្ជូន	សមាជិក
១៣	ឯកឧត្តម ភោគ សុវណ្ណរិទ្ធ	រដ្ឋលេខាធិការក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល	សមាជិក
១៤	ឯកឧត្តម គឹម ស៊ីថន	រដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម	សមាជិក
១៥	ឯកឧត្តម សារ៉ាក់ ខាន់	រដ្ឋលេខាធិការក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍	សមាជិក
១៦	ឯកឧត្តម សយ ស៊ីផុន	រដ្ឋលេខាធិការក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា	សមាជិក
១៧	ឯកឧត្តម ថាច់ ផែន	រដ្ឋលេខាធិការក្រសួងពត៌មាន	សមាជិក
១៨	ឯកឧត្តម ទូត លុច	រដ្ឋលេខាធិការក្រសួងយុត្តិធម៌	សមាជិក
១៩	ឯកឧត្តម ម៉ៅ សម្បត្តិ	រដ្ឋលេខាធិការក្រសួងទំនាក់ទំនងរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច	សមាជិក
២០	ឯកឧត្តម អ៊ិន ស៊ីយ៉ុន្ធា	រដ្ឋលេខាធិការក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ	សមាជិក
២១	ឯកឧត្តម អ៊ិត ណូឌី	អនុរដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ	សមាជិក

២២	ឯកឧត្តម ណាត ប៊ុនរឿន	អនុរដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា	សមាជិក
២៣	ឯកឧត្តម អ៊ុំ មាន	អនុរដ្ឋលេខាធិការក្រសួងការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ	សមាជិក
២៤	ឯកឧត្តម អៀម សារុំ	អនុរដ្ឋលេខាធិការ រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ	សមាជិក
២៥	ឯកឧត្តម អ៊ុង ទិន	អនុរដ្ឋលេខាធិការក្រសួងកាបរទេស និងសហប្រតិបត្តិការអន្តរជាតិ	សមាជិក
២៦	ឯកឧត្តម យិន លួត	អនុរដ្ឋលេខាធិការក្រសួងធម្មការ និងកិច្ចការសាសនា	សមាជិក
២៧	ឯកឧត្តម ទា សុត្ថា	រដ្ឋលេខាធិការដ្ឋាន អាកាសចរស៊ីវិល	សមាជិក
២៨	ឯកឧត្តម រោង ឈង	អគ្គលេខាធិការគណៈកម្មាធិការជាតិប្រជាជននិងការអភិវឌ្ឍ	សមាជិក
២៩	ឯកឧត្តម ប៉ុន ណារិទ្ធី	អគ្គលេខាធិការរងគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ	សមាជិក
៣០	ឯកឧត្តម ឡេង សុជា	អគ្គលេខាធិការរងបច្ចេកទេស អាជ្ញាធរកម្ពុជាគ្រប់គ្រងសកម្មភាពកំចាត់មីន និងសង្គ្រោះជនពិការដោយសារមីន	សមាជិក
៣១		ក្រសួងមហាផ្ទៃ	សមាជិក
៣២	លោក នាក់ សារិន	អនុប្រធាននាយកដ្ឋានធនាគារជាតិនៃកម្ពុជា	សមាជិក
៣៣	លោកវេជ្ជ. តែង គន្ធី	អគ្គលេខាធិការរងអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍	សមាជិក
៣៤		<u>ក្រសួងទេសចរណ៍</u>	សមាជិក
៣៥		<u>អគ្គលេខាធិការក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល</u>	សមាជិក
៣៦		<u>ក្រុមប្រឹក្សាអភិវឌ្ឍន៍កសិកម្ម និងជនបទ</u>	សមាជិក
៣៧		<u>គណៈកម្មាធិការជាតិទន្លេមេគង្គ</u>	សមាជិក
៣៨	<u>លោក រិត វុទ្ធី</u>	<u>ប្រធាននាយកដ្ឋានសំរបសំរួលជំនួយអឺរ៉ុប និងសហគមន៍អឺរ៉ុប គ.ជ.នា/គ.អ.គ</u>	សមាជិក
៣៩	<u>លោក ណាង សុធី</u>	<u>សមាជិកសភាពាណិជ្ជកម្មរាជធានីភ្នំពេញ</u>	សមាជិក
៤០	ឯកឧត្តម ទូន ថាវរៈ	អគ្គនាយកផែនការ ក្រសួងផែនការ	លេខាធិការ

<u>ចំណាំ</u>: *ឈ្មោះ និងស្ថាប័នដែលមានគូសបន្ទាត់ពីក្រោម គឺជាសមាជិកថ្មី*

ខ. បណ្តាដៃគូអភិវឌ្ឍន៍

ខ១. អ្នកសំរបសំរួលរួមរបស់ស្ថាប័នផ្តល់ជំនួយ

1. Ms. Nisha Agrawal, Country Manager, World Bank Cambodia Country Office
2. Mr. Douglas Gardner, UN Resident Coordinator, UNDP Resident Representative

ខ២. សមាជិកពីស្ថាប័នផ្តល់ជំនួយ

ស្ថាប័ន ទ្វេភាគី និង ពហុភាគី

1. Ms. Nisha Agrawal, WB, co-facilitator
2. Mr. Douglas Gardner, UN System, co-facilitator
3. Ms. Bettina Maas, UNFPA
4. Mr. Shyam Bajpai, ADB
5. Mr. Daniel Costa Llobet, Delegation of the European Commission
6. Mr. Robert Hagemann, IMF
7. Mr. Mogens Laumand Christensen, DANIDA
8. Ms. Fleur Davies/ Mr. Stephen Close, AusAID
9. Mr. Peter Kaufmann, GTZ
10. Mr. Juro Chikaraishi, JICA
11. Ms. Helen Appleton, DFID
12. Ms. Karla Quizon, MPDF/IFC
13. Ms. Johnathon Addleton, USAID
14. Mr. Claes Leijon, SIDA

អង្គការមិនមែនរដ្ឋាភិបាល និងសង្គមស៊ីវិល

15. Mr Russell Peterson, NGOF
16. Ms Carol Strickler, CCC
17. Mr Larry Strange, CDRI
18. Dr Sin Somony, MEDICAM
19. Ms. Chea Vannnath, CSD
20. Mr Kim Dara, NEP
21. Mr Thun Saray, ADHOC, Cambow, CHRAC
22. Ms Ros Sopheap, GADC
23. Mr Hean Sokhom, CAS
24. Mr Sok Hach, EIC

ព្រះរាជក្រម

នស/រកម/០៦០៦/០១៩

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

-បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ

-បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា និងរបស់ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

ប្រកាសឱ្យប្រើ

ច្បាប់ស្តីពីវិសោធនកម្មមាត្រា១៣ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី ២៥ ខែ ឧសភា ឆ្នាំ ២០០៦ នាសម័យប្រជុំរដ្ឋសភាលើកទី ៤ នីតិកាលទី ៣ និងដែលព្រឹទ្ធសភាបានពិនិត្យ និងឱ្យយោបល់យល់ស្របលើទម្រង់ និងគតិច្បាប់ព្រមទាំងលើខ្លឹមសារនៃអត្ថបទច្បាប់នេះទាំងស្រុងដោយគ្មានការកែប្រែ កាលពីថ្ងៃទី ០៩ ខែមិថុនា ឆ្នាំ ២០០៦ នាសម័យប្រជុំពេញអង្គលើកទី១ នីតិកាលទី ២ ហើយដែលក្រុមប្រឹក្សាធម្មនុញ្ញប្រកាសថាស្របនឹងរដ្ឋធម្មនុញ្ញតាមរយៈសេចក្តីសម្រេចលេខ ០៧៩/០០៦/ ២០០៦ កបធ.ច ចុះថ្ងៃទី ១៦ ខែមិថុនា ឆ្នាំ ២០០៦ ហើយដែលមានសេចក្តីទាំងស្រុង ដូចតទៅនេះ :

ច្បាប់
ស្តីពី
វិសោធនកម្មមាត្រា ១៣ ថ្មី នៃច្បាប់ស្តីពីវិសោធនកម្ម ច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ

មាត្រាមួយ.—

ត្រូវបានកែប្រែមាត្រា ១៣ ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៩០២/០១៧ ចុះថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ២០០២ ដូចខាងក្រោម :

មាត្រា ១៣ថ្មី (ពីរ) .—

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតមានសមាសភាពដូចតទៅ :

- ឥស្សរជនខ្មែរមួយរូប ប្រធាន
- ឥស្សរជនខ្មែរមួយរូប អនុប្រធាន
- ឥស្សរជនខ្មែរប្រាំពីររូប សមាជិក

ប្រធាន អនុប្រធាន និងសមាជិកនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវជ្រើសរើសក្នុងចំណោមឥស្សរជនដែលមានសមត្ថភាពខាងនយោបាយ បទពិសោធន៍ក្នុងការងារ និងមានកេរ្តិ៍ឈ្មោះល្អ ។

ប្រធាន អនុប្រធាន និងសមាជិកនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវបានតែងតាំងដោយព្រះរាជក្រឹត្យយ៉ាងតិចប្រាំពីរ (៧) ខែ មុនថ្ងៃបោះឆ្នោត តាមសំណើរបស់គណៈរដ្ឋមន្ត្រី ក្រោយពីបានទទួលការយល់ព្រមពីរដ្ឋសភា តាមមតិភាគច្រើនដាច់ខាតនៃសមាជិករដ្ឋសភាទាំងមូល ។

/.

ប្រធាន អនុប្រធាន និងសមាជិកនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវធ្វើសច្ចាប្រណិធានមុនចូលកាន់តំណែង ។

រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ មានភារកិច្ចដាក់ជូនគណៈរដ្ឋមន្ត្រីនូវសេចក្តីព្រាងសមាសភាពនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត យ៉ាងតិចប្រាំបួន (៩) ខែ មុនថ្ងៃ បោះឆ្នោត ។

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតមានសិទ្ធិជ្រើសរើសបុគ្គលិកតាមការចាំបាច់សម្រាប់ដំណើរការបោះឆ្នោត និងមានអគ្គលេខាធិការដ្ឋានមួយជាជំនួយការ ។

មាត្រាពីរ.-

ច្បាប់នេះត្រូវបានប្រកាសជាការប្រញាប់ ។

ធ្វើនៅព្រះបរមរាជវាំងរាជធានីភ្នំពេញថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ ២០០៦

ពាល.០៦០៦.២៩៣ **ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

នរោត្តម សីហមុនី

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

នាយករដ្ឋមន្ត្រី

ហត្ថលេខា

ហ៊ុន សែន

បានជម្រាបជូនសម្តេចនាយករដ្ឋមន្ត្រី

ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

ហត្ថលេខា

ស ខេង

លេខ: ២៧៤២ច.ល

...ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែ មិថុនា ឆ្នាំ២០០៦

អគ្គលេខាធិការរងទីស្តីការរដ្ឋាភិបាល

ឃុន ជិនកេន

នស/រកត/០៦០៦/២៧៩

ព្រះរាជក្រឹត្យ

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៨០១/១២ ចុះថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្ម ដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១០០៤/០០៦ ចុះថ្ងៃទី ២៧ ខែ តុលា ឆ្នាំ ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតឱ្យមានសាលាក្តីកាត់សេចក្តីឧក្រិដ្ឋកម្ម ដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៥០៦/២១៤ ចុះថ្ងៃទី ៧ ខែ ឧសភា ឆ្នាំ ២០០៦ ស្តីពីការតែងតាំងសមាសភាពចៅក្រមសាលាដំបូង តុលាការកំពូល សហចៅក្រមស៊ើបអង្កេត សហព្រះរាជអាជ្ញា និងអង្គបុរេជំនុំជម្រះនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្ម ដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា និងដោយផ្អែកតាមសំណើរបស់សហព្រះរាជអាជ្ញានៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

ត្រាស់បង្គាប់

មាត្រា១ : ត្រូវបានតែងតាំងលោក **យ៉េត ចរិយា** បច្ចុប្បន្នព្រះរាជអាជ្ញារងនៃអយ្យការអមតុលាការខេត្តបន្ទាយមានជ័យ ជាព្រះរាជអាជ្ញារងនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។

មាត្រា២ : បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា៣ : ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម និងសម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចតាមព្រះរាជក្រឹត្យនេះ។

មាត្រា៤ : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣រល.០៦០៦-២៩៩

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ មិថុនា ឆ្នាំ ២០០៦

លេខ : ២៧៣៤ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ២០០៦
អគ្គលេខាធិការរងទីស្តីការគណៈរដ្ឋមន្ត្រី

ឃុន ជិនកេន

នស/រកត/០៦០៦/២៨០

ព្រះរាជក្រឹត្យ

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

(យោងតាមសេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រី នៃ រាជរដ្ឋាភិបាលកម្ពុជា)

ប្រោសព្រះរាជទាន

ចំពោះ

ឯកឧត្តម បណ្ឌិត **ចំន្ទ សារុន**

នូវ

គ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេនា

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

ព្រ.ស-០៦០៦-៣០០

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ២៩ ខែ មិថុនា ឆ្នាំ ២០០៦

លេខ: ៦៤៧ ស.ជ.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ, ថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ២០០៦
អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល

ស៊ុន ជិនភេន

នស/រកត/០៧០៦/២៨២

ព្រះរាជក្រឹត្យ

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ នៃ គណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រី នៃ រាជរដ្ឋាភិបាលកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : ត្រូវបានទទួលការប្រោសប្រទាននូវ គ្រឿងឥស្សរិយយស **មេដាយការពារជាតិ** តាមលំដាប់ថ្នាក់ ជូនមន្ត្រីពន្ធនាគារ នៃក្រសួងមហាផ្ទៃ ចំនួន ១២៩ រូប ដែលមានស្នាដៃល្អ និងស្មារតីទទួលខុសត្រូវខ្ពស់ ក្នុងការបំពេញភារកិច្ចបំរើជាតិមាតុភូមិ ដូចមានរាយនាមខាងក្រោម :-

ក- ***មេដាយការពារជាតិ*** ថ្នាក់មាស ០២ គ្រឿង ប្រាក់ ០២ គ្រឿង និងសំរិទ្ធ ០២ គ្រឿង

១-លោក	គុយ ប៊ុនសន	ប្រធាននាយកដ្ឋានពន្ធនាគារ

ខ- ***មេដាយការពារជាតិ*** ថ្នាក់មាស ០១ គ្រឿង ប្រាក់ ០២ គ្រឿង និងសំរិទ្ធ ០១ គ្រឿង

១-លោក	ជិន លី	អនុប្រធាននាយកដ្ឋានពន្ធនាគារ
២-លោក	ឃាក់ វ៉ាត	អនុប្រធាននាយកដ្ឋានពន្ធនាគារ
៣-លោក	ម៉ាន់ ហាំ	អនុប្រធាននាយកដ្ឋានពន្ធនាគារ
៤-លោក	ហ៊ុយ ឧក	អនុប្រធាននាយកដ្ឋានពន្ធនាគារ

គ- ***មេដាយការពារជាតិ*** ថ្នាក់មាស ០១ គ្រឿង ប្រាក់ ០១ គ្រឿង និងសំរិទ្ធ ០២ គ្រឿង

១-លោក	ឧខ តាប៊ូរ៉ា	ប្រធានការិយាល័យ នៃនាយកដ្ឋានពន្ធនាគារ
២-លោក	ម៉ៅ ណាំ	ប្រធានការិយាល័យ នៃនាយកដ្ឋានពន្ធនាគារ
៣-លោក	សាច នី	ប្រធានការិយាល័យ នៃនាយកដ្ឋានពន្ធនាគារ
៤-លោកស្រី	សោម សួតាំ	ប្រធានការិយាល័យ នៃនាយកដ្ឋានពន្ធនាគារ

៥-លោក	គីម សារិន	ប្រធានមណ្ឌលអប់រំកែប្រែទី ១ នាយកដ្ឋានពន្ធនាគារ
៦-លោក	គីម ជួន	ប្រធានមណ្ឌលអប់រំកែប្រែទី ២ នាយកដ្ឋានពន្ធនាគារ
៧-លោក	គៀ សុវណ្ណា	ប្រធានមណ្ឌលអប់រំកែប្រែទី ៣ នាយកដ្ឋានពន្ធនាគារ
៨-លោក	មួង សំអាត	ប្រធានពន្ធនាគារ ខេត្តកណ្តាល
៩-លោក	ភាក់ សាវុន	ប្រធានពន្ធនាគារ ខេត្តកំពង់ស្ពឺ
១០-លោក	ឆែម សាវុធ	ប្រធានពន្ធនាគារ ខេត្តសៀមរាប
១១-លោក	ភង សារ៉េន	ប្រធានពន្ធនាគារ ខេត្តបាត់ដំបង
១២-លោក	ឡា មនោរិទ្ធ	ប្រធានពន្ធនាគារ ខេត្តស្ទឹងត្រែង
១៣-លោក	ចិន ណែល	ប្រធានពន្ធនាគារ ខេត្តរតនគិរី

ឃ. *មេដាយការពារជាតិ* ថ្នាក់មាស ០១ គ្រឿង ប្រាក់ ០១ គ្រឿង និងសំរិទ្ធ ០១ គ្រឿង

១-លោក	សួន ឧុង្គី	អនុប្រធានការិយាល័យ នៃនាយកដ្ឋានពន្ធនាគារ
២-លោក	ប៊ុន តារម្យ	អនុប្រធានការិយាល័យ នៃនាយកដ្ឋានពន្ធនាគារ
៣-លោក	ភ្នំ ផល្លី	អនុប្រធានការិយាល័យ នៃនាយកដ្ឋានពន្ធនាគារ
៤-លោក	ហ៊ុ ពុធវិសាល	អនុប្រធានការិយាល័យ នៃនាយកដ្ឋានពន្ធនាគារ
៥-លោក	អ៊ុច ពន្យ	អនុប្រធានការិយាល័យ នៃនាយកដ្ឋានពន្ធនាគារ
៦-លោក	ស្រ៊ុន លាង	អនុប្រធានការិយាល័យ នៃនាយកដ្ឋានពន្ធនាគារ
៧-លោក	ថោង តិរុណា	អនុប្រធានការិយាល័យ នៃនាយកដ្ឋានពន្ធនាគារ
៨-លោក	ឡឹប សាមឿន	អនុប្រធានមណ្ឌលអប់រំកែប្រែទី ១ នាយកដ្ឋានពន្ធនាគារ
៩-លោក	ម៉ីញ សំរឿន	អនុប្រធានមណ្ឌលអប់រំកែប្រែទី ១ នាយកដ្ឋានពន្ធនាគារ
១០-លោក	ហ៊ឹម វណ្ណៈសិតិរក្ស	អនុប្រធានមណ្ឌលអប់រំកែប្រែទី ១ នាយកដ្ឋានពន្ធនាគារ
១១-លោក	ឯម សុន្ទរិទ្ធ	អនុប្រធានមណ្ឌលអប់រំកែប្រែទី ២ នាយកដ្ឋានពន្ធនាគារ
១២លោកស្រី	គួន សំអ៊ីន	អនុប្រធានមណ្ឌលអប់រំកែប្រែទី ២ នាយកដ្ឋានពន្ធនាគារ
១៣-លោក	គង់ សំអុន	អនុប្រធានមណ្ឌលអប់រំកែប្រែទី ២ នាយកដ្ឋានពន្ធនាគារ
១៤-លោក	សោម សំអ៊ាន	អនុប្រធានមណ្ឌលអប់រំកែប្រែទី ៣ នាយកដ្ឋានពន្ធនាគារ
១៥-លោក	សេត សុវណ្ណ	អនុប្រធានមណ្ឌលអប់រំកែប្រែទី ៣ នាយកដ្ឋានពន្ធនាគារ
១៦-លោក	សើង នួនថា	អនុប្រធានមណ្ឌលអប់រំកែប្រែទី ៣ នាយកដ្ឋានពន្ធនាគារ
១៧-លោក	ស្រី វន្ថា	ប្រធានពន្ធនាគារប៉េហ្ស៊ី
១៨-លោក	ឈុល ណែម	ប្រធានពន្ធនាគារ ខេត្តតាកែវ
១៩-លោក	ប៉ូច ប៊ុនរិទ្ធ	ប្រធានពន្ធនាគារ ខេត្តកំពត
២០-លោក	ជា យឿន	ប្រធានពន្ធនាគារ ខេត្តកំពង់ធំ
២១-លោក	កែន សាវឿន	ប្រធានពន្ធនាគារ ខេត្តស្វាយរៀង
២២-លោក	ភ្រួច ប៊ុនឌិល	ប្រធានពន្ធនាគារ ខេត្តព្រះវិហារ
២៣-លោក	មុត ខន	ប្រធានពន្ធនាគារ ខេត្តប៉ៃលិន
២៤-លោក	ចាត ស៊ីនាង	ប្រធានពន្ធនាគារ ខេត្តកំពង់ឆ្នាំង
២៥-លោក	ហោង ហួន	ប្រធានពន្ធនាគារ ក្រុងព្រះសីហនុ
២៦-លោក	អាន គីមឡេង	ប្រធានពន្ធនាគារ ខេត្តមណ្ឌលគិរី
២៧-លោក	នួន វណ្ណា	ប្រធានពន្ធនាគារ ខេត្តបន្ទាយមានជ័យ
២៨-លោក	ខ្វា សារ៉ិន	ប្រធានពន្ធនាគារ ខេត្តក្រចេះ
២៩-លោក	ខាំ យ៉ន	ប្រធានពន្ធនាគារ ខេត្តព្រៃវែង

៣០-លោក សំរុល ធារិទ្ធ ប្រធានពន្ធនាគារ ខេត្តកោះកុង
៣១-លោក តិន ពេជ្រ ប្រធានផ្នែកមណ្ឌលអប់រំកែប្រែទី ១ នាយកដ្ឋានពន្ធនាគារ

ខ. *មេដាយការងារជាតិ* ថ្នាក់ប្រាក់ ០១ គ្រឿង និងសំរិទ្ធ ០១ គ្រឿង

១-លោក ចេង ហាន ប្រធានផ្នែក នៃនាយកដ្ឋានពន្ធនាគារ
២-លោក អ៊ុន សំអៀត ប្រធានផ្នែក នៃនាយកដ្ឋានពន្ធនាគារ
៣-លោក មាន ថាវរិទ្ធ ប្រធានផ្នែក នៃនាយកដ្ឋានពន្ធនាគារ
៤-លោក ឃិន ឌីគុណ ប្រធានផ្នែក នៃនាយកដ្ឋានពន្ធនាគារ
៥-លោក ស្រ្វាប ណារិទ្ធ ប្រធានផ្នែក នៃនាយកដ្ឋានពន្ធនាគារ
៦-លោក ឃី សាវុធ ប្រធានផ្នែក នៃនាយកដ្ឋានពន្ធនាគារ
៧-លោក យិន គុន្ថ ប្រធានផ្នែក នៃនាយកដ្ឋានពន្ធនាគារ
៨-លោក តេង បុត្រធី ប្រធានផ្នែក នៃនាយកដ្ឋានពន្ធនាគារ
៩-លោក ប៊ុត បូរិន ប្រធានផ្នែក នៃនាយកដ្ឋានពន្ធនាគារ
១០-លោក យិន ប៊ុនហេង ប្រធានផ្នែក នៃនាយកដ្ឋានពន្ធនាគារ
១១-លោក យឹម សុផល ប្រធានផ្នែក នៃនាយកដ្ឋានពន្ធនាគារ
១២-លោក កែប សំអុន ប្រធានផ្នែក នៃនាយកដ្ឋានពន្ធនាគារ
១៣-លោក សំ ឈឿន ប្រធានផ្នែក នៃនាយកដ្ឋានពន្ធនាគារ
១៤-លោក អ៊ូច គតិបណ្ឌិត ប្រធានផ្នែក នៃនាយកដ្ឋានពន្ធនាគារ
១៥-លោក ហាក់ សារ៉េន ប្រធានផ្នែក នៃនាយកដ្ឋានពន្ធនាគារ
១៦-លោក ហួន សុខន ប្រធានផ្នែក នៃនាយកដ្ឋានពន្ធនាគារ
១៧-លោក ឯក សុខុន ប្រធានផ្នែក នៃនាយកដ្ឋានពន្ធនាគារ
១៨-លោក ចាន់ សាខន ប្រធានផ្នែក នៃនាយកដ្ឋានពន្ធនាគារ
១៩-លោក ដូ ឆៃឆាង ប្រធានផ្នែក នៃនាយកដ្ឋានពន្ធនាគារ
២០-លោក កែវ នន់ ប្រធានផ្នែក នៃនាយកដ្ឋានពន្ធនាគារ
២១-លោក ឆ៉ា អៀង ប្រធានផ្នែក នៃនាយកដ្ឋានពន្ធនាគារ
២២-លោក ធន់ យ៉េង អនុប្រធានពន្ធនាគារ ប៉េហ្ស៊ី
២៣-លោក អ៊ូ ម៉ែន អនុប្រធានពន្ធនាគារ ប៉េហ្ស៊ី
២៤-លោក អេង ខួន អនុប្រធានពន្ធនាគារ ប៉េហ្ស៊ី
២៥-លោក ឈួន ចាន់ថន អនុប្រធានពន្ធនាគារ ខេត្តកណ្តាល
២៦-លោក ខួន ឡាយ អនុប្រធានពន្ធនាគារ ខេត្តកណ្តាល
២៧-លោក ឃុត ខាន់ឌី អនុប្រធានពន្ធនាគារ ខេត្តតាកែវ
២៨លោកស្រី ចាន់ សុខាលី អនុប្រធានពន្ធនាគារ ខេត្តតាកែវ
២៩-លោក គង់ ស៊ីថា អនុប្រធានពន្ធនាគារ ខេត្តតាកែវ
៣០-លោក នូ សាត អនុប្រធានពន្ធនាគារ ខេត្តកំពត
៣១-លោក អែម បូ អនុប្រធានពន្ធនាគារ ខេត្តកំពត
៣២-លោក អ៊ុក ឡាយ អនុប្រធានពន្ធនាគារ ខេត្តកំពត
៣៣-លោក ចែម សុផល អនុប្រធានពន្ធនាគារ ខេត្តកំពង់ស្ពឺ
៣៤-លោក កែវ ឌន អនុប្រធានពន្ធនាគារ ខេត្តកំពង់ស្ពឺ
៣៥-លោក មុត ជឿន អនុប្រធានពន្ធនាគារ ខេត្តកំពង់ស្ពឺ
៣៦-លោក ធីម សោមបញ្ញា អនុប្រធានពន្ធនាគារ ខេត្តកំពង់ធំ

៣៧-លោក	កែង ផុន	អនុប្រធានពន្ធនាគារ ខេត្តកំពង់ធំ
៣៨-លោក	នង នរិទ្ធ	អនុប្រធានពន្ធនាគារ ខេត្តកំពង់ធំ
៣៩-លោក	ខន សំអឿន	អនុប្រធានពន្ធនាគារ ខេត្តកំពង់ចាម
៤០-លោក	លុយ ស៊ីម៉ៅ	អនុប្រធានពន្ធនាគារ ខេត្តសៀមរាប
៤១-លោក	អុំ មណ្ណា	អនុប្រធានពន្ធនាគារ ខេត្តសៀមរាប
៤២-លោក	ឆិញ ព្រឹក	អនុប្រធានពន្ធនាគារ ខេត្តសៀមរាប
៤៣-លោក	ឡុង ប៊ុនថុល	អនុប្រធានពន្ធនាគារ ខេត្តពោធិ៍សាត់
៤៤-លោក	ចាន់ វិចិត្រ	អនុប្រធានពន្ធនាគារ ខេត្តពោធិ៍សាត់
៤៥-លោក	ចាប សឹក	អនុប្រធានពន្ធនាគារ ខេត្តពោធិ៍សាត់
៤៦-លោក	នី ណាន	អនុប្រធានពន្ធនាគារ ខេត្តបាត់ដំបង
៤៧-លោក	ហ៊ឹង ចំរើន	អនុប្រធានពន្ធនាគារ ខេត្តបាត់ដំបង
៤៨-លោក	សួស សាខូ	អនុប្រធានពន្ធនាគារ ខេត្តស្វាយរៀង
៤៩-លោក	ម៉ា ចន្ថា	អនុប្រធានពន្ធនាគារ ខេត្តស្វាយរៀង
៥០-លោក	ឌុច សឿន	អនុប្រធានពន្ធនាគារ ខេត្តស្ទឹងត្រែង
៥១-លោក	ប៊ុន ថ្រាំង	អនុប្រធានពន្ធនាគារ ខេត្តស្ទឹងត្រែង
៥២-លោក	ថាច់ សុគន្ធី	អនុប្រធានពន្ធនាគារ ខេត្តព្រះវិហារ
៥៣-លោក	ស សាំង	អនុប្រធានពន្ធនាគារ ខេត្តព្រះវិហារ
៥៤-លោក	នៅ ធឿង	អនុប្រធានពន្ធនាគារ ក្រុងប៉ៃលិន
៥៥-លោកស្រី	ហោង សុខឈៀប	អនុប្រធានពន្ធនាគារ ក្រុងប៉ៃលិន
៥៦-លោក	ដូ វ៉ាន់ធិន	អនុប្រធានពន្ធនាគារ ខេត្តកំពង់ឆ្នាំង
៥៧-លោក	គង់ ប៊ីន	អនុប្រធានពន្ធនាគារ ខេត្តកំពង់ឆ្នាំង
៥៨-លោក	គីម ឆែ	អនុប្រធានពន្ធនាគារ ខេត្តកំពង់ឆ្នាំង
៥៩-លោក	ញ៉ឹន វ៉ែន	អនុប្រធានពន្ធនាគារ ខេត្តរតនគិរី
៦០-លោក	ឡាត់ លើយ	អនុប្រធានពន្ធនាគារ ខេត្តរតនគិរី
៦១-លោក	អឿន សាខុន	អនុប្រធានពន្ធនាគារ ខេត្តរតនគិរី
៦២-លោក	តុប សោភា	អនុប្រធានពន្ធនាគារ ក្រុងព្រះសីហនុ
៦៣-លោក	សំ សុផល	អនុប្រធានពន្ធនាគារ ក្រុងព្រះសីហនុ
៦៤-លោក	ម៉ន ខួន	អនុប្រធានពន្ធនាគារ ខេត្តមណ្ឌលគិរី
៦៥-លោក	អ៊ិន សុវណ្ណ	អនុប្រធានពន្ធនាគារ ខេត្តមណ្ឌលគិរី
៦៦-លោក	ឡុង តុល	អនុប្រធានពន្ធនាគារ ខេត្តមណ្ឌលគិរី
៦៧-លោក	ស្រ៊ិន កែន	អនុប្រធានពន្ធនាគារ ខេត្តបន្ទាយមានជ័យ
៦៨-លោក	តាន ឆវ័ន្ត	អនុប្រធានពន្ធនាគារ ខេត្តបន្ទាយមានជ័យ
៦៩-លោក	គង់ មឿន	អនុប្រធានពន្ធនាគារ ខេត្តក្រចេះ
៧០-លោក	ហ៊ុយ ឆែម៉ន	អនុប្រធានពន្ធនាគារ ខេត្តក្រចេះ
៧១-លោក	គ្រាច ចន	អនុប្រធានពន្ធនាគារ ខេត្តក្រចេះ
៧២-លោក	ជុំ វ៉ាន់	អនុប្រធានពន្ធនាគារ ខេត្តព្រៃវែង
៧៣-លោក	សូ ឡៃ	អនុប្រធានពន្ធនាគារ ខេត្តព្រៃវែង
៧៤-លោក	អ៊ុង វណ្ឌី	អនុប្រធានពន្ធនាគារ ខេត្តព្រៃវែង
៧៥-លោក	ត្រី ប៊ុន្ថា	អនុប្រធានពន្ធនាគារ ខេត្តកោះកុង

៧៦-លោក	ឆេស សាឡុរ៉ាត់	អនុប្រធានពន្ធនាគារ ខេត្តកោះកុង
៧៧-លោក	សឹយុទ្ធ សែនថន	អនុប្រធានផ្នែកពន្ធនាគារខេត្តកោះកុង
៧៨-លោក	សុខ ពៅ	ប្រធានផ្នែកមណ្ឌលអប់រំកែប្រែទី ១ នាយកដ្ឋានពន្ធនាគារ
៧៩-លោក	សៀ អ៊ីម	អនុប្រធានផ្នែកមណ្ឌលអប់រំកែប្រែទី ១ នាយកដ្ឋានពន្ធនាគារ
៨០-លោក	ឃឹម ស្រ៊ីន	អនុប្រធានផ្នែកមណ្ឌលអប់រំកែប្រែទី ១ នាយកដ្ឋានពន្ធនាគារ

មាត្រា ២ : សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តន៍ឱ្យបានសំរេច នូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

នស/រកត.០៦០៧.៣០៤

ធ្វើនៅព្រះបរមរាជវាំងរាជធានីភ្នំពេញ ថ្ងៃទី ២ ខែ កក្កដា ឆ្នាំ ២០០៦

លេខ : ២០៧៥ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែកក្កដា ឆ្នាំ២០០៦
អគ្គលេខាធិការរងរាជរដ្ឋាភិបាល

យុន ឌីនកេន

នស/រកត/០៧០៦/២៨៣

ព្រះរាជក្រឹត្យ

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានគុណជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើត ក្រសួងការពារជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

ត្រាស់បង្គាប់

មាត្រា១ : តម្លើងឋានន្តរស័ក្តិថ្នាក់ **ឧត្តមសេនីយ៍ត្រី** នាយទាហានជាន់ខ្ពស់ នៃកងយោធពលខេមរភូមិន្ទ ដែលមានរាយនាមដូចខាងក្រោម ៖

១-វរសេនីយ៍ឯក **ពិន សេដ្ឋថុល** អត្តលេខ ០០០៥៩៥
២-វរសេនីយ៍ឯក **អៀង លីសក្តិ** អត្តលេខ ០០០៥៧២

មាត្រា២ : សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តឱ្យបានសំរេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

ពរល-០៦០៧-៣០៣

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ២ ខែ កក្កដា ឆ្នាំ ២០០៦

លេខ :២៧៩៥ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ កក្កដា ឆ្នាំ២០០៦
អគ្គលេខាធិការរាជរដ្ឋាភិបាល

ឃួន ឌិនភេន

៤/២-៤

នស/រកត/០៧០៦/២៨៨

ព្រះរាជក្រឹត្យ

យើង

ព្រះករុណាព្រះបាទសម្ដេចព្រះបរមនាថ នរោត្ដម សីហមុនី
សមានត្ថមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្ដីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្ដីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្ដីពីការបង្កើតក្រសួងផែនការ
- បានទ្រង់យល់សេចក្ដីក្រាបបង្គំទូលថ្វាយរបស់សម្ដេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : ត្រូវបានតែងតាំង :

១_ឯកឧត្ដម កោះ សំអុល ជាទីប្រឹក្សាអមក្រសួងផែនការ មានឋានៈស្មើ អនុរដ្ឋលេខាធិការ
២_លោកជំទាវ ឯម សារម៉ឿន ជាសមាជិកក្រុមសង្កេតការណ៍សេដ្ឋកិច្ច សង្គមកិច្ច និង វប្បធម៌ មានឋានៈស្មើ អនុរដ្ឋលេខាធិការ ។

មាត្រា ២ : បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា ៣ : សម្ដេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តអោយបានសំរេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៤ : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្ដលេខាតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

ពរល-០៦០៧-៣០៨

ធ្វើនៅព្រះបរមរាជវាំងរាជធានីភ្នំពេញ, ថ្ងៃទី ៦ ខែ កក្កដា ឆ្នាំ ២០០៦

លេខ : ៤៨១ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែ កក្កដា ឆ្នាំ២០០៦
អគ្គលេខាធិការរងរាជរដ្ឋាភិបាល

ឃុន ជិនកេង

ព្រះរាជក្រឹត្យ

នស/រកត/០៧០៦/៧៤៩

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរមហាក្សត្រ
ខេមរជនា សមូហោភាស កម្ពុជឯករាជ្យបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខនស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២ /នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម / ០១៩៦ / ០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត /០៥០១ / ១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

ព្រះរាជបញ្ញត្តិ

មាត្រា ១ : តម្លើងឋានន្តរស័ក្តិថ្នាក់ ឧត្តមសេនីយ៍ត្រី ជូននាយនគរបាលជាតិជាន់ខ្ពស់ នៃក្រសួងមហាផ្ទៃ ដូចមានរាយនាមខាងក្រោម :

១- លោកវរសេនីយ៍ឯក សន ណារី អត្តលេខ ០១០៦
២- លោកវរសេនីយ៍ឯក ហ៊ី សាគុណ អត្តលេខ ០១៧១
៣- លោកវរសេនីយ៍ឯក អៀង ទ៉ែម អត្តលេខ ០៤២២
៤- លោកវរសេនីយ៍ឯក ជា ណារ៉ិន អត្តលេខ ០២២០៤ ។

មាត្រា ២ : សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តអោយបានសំរេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ៕

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣រស-០៦០៧-៣០៩

ធ្វើនៅព្រះបរមរាជវាំងរាជធានីភ្នំពេញ ថ្ងៃទី ៦ ខែកក្កដាឆ្នាំ ២០០៦

លេខ :៥៨០ ច.ល
ចំលងចេញពីច្បាប់ដើម
រាជធានីភ្នំពេញ ថ្ងៃទី ៦ ខែកក្កដាឆ្នាំ២០០៦
អគ្គលេខាធិការរាជរដ្ឋាភិបាល

ស៊ុន ចិន្តា

នស/រកត/០៧០៦/២៩០

ព្រះរាជក្រឹត្យ

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជ្យបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១០ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤/ ចុះថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស / រកត / ០៤០១ / ០៨៥ ចុះថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីការទូតជាន់ខ្ពស់
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : ត្រូវបានប្រគល់ភារកិច្ចជូនឯកឧត្តម **តាន់ ដារិទ្ធ** អោយបំពេញមុខងារជា អគ្គនាយក នៃអគ្គនាយកដ្ឋានអាស៊ាន នៃក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ ។

មាត្រា ២ : សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តអោយបានសំរេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣រស.០២០៧.៣១១

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ៧ ខែ កក្កដា ឆ្នាំ ២០០៦

លេខ : ២៧៦៦ច.ល
ដើម្បីចម្លងចែក
ភ្នំពេញ ថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ២០០៦
អគ្គលេខាធិការរងរាជរដ្ឋាភិបាល
ឃុំន ជិនកេន

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ:...៦៤...អនក្រ.បក

អនុក្រឹត្យ

ស្តីពី

ការអនុវត្តច្បាប់ស្តីពីម៉ាក ពាណិជ្ជនាម និង អំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦/៩៤ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០០/០០១ ចុះថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ២០០០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងគុណភាព សុវត្ថិភាពលើផលិតផលទំនិញ និងសេវា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២០២/០០៦ ចុះថ្ងៃទី ០៧ ខែ កុម្ភៈ ឆ្នាំ ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់
- បានឃើញអនុក្រឹត្យលេខ៥៤ អនក្រ.បក ចុះថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងពាណិជ្ជកម្ម
- បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គនាថ្ងៃទី ០៧ ខែ កក្កដា ឆ្នាំ ២០០៦

សម្រេច

ជំពូកទី ១

បទប្បញ្ញត្តិទូទៅ

មាត្រា ១. – គោលបំណង

អនុក្រឹត្យនេះមានគោលបំណងកំណត់ នីតិវិធីនៃការចុះបញ្ជីម៉ាក ការបដិសេធ ភ្នាក់ងារតំណាង ការប្រកាសសិទ្ធិជាអាទិភាព ការលុបម៉ាកចេញពីបញ្ជី និងវិធានការតាមមាត់ច្រកព្រំដែន សំដៅអនុវត្តច្បាប់ស្តីពីម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់ នៃព្រះរាជាណាចក្រកម្ពុជា។

មាត្រា ២. – និយមន័យ

វាក្យស័ព្ទដែលប្រើក្នុងអនុក្រឹត្យនេះ ត្រូវបានកំណត់និយមន័យដូចក្នុងឧបសម្ព័ន្ធភ្ជាប់ ។

ជំពូកទី ២

លក្ខខណ្ឌទូទៅ នៃការស្នើសុំចុះបញ្ជីម៉ាក

មាត្រា ៣. – គំរូពាក្យស្នើសុំ

គំរូពាក្យស្នើសុំ ដែលបោះពុម្ពរួចត្រូវចែកជូន ដល់អ្នកដាក់ពាក្យស្នើសុំដោយឥតគិតថ្លៃ ដោយមន្ត្រីកាន់កាប់បញ្ជី ។

គំរូពាក្យស្នើសុំ ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងពាណិជ្ជកម្ម ។

មាត្រា ៤. – ភាសាប្រើប្រាស់ក្នុងឯកសារដាក់ពាក្យស្នើសុំ និងការបកប្រែ

តាមការតម្រូវនៃច្បាប់ ឬអនុក្រឹត្យនេះ ពាក្យស្នើសុំត្រូវធ្វើជាភាសាខ្មែរ ឬជាភាសាអង់គ្លេស ។ ឯកសារណាមួយ ដែលប្រើប្រាស់អមភ្ជាប់ជាមួយពាក្យស្នើសុំ ដែលបង្កើតជាផ្នែកមួយ នៃពាក្យស្នើសុំនោះ ឬ ឯកសារដែលបានដាក់ជូនទៅមន្ត្រីកាន់កាប់បញ្ជី ដែលប្រើប្រាស់ភាសាណាមួយ ក្រៅពីភាសាខ្មែរ ឬ ភាសាអង់គ្លេស ត្រូវភ្ជាប់មកជាមួយ នូវការបកប្រែជាភាសាខ្មែរ ឬ ភាសាអង់គ្លេស ។

មាត្រា ៥. – ការបញ្ជាក់ឈ្មោះ អាសយដ្ឋាន សញ្ជាតិ និង និវេសនដ្ឋាន របស់អ្នកដាក់ពាក្យស្នើសុំ

១-ឈ្មោះរបស់រូបវន្តបុគ្គល ត្រូវបញ្ជាក់ដោយនាមត្រកូល និងនាមខ្លួនរបស់បុគ្គលនោះ ឈ្មោះនីតិបុគ្គល ត្រូវបញ្ជាក់ដោយឈ្មោះពេញលេញ ជាផ្លូវការរបស់នីតិបុគ្គលនោះ ។

២-អាសយដ្ឋានរបស់អ្នកដាក់ពាក្យស្នើសុំ ត្រូវបញ្ជាក់ឱ្យបានច្បាស់លាស់ ដើម្បីបំពេញតម្រូវការជាធម្មតាសម្រាប់សម្រួលដល់ការបញ្ជូនតាមប្រៃសណីយ៍ ។ ក្នុងករណីណាក៏ដោយ អាសយដ្ឋាន ត្រូវមានការបញ្ជាក់ផងដែរ នូវលេខផ្ទះ ទូរស័ព្ទ និង ទូរសារ ។

៣-សញ្ជាតិត្រូវបញ្ជាក់នូវឈ្មោះរដ្ឋ ឬប្រទេស ដែលបុគ្គលនោះជាពលរដ្ឋនៃរដ្ឋ ឬប្រទេសនោះ។ ចំពោះនីតិបុគ្គលត្រូវបញ្ជាក់ឈ្មោះរដ្ឋ ឬប្រទេស ដែលនីតិបុគ្គលនោះ ត្រូវបានបង្កើតឡើង តាមច្បាប់របស់រដ្ឋ ឬប្រទេសនោះ ព្រមទាំងការិយាល័យ របស់នីតិបុគ្គលនោះដែលបានចុះបញ្ជីរួច។

៤-និវេសនដ្ឋាន ត្រូវបញ្ជាក់នូវឈ្មោះរដ្ឋ ឬប្រទេស ដែលបុគ្គលនោះមានទីលំនៅជាអចិន្ត្រៃយ៍ ។

មាត្រា ៦. – ហត្ថលេខាក្នុងនាមក្រុមហ៊ុនសហកម្មសិទ្ធិ ក្រុមហ៊ុនមូលធន និង សមាគម

១-ឯកសារដែលត្រូវចុះហត្ថលេខា ក្នុងនាមក្រុមហ៊ុនសហកម្មសិទ្ធិមួយ ត្រូវមានឈ្មោះរបស់ម្ចាស់ភាគហ៊ុនទាំងអស់ ជាឈ្មោះពេញលេញ និងត្រូវចុះហត្ថលេខា ដោយម្ចាស់ភាគហ៊ុនទាំងអស់ ឬដោយម្ចាស់ភាគហ៊ុនណាមួយ ដែលមានលក្ខណសម្បត្តិគ្រប់គ្រាន់ ដើម្បីចុះហត្ថលេខា ដោយមានបញ្ជាក់ថា ម្ចាស់ភាគហ៊ុននោះចុះហត្ថលេខា ក្នុងនាមក្រុមហ៊ុនសហកម្មសិទ្ធិ ឬដោយតតិយជនណាម្នាក់ដែលមន្ត្រី កាន់កាប់បញ្ជីទទួលស្គាល់ថា ជននោះត្រូវអនុញ្ញាតឱ្យចុះហត្ថលេខាលើឯកសារនោះ។ ឯកសារដែលត្រូវចុះហត្ថលេខា ក្នុងនាមក្រុមហ៊ុនមូលធន ជូសមុខឱ្យនីតិបុគ្គលមួយ ត្រូវចុះហត្ថលេខាដោយអភិបាលមួយរូប ឬដោយលេខាធិការ ឬមន្ត្រីសំខាន់ដទៃទៀត របស់នីតិបុគ្គលនោះ ឬចុះហត្ថលេខាដោយតតិយជនណាម្នាក់ ដែលមន្ត្រីកាន់កាប់បញ្ជីទទួលស្គាល់ថា ជននោះត្រូវអនុញ្ញាតឱ្យធ្វើការចុះហត្ថលេខាលើឯកសារនោះ ហើយឯកសារនោះត្រូវមានប្រថាប់ត្រា របស់នីតិបុគ្គលនោះផង។ ឯកសារដែលត្រូវចុះហត្ថលេខា ក្នុងនាមសមាគមមួយ ត្រូវចុះហត្ថលេខាដោយបុគ្គលណាម្នាក់ ដែលមន្ត្រីកាន់កាប់បញ្ជីទទួលស្គាល់ថា បុគ្គលនោះបានទទួលសិទ្ធិស្របច្បាប់ ដើម្បីចុះហត្ថលេខា ហើយត្រូវប្រថាប់ត្រារបស់សមាគមនោះផង។

២-នៅពេលចាំបាច់ មន្ត្រីកាន់កាប់បញ្ជី អាចស្នើសុំឱ្យផ្តល់ភស្តុតាងនៃការប្រគល់សិទ្ធិ ក្នុងការចុះហត្ថលេខានោះ ។

មាត្រា ៧. – ភ្នាក់ងារតំណាង

លិខិតប្រគល់សិទ្ធិ ដែលចាត់តាំងភ្នាក់ងារតំណាងមួយឱ្យធ្វើការដាក់ពាក្យ អាចភ្ជាប់ជាមួយនឹងពាក្យស្នើសុំចុះបញ្ជី ឬ ត្រូវប្រគល់លិខិតប្រគល់សិទ្ធិនោះ ទៅឱ្យមន្ត្រីកាន់កាប់បញ្ជី ក្នុងរយៈពេល ០២ (ពីរ)ខែ គិតចាប់ពីកាលបរិច្ឆេទនៃការដាក់ពាក្យ។ ប្រសិនបើការប្រគល់សិទ្ធិនេះ មិនត្រូវបានធ្វើឡើង

និង ធ្វើឡើងមិនសមស្របតាមមាត្រា៥៨ និង មាត្រា៥៩ នៃច្បាប់ និង មាត្រា២៨ នៃអនុក្រឹត្យនេះទេនោះ ចំណាត់ការតាមនីតិវិធីណាមួយ ក្នុងការចុះបញ្ជី នឹងមិនត្រូវធ្វើឡើងឡើយ ។

មាត្រា ៨. – កម្រៃផ្សេងៗ

កម្រៃផ្សេងៗ ដែលតម្រូវតាមច្បាប់ ឬតាមអនុក្រឹត្យនេះ ត្រូវកំណត់ដោយប្រកាសអន្តរក្រសួង របស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និង ក្រសួងពាណិជ្ជកម្ម ។

ជំពូកទី ៣
នីតិវិធីនៃការចុះបញ្ជីម៉ាក
ការបដិសេធការចុះបញ្ជីម៉ាក និងការលុបម៉ាកចេញពីបញ្ជី

ផ្នែកទី ១
ពាក្យស្នើសុំចុះបញ្ជីម៉ាក នីតិវិធីនៃការចុះបញ្ជីម៉ាក និងការបោះពុម្ពផ្សាយ

មាត្រា ៩. – ចំណាត់ថ្នាក់នៃម៉ាក

ក្នុងការចុះបញ្ជី និងការបោះពុម្ពផ្សាយម៉ាក មន្ត្រីកាន់កាប់បញ្ជីត្រូវអនុវត្តតាម "ចំណាត់ថ្នាក់អន្តរជាតិ នៃទំនិញ និង សេវា នៃការចុះបញ្ជីម៉ាក" ដែលអនុម័តដោយកិច្ចព្រមព្រៀងទីក្រុង នីស ចុះថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ១៩៥៧ ហើយដែលចំណាត់ថ្នាក់នេះ បានធ្វើវិសោធនកម្មជាបន្តបន្ទាប់ ។

មាត្រា ១០. – ការដាក់ពាក្យស្នើសុំចុះបញ្ជីម៉ាក

ការដាក់ពាក្យស្នើសុំចុះបញ្ជីម៉ាកមួយ ត្រូវធ្វើឡើងតាមរយៈគំរូពាក្យស្នើសុំ ដូចមានចែងក្នុងប្រកាសរបស់ក្រសួងពាណិជ្ជកម្ម ហើយត្រូវចុះហត្ថលេខាដោយអ្នកស្នើសុំ ឬភ្នាក់ងារតំណាងស្របច្បាប់ ។ ពាក្យស្នើសុំមួយ អាចធ្វើឡើងសម្រាប់ការស្នើសុំចុះបញ្ជីម៉ាកមួយ ចំពោះទំនិញ ឬសេវាក្នុងចំណាត់ថ្នាក់មួយ ឬច្រើននៃចំណាត់ថ្នាក់អន្តរជាតិ ។

ការប្រើប្រាស់ម៉ាកពុំមែនជាលក្ខខណ្ឌដែលតម្រូវ នៅពេលដាក់ពាក្យស្នើសុំ ចុះបញ្ជីម៉ាកឡើយ ។

មាត្រា ១១. – ការផ្តល់គំរូម៉ាក

១-ពាក្យស្នើសុំចុះបញ្ជី ត្រូវភ្ជាប់មកជាមួយនូវគំរូម៉ាក ក្រោមរូបភាព[illegible] និងមិនរលុប ដែលមានទំហំមិនលើសពី ៨សង្ទីម៉ែត្រ គុណ ៨សង្ទីម៉ែត្រ [illegible]

ដែលបានផ្តល់ជូន នៅលើគំរូពាក្យស្នើសុំចុះបញ្ជីម៉ាក ។ គ្រប់ករណីទាំងអស់ គំរូម៉ាកត្រូវពិពណ៌នាគ្រប់ចំណុចលំអិតទាំងអស់ ដែលចំណុចលំអិតទាំងនោះ អាចនឹងត្រូវទាមទារក្នុងពេលណាមួយដែលចាំបាច់ដោយមន្ត្រីកាន់កាប់បញ្ជី ។ ប្រសិនបើ មានលក្ខខណ្ឌតម្រូវ ចំណុចលំអិតទាំងនោះ ត្រូវចុះហត្ថលេខាដោយអ្នកស្នើសុំ ឬដោយភ្នាក់ងារតំណាង ដែលបានទទួលសិទ្ធិ។

២-គំរូម៉ាកបន្ថែមចំនួន ១៥ (ដប់ប្រាំ) ទៀត ត្រូវភ្ជាប់ជាមួយនឹងគ្រប់ពាក្យស្នើសុំចុះបញ្ជីម៉ាក។ គំរូម៉ាក ដែលបិទភ្ជាប់នៅលើពាក្យស្នើសុំ និងគំរូម៉ាកបន្ថែម ត្រូវមានលក្ខណៈដូចគ្នាបេះបិទ ។

៣-ប្រសិនបើ មន្ត្រីកាន់កាប់បញ្ជីយល់ថា គំរូម៉ាកណាមួយនៅមិនទាន់សមស្របសម្រាប់ការចុះបញ្ជី មន្ត្រីកាន់កាប់បញ្ជី អាចទាមទារឱ្យផ្តល់គំរូម៉ាកមួយទៀត ដែលសមស្រប ដើម្បីជំនួសគំរូចាស់ ។

៤-នៅពេលដែលគំរូ ឬការចម្លងឡើងវិញផ្សេងទៀត ពុំបានធ្វើឡើងតាមលក្ខណៈ ដូចបានពោលខាងលើនោះ គំរូម៉ាក ឬរូបភាពចម្លងនៃម៉ាក អាចនឹងត្រូវផ្តល់ក្រោមរូបភាព ជាទំហំពេញលេញ ឬ បំព្រួញ និងតាមទម្រង់មួយ ដែលមន្ត្រីកាន់កាប់បញ្ជីយល់ថាសមស្រប ។

មាត្រា ១២. – សម្លេងអាន និងការបកប្រែអត្ថន័យរបស់ម៉ាក

តាមការតម្រូវរបស់មន្ត្រីកាន់កាប់បញ្ជី ក្នុងករណីដែលម៉ាកមួយ មានពាក្យមួយព្យាង្គ ឬច្រើនព្យាង្គ ជាអក្សរ ក្រៅពីអក្សរខ្មែរ ឬអក្សររ៉ូម៉ាំង ការបំពេញពាក្យស្នើសុំតាមគំរូ ដូចមានចែងក្នុងប្រកាសរបស់ក្រសួងពាណិជ្ជកម្ម ហើយនិងការផ្តល់នូវគំរូម៉ាកបន្ថែម ត្រូវភ្ជាប់មកជាមួយផងដែរនូវការសរសេរ សម្លេងអាន និងការបកប្រែអត្ថន័យរបស់ម៉ាកនោះ ឱ្យបានពេញលេញតាមពាក្យមួយព្យាង្គៗ ដោយបញ្ជាក់នូវភាសា ដែលពាក្យនីមួយៗនោះ ត្រូវបានប្រើប្រាស់ ។

មាត្រា ១៣. – ការប្រកាសសិទ្ធិអាទិភាព និងការបកប្រែពាក្យស្នើសុំលើកដំបូង

១-អនុលោមតាមមាត្រា៦ នៃច្បាប់ ពាក្យស្នើសុំចុះបញ្ជីម៉ាក អាចអមមកជាមួយសេចក្តីប្រកាសទាមទារសិទ្ធិអាទិភាព នៃការដាក់ពាក្យស្នើសុំលើកដំបូង នៅក្រៅប្រទេស ក្នុងកម្រិតជាតិ ឬកម្រិតតំបន់ ដែលបានធ្វើឡើងដោយអ្នកដាក់ពាក្យស្នើសុំ ឬអ្នកទទួលសិទ្ធិ ដូចមានចែងក្នុងអនុសញ្ញាទីក្រុង ប៉ារីស ដែលផ្តល់សិទ្ធិអាទិភាពនៅក្នុងរដ្ឋណាមួយ ជាសមាជិករបស់អនុសញ្ញានោះ។ ក្នុងករណីនេះមន្ត្រីកាន់កាប់បញ្ជី អាចតម្រូវឱ្យអ្នកដាក់ពាក្យស្នើសុំផ្តល់ នូវច្បាប់ចម្លង នៃពាក្យស្នើសុំចុះបញ្ជីលើកដំបូងមួយច្បាប់ ដែលបានបញ្ជាក់ថា ត្រឹមត្រូវពីការិយាល័យទទួលពាក្យស្នើសុំនោះ ក្នុងរយៈពេលដែលបានកំណត់ក្នុងកថាខ័ណ្ឌ (៣) នៃមាត្រានេះ ។ អ្នកដាក់ពាក្យស្នើសុំចុះបញ្ជី ឬអ្នកទទួលសិទ្ធិរបស់គាត់ អាចធ្វើការទាមទារសិទ្ធិអាទិភាព ពីការចុះបញ្ជីលើកដំបូង ដែលបានធ្វើ នៅក្នុងរដ្ឋ ឬប្រទេសណាមួយ ជាសមាជិករបស់អង្គការពាណិជ្ជកម្មពិភពលោកផងដែរ ។

២-ការប្រកាសអំពីសិទ្ធិអាទិភាព ដែលធ្វើឡើងតាមមាត្រា៦ នៃច្បាប់ និង មាត្រា១៣ កថាខ័ណ្ឌ (១) នៃអនុក្រឹត្យនេះ ត្រូវបញ្ជាក់នូវ ៖

ក- កាលបរិច្ឆេទដែលបានដាក់ពាក្យស្នើសុំចុះបញ្ជីម៉ាកលើកដំបូង

ខ- លេខដាក់ពាក្យនៃការស្នើសុំចុះបញ្ជីម៉ាកលើកដំបូង អនុលោមតាមកថាខ័ណ្ឌ (៣) ខាងក្រោមនៃមាត្រានេះ

គ- ឈ្មោះប្រទេស ដែលអ្នកស្នើសុំចុះបញ្ជីម៉ាក បានដាក់ពាក្យលើកដំបូង ឬ ក្នុងករណីដែលពាក្យស្នើសុំចុះបញ្ជីម៉ាកលើកដំបូង ទៅជាការដាក់ពាក្យស្នើសុំចុះបញ្ជីម៉ាកក្រោមរូបភាពតំបន់ ឬ អន្តរជាតិ។ អ្នកដាក់ពាក្យស្នើសុំ ត្រូវបញ្ជាក់ឈ្មោះការិយាល័យ និង ឈ្មោះប្រទេស ដែលពាក្យស្នើសុំចុះបញ្ជីម៉ាកនោះ ត្រូវដាក់ ។

៣-ប្រសិនបើនៅពេលដាក់សេចក្តីប្រកាស ដែលបានចែងក្នុងកថាខ័ណ្ឌ (១) និង (២) ខាងលើ ហើយអ្នកដាក់ពាក្យពុំទាន់ដឹងលេខដាក់ពាក្យ នៃពាក្យស្នើសុំចុះបញ្ជីម៉ាកលើកដំបូងទេ អ្នកដាក់ពាក្យស្នើសុំ ត្រូវផ្តល់លេខដាក់ពាក្យនោះ ក្នុងរយៈពេល ០៣ (បី)ខែ គិតចាប់ពីកាលបរិច្ឆេទនៃការដាក់ពាក្យស្នើសុំចុះបញ្ជីម៉ាក ដែលបានប្រកាសសុំសិទ្ធិអាទិភាពនោះ ។ ប្រសិនបើ អ្នកដាក់ពាក្យស្នើសុំផ្តល់ នូវភស្តុតាងគ្រប់គ្រាន់ ដែលបង្ហាញថា ការដែលគាត់ពុំអាចអនុវត្តបានត្រឹមត្រូវ តាមកាលកំណត់ខាងលើ ដោយសារមានកាលៈទេសៈជាឧបសគ្គមួយចំនួន ហួសពីសមត្ថភាពគ្រប់គ្រងរបស់គាត់ មន្ត្រីកាន់កាប់បញ្ជីអាចពន្យារពេល ០៣ (បី) ខែទៀតចំពោះកាលកំណត់ នៃការផ្តល់នូវលេខដាក់ពាក្យ ដែលមានចែងក្នុងកថាខ័ណ្ឌនេះ ។

៤-ក្នុងករណីមានការស្នើសុំសិទ្ធិអាទិភាព នៃការដាក់ពាក្យស្នើសុំចុះបញ្ជីម៉ាកលើកដំបូង ចំនួន ០២ (ពីរ) ឬ ច្រើនជាង ដែលអនុលោមតាមកថាខ័ណ្ឌ (១) ខាងលើ ការបញ្ជាក់អំពីការដាក់ពាក្យស្នើសុំសិទ្ធិអាទិភាព អាចបញ្ចូល ក្នុងប្រកាសទាមទារសិទ្ធិអាទិភាព តែមួយបាន ។

៥-ប្រសិនបើមន្ត្រីកាន់កាប់បញ្ជីរកឃើញថា លក្ខខណ្ឌតម្រូវទាំងឡាយតាមមាត្រា៦ នៃច្បាប់ និង កថាខ័ណ្ឌ (១) (២) និង (៣) ខាងលើ មិនត្រូវបំពេញគ្រប់គ្រាន់ទេនោះ ការប្រកាសទាមទារសិទ្ធិអាទិភាព នឹងមិនត្រូវចាត់ទុកថា បានធ្វើឡើងឡើយ ។

៦-មុនពេលធ្វើការចុះបញ្ជីម៉ាក អ្នកដាក់ពាក្យស្នើសុំចុះបញ្ជីម៉ាក អាចធ្វើការកែតម្រូវការប្រកាសទាមទារ សិទ្ធិអាទិភាពរបស់ខ្លួន ដែលធ្វើឡើងតាមកថាខ័ណ្ឌនានាខាងលើបាន ។

មាត្រា ១៤. – ច្បាប់ចម្លងនៃការដាក់ពាក្យស្នើសុំចុះបញ្ជីម៉ាកលើកដំបូង

អ្នកដាក់ពាក្យស្នើសុំចុះបញ្ជីម៉ាក ត្រូវបានអនុញ្ញាតរយៈពេល ០៣ (បី) ខែ គិតចាប់ពីកាលបរិច្ឆេទនៃការទាមទាររបស់មន្ត្រីកាន់កាប់បញ្ជី ដើម្បីផ្តល់នូវច្បាប់ចម្លង នៃការដាក់ពាក្យស្នើសុំចុះបញ្ជីម៉ាកលើកដំបូង ដោយមានការបញ្ជាក់នូវភាពត្រឹមត្រូវ ។

មាត្រា ១៥. – ការដកពាក្យស្នើសុំចុះបញ្ជីម៉ាក

ការដកពាក្យស្នើសុំចុះបញ្ជីម៉ាក ត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ ដែលត្រូវចុះហត្ថលេខាដោយអ្នកដាក់ពាក្យស្នើសុំ ឬភ្នាក់ងារតំណាងស្របច្បាប់ ហើយត្រូវដាក់ជូនទៅមន្ត្រីកាន់កាប់បញ្ជី ។

កម្រៃនៃការដាក់ពាក្យស្នើសុំចុះបញ្ជីម៉ាក នឹងមិនត្រូវផ្តល់ជូនវិញទេ ក្នុងករណីដែលមានការដកពាក្យស្នើសុំចុះបញ្ជីម៉ាក ទៅវិញនោះ ។

មាត្រា ១៦. – ការកត់ត្រាពាក្យស្នើសុំចុះបញ្ជីម៉ាក និងកាលបរិច្ឆេទដាក់ពាក្យស្នើសុំ

១-មន្ត្រីកាន់កាប់បញ្ជី ត្រូវកត់ត្រានៅលើសំណុំឯកសារ នៃពាក្យស្នើសុំចុះបញ្ជីម៉ាកនីមួយៗនូវកាលបរិច្ឆេទពិតប្រាកដ និង លេខរៀងដាក់ពាក្យនៃពាក្យស្នើសុំចុះបញ្ជី ដោយមានសរសេរអក្សរ KH ភ្ជាប់នឹងរបាផ្ទៀង ហើយសរសេរលេខចំនួន ០៥ (ប្រាំ) ខ្ទង់យ៉ាងតិច ដែលកំណត់តាមលំដាប់លំដោយបន្តបន្ទាប់ ព្រមទាំងលេខចុងក្រោយពីរខ្ទង់នៃឆ្នាំ ដែលទទួលបានសំណុំឯកសារ ពាក្យស្នើសុំចុះបញ្ជីម៉ាកនោះ ។ នៅពេលដែលមានការកែតម្រូវណាមួយ ឬនៅពេលដែលទទួលបានឯកសារដទៃទៀត ដែលដាក់ជូនក្នុងកាលបរិច្ឆេទខុសគ្នានោះ មន្ត្រីកាន់កាប់បញ្ជីត្រូវកត់ត្រាកាលបរិច្ឆេទជាក់ស្តែង នៃការទទួលឯកសារទាំងនោះ ។

២-លេខដាក់ពាក្យស្នើសុំចុះបញ្ជីម៉ាក ដែលបានកំណត់នៅក្នុងកថាខ័ណ្ឌ (១) ខាងលើ ត្រូវយកមកប្រើក្នុងគ្រប់ទំនាក់ទំនង ជាបន្តបន្ទាប់ ដែលពាក់ព័ន្ធនឹងការស្នើសុំចុះបញ្ជីម៉ាក ។

៣-មន្ត្រីកាន់កាប់បញ្ជី ត្រូវផ្តល់នូវកាលបរិច្ឆេទ នៃការដាក់ពាក្យស្នើសុំចុះបញ្ជីម៉ាក នៅពេលពាក្យស្នើសុំចុះបញ្ជី បំពេញបាននូវព័ត៌មានគ្រប់គ្រាន់ និងត្រឹមត្រូវដូចខាងក្រោម ៖

ក- ឈ្មោះរបស់អ្នកដាក់ពាក្យស្នើសុំចុះបញ្ជីម៉ាក

ខ- អាសយដ្ឋានទំនាក់ទំនង

គ- គំរូម៉ាក ដែលស្នើសុំចុះបញ្ជី

ឃ- យថាប្រភេទរបស់ទំនិញ ឬសេវា ដែលស្នើសុំចុះបញ្ជីក្នុងចំណាត់ថ្នាក់នីមួយៗ

ង- កម្រៃនៃការដាក់ពាក្យស្នើសុំចុះបញ្ជីម៉ាក ដែលតម្រូវសម្រាប់ចំណាត់ថ្នាក់នីមួយៗ នៃទំនិញ ឬសេវា ដែលស្នើសុំចុះបញ្ជីម៉ាក ។

៤-មន្ត្រីកាន់កាប់បញ្ជី ត្រូវចេញលិខិតទទួលស្គាល់ការដាក់ពាក្យ ជាលាយលក្ខណ៍អក្សរ ទៅអ្នកដាក់ពាក្យស្នើសុំចុះបញ្ជីម៉ាក នូវលេខរៀង និងកាលបរិច្ឆេទ នៃការដាក់ពាក្យស្នើសុំ ។

មាត្រា ១៧. – ការច្រានចោលការដាក់ពាក្យស្នើសុំចុះបញ្ជី ឬការយល់ព្រមទទួលដោយមានលក្ខខណ្ឌចំពោះការចុះបញ្ជី និងសវនាការ

១-នៅពេលពិនិត្យសំណុំឯកសារ ពាក្យស្នើសុំចុះបញ្ជីម៉ាក ដែលធ្វើឡើងតាមមាត្រា៨ (ក) នៃច្បាប់ ប្រសិនបើ មន្ត្រីកាន់កាប់បញ្ជីសម្រេចច្រានចោល ពាក្យស្នើសុំចុះបញ្ជីម៉ាកណាមួយ មន្ត្រីកាន់កាប់បញ្ជី ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរ អំពីការច្រានចោលនោះ ទៅអ្នកដាក់ពាក្យស្នើសុំដោយភ្ជាប់នូវព័ត៌មានលំអិតទាំងអស់ ដែលពាក់ព័ន្ធនឹងសេចក្តីសម្រេចរបស់ខ្លួន ហើយស្នើឱ្យអ្នកដាក់ពាក្យស្នើសុំធ្វើការកែតម្រូវពាក្យស្នើសុំចុះបញ្ជីរបស់ខ្លួន និងឆ្លើយតបទៅមន្ត្រីកាន់កាប់បញ្ជី ជាលាយលក្ខណ៍អក្សរ ឬធ្វើការដាក់ពាក្យស្នើសុំធ្វើសវនាការ ក្នុងរយៈពេល ៤៥ (សែសិបប្រាំ) ថ្ងៃ គិតចាប់ពីពេលទទួលបានសេចក្តីជូនដំណឹងអំពី ការច្រានចោលនោះ ។ ប្រសិនបើ អ្នកដាក់ពាក្យស្នើសុំចុះបញ្ជីម៉ាកមិនបានអនុវត្តទៅតាមកាលកំណត់ នៃការជូនដំណឹងនេះទេ អ្នកដាក់ពាក្យស្នើសុំចុះបញ្ជីម៉ាកនោះ នឹងត្រូវចាត់ទុកថា បានដកពាក្យស្នើសុំចុះបញ្ជីម៉ាករបស់ខ្លួន ។

២-នៅពេលពិនិត្យខ្លឹមសារម៉ាក ដែលបានដាក់ពាក្យស្នើសុំចុះបញ្ជី ដោយធ្វើឡើងតាមមាត្រា៨ (ខ) នៃច្បាប់ ប្រសិនបើ មន្ត្រីកាន់កាប់បញ្ជីយល់ព្រមទទួលយកពាក្យស្នើសុំ ក្នុងលក្ខខណ្ឌនៃការកែតម្រូវ ការកែសម្រួល ការប្រកាសមិនទាមទារសិទ្ធិ លើចំណុចណាមួយរបស់ម៉ាក ឬការកម្រិតកំណត់សិទ្ធិ ឬ លក្ខខណ្ឌផ្សេងៗទៀត មន្ត្រីកាន់កាប់បញ្ជី ត្រូវជូនដំណឹងអំពីការសម្រេចរបស់ខ្លួនជាលាយលក្ខណ៍អក្សរ ទៅឱ្យអ្នកដាក់ពាក្យស្នើសុំ ។ ប្រសិនបើ អ្នកដាក់ពាក្យស្នើសុំចុះបញ្ជី មិនឯកភាពចំពោះការកែតម្រូវ ការកែសម្រួល ការប្រកាសមិនទាមទារសិទ្ធិ ឬការកម្រិតកំណត់នៃសិទ្ធិ ឬលក្ខខណ្ឌផ្សេងៗទៀត អ្នកដាក់ពាក្យស្នើសុំចុះបញ្ជីម៉ាក អាចដាក់ពាក្យស្នើសុំធ្វើសវនាការ ឬផ្តល់នូវការយល់ឃើញរបស់ខ្លួន ជាលាយលក្ខណ៍អក្សរ ក្នុងរយៈពេល ៦០ (ហុកសិប) ថ្ងៃ គិតចាប់ពីកាលបរិច្ឆេទទទួលបានសេចក្តីជូនដំណឹងពីមន្ត្រីកាន់កាប់បញ្ជី ។ ប្រសិនបើ អ្នកដាក់ពាក្យស្នើសុំចុះបញ្ជីម៉ាកឯកភាព ទៅនឹងសំណូមពរឱ្យធ្វើការកែតម្រូវ ការកែសម្រួល ការប្រកាសមិនទាមទារសិទ្ធិ ឬការកម្រិតកំណត់ នៃសិទ្ធិ ឬលក្ខខណ្ឌផ្សេងៗទៀត អ្នកដាក់ពាក្យស្នើសុំចុះបញ្ជីម៉ាក ត្រូវជូនដំណឹងទៅមន្ត្រីកាន់កាប់បញ្ជីវិញ ជាលាយលក្ខណ៍អក្សរ ហើយធ្វើការកែតម្រូវពាក្យស្នើសុំរបស់ខ្លួន ទៅតាមសេចក្តីជូនដំណឹងខាងលើ ។ ប្រសិនបើ អ្នកដាក់ពាក្យស្នើសុំចុះបញ្ជីម៉ាក មិនធ្វើការឆ្លើយតបតាមកាលកំណត់ និងតាមវិធីណាមួយក្នុងចំណោមវិធីខាងលើ អ្នកដាក់ពាក្យស្នើសុំចុះបញ្ជីម៉ាក ត្រូវចាត់ទុកថា បានបោះបង់ចោលពាក្យស្នើសុំចុះបញ្ជីម៉ាករបស់ខ្លួន ។

៣-ការស្នើសុំធ្វើសវនាការមួយ ត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ ដោយផ្ញើជូនទៅមន្ត្រីកាន់កាប់បញ្ជី។ នៅពេលដែលទទួលបានពាក្យស្នើសុំនេះ មន្ត្រីកាន់កាប់បញ្ជី ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរ ទៅអ្នកដាក់ពាក្យស្នើសុំចុះបញ្ជីម៉ាកយ៉ាងយូរ ០១ (មួយ)ខែ មុនកាលបរិច្ឆេទ ដែលអ្នកដាក់ពាក្យស្នើសុំចុះបញ្ជី ត្រូវអញ្ជើញមកចូលរួមក្នុងសវនាការ ។

មាត្រា ១៨. – ការបដិសេធពាក្យស្នើសុំចុះបញ្ជី ឬ ការយល់ព្រម ដោយមានលក្ខខណ្ឌរបស់មន្ត្រីកាន់កាប់បញ្ជី ដែលអ្នកដាក់ពាក្យស្នើសុំធ្វើការជំទាស់

១-បន្ទាប់ពីសវនាការ ឬបន្ទាប់ពីការពិនិត្យពិចារណា លើការស្នើសុំកែតម្រូវ ឬការផ្តល់យោបល់ជាលាយលក្ខណ៍អក្សរ ពីអ្នកដាក់ពាក្យស្នើសុំចុះបញ្ជី ប្រសិនបើ មន្ត្រីកាន់កាប់បញ្ជីនៅតែបដិសេធការចុះបញ្ជី ឬយល់ព្រមចុះបញ្ជី ដោយមានលក្ខខណ្ឌឱ្យមានការកែតម្រូវ ការកែសម្រួល ការឈប់ទាមទារសិទ្ធិ ឬការកម្រិតកំណត់សិទ្ធិ ឬលក្ខខណ្ឌផ្សេងៗទៀត ហើយអ្នកដាក់ពាក្យស្នើសុំចុះបញ្ជី នៅតែមិនយល់ព្រមទៅនឹងការប្រានចោល ឬការយល់ព្រមទទួលចុះបញ្ជីជូនដោយមានលក្ខខណ្ឌ មន្ត្រីកាន់កាប់បញ្ជី ត្រូវបដិសេធជាលាយលក្ខណ៍អក្សរ ទៅអ្នកដាក់ពាក្យស្នើសុំ អំពីសេចក្តីសម្រេចរបស់ខ្លួន ។ ក្នុងរយៈពេល ០១ (មួយ) ខែ ចាប់ពីកាលបរិច្ឆេទនៃការផ្តល់សេចក្តីជូនដំណឹងនេះ អ្នកដាក់ពាក្យស្នើសុំចុះបញ្ជី អាចស្នើសុំឱ្យមន្ត្រីកាន់កាប់បញ្ជី ធ្វើការបញ្ជាក់ជាលាយលក្ខណ៍អក្សរ អំពីមូលហេតុដែលនាំឱ្យឈានដល់សេចក្តីសម្រេចរបស់ខ្លួន ព្រមទាំងឯកសារយោងទាំងឡាយ ដែលប្រើប្រាស់នៅក្នុងការធ្វើសេចក្តីសម្រេចនេះ ។

២-អ្នកដាក់ពាក្យស្នើសុំចុះបញ្ជី មានសិទ្ធិប្តឹងតវ៉ា អំពីការបដិសេធមិនព្រមចុះបញ្ជី របស់មន្ត្រីកាន់កាប់បញ្ជី ទៅក្រុមប្រឹក្សាដោះស្រាយបណ្តឹងតវ៉ា នៃក្រសួងពាណិជ្ជកម្ម ឬទៅតុលាការមានសមត្ថកិច្ច ក្នុងរយៈពេល ០៣ (បី) ខែ គិតចាប់ពីថ្ងៃចេញសេចក្តីសម្រេច របស់មន្ត្រីកាន់កាប់បញ្ជី ។

៣-អនុលោមតាមមាត្រា៦២ នៃច្បាប់ ភាគីមានផលប្រយោជន៍ មានសិទ្ធិប្តឹងតវ៉ា អំពីសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាដោះស្រាយបណ្តឹងតវ៉ា នៃក្រសួងពាណិជ្ជកម្មទៅតុលាការមានសមត្ថកិច្ច ក្នុងរយៈពេល ០៣ (បី) ខែ គិតចាប់ពីថ្ងៃចេញសេចក្តីសម្រេច របស់ក្រុមប្រឹក្សាបណ្តឹងតវ៉ា ។

មាត្រា ១៩. – ការយល់ព្រមចំពោះការដាក់ពាក្យស្នើសុំចុះបញ្ជី ការចុះបញ្ជីម៉ាក ការបោះពុម្ពផ្សាយ និង ការចេញវិញ្ញាបនបត្រ

១-ប្រសិនបើ មន្ត្រីកាន់កាប់បញ្ជីយល់ព្រម ចំពោះការដាក់ពាក្យស្នើសុំចុះបញ្ជីម៉ាក ដោយមាន ឬ គ្មានលក្ខខណ្ឌ ឬការកម្រិតកំណត់ណាមួយ ដែលលក្ខខណ្ឌ និងការកំណត់ទាំងនោះ ត្រូវបានយល់ព្រម ដោយអ្នកដាក់ពាក្យស្នើសុំចុះបញ្ជី មន្ត្រីកាន់កាប់បញ្ជីត្រូវចុះបញ្ជីម៉ាក និងចេញវិញ្ញាបនបត្រ នៃការ

ចុះបញ្ជីម៉ាកជូនអ្នកដាក់ពាក្យស្នើសុំចុះបញ្ជី ហើយត្រូវបោះពុម្ពផ្សាយការចុះបញ្ជីម៉ាកនោះ នៅក្នុងព្រឹត្តិបត្រផ្លូវការរបស់ក្រសួងពាណិជ្ជកម្ម ។

២-មន្ត្រីកាន់កាប់បញ្ជី ត្រូវផ្តល់នូវលេខរៀងមួយតាមលំដាប់លំដោយ នៃការចុះបញ្ជីម៉ាកនៅលើវិញ្ញាបនបត្រចុះបញ្ជី ។

៣-ការចុះបញ្ជីម៉ាកមួយត្រូវមាន ៖

ក- គំរូម៉ាក ដែលត្រូវបានចុះបញ្ជី

ខ- លេខដាក់ពាក្យ និង លេខចុះបញ្ជី

គ- ឈ្មោះ និង អាសយដ្ឋានរបស់ម្ចាស់ម៉ាក ដែលស្នើសុំចុះបញ្ជី

ឃ- ឈ្មោះ និង អាសយដ្ឋានរបស់ភ្នាក់ងារតំណាង (ប្រសិនបើមាន)

ង- កាលបរិច្ឆេទនៃការដាក់ពាក្យ និងកាលបរិច្ឆេទនៃការចុះបញ្ជី

ច- ប្រសិនបើសិទ្ធិអាទិភាពត្រូវបានទាមទារ ហើយការទាមទារសិទ្ធិនោះត្រូវបានយល់ព្រម ត្រូវបញ្ជាក់ឈ្មោះ រដ្ឋ ឬប្រទេស និងលេខដាក់ពាក្យដែលបានដាក់ពាក្យស្នើសុំលើកដំបូង ។

ឆ- ចំណាត់ថ្នាក់ និង ទំនិញ ឬសេវាដែលជាកម្មវត្ថុនៃការចុះបញ្ជីម៉ាក ដោយមានបញ្ជាក់អំពីចំណាត់ថ្នាក់នៃទំនិញ ឬសេវានោះ ស្របតាមចំណាត់ថ្នាក់អន្តរជាតិ ។

៤-ការបោះពុម្ពផ្សាយការចុះបញ្ជីម៉ាកមួយ ដែលបានកំណត់ក្នុងកថាខណ្ឌ (១) ខាងលើ ត្រូវមានព័ត៌មានមួយចំនួនដូចតទៅ ៖

ក- កាលបរិច្ឆេទនៃការដាក់ពាក្យស្នើសុំចុះបញ្ជីម៉ាក និង កាលបរិច្ឆេទនៃសិទ្ធិអាទិភាព (ប្រសិន បើមាន)

ខ- គំរូម៉ាក ដែលបានចុះបញ្ជី

គ- លេខដាក់ពាក្យ និង លេខចុះបញ្ជី

ឃ- ចំណាត់ថ្នាក់ និង ទំនិញ ឬ សេវា ដែលជាកម្មវត្ថុនៃការចុះបញ្ជីម៉ាក ដោយមានបញ្ជាក់អំពីចំណាត់ថ្នាក់នៃទំនិញ ឬសេវានោះ ស្របតាមចំណាត់ថ្នាក់អន្តរជាតិ

ង- ឈ្មោះ និងអាសយដ្ឋានរបស់ម្ចាស់ម៉ាក ដែលបានចុះបញ្ជី

ច- ឈ្មោះ និងអាសយដ្ឋានរបស់ភ្នាក់ងារតំណាង (ប្រសិនបើមាន) ។

មាត្រា ២០. – បណ្តឹងជំទាស់

១-ក្នុងរយៈពេល ៩០ (កៅសិប) ថ្ងៃ គិតចាប់តាំងពីកាលបរិច្ឆេទ នៃការបោះពុម្ពផ្សាយ ដូចមាន ចែងក្នុងមាត្រា១៩នៃអនុក្រឹត្យនេះរាល់លិខិតជំទាស់របស់ជនណា ដែលមានការពាក់ព័ន្ធនឹងការចុះបញ្ជីម៉ាក តាមមាត្រា១០ (គ) នៃច្បាប់ ត្រូវធ្វើឡើងតាមគំរូដែលកំណត់ ដោយក្រសួងពាណិជ្ជកម្ម ព្រមទាំងភ្ជាប់មកជាមួយនូវឯកសារគាំទ្រនានាជាភស្តុតាងផង ។

២-អនុលោមតាមមាត្រា១០ (ង) នៃច្បាប់ ក្នុងរយៈពេល ៩០ (កៅសិប) ថ្ងៃ គិតពីកាលបរិច្ឆេទ នៃការជូនដំណឹងពីបណ្តឹងជំទាស់ អ្នកដាក់ពាក្យស្នើសុំចុះបញ្ជី ត្រូវផ្តល់អំណះអំណាងជាចម្លើយតបវិញ ជាលាយលក្ខណ៍អក្សរ ដោយបញ្ជាក់ពីហេតុផលជាមូលដ្ឋាន ក្នុងការដាក់ពាក្យស្នើសុំចុះបញ្ជីម៉ាករបស់ខ្លួន និងមានភ្ជាប់មកជាមួយនូវឯកសារគាំទ្រនានាជាភស្តុតាងផង ។

មាត្រា ២១. – សេចក្តីប្រកាសអំពីការប្រើប្រាស់ ឬមិនបានប្រើប្រាស់ម៉ាក និង ភស្តុតាង

១-ដើម្បីរក្សាសុពលភាពនៃការចុះបញ្ជីម៉ាក ឬការចុះបញ្ជីម៉ាកសាឡើងវិញ ម្ចាស់ម៉ាកដែលបានចុះបញ្ជីរួច ត្រូវប្រកាសអំពីការប្រើប្រាស់ម៉ាក ឬមិនបានប្រើប្រាស់ម៉ាកក្នុងរយៈពេល ០១ (មួយ) ឆ្នាំ បន្ទាប់ពីខួបលើកទី ៥ (ប្រាំ) នៃកាលបរិច្ឆេទចុះបញ្ជីម៉ាក ។

២-នៅពេលម៉ាក ត្រូវបានចុះបញ្ជីសាឡើងវិញ ម្ចាស់ម៉ាកត្រូវប្រកាសអំពីការប្រើប្រាស់ម៉ាក ឬមិនបានប្រើប្រាស់ម៉ាករបស់ខ្លួន ក្នុងរយៈពេល ០១ (មួយ) ឆ្នាំ បន្ទាប់ពីខួបលើកទី ០៥ (ប្រាំ) នៃកាលបរិច្ឆេទចុះបញ្ជីសាឡើងវិញ ។

៣-សេចក្តីប្រកាសអំពីការប្រើប្រាស់ ឬមិនបានប្រើប្រាស់ម៉ាក ត្រូវធ្វើឡើងតាមគំរូដែលបានកំណត់ ដោយក្រសួងពាណិជ្ជកម្ម និងត្រូវបង់កម្រៃតាមប្រកាសអន្តរក្រសួង របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និង ក្រសួងពាណិជ្ជកម្ម ។

៤-ម៉ាកដែលបានចុះបញ្ជីរួច នឹងត្រូវលុបចេញពីបញ្ជីវិញ ក្នុងករណីដែលម្ចាស់ម៉ាក ឬភ្នាក់ងារតំណាងខកខានមិនបានប្រកាស អំពីការប្រើប្រាស់ ឬមិនបានប្រើប្រាស់ម៉ាកនោះ ដូចដែលបានកំណត់ក្នុងកថាខណ្ឌ (១) ខាងលើ ។

មាត្រា ២២. – ការចុះបញ្ជីម៉ាកសាជាថ្មីឡើងវិញ

១-ពាក្យស្នើសុំចុះបញ្ជីម៉ាកសាជាថ្មីឡើងវិញ តាមមាត្រា១២ (ខ) នៃច្បាប់ អាចធ្វើឡើងក្នុងរយៈពេល ០៦ (ប្រាំមួយ) ខែ មុនពេលផុតសុពលភាព នៃការចុះបញ្ជីម៉ាក ហើយពាក្យស្នើសុំចុះបញ្ជីសាជាថ្មីឡើងវិញនេះ ត្រូវចុះហត្ថលេខាដោយម្ចាស់ម៉ាក ដែលបានចុះបញ្ជីរួច ឬដោយភ្នាក់ងារតំណាងរបស់ខ្លួន ។

២-ការចុះបញ្ជីម៉ាកសាជាថ្មីឡើងវិញ អាចធ្វើឡើងបាន ដោយមានការទូទាត់កម្រៃនៃការចុះបញ្ជីម៉ាកសាជាថ្មីឡើងវិញ ដែលត្រូវធ្វើនៅក្នុងរយៈពេលកំណត់ ដូចមានចែងនៅក្នុងកថាខ័ណ្ឌ (១) ខាងលើ ឬ ធ្វើឡើងក្នុងរយៈពេលនៃការអនុគ្រោះ ដែលអនុញ្ញាតដោយមាត្រា១២ (ឃ) នៃច្បាប់ ។

៣-ការចុះបញ្ជីម៉ាកសាជាថ្មីឡើងវិញ ត្រូវតែកត់ត្រានៅក្នុងបញ្ជីម៉ាក ហើយត្រូវបោះពុម្ពផ្សាយក្នុងព្រឹត្តិបត្រផ្លូវការ ។

៤-មន្ត្រីកាន់កាប់បញ្ជីត្រូវចេញវិញ្ញាបនបត្រ នៃការចុះបញ្ជីម៉ាកសាជាថ្មីឡើងវិញ ទៅឱ្យម្ចាស់ម៉ាក ដែលបានចុះបញ្ជីរួច ហើយវិញ្ញាបនបត្រនោះត្រូវមានព័ត៌មានដូចខាងក្រោម :

ក- លេខចុះបញ្ជីដើមរបស់ម៉ាក

ខ- គំរូម៉ាក

គ- កាលបរិច្ឆេទនៃការចុះបញ្ជីម៉ាកសាជាថ្មីឡើងវិញ និងកាលបរិច្ឆេទផុតកំណត់

ឃ- ឈ្មោះ និង អាសយដ្ឋានរបស់ម្ចាស់ម៉ាក ដែលបានចុះបញ្ជីរួច

ង- ឈ្មោះ និង អាសយដ្ឋានរបស់ភ្នាក់ងារតំណាង (ប្រសិនមាន)

ច- ទំនិញ ឬសេវា ដែលជាកម្មវត្ថុនៃការចុះបញ្ជីម៉ាក ដោយមានការបញ្ជាក់អំពីចំណាត់ថ្នាក់ នៃទំនិញ ឬសេវាស្របតាមចំណាត់ថ្នាក់អន្តរជាតិ ។

ផ្នែកទី ២
ម៉ាកសមូហភាព និងមោឃភាពនៃការចុះបញ្ជី

មាត្រា ២៣. - ម៉ាកសមូហភាព

មាត្រា៩ រហូតដល់មាត្រា២២ នៃអនុក្រឹត្យនេះ ត្រូវយកមកអនុវត្តចំពោះម៉ាកសមូហភាព តាមលក្ខខណ្ឌតម្រូវមួយចំនួនដូចខាងក្រោម ៖

១-ការទទួលយកពាក្យស្នើសុំចុះបញ្ជីម៉ាកសមូហភាព លុះត្រាតែនៅក្នុងពាក្យស្នើសុំចុះបញ្ជីនោះត្រូវកំណត់ថា ជាម៉ាកសមូហភាព និងមានភ្ជាប់មកជាមួយ នូវច្បាប់ចម្លងនៃបទបញ្ជារួមគ្រប់គ្រងការប្រើប្រាស់ម៉ាកនោះមួយច្បាប់ ដោយមានការបញ្ជាក់ត្រឹមត្រូវ ពីអ្នកដាក់ពាក្យស្នើសុំចុះបញ្ជីម៉ាក ។ ការបញ្ជាក់ ដែលធ្វើឡើង ដោយអ្នកដាក់ពាក្យស្នើសុំចុះបញ្ជីម៉ាក នោះពុំចាំបាច់តម្រូវឱ្យមានការធ្វើនីត្យានុកូលកម្ម ណាមួយឡើយ ។

២-បទបញ្ជារួមស្តីពីការគ្រប់គ្រងការប្រើប្រាស់ម៉ាកសមូហភាព ត្រូវកំណត់[illegible] គុណភាពរបស់ទំនិញ ឬសេវាដែលម៉ាកសមូហភាពនោះ ត្រូវជ្រើសរើសយកទៅប្រើ[illegible]

លក្ខខណ្ឌទាំងឡាយ ដែលបុគ្គលប្រើប្រាស់ម៉ាកសមូហភាពនោះ ត្រូវធ្វើតាម ។ បទបញ្ជានោះ ត្រូវផ្តល់នូវការត្រួតពិនិត្យប្រកបដោយប្រសិទ្ធភាព ចំពោះការប្រើប្រាស់ម៉ាកសមូហភាព ដោយស្របទៅតាមប្រការនានានៃបទបញ្ជានោះ ហើយត្រូវកំណត់នូវទណ្ឌកម្មសមល្មម ចំពោះរាល់ការប្រើប្រាស់ដែលផ្ទុយទៅនឹងបទបញ្ជានោះ ។

៣-ច្បាប់ចម្លងមួយច្បាប់ នៃបទបញ្ជារួមស្តីពីការគ្រប់គ្រងការប្រើប្រាស់ម៉ាកសមូហភាព ត្រូវភ្ជាប់បន្ថែមមកជាមួយនឹងការចុះបញ្ជីម៉ាកសមូហភាពមួយ ។

៤-ការបោះពុម្ពផ្សាយការចុះបញ្ជីម៉ាកសមូហភាព តាមមាត្រា១៩ (១) នៃអនុក្រឹត្យនេះ ត្រូវរួមបញ្ចូលសេចក្តីសង្ខេបនៃបទបញ្ជារួម ស្តីពីការគ្រប់គ្រងការប្រើប្រាស់ម៉ាកសមូហភាព ដែលបានភ្ជាប់បន្ថែមទៅនឹងការចុះបញ្ជីម៉ាកសមូហភាព ។

៥-សេចក្តីជូនដំណឹងអំពីការផ្លាស់ប្តូរព័ត៌មាននានា ដែលប៉ះពាល់ដល់បទបញ្ជារួម ស្តីពីការគ្រប់គ្រងការប្រើប្រាស់ម៉ាកសមូហភាព ចាំបាច់ត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ ។

៦-គ្រប់សេចក្តីជូនដំណឹង អំពីការផ្លាស់ប្តូរព័ត៌មានបែបនេះ ចាំបាច់ត្រូវកត់ត្រានៅក្នុងបញ្ជីម៉ាក ។ រាល់ការផ្លាស់ប្តូរព័ត៌មានទាំងឡាយណា នៅក្នុងបទបញ្ជារួម ស្តីពីការគ្រប់គ្រងការប្រើប្រាស់ម៉ាក នឹងពុំមានប្រសិទ្ធភាពជាធរមានទេ រហូតទាល់តែការកត់ត្រានេះត្រូវបានធ្វើឡើង ។ សេចក្តីសង្ខេបអំពីការផ្លាស់ប្តូរព័ត៌មាន ដែលបានកត់ត្រារួច ចាំបាច់ត្រូវបោះពុម្ពផ្សាយជាសាធារណៈ ។

៧-ក្នុងគោលបំណងនៃការប្រើប្រាស់ម៉ាកសមូហភាព ដែលទាក់ទងនឹងមាត្រា១៥ និង មាត្រា១៦ នៃច្បាប់ ម្ចាស់ម៉ាកសមូហភាពដែលបានចុះបញ្ជីរួច អាចប្រើប្រាស់ម៉ាកសមូហភាពនោះ ដោយខ្លួនឯងបាន លុះត្រាតែម៉ាកនោះ ត្រូវបានប្រើប្រាស់ផងដែរដោយបុគ្គលដទៃទៀត ដែលបានទទួលសិទ្ធិតាមបទបញ្ជារួម ស្តីពីការគ្រប់គ្រងការប្រើប្រាស់ម៉ាកនេះ ។ ការប្រើប្រាស់ម៉ាកសមូហភាព ដោយបុគ្គលទាំងនោះ ត្រូវបានចាត់ទុកថា ម៉ាកនោះបានប្រើប្រាស់ ដោយម្ចាស់ម៉ាកដែលបានចុះបញ្ជីរួច ។

មាត្រា ២៤. – មោឃភាព និង ការលុបម៉ាកចេញពីបញ្ជីដោយផ្អែកលើការមិនបានប្រើប្រាស់

១-អនុលោមតាមមាត្រា១០ (គ) មាត្រា១៣ និង មាត្រា១៥ នៃច្បាប់ ភាគីដែលមានផលប្រយោជន៍ មានសិទ្ធិដាក់ពាក្យស្នើសុំមោឃភាព ចំពោះការចុះបញ្ជីម៉ាក ទោះផុតកំណត់រយៈពេល ៩០ (កៅសិប) ថ្ងៃ បន្ទាប់ពីការបោះពុម្ពផ្សាយ ក្នុងព្រឹត្តិបត្រផ្លូវការក៏ដោយ ។

២-អនុលោមតាមមាត្រា១៣ (ខ) នៃច្បាប់ មន្ត្រីកាន់កាប់បញ្ជី មានសិទ្ធិលុបម៉ាកចេញពីបញ្ជី នៅពេលម្ចាស់ម៉ាកដែលបានចុះបញ្ជី មិនបានបំពេញតាមលក្ខខណ្ឌណាមួយ នៃមាត្រា២ ចំណុច ... និង មាត្រា៤ នៃច្បាប់ ។

៣-អនុលោមតាមមាត្រា១៤ (ង) មាត្រា២២ មាត្រា២៣ និង មាត្រា២៨ នៃច្បាប់ ម៉ាកមួយ ត្រូវបានលុបចេញពីបញ្ជី នៅពេលម្ចាស់ម៉ាក ឬអ្នកទទួលសិទ្ធិបានប្រើប្រាស់ម៉ាកនោះ ខុសទម្រង់ដើម ដែលបានចុះបញ្ជី ហើយរំលោភបំពានទៅលើម៉ាករបស់អ្នកផ្សេង ដែលបានចុះបញ្ជីរួច ។

៤-អនុលោមតាមមាត្រា៤ (ង) មាត្រា១៤ (ង) មាត្រា២២ មាត្រា២៣ និង មាត្រា២៨ នៃច្បាប់ ម៉ាកមួយ ត្រូវបានលុបចេញពីបញ្ជីនៅពេលម្ចាស់ម៉ាកនោះ ឬអ្នកទទួលសិទ្ធិបានបន្ថែមស្លាកសញ្ញា ដូច ឬស្រដៀង ធ្វើឱ្យភន្តច្រឡំ ទៅនឹងស្លាកសញ្ញាល្បីរបស់អ្នកផ្សេង ដែលបានប្រើប្រាស់មុន ។

៥-ការលុបម៉ាកមួយចេញពីបញ្ជី ចាំបាច់ត្រូវតែបោះពុម្ពផ្សាយក្នុងព្រឹត្តិបត្រផ្លូវការ ។

៦-មានតែការលុបម៉ាកចេញពីបញ្ជី ដោយផ្អែកលើមូលហេតុមិនបានប្រកាស អំពីការប្រើប្រាស់ ឬមិនបានប្រើប្រាស់ម៉ាកតែម្យ៉ាងគត់ ដែលត្រូវបានអនុញ្ញាតឱ្យចុះបញ្ជីឡើងវិញ តាមការស្នើសុំរបស់ ម្ចាស់ម៉ាក ឬភ្នាក់ងារតំណាងក្នុងរយៈពេលមិនលើសពី ៦០ (ហុកសិប) ថ្ងៃ គិតពីថ្ងៃសម្រេចលុប ។

៧-ក្រោយពីមានសេចក្ដីសម្រេច របស់មន្ត្រីកាន់កាប់បញ្ជី អំពីការផ្ដល់មោឃភាពនៃការចុះបញ្ជី ឬ រក្សាទុកការចុះបញ្ជី ឬមួយសម្រេចឱ្យកែតម្រូវម៉ាកដែលបានចុះបញ្ជី បើភាគីណាមួយមិនយល់ព្រមនឹង សេចក្ដីសម្រេចនោះ អាចប្ដឹងតវ៉ាទៅក្រុមប្រឹក្សាដោះស្រាយបណ្ដឹងតវ៉ា របស់ក្រសួងពាណិជ្ជកម្ម ឬប្ដឹងទៅតុលាការមានសមត្ថកិច្ច ក្នុងរយៈពេល ០៣ (បី) ខែ បន្ទាប់ពីថ្ងៃចេញសេចក្ដីសម្រេច ។

៨-អនុលោមតាមមាត្រា៦២ នៃច្បាប់ ភាគីមានផលប្រយោជន៍ មានសិទ្ធិប្ដឹងតវ៉ា អំពីសេចក្ដី សម្រេចរបស់ក្រុមប្រឹក្សាដោះស្រាយបណ្ដឹងតវ៉ា របស់ក្រសួងពាណិជ្ជកម្ម ទៅតុលាការមានសមត្ថកិច្ច ក្នុង រយៈពេល ០៣ (បី) ខែ បន្ទាប់ពីថ្ងៃចេញសេចក្ដីសម្រេច ។

៩-ការបង្កើតក្រុមប្រឹក្សាប្ដឹងតវ៉ា សមាសភាព និង ដែនអំណាចនៃក្រុមប្រឹក្សាប្ដឹងតវ៉ា និង នីតិវិធីដោះស្រាយទំនាស់នឹងត្រូវកំណត់ ដោយប្រកាសរបស់ក្រសួងពាណិជ្ជកម្ម ។

១០-អនុលោមតាមមាត្រា៦២ នៃច្បាប់ នៅពេលតុលាការសម្រេចលើបណ្ដឹងតវ៉ា តម្រូវឱ្យ លុបម៉ាកចេញពីបញ្ជី ឬរក្សាទុក ឬកែតម្រូវម៉ាក មន្ត្រីកាន់កាប់បញ្ជី ត្រូវអនុវត្តតាមសេចក្ដីសម្រេចនោះ ។

ផ្នែកទី ៣

ការកំណត់បែបបទរដ្ឋបាលសម្រួលដល់ការចុះបញ្ជី និងការដោះស្រាយ វិវាទ ព្រមទាំងការផ្ទេរសិទ្ធិ

មាត្រា ២៥. - អាសយដ្ឋានសម្រាប់ទាក់ទង

អ្នកដាក់ពាក្យស្នើសុំចុះបញ្ជីម៉ាក ចាំបាច់ត្រូវផ្ដល់មកឱ្យមន្ត្រីកាន់កាប់បញ្ជី នូវអាសយដ្ឋានសម្រាប់ ទាក់ទងនៅក្នុងប្រទេសកម្ពុជា ដែលប្រើប្រាស់ក្នុងគោលបំណងនៃការដាក់ពាក្យ ។

ជនទាំងឡាយណា ដែលពាក់ពន្ធ័នឹងកិច្ចការនានាទាក់ទងនឹងម៉ាក ត្រូវផ្តល់អាសយដ្ឋានទាក់ទងក្នុងប្រទេសកម្ពុជាដល់មន្ត្រីកាន់កាប់បញ្ជី ។

មាត្រា ២៦. – ការផ្លាស់ប្តូរឈ្មោះ អាសយដ្ឋាន ឬ អាសយដ្ឋានសម្រាប់ទាក់ទង

១-ការស្នើសុំប្តូរឈ្មោះ សញ្ជាតិ អាសយដ្ឋាន ឬអាសយដ្ឋានសម្រាប់ទាក់ទង ចំពោះពាក្យស្នើសុំចុះបញ្ជីម៉ាក ឬម៉ាកដែលបានចុះបញ្ជីរួច ត្រូវធ្វើជាលាយលក្ខណ៍អក្សរ ហើយត្រូវទូទាត់កម្រៃ ដូចមានចែងក្នុងប្រកាសអន្តរក្រសួងរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងពាណិជ្ជកម្ម ។

២-មុនពេលអនុវត្តតាមសំណើនៃការសុំប្តូរឈ្មោះ សញ្ជាតិ អាសយដ្ឋាន ឬ អាសយដ្ឋាន ទាក់ទង មន្ត្រីកាន់កាប់បញ្ជីត្រូវទាមទាររកភស្តុតាងនៃការសុំប្តូរនោះ ។

៣-ប្រសិនបើសំណើសុំប្តូរឈ្មោះ សញ្ជាតិ អាសយដ្ឋាន ឬអាសយដ្ឋានសម្រាប់ទាក់ទង ត្រូវបានអនុញ្ញាត មន្ត្រីកាន់កាប់បញ្ជី ត្រូវធ្វើការកែតម្រូវ ពាក្យស្នើសុំចុះបញ្ជីម៉ាក ឬកត់ត្រាក្នុងបញ្ជីដើមនៃម៉ាក និង កត់ត្រាក្នុងបញ្ជីម៉ាក ។

មាត្រា ២៧. – ការប្តូរម្ចាស់កម្មសិទ្ធិ កិច្ចសន្យាផ្តល់អាជ្ញាប័ណ្ណ

១-សំណើសុំប្តូរម្ចាស់កម្មសិទ្ធិ ដែលអនុញ្ញាតដោយច្បាប់តាមមាត្រា៤៨ ត្រូវធ្វើឡើងតាមគំរូដែលមានចែងក្នុងប្រកាសរបស់ក្រសួងពាណិជ្ជកម្ម រួចផ្ញើជូនមកមន្ត្រីកាន់កាប់បញ្ជី ដោយត្រូវទូទាត់កម្រៃ ដូចមានចែងក្នុងប្រកាសអន្តរក្រសួងរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងពាណិជ្ជកម្ម ។

២-ការបោះពុម្ពផ្សាយជាសាធារណៈ អំពីការប្តូរម្ចាស់កម្មសិទ្ធិ ត្រូវបញ្ជាក់នូវព័ត៌មានដូចតទៅ ៖

ក- ម៉ាក ដែលពាក់ព័ន្ធនឹងការប្តូរម្ចាស់កម្មសិទ្ធិនេះ

ខ- លេខដាក់ពាក្យ និង លេខចុះបញ្ជី

គ- កាលបរិច្ឆេទនៃការដាក់ពាក្យស្នើសុំចុះបញ្ជីម៉ាក កាលបរិច្ឆេទទាមទារសិទ្ធិអាទិភាព (ប្រសិនបើមាន) និងកាលបរិច្ឆេទនៃការចុះបញ្ជីម៉ាក

ឃ- ឈ្មោះ អាសយដ្ឋានម្ចាស់ម៉ាកដើម និង ឈ្មោះ អាសយដ្ឋានម្ចាស់ម៉ាកថ្មី ដែលពាក់ព័ន្ធ នឹងការប្តូរម្ចាស់កម្មសិទ្ធិនេះ

ង- ថ្ងៃ ខែ ឆ្នាំ ប្តូរឈ្មោះម្ចាស់កម្មសិទ្ធិ ។

៣-កិច្ចសន្យាផ្តល់អាជ្ញាប័ណ្ណ ដែលបានដាក់ជូនមន្ត្រីកាន់កាប់បញ្ជី ដើម្បីស្នើសុំធ្វើការកត់ត្រាតាមមាត្រា៥២ នៃច្បាប់ ត្រូវភ្ជាប់មកជាមួយនូវវិញ្ញាបនបត្រថតចម្លងមួយច្បាប់ នៃវិញ្ញាបនបត្រកម្មសិទ្ធិ និងកិច្ចសន្យាផ្តល់អាជ្ញាប័ណ្ណច្បាប់ដើម ឬច្បាប់ចម្លង ដែលបញ្ជាក់ភាពត្រឹមត្រូវមួយច្បាប់ ។

មាត្រា ២៨. – ការចាត់តាំងភ្នាក់ងារតំណាង អាសយដ្ឋានសម្រាប់ទាក់ទង

ការចាត់តាំងភ្នាក់ងារតំណាងមួយ ត្រូវធ្វើឡើងដោយមានលិខិតប្រគល់សិទ្ធិ ដែលត្រូវបញ្ជាក់ភាពស្របច្បាប់ និងចុះហត្ថលេខា ដោយអ្នកដាក់ពាក្យស្នើសុំចុះបញ្ជីម៉ាក ឬប្រសិនបើអ្នកដាក់ពាក្យស្នើសុំចុះបញ្ជីម៉ាកច្រើននាក់ ការចុះហត្ថលេខាត្រូវធ្វើឡើង ដោយអ្នកដាក់ពាក្យស្នើសុំចុះបញ្ជីម៉ាកទាំងនោះ ។ អាសយដ្ឋានរបស់ភ្នាក់ងារតំណាង ត្រូវបានចាត់ទុកថាជាអាសយដ្ឋានប្រើប្រាស់សម្រាប់ទាក់ទងរវាងបុគ្គលម្នាក់ ឬ ច្រើននាក់ដែលត្រូវបានចាត់តាំងជាភ្នាក់ងារតំណាង ហើយព័ត៌មានផ្សេងៗត្រូវផ្ញើតាមរយៈភ្នាក់ងារតំណាងនោះ ។

មាត្រា ២៩. – ចំនួនថ្ងៃដែលពុំត្រូវរាប់បញ្ចូល

នៅពេលដែលថ្ងៃចុងក្រោយសម្រាប់បំពេញការងារ ឬសម្រាប់ចាត់វិធានការណាមួយ ត្រូវចំថ្ងៃឈប់សម្រាក ថ្ងៃបន្ទាប់ត្រូវបានចាត់ទុកថា ស្របច្បាប់ ចំពោះការបំពេញការងារ ឬ ចាត់វិធានការ ។

មាត្រា ៣០. – ការស្នើសុំពិនិត្យបញ្ជីម៉ាក និងការស្នើសុំដកស្រង់ព័ត៌មានពីបញ្ជីម៉ាក

ការស្នើសុំពិគ្រោះយោបល់អំពីបញ្ជីម៉ាក ត្រូវបានអនុញ្ញាត ដោយផ្អែកតាមសំណើជាលាយលក្ខណ៍អក្សរ របស់ភាគីណាមួយដែលមានផលប្រយោជន៍ មន្ត្រីកាន់កាប់បញ្ជី ត្រូវធ្វើការថតចម្លងឯកសារក្នុងបញ្ជីម៉ាក និងឯកសារដទៃទៀត ព្រមទាំងបញ្ជាក់ភាពត្រឹមត្រូវផង ។

មាត្រា ៣១. – ការកែតម្រូវកំហុស

ការកែតម្រូវកំហុសតាមមាត្រាទី៥៦ នៃច្បាប់ អាចធ្វើឡើងដោយមន្ត្រីកាន់កាប់បញ្ជី នៅពេលបានទទួលសំណើជាលាយលក្ខណ៍អក្សរ ហើយដែលសំណើនោះបានបំពេញតាមលក្ខខណ្ឌទាំងឡាយ ដែលមន្ត្រីកាន់កាប់បញ្ជីយល់ថា សមស្រប ឬ ធ្វើឡើងតាមគំនិតផ្តួចផ្តើមផ្ទាល់របស់មន្ត្រីកាន់កាប់បញ្ជី ។ រាល់ការកែតម្រូវ ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរ ទៅបុគ្គលទាំងអស់ដែលមានការពាក់ព័ន្ធ ហើយត្រូវបោះពុម្ពផ្សាយជាសាធារណៈ ដោយមន្ត្រីកាន់កាប់បញ្ជី បើយល់ឃើញថា ជាការចាំបាច់ ។

មាត្រា ៣២. – សវនាការ

១-មន្ត្រីកាន់កាប់បញ្ជី ត្រូវចាត់ចែងឱ្យមានសវនាការ បើភាគីណាមួយ ឬភាគីទាំងពីរនៃជំលោះស្នើសុំជាលាយលក្ខណ៍អក្សរ ឱ្យមានសវនាការមុនពេលចេញសេចក្តីសម្រេចណាមួយ ។ ពាក្យស្នើសុំសវនាការនេះ ត្រូវធ្វើឡើងនៅមុនពេល ឬក្រោយពេល ០១ (មួយ) ខែ នៃថ្ងៃដាក់ពាក្យបណ្តឹង ឬឯកសារគាំទ្ររបស់ខ្លួនមកមន្ត្រីកាន់កាប់បញ្ជី ។ ក្នុងករណីគ្មានពាក្យស្នើសុំសវនាការ [illegible] កំណត់ខាងលើ តាមឆន្ទានុសិទ្ធិដែលផ្តល់ដោយច្បាប់ ឬដោយអនុក្រឹត្យនេះ មន្ត្រីកាន់កាប់បញ្ជីអាច

ចេញសេចក្តីសម្រេចរបស់ខ្លួន ដោយគ្មានសវនាការ ឬបើយល់ថា ចាំបាច់ត្រូវអញ្ជើញភាគីនៃជម្លោះមកធ្វើសវនាការ ។

២-នៅពេលទទួលបានសំណើសុំធ្វើសវនាការ មន្ត្រីកាន់កាប់បញ្ជី ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរអំពីកាលបរិច្ឆេទ នៃការបើកសវនាការយ៉ាងតិច ០៧ (ប្រាំពីរ) ថ្ងៃ នៃថ្ងៃធ្វើការមុនពេលបើកសវនាការ ទៅឱ្យបុគ្គលដែលបានដាក់ពាក្យស្នើសុំធ្វើសវនាការ និងបុគ្គលដែលពាក់ព័ន្ធដទៃទៀត ។

មាត្រា ៣៣. – ទំនាក់ទំនងតាមរយៈប្រៃសណីយ៍

១-សេចក្តីជូនដំណឹង ពាក្យស្នើសុំ ឬឯកសារដទៃទៀត ដែលផ្ញើទៅឱ្យមន្ត្រីកាន់កាប់បញ្ជី តាមបញ្ញើប្រៃសណីយ៍ ត្រូវបានចាត់ទុកថា បានផ្តល់នៅត្រឹមកាលបរិច្ឆេទ ដែលបញ្ញើទាំងនោះត្រូវបានទទួលដោយការិយាល័យមន្ត្រីកាន់កាប់បញ្ជី។ នៅពេលទទួលបានឯកសារទាំងនោះ ការិយាល័យមន្ត្រីកាន់កាប់បញ្ជី ត្រូវវាយត្រាចូល ចុះលេខ ថ្ងៃ ខែ ឆ្នាំទទួលជាបន្ទាន់ ដើម្បីជាភស្តុតាងបញ្ជាក់ អំពីពេលវេលាទទួលឯកសារទាំងនោះ ។

២-កថាខណ្ឌ ១ ខាងលើ នឹងមិនត្រូវបានអនុវត្តទេ ចំពោះការកំណត់អំពីកាលបរិច្ឆេទដាក់ពាក្យក្នុងករណីផ្ទុយនឹងមាត្រា១៦ នៃអនុក្រឹត្យនេះ ។

មាត្រា ៣៤. – ភស្តុតាង

១-ភស្តុតាងទាំងឡាយដែលដាក់ជូនពិនិត្យ ត្រូវធ្វើឡើងតាមរយៈលិខិតប្រកាស ឬតាមរយៈលិខិតថ្លែងសច្ចា ។

២-ប្រសិនបើមន្ត្រីកាន់កាប់បញ្ជីយល់ថា សមស្របចំពោះករណីដោយឡែកណាមួយ មន្ត្រីកាន់កាប់បញ្ជី អាចសាកសួរដោយផ្ទាល់មាត់ជាជំនួស ឬជាការបន្ថែមលើភស្តុតាងដទៃទៀត ហើយអនុញ្ញាតឱ្យសាក្សីណាមួយចូលរួម ដើម្បីបញ្ជាក់លើលិខិតថ្លែងសច្ចា ឬលិខិតប្រកាសរបស់ខ្លួន ។

មាត្រា ៣៥. – លិខិតប្រកាស និងលិខិតថ្លែងសច្ចា

លិខិតប្រកាស ឬលិខិតថ្លែងសច្ចា ត្រូវធ្វើឡើងនៅចំពោះមុខមន្ត្រីកុងស៊ុល ឬសារការី ឬអ្នកប្រកបវិជ្ជាជីវៈច្បាប់ ដែលមានការទទួលស្គាល់ត្រឹមត្រូវ ។

មាត្រា ៣៦. – អាជ្ញាធរមានសមត្ថកិច្ច

អាជ្ញាធរមានសមត្ថកិច្ច ដែលមានចែងក្នុងមាត្រា៣៥ មាត្រា៣៧ មាត្រា៣៨ មាត្រា៤២ និងមាត្រា៤៦ នៃច្បាប់ រួមមានអង្គភាពគយ និងរដ្ឋាករ នាយកដ្ឋានកម្ពុជាត្រួតពិនិត្យអនុលោមភាព–

អាហារ៍ណ និងបង្ក្រាបការក្លែងបន្លំ ហៅកាត់ថាកាំកុងត្រូល នៃក្រសួងពាណិជ្ជកម្ម និង នគរបាលមានសមត្ថកិច្ចនៃក្រសួងមហាផ្ទៃ ។

មាត្រា ៣៧.- ការបោះពុម្ពផ្សាយ និង ព្រឹត្តិបត្រផ្លូវការ

ចំណុចពិសេសទាំងឡាយរបស់ម៉ាក និងចំណាត់ការនានា ព្រមទាំងព័ត៌មានផ្សេងទៀត ដែលតម្រូវឱ្យបោះពុម្ពផ្សាយដោយច្បាប់ ឬអនុក្រឹត្យនេះ ត្រូវតែបោះពុម្ពផ្សាយនៅក្នុងព្រឹត្តិបត្រផ្លូវការ តាមការណែនាំរបស់មន្ត្រីកាន់កាប់បញ្ជី ។

ជំពូកទី ៤
វិធានការតាមមាត់ច្រកព្រំដែន

មាត្រា ៣៨.- ពាក្យប្តឹង

១-អនុលោមតាមមាត្រា៣៥ និងមាត្រា៣៦ នៃច្បាប់ និង ច្បាប់ ស្តីពីកាគ្រប់គ្រង គុណភាពសុវត្ថិភាពលើផលិតផលទំនិញ និងសេវា ម្ចាស់ម៉ាកដែលបានចុះបញ្ជី ឬអ្នកទទួលអាជ្ញាប័ណ្ណ ឬភ្នាក់ងារតំណាងស្របច្បាប់ អាចធ្វើពាក្យប្តឹងទៅរដ្ឋបាលគយ និង រដ្ឋាករ ឬអាជ្ញាធរមានសមត្ថកិច្ច ឬតុលាការឱ្យព្យួរទុកនូវការធ្វើបែបបទទំនិញណា ដែលសង្ស័យថា មានម៉ាកក្លែងក្លាយ ដោយបង្ហាញនូវភស្តុតាងច្បាស់លាស់ថា គាត់ជាម្ចាស់នៃម៉ាកដែលបានចុះបញ្ជី ។

២-ក្នុងរង្វង់មិនលើសពី ៣០ (សាមសិប) ថ្ងៃ បន្ទាប់ពីអនុក្រឹត្យនេះចូលជាធរមាន ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និង ក្រសួងពាណិជ្ជកម្ម ត្រូវចេញប្រកាសអន្តរក្រសួងមួយ អំពីគំរូនៃពាក្យប្តឹង និងតម្រូវការនានាស្របតាមច្បាប់ជាធរមាន។

៣-ពាក្យប្តឹងនោះមានសុពលភាព ៦០ (ហុកសិប) ថ្ងៃ គិតចាប់ពីថ្ងៃទទួលពាក្យប្តឹង។ ពេលផុតសុពលភាព អ្នកដាក់ពាក្យត្រូវធ្វើពាក្យប្តឹងឡើងវិញ បើសំណូមពរនៃការឃាត់ និងត្រួតពិនិត្យទំនិញនៅមាននៅឡើយ ។

មាត្រា ៣៩.- កម្រៃរដ្ឋបាល

ពាក្យប្តឹងនីមួយៗ ត្រូវអមមកជាមួយនូវការទូទាត់កម្រៃរដ្ឋបាល ដែលកំណត់ដោយប្រកាសអន្តរក្រសួងរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងពាណិជ្ជកម្ម ។

មាត្រា ៤០.- កាតព្វកិច្ចរបស់អ្នកដាក់ពាក្យប្តឹង

ក្រៅពីកាតព្វកិច្ចនានាដែលមានចែងក្នុងមាត្រា៣៥ មាត្រា៣៦ និងមាត្រា៣៧ នៃច្បាប់ អ្នកដាក់ពាក្យមានភារកិច្ចទទួលខុសត្រូវ ចំពោះមធ្យោបាយដឹកជញ្ជូន ឃ្លាំងដែលស្តុកទុកនូវទំនិញ

ឃាត់រក្សាទុក ។ ឃ្លាំងស្តុកទំនិញត្រូវស្ថិតនៅក្នុងបរិវេណកំពង់ផែ ឬក្នុងបរិវេណមាត់ច្រកនាំចេញ នាំចូល ដែលបានកំណត់ និងគ្រប់គ្រងដោយអាជ្ញាធរមានសមត្ថកិច្ច តាមច្បាប់ជាធរមាន ។ ការចំណាយនានាក្នុងការបំផ្លាញចោលទំនិញមិនស្របច្បាប់ ជាកាតព្វកិច្ចរបស់អ្នកដាក់ពាក្យ ។

មាត្រា ៤១. – ការបដិសេធចំពោះការឃាត់ទុកទំនិញសង្ស័យថា មានម៉ាកក្លែងក្លាយ

អង្គភាពគយ និងរដ្ឋាករ ឬ កាំកុងត្រូល អាចមានសិទ្ធិបដិសេធការស្នើសុំឃាត់ទំនិញដែលសង្ស័យ ឬមានម៉ាកក្លែងក្លាយ តែក្នុងករណីដែលអ្នកដាក់ពាក្យស្នើសុំឃាត់ទំនិញ មិនបានអនុវត្តតាមការទាមទារណាមួយ របស់អង្គភាពគយ និងរដ្ឋាករ ឬ កាំកុងត្រូល ដែលស្របតាមមាត្រានានានៃច្បាប់ និងអនុក្រឹត្យនេះប៉ុណ្ណោះ ។

មាត្រា ៤២. – ចំណាត់ការ និង ថេរៈវេលា

បែបបទ និងថេរៈវេលានៃចំណាត់ការនានារបស់អង្គភាពគយ និងរដ្ឋាករ និង ឬកាំកុងត្រូល ត្រូវអនុលោមតាមជំពូកទី១០ នៃច្បាប់ និង មាត្រានានានៃអនុក្រឹត្យនេះ ។

ជំពូកទី ៥

អវសានប្បញ្ញត្តិ

មាត្រា ៤៣. –

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ៤៤. –

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការ ក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវអនុវត្តអនុក្រឹត្យនេះ ឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខា តទៅ ។

ភ្នំពេញ, ថ្ងៃទី[illegible] ខែកក្កដា ឆ្នាំ ២០០៦

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៤៤
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ឧបសម្ព័ន្ធ នៃអនុក្រឹត្យ លេខ៦៤អនក្រ.បក ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ ២០០៦

ស្តីពី

ការអនុវត្តច្បាប់ស្តីពីម៉ាក ពាណិជ្ជនាម និង អំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់

វាក្យស័ព្ទដែលប្រើក្នុងអនុក្រឹត្យនេះ ត្រូវបានកំណត់និយមន័យដូចតទៅ :

- "ច្បាប់" សំដៅដល់ច្បាប់ស្តីពីម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់ ដែលបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០២០២/០៦ ចុះថ្ងៃទី ០៧ ខែ កុម្ភៈ ឆ្នាំ ២០០២ ។
- "ការបដិសេធ" (Refusal) សំដៅដល់ការមិនយល់ព្រមចុះបញ្ជីម៉ាកដែលស្នើសុំដោយ អ្នកដាក់ពាក្យពីសំណាក់មន្ត្រីកាន់កាប់បញ្ជី ។
- "បណ្តឹងជំទាស់" (Opposition) សំដៅដល់បណ្តឹងជំទាស់ទៅនឹងសេចក្តីសម្រេច របស់មន្ត្រីកាន់កាប់បញ្ជីក្នុងរយៈពេល ៩០ (កៅសិប) ថ្ងៃ បន្ទាប់ពីការចុះបញ្ជីម៉ាកមួយ ត្រូវបានបោះពុម្ពផ្សាយ ក្នុងព្រឹត្តិបត្រផ្លូវការ ។
- បណ្តឹងតវ៉ា (Appeal) សំដៅដល់ការប្តឹងតវ៉ាទៅនឹងសេចក្តីសំរេចចុងក្រោយរបស់មន្ត្រីកាន់កាប់បញ្ជី ឬ សេចក្តីសំរេចរបស់ក្រុមប្រឹក្សាដោះស្រាយបណ្តឹងតវ៉ា ។
- "មោឃភាព ឬ ការលុបម៉ាកចេញពីបញ្ជី " (Invalidation or Cancellation) សំដៅដល់ការលុបម៉ាកណាមួយ ដែលបានចុះបញ្ជីរួចដោយមន្ត្រីកាន់កាប់បញ្ជី ។
- "សេចក្តីប្រកាសពីការប្រើប្រាស់ ឬមិនប្រើប្រាស់" (Affidavit of Use Non-Use) សំដៅដល់សេចក្តីប្រកាសរបស់ម្ចាស់ម៉ាកដែលបានចុះបញ្ជី ឬ ដោយភ្នាក់ងារតំណាងអំពីការប្រើប្រាស់ ឬ មិនបានប្រើប្រាស់ម៉ាករបស់ខ្លួនដែលបានចុះបញ្ជីរួច ។
- "លិខិតថ្លែងសច្ចា" (Affidavit) សំដៅដល់លិខិតអំណះអំណាង ដែលត្រូវបានភ្ជាប់ជាមួយនឹងលិខិតស្នើសុំឱ្យមន្ត្រីកាន់កាប់បញ្ជីចាត់ការនូវកិច្ចការណាមួយ ដូចជាការសុំលុបម៉ាក ការសុំរក្សាទុកការចុះបញ្ជីម៉ាក ឬស្នើសុំចាត់វិធានការណាមួយចំពោះការរំលោភបំពានម៉ាក ។
- "ការច្រានចោល" (Rejection) សំដៅដល់ការមិនយល់ព្រមជាលើកដំបូងរបស់មន្ត្រីកាន់កាប់បញ្ជីចំពោះពាក្យស្នើសុំ ឬការចុះបញ្ជីម៉ាក ។
- "មន្ត្រីកាន់កាប់បញ្ជី" (Registrar) សំដៅដល់ប្រធាននាយកដ្ឋានកម្មសិទ្ធិបញ្ញា នៃក្រសួងពាណិជ្ជកម្ម ។
- "សវនាការ" (Hearing) សំដៅដល់ការប្រជុំដោះស្រាយវិវាទរបស់មន្ត្រីកាន់កាប់បញ្ជី មុននឹងសំរេចលើករណីជំទាស់តវ៉ានានារបស់ដើមបណ្តឹង ។

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៤៧៤ អនក្រ.បក

អនុក្រឹត្យ

ស្តីពីការជូនមេដាយស្ថាបនាជាតិ

៣០៨

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាស ឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពី ការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ អភិបាលរាជធានីភ្នំពេញ

សម្រេច

មាត្រា១: ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនឧកញ៉ា **ឡី ហេង** ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួន ជួយសាងសង់អគារសិក្សា ០១ ខ្នង មាន០៥បន្ទប់ នៅសាលាបឋមសិក្សាក្រាំងធ្នង់ ស្ថិតក្នុងសង្កាត់ ក្រាំងធ្នង់ ខណ្ឌដង្កោ រាជធានីភ្នំពេញ អស់ទឹកប្រាក់ ចំនួន ១៥.០០០ ដុល្លារអាមេរិក ។

មាត្រា២: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង អភិបាលរាជធានីភ្នំពេញ ត្រូវអនុវត្ត អនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។/។

រាជធានីភ្នំពេញ, ថ្ងៃទី [illegible] ខែ កក្កដា ឆ្នាំ ២០០៦

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល:
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចក្នុងមាត្រា ១ និង មាត្រា ២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៤៨៥ អនក្រ.បក

អនុក្រឹត្យ
ស្តីពីការជូនមេដាយការងារ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាស អោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពី ការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ អភិបាលខេត្តបន្ទាយមានជ័យ

សម្រេច

មាត្រា១ : ត្រូវបានបំពាក់ **មេដាយមាសការងារ** ជូនលោក **ជង់ ប្រុស៊ីដ្ឋ** នាយខុទ្ទកាល័យស្តីទី សាលាខេត្តបន្ទាយមានជ័យ ដែលមានស្នាដៃល្អប្រសើរក្នុងការបំពេញភារកិច្ចជូនជាតិមាតុភូមិ ដោយស្មារតីឧស្សាហ៍ព្យាយាម និងទទួលខុសត្រូវខ្ពស់ ។

មាត្រា២: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងអភិបាលខេត្តបន្ទាយមានជ័យ ត្រូវអនុវត្ត អនុក្រឹត្យ នេះ អោយទទួលបានលទ្ធផលល្អ ។/.

រាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៦

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ:៤៥៩.អនក្រ.បក

អនុក្រឹត្យ
ស្តីពីការជូនមេដាយស្ថាបនាជាតិ

១៧

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពី ការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សម្រេច

មាត្រា១ : ត្រូវបានបំពាក់ **មេដាយស្ថាបនាជាតិ** តាមលំដាប់ថ្នាក់ ជូនតំណាង ***អង្គការមនុស្សធម៌ជប៉ុន*** និងសប្បុរសជនខ្មែរ ០៣រូប ដែលបានឧបត្ថម្ភថវិកា ជួយកសាងមណ្ឌល ពិគ្រោះជម្ងឺ មួយខ្នង អគារសិក្សា ០១ខ្នង មាន០៦ បន្ទប់ និងបំពាក់សង្ហារឹមគ្រប់ប្រភេទ នៅស្រុកកំពត និង ស្រុកអង្គរជ័យ ខេត្តកំពត ដូចមានខាងក្រោម :-

ក.មេដាយមាសស្ថាបនាជាតិ :

១-***តំណាង អង្គការពិគ្រោះជម្ងឺ រ៉ូតារីក្លឹប នៃទីក្រុង ណាហ្គោយ៉ាសោណិន ប្រទេសជប៉ុន*** បានឧបត្ថម្ភថវិកា ចំនួន ២០.២០០ ដុល្លារ ជួយកសាងមណ្ឌលពិគ្រោះជម្ងឺ មួយខ្នង នៅភូមិច្បារអំពៅ ឃុំព្រៃថ្នង ស្រុកកំពត ខេត្តកំពត ។

២-លោក **សួន សំ** នៅសហរដ្ឋអាមេរិក បានឧបត្ថម្ភថវិកា ចំនួន ១០.០០០ ដុល្លារ ជួយកសាងអគារសិក្សា នៅឃុំសំឡាញ ស្រុកអង្គរជ័យ ខេត្តកំពត ។

៣-លោក **សួន រិន** នៅសហរដ្ឋអាមេរិក បានឧបត្ថម្ភថវិកា ចំនួន ១០.០០០ ដុល្លារ ជួយកសាងអគារសិក្សា នៅឃុំសំឡាញ ស្រុកអង្គរជ័យ ខេត្តកំពត ។

ខ.មេដាយប្រាក់ស្ថាបនាជាតិ :

-លោកស្រី **ទៀង ណម** នៅសហរដ្ឋអាមេរិក បានឧបត្ថម្ភថវិកា ចំនួន ៥.៤៦០ ដុល្លារ ជួយកសាងអគារសិក្សា នៅឃុំសំឡាញ ស្រុកអង្គរជ័យ ខេត្តកំពត ។

មាត្រា២: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង អភិបាលខេត្តកំពត ត្រូវអនុវត្ត អនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៦

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចក្នុងមាត្រា ១ និង មាត្រា ២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ ៤៨៣ អនក្រ.តត

អនុក្រឹត្យ
ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា.
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សម្រេច

មាត្រា ១ : ត្រូវបានចំពាក់ **មេដាយមុនីសារាភ័ណ្ឌ** ថ្នាក់ **ធិបឌិន្ទ** ជូនសប្បុរសជនចំនួន ០៤ នាក់ ដែលបានយកអស់កំលាំងកាយចិត្ត និង បានបរិច្ចាកធនធានផ្ទាល់ខ្លួន ជួយកសាងហេដ្ឋារចនាសម្ព័ន្ធលើគ្រប់វិស័យនៅខេត្តបាត់ដំបង ដូចមានរាយនាមខាងក្រោម :

១	លោក ឈឹម ប៊ុនឡេខ	ប្រធានអង្គការអាសា
២	លោក កុក សុខគីម	អនុប្រធានអង្គការអាសា
៣	លោក កុល ធីរក្ស	ទីប្រឹក្សាអង្គការអាសា
៤	លោក DOMINIQUE DORDAIN	មន្ត្រីស្ថានទូតបារាំង ប្រចាំព្រះរាជាណាចក្រកម្ពុជា

មាត្រា ២ : រដ្ឋមន្ត្រី ទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ត្រូវអនុវត្តអនុក្រឹត្យនេះ ឱ្យទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ. ថ្ងៃទី ១៤ ខែ កក្កដា ឆ្នាំ ២០០៦

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :
- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ១ និងមាត្រា ២*
- *ឯកសារ កាលប្បវត្តិ*

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ៧៨ សសរ

សេចក្តីសម្រេច

ស្តីពី

ការកែសម្រួលសមាសភាពនៃ គណៈកម្មាធិការជាតិ និងលេខាធិការដ្ឋាន គណៈកម្មាធិការជាតិ ដឹកនាំ បញ្ហាការប្រយុទ្ធ ប្រឆាំង និងទប់ស្កាត់អំពើភេរវកម្ម

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាលលេខ ៨០ សសរ ចុះថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ២០០៤ - លេខ ២៥ សសរ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ២០០៥ - លេខ ៨០ សសរ ចុះថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ២០០៤ - ចុះថ្ងៃទី ៣០ ខែ កញ្ញា ឆ្នាំ ២០០៥ ស្តីពីការបង្កើតគណៈកម្មាធិការជាតិ - លេខាធិការដ្ឋានគណៈកម្មាធិការជាតិ និងការបន្ថែមសមាសភាពលេខាធិការដ្ឋានគណៈកម្មាធិការជាតិដឹកនាំ បញ្ហាការប្រយុទ្ធ ប្រឆាំង និងទប់ស្កាត់អំពើភេរវកម្ម
- យោងតាមសំណើរបស់ប្រធានគណៈកម្មាធិការជាតិដឹកនាំ បញ្ហាការប្រយុទ្ធ ប្រឆាំង និងទប់ស្កាត់អំពើភេរវកម្ម
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

សម្រេច

ប្រការ ១: ត្រូវបានកែសម្រួលសមាសភាពក្នុងប្រការ ១ នៃសេចក្តីសម្រេចលេខ ៨០ សសរ ស្តីពីការបង្កើតគណៈកម្មាធិការជាតិដឹកនាំ បញ្ហាការប្រយុទ្ធ ប្រឆាំង និងទប់ស្កាត់អំពើភេរវកម្ម (គជបភ) រួមមានសមាសភាពជាថ្មីដូចតទៅ:

១- សម្តេច ហ៊ុន សែន	នាយករដ្ឋមន្ត្រី	ប្រធាន
២- ឯកឧត្តម ស ខេង	ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ	អនុប្រធាន
៣- ឯកឧត្តម ទៀ បាញ់	ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ	សមាជិក

៤- ឯកឧត្តម ហោ ណាំហុង	ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ	សមាជិក
៥- ឯកឧត្តម ញ៉ឹក ប៊ុនឆៃ	ឧបនាយករដ្ឋមន្ត្រី	សមាជិក
៦- ឯកឧត្តម គាត ឈន់	ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ	សមាជិក
៧- ឯកឧត្តម ជា ចាន់តូ	ទេសាភិបាលធនាគារជាតិ	សមាជិក
៨- ឯកឧត្តម សូរ ឃុន	រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍	សមាជិក
៩- ឯកឧត្តម អង្គ វង្សវឌ្ឍនា	រដ្ឋមន្ត្រីក្រសួងយុត្តិធម៌	សមាជិក
១០-ឯកឧត្តម ឯម សំអាន	រដ្ឋលេខាធិការក្រសួងមហាផ្ទៃ	សមាជិក
១១-ឯកឧត្តម ប្រាក់ សុខុន	រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី	សមាជិក
១២- នាយឧត្តមសេនីយ៍ កែ គីមយ៉ាន	អគ្គមេបញ្ជាការកងយោធពលខេមរភូមិន្ទ	សមាជិក
១៣- នាយឧត្តមសេនីយ៍ ហុក ឡុងឌី	អគ្គស្នងការនគរបាលជាតិ	សមាជិក
១៤- ឯកឧត្តម ទិម យ៉ិនឆៀង	ទីប្រឹក្សាផ្ទាល់សម្តេចនាយករដ្ឋមន្ត្រី	សមាជិក
១៥- ឧត្តមសេនីយ៍ឯក សៅ សុខា	មេបញ្ជាការកងរាជអាវុធហត្ថលើផ្ទៃប្រទេស	សមាជិក

ប្រការ ២: ត្រូវបានកែសំរួលសមាសភាពលេខាធិការដ្ឋាន គជបភ ក្នុងប្រការ ៤ -ប្រការ ៧ នៃសេចក្តីសំរេចលេខ ២៥ សសរ ស្តីពីការបង្កើតលេខាធិការដ្ឋានគណៈកម្មាធិការជាតិដឹកនាំ បញ្ជាការប្រយុទ្ធ ប្រឆាំង និងទប់ស្កាត់អំពើភេរវកម្ម និង ប្រការ ១ -ប្រការ ២ និងប្រការ ៣ នៃសេចក្តីសំរេចលេខ ៤០ សសរ ស្តីពីការបំពេញ និងការបន្ថែមសមាសភាពលេខាធិការដ្ឋានគណៈកម្មាធិការជាតិដឹកនាំ បញ្ជាការប្រយុទ្ធ ប្រឆាំង និងទប់ស្កាត់អំពើភេរវកម្ម រួមមានសមាសភាពជាថ្មីដូចតទៅ:

ក-សមាសភាពលេខាធិការដ្ឋានគណៈកម្មាធិការជាតិដឹកនាំ បញ្ជាការប្រយុទ្ធ ប្រឆាំង និងទប់ស្កាត់ អំពើភេរវកម្ម

១- ឯកឧត្តម ឯម សំអាន រដ្ឋលេខាធិការក្រសួងមហាផ្ទៃ - សមាជិក គជបភ.............................. ប្រធាន
(ទទួលបន្ទុករួម និងទទួលផ្ទាល់ទំនាក់ទំនងសំរបសំរួលការងារស្ថាប័នស៊ីវិល និងឯកជន)

២- ឯកឧត្តម ហុក ឡុងឌី អគ្គស្នងការនគរបាលជាតិ - សមាជិក គជបភ............................ អនុប្រធាន
(ទទួលបន្ទុករួមលើកិច្ចការពារហេដ្ឋារចនាសម្ព័ន្ធ)

៣- ឯកឧត្តម ម៉ុល សារឿន អគ្គមេបញ្ជាការរង និងជានាយសេនាធិការចំរុះនៃកងយោធពលខេមរភូមិន្ទ ..អនុប្រធាន

៤- ឯកឧត្តម ទិម យ៉ិនឆៀង ទីប្រឹក្សាផ្ទាល់សម្តេចនាយករដ្ឋមន្ត្រី - សមាជិក គជបភ................. អនុប្រធាន
(ទទួលបន្ទុកពត៌មាន ស្រាវជ្រាវ បណ្តុះបណ្តាល សំភារៈ បច្ចេកទេស ទំនាក់ទំនង និងសហប្រតិបត្តិការជាតិ អន្តរជាតិ ទ្វេភាគី និងពហុភាគី)

៥- ឯកឧត្តម មាស សឿប ទីប្រឹក្សាផ្ទាល់សម្តេចនាយករដ្ឋមន្ត្រី - នាយរងសេនាធិការចំរុះ និងជានាយកស្រាវជ្រាវចារកិច្ចអគ្គបញ្ជាការដ្ឋានកងយោធពលខេមរភូមិន្ទ... អនុប្រធាន
(ទទួលបន្ទុកសំរបសំរួលទំនាក់ទំនងការងារយោធា)

៦- ឯកឧត្តម **យុ ស៊ុនឡុង** ទីប្រឹក្សាផ្ទាល់សម្តេចនាយករដ្ឋមន្ត្រី - អគ្គស្នងការរងនគរបាលជាតិ....... អនុប្រធាន
(ទទួលបន្ទុកសំរបសំរួល និងទំនាក់ទំនងការងារនគរបាល)

៧- ឧត្តមសេនីយ៍ឯក **សៅ សុខា** មេបញ្ជាការកងរាជអាវុធហត្ថលើផ្ទៃប្រទេស-សមាជិក គជបក ...... អនុប្រធាន

៨- ឯកឧត្តម **មៅ ចំនួនតារា** អគ្គស្នងការរងនគរបាលជាតិ .... អនុប្រធានអចិន្ត្រៃយ៍

៩- ឯកឧត្តម **ញៀម សុខារ័ត្ន**... អនុប្រធានប្រចាំការ

១០- នាយឧត្តមសេនីយ៍ **មាស សុភា** អគ្គមេបញ្ជាការរង និងជាមេបញ្ជាការកងទ័ពជើងគោក នៃកងយោធពល-ខេមរភូមិន្ទ... សមាជិក

១១- ឯកឧត្តម **គឹម ស៊ីថន** រដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម... សមាជិក

១២- ឯកឧត្តម **ជុំ អឿត** រដ្ឋលេខាធិការក្រសួងសាធារណការ និងដឹកជញ្ជូន............................ សមាជិក

១៣- ឧត្តមសេនីយ៍ឯក **សុ ផន** អគ្គស្នងការរងនគរបាលជាតិ .... សមាជិក

១៤- ឧត្តមសេនីយ៍ឯក **នេត្រ សាវឿន** អគ្គស្នងការរងនគរបាលជាតិ .... សមាជិក

១៥- ឧត្តមសេនីយ៍ឯក **សុខ ផល** អគ្គស្នងការរងនគរបាលជាតិ .... សមាជិក

១៦- ឧត្តមសេនីយ៍ឯក **ជា សារ៉ន** មេបញ្ជាការរង និងជានាយសេនាធិការកងទ័ពជើងគោក........... សមាជិក

១៧- ឧត្តមសេនីយ៍ឯក **ហ៊ីង ប៊ុនហៀង** នាយកងរក្សាការពារខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី.................. សមាជិក

១៨- ឯកឧត្តម **ឌឹម ចាន់តារា** អនុរដ្ឋលេខាធិការក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ.... សមាជិក

១៩- ឯកឧត្តម **រ័ត្ន សារិន** អនុរដ្ឋលេខាធិការក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ .... សមាជិក

២០- ឯកឧត្តម **ទី តាយ៉** អនុរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ .... សមាជិក

២១- ឯកឧត្តម **អ៊ិត រ៉ាឌី** អនុរដ្ឋលេខាធិការក្រសួងយុត្តិធម៌... សមាជិក

២២- ឯកឧត្តម **អ៊ុក សាខន** អនុរដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ................ សមាជិក

២៣- ឯកឧត្តម **សុខ ផេង** អនុរដ្ឋលេខាធិការក្រសួងសុខាភិបាល .... សមាជិក

២៤- ឯកឧត្តម **កែវ សាផល** អនុរដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល .... សមាជិក

២៥- ឯកឧត្តម **មាន់ឡ្ញ ឡារ៉ាម៉ានី** សមាជិកគណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា.......................... សមាជិក

២៦- មេបញ្ជាការយោធភូមិភាគពិសេស .... សមាជិក

២៧- មេបញ្ជាការយោធភូមិភាគទី ៣.. សមាជិក

២៨- មេបញ្ជាការយោធភូមិភាគទី ៤.. សមាជិក

២៩- មេបញ្ជាការកងពលតូចលេខ ៧០ .... សមាជិក

៣០- មេបញ្ជាការកងពលតូចទ័ពពិសេសឆត្រ័យោង ៩១១.. សមាជិក

៣១- អភិបាលក្រុងភ្នំពេញ.. សមាជិក

៣២- អភិបាលខេត្ត សៀមរាប... សមាជិក

៣៣- អភិបាលក្រុងព្រះសីហនុ .... សមាជិក

៣៤- អគ្គលេខាធិការអាជ្ញាធរកម្ពុជាគ្រប់គ្រងសកម្មភាពកំចាត់មីន និងសង្គ្រោះជនពិការដោយសារមីន.....សមាជិក
៣៥- អគ្គលេខាធិការនៃគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ.....................................សមាជិក
៣៦- អគ្គនាយកនៃធនាគារជាតិកម្ពុជា..សមាជិក
៣៧- អគ្គនាយកទូរគមនាគមន៍កម្ពុជា នៃក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ....សមាជិក
៣៨- ស្នងការនគរបាលរាជធានីភ្នំពេញ ....សមាជិក
៣៩- ស្នងការនគរបាលខេត្តសៀមរាប ....សមាជិក
៤០- ស្នងការនគរបាលក្រុងព្រះសីហនុ ....សមាជិក
៤១- មេបញ្ជាការកងរាជអាវុធហត្ថក្រុងភ្នំពេញ...សមាជិក
៤២- មេបញ្ជាការកងរាជអាវុធហត្ថខេត្តសៀមរាប..សមាជិក
៤៣- មេបញ្ជាការកងរាជអាវុធហត្ថក្រុងព្រះសីហនុ ....សមាជិក
៤៤- ប្រធាននាយកដ្ឋានគ្រប់គ្រងអាវុធជាតិផ្ទុះ និងពន្លត់អគ្គីភ័យ នៃអគ្គស្នងការនគរបាលជាតិ - ក្រសួងមហាផ្ទៃ...សមាជិក

ខ-សមាសភាព ក្រុមវិភាគ និងចារកម្មប្រឆាំងភេរវកម្ម ដែលមានឯកឧត្តម ខឹម យ៉ិនឡឿង ទីប្រឹក្សាផ្ទាល់សម្តេចនាយករដ្ឋមន្ត្រី និងជាសមាជិក គជបភ ជាប្រធាន ត្រូវបានកែសំរួលជំនួសឯកឧត្តម ហោង ពៅ ដោយស្នងការនគរបាលក្រុងភ្នំពេញ និង ឧត្តមសេនីយ៍ គៀត ចន្ទ័ថារិទ្ធ ត្រូវជំនួសសមាសភាពដោយប្រធាននាយកដ្ឋាន អន្តោប្រវេសន៍ នៃអគ្គស្នងការនគរបាលជាតិ-ក្រសួងមហាផ្ទៃ ហេតុនេះ សមាសភាពសមាជិកក្រុមវិភាគ និងក្រុមចារកម្មប្រឆាំងភេរវកម្ម រួមមាន៖

សមាសភាពសមាជិកក្រុមវិភាគ

១-ឯកឧត្តម ច្រាក់ សុខុន ទីប្រឹក្សាផ្ទាល់សម្តេចនាយករដ្ឋមន្ត្រី-រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រីសមាជិក គជបភ...សមាជិក
២- ឧត្តមសេនីយ៍ឯក មាស់ សឿប ទីប្រឹក្សាផ្ទាល់សម្តេចនាយករដ្ឋមន្ត្រី- នាយរងសេនាធិការចំរុះ និងជានាយកស្រាវជ្រាវចារកិច្ចអគ្គបញ្ជាការដ្ឋានកងយោធពលខេមរភូមិន្ទ ....សមាជិក
៣- ឧត្តមសេនីយ៍ឯក យូ ស៊ុនឡុង ទីប្រឹក្សាផ្ទាល់សម្តេចនាយករដ្ឋមន្ត្រី-អគ្គស្នងការរងនគរបាលជាតិ... ....សមាជិក
៤ - ឯកឧត្តម នូ ប៊ុនរិទ្ធ រដ្ឋលេខាធិការក្រសួងការបរទេស.................................សមាជិក
៥ - ឧត្តមសេនីយ៍ឯក សៅ សុខា មេបញ្ជាការកងរាជអាវុធហត្ថលើផ្ទៃប្រទេស-សមាជិក គជបភ ....សមាជិក
៦- ឧត្តមសេនីយ៍ឯក នេត្រ សាវឿន អគ្គស្នងការរងនគរបាលជាតិ ....សមាជិក

៧- ឧត្តមសេនីយ៍ឯក **សុខ ផល** អគ្គស្នងការរងនគរបាលជាតិ ....សមាជិក

៨- ឧត្តមសេនីយ៍ឯក **ជុំ ហាក់** មេបញ្ជាការរងកងទ័ពជើងគោក .... សមាជិក

៩- ឧត្តមសេនីយ៍ឯក **គន្ធ សំអឿន** ប្រធាននាយកដ្ឋានកណ្តាលសន្តិសុខ .... សមាជិក

១០- ឧត្តមសេនីយ៍ត្រី **ស៊ិន សុផាន្នី** នាយសេនាធិការរង និងជានាយការិយាល័យកណ្តាល ស្រាវជ្រាវកងរាជអាវុធលើផ្ទៃប្រទេស .... សមាជិក

១១- ឧត្តមសេនីយ៍ត្រី **ឌុច ណារុធ** ស្នងការនគរបាលក្រុងភ្នំពេញ.. សមាជិក

១២- ឧត្តមសេនីយ៍ត្រី **យើ គឹមអ៊ី** មេបញ្ជាការកងរាជអាវុធហត្ថក្រុងភ្នំពេញ .... សមាជិក

សមាសភាពសមាជិកក្រុមចារកម្មប្រឆាំងភេរវកម្ម

១- ឧត្តមសេនីយ៍ឯក **គន្ធ សំអឿន** ប្រធាននាយកដ្ឋានកណ្តាលសន្តិសុខ .... សមាជិក

២- ឧត្តមសេនីយ៍ទោ **ស៊ិត ហ៊ុន** នាយសេនាធិការរងកងទ័ពជើងគោក និងជានាយការិយាល័យទី ២ កងទ័ពជើងគោក..សមាជិក

៣- ឧត្តមសេនីយ៍ទោ **ថោង លឹម** ប្រធាននាយកដ្ឋានអន្តោប្រវេសន៍.. សមាជិក

៤- ឧត្តមសេនីយ៍ត្រី **ស៊ិន សុផាន្នី** នាយសេនាធិការរង និងជានាយការិយាល័យកណ្តាល ស្រាវជ្រាវកងរាជអាវុធលើផ្ទៃប្រទេស .... សមាជិក

៥- ឧត្តមសេនីយ៍ត្រី **នៃ ស៊ីណារិទ្ធ** ប្រធាននាយកដ្ឋានពត៌មានទូទៅ.. សមាជិក

៦- ឧត្តមសេនីយ៍ត្រី **ប៊ិត គឹមហុង** ប្រធាននាយកដ្ឋានប្រឆាំងភេរវកម្ម .... សមាជិក

៧- ឧត្តមសេនីយ៍ត្រី **មាស អ៊ីន** នាយរងនាយកដ្ឋានស្រាវជ្រាវចារកិច្ចអគ្គបញ្ជាការដ្ឋានកងយោធពលខេមរភូមិន្ទ .... សមាជិក

៨-ឧត្តមសេនីយ៍ត្រី **ស៊ិទ្ធិ សាឡឿន** នាយរងនាយកដ្ឋានស្រាវជ្រាវចារកិច្ចអគ្គបញ្ជាការដ្ឋានកងយោធពលខេមរភូមិន្ទ .... សមាជិក

៩- ឧត្តមសេនីយ៍ត្រី **គឹម នាន** ជំនួយការសម្តេចនាយករដ្ឋមន្ត្រី .... សមាជិក

១០-វរៈសេនីយ៍ឯក **ហ៊ី ត្រា** ស្នងការរងនគរបាលក្រុងភ្នំពេញ.. សមាជិក

១១-វរៈនាវីឯក **មី ឌីណា** នាយការិយាល័យទី ២ កងទ័ពជើងទឹក .... សមាជិក

១២-វរៈសេនីយ៍ឯក **ពៅ ពិចិត្រ** នាយក្រុមប្រតិបត្តិការក្នុងប្រទេសនាយកដ្ឋានស្រាវជ្រាវចារកិច្ចអគ្គបញ្ជាការដ្ឋានកងយោធពលខេមរភូមិន្ទ ....សមាជិក

១៣-វរៈសេនីយ៍ឯក **ស៊ឹម ហុង** មេបញ្ជាការរងកងរាជអាវុធហត្ថក្រុងភ្នំពេញ .... សមាជិក

១៤-វរៈសេនីយ៍ត្រី **ម៉ាក់ សុផារី** សមាជិកក្រុមលេខាសម្តេចនាយករដ្ឋមន្ត្រី.. សមាជិក

ប្រការ ៣៖ គណៈកម្មាធិការជាតិដឹកនាំ បញ្ហាការប្រយុទ្ធ ប្រឆាំង និងទប់ស្កាត់អំពើភេរវកម្ម រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការ គណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រី ប្រធានស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួនមានឈ្មោះក្នុងប្រការ ១ និង ២ ត្រូវអនុវត្តសេចក្តីសម្រេចនេះអោយមានប្រសិទ្ធភាពចាប់តាំងពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ កក្កដា ឆ្នាំ ២០០៦

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល ៖

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ ៣
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ :.៧៩..សសរ

សេចក្តីសំរេច
ស្តីពីការផ្ទេរសិទ្ធិការងាររបស់រាជរដ្ឋាភិបាល

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រមលេខ នស / រកម / ០៧០៤ / ០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសអោយប្រើច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានាដំណើរការប្រក្រតីនៃស្ថាប័នជាតិ
-បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ០៧០៤ / ១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
-យោងតាមការងារចាំបាច់របស់រាជរដ្ឋាភិបាល

សំ រេ ច

ប្រការ ១ : ត្រូវបានផ្ទេរសិទ្ធិជូនឯកឧត្តម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ជានាយករដ្ឋមន្ត្រីស្តីទី នៃរាជរដ្ឋាភិបាលកម្ពុជា ជំនួសសម្តេចនាយករដ្ឋមន្ត្រីដែលត្រូវអញ្ជើញទៅចូលរួមពិធីប្រារព្ធខួបទី៦០ ព្រះវស្សា នៃព្រះចៅស៊ុលតង់ ហាជី ហាស់ស្សាណាល់ ប៊ូគីយ៉ាស់ នៃប្រទេសប្រ៊ុយណេ ដារូស្សាឡាម ចាប់ពីថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៦ រហូតដល់សម្តេចនាយករដ្ឋមន្ត្រីអញ្ជើញវិលនិវត្តន៍មកកាន់មាតុប្រទេសវិញ ។

ប្រការ ២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នរបស់រាជរដ្ឋាភិបាល ប្រតិភូរាជរដ្ឋាភិបាល អភិបាលខេត្ត-ក្រុង និងឯកឧត្តម ស ខេង ត្រូវអនុវត្តសេចក្តីសំរេចនេះអោយមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៦

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

<u>កន្លែងទទួល</u> :
- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
- *ដូចប្រការ ២*
- *ឯកសារ-កាលប្បវត្តិ*

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
Ministry of Industry, Mines and Energy
N°

រាជធានីភ្នំពេញ, ថ្ងៃទី ២៩ ខែ មិថុនា ឆ្នាំ ២០០៦

លិខិតចូល
ថ្ងៃទី...ខែ...ឆ្នាំ200...

ប្រកាស
ស្តីពី
នីតិវិធីផ្តល់ប្រកាសនីយបត្រតក្កកម្ម និងវិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍

រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៥ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៣/០០៥ ចុះថ្ងៃទី ២២ ខែ មករា ឆ្នាំ ២០០៣ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីប្រកាសនីយបត្រតក្កកម្ម វិញ្ញាបន-បត្រម៉ូដែលមានអត្ថប្រយោជន៍ និងគំនូរឧស្សាហកម្ម
- បានឃើញអនុក្រឹត្យលេខ ៣៥ អនក្របក ចុះថ្ងៃទី ២៦ ខែ មេសា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- បានឃើញអនុក្រឹត្យលេខ ៤៣ អនក្របក ចុះថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ២០០៣ ស្តីពីការតម្លើងការិយាល័យកម្មសិទ្ធិឧស្សាហកម្ម នៃនាយកដ្ឋានបច្ចេកទេសទៅជានាយកដ្ឋានកម្មសិទ្ធិឧស្សាហកម្ម នៃអគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួង ៤

៤៥ មហាវិថីព្រះនរោត្តម ខណ្ឌដូនពេញ ភ្នំពេញ ទូរស័ព្ទ : (៨៥៥) ២៣.២១១១៤១ , ទូរសារ : ៨៥៥.២៣.៤២៨២៦៣
45 Preah Norodom Boulevard, Khan Daun Penh, Phnom Penh, Phone : 855.23.211141 , Fax : 855.23.428263

ឧស្សាហកម្ម រ៉ែ និងថាមពល

- បានឃើញប្រកាសលេខ ៤៨៧ ឧរថ.បល.ប្រក ចុះថ្ងៃទី ១៩ ខែ មិថុនា ឆ្នាំ ២០០៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់នាយកដ្ឋានកម្មសិទ្ធិឧស្សាហកម្ម
- តាមសំណូមពរចាំបាច់របស់ក្រសួង

សម្រេច

ជំពូកទី ១

បទប្បញ្ញត្តិទូទៅ

ប្រការ ១.- ការកំណត់លក្ខណៈរបស់ប្រកាស

ប្រកាសនេះត្រូវបានចាត់ទុកជាបទបញ្ជាណែនាំនៃការអនុវត្តន៍ច្បាប់ស្តីពីប្រកាសនីយបត្រតក្កកម្ម វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ និងគំនូរឧស្សាហកម្ម អនុលោមតាមមាត្រា ១៣០ នៃច្បាប់ ស្តីពីប្រកាសនីយបត្រតក្កកម្ម វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ និងគំនូរឧស្សាហកម្ម ។

ប្រការ ២.- ភារកិច្ចរបស់នាយកដ្ឋានទទួលបន្ទុកចុះបញ្ជី

នាយកដ្ឋានទទួលបន្ទុកចុះបញ្ជីត្រូវ ទទួល ពិនិត្យសំណុំលិខិតស្នើសុំប្រកាសនីយបត្រតក្កកម្ម និងវិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ ព្រមទាំងផ្តល់ប្រកាសនីយបត្រតក្កកម្ម និងវិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ ដើម្បីការពារកម្មសិទ្ធិបញ្ញារបស់តក្កករ ដែលបានបង្កើតតក្កកម្ម និងការច្នៃប្រឌិត អនុលោមតាមច្បាប់ ។

ប្រការ ៣.- ការបកស្រាយ

នៅក្នុងប្រកាសនេះពាក្យដូចខាងក្រោមត្រូវបានបកស្រាយ :

-**ច្បាប់** គឺច្បាប់ស្តីពីប្រកាសនីយបត្រតក្កកម្ម វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ និងគំនូរឧស្សាហកម្មដែលត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០១០៣/០០៥ ចុះថ្ងៃទី ២២ ខែ មករា ឆ្នាំ ២០០៣ ។

-**រដ្ឋមន្ត្រី** គឺរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។

-**មន្ត្រីកាន់កាប់បញ្ជី** គឺប្រធាននាយកដ្ឋានកម្មសិទ្ធិឧស្សាហកម្ម ។

-**នាយកដ្ឋានទទួលបន្ទុកចុះបញ្ជី** គឺនាយកដ្ឋានកម្មសិទ្ធិឧស្សាហកម្ម ។

-**អនុសញ្ញាទីក្រុងប៉ារីស** គឺអនុសញ្ញាដែលបានចុះហត្ថលេខានៅទីក្រុងប៉ារីសស្តីពីការការពារកម្មសិទ្ធិឧស្សាហកម្ម ចុះថ្ងៃទី ២០ ខែ មីនា ឆ្នាំ ១៨៨៣ ហើយបានកែសម្រួលជាបន្តក្រោយ ។

-**តក្កកម្ម** គឺជាគំនិតរបស់តក្កករដែលអាចយកទៅអនុវត្តបាន នៅក្នុងដំណោះស្រាយបញ្ហា

ជាក់លាក់ណាមួយក្នុងវិស័យបច្ចេកវិជ្ជា ។

- សំណុំលិខិតស្នើសុំដំបូង គឺជាសំណុំលិខិតស្នើសុំដែលបានដាក់មុន ឬបានសុំចុះបញ្ជីមុន ។

ផ្នែកទី ២

នីតិវិធីផ្តល់ប្រកាសនីយបត្រតក្កកម្ម និងវិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍

ប្រការ ៤.- ចំណាត់ថ្នាក់នៃប្រកាសនីយបត្រតក្កកម្ម និងវិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍

មន្ត្រីកាន់កាប់បញ្ជីត្រូវអនុវត្តតាមចំណាត់ថ្នាក់អន្តរជាតិនៃប្រកាសនីយបត្រតក្កកម្ម ដែលបានអនុម័តក្រោមកិច្ចព្រមព្រៀងទីក្រុងស្ត្រាសបួ ចុះថ្ងៃទី ២៤ ខែ មីនា ឆ្នាំ ១៩៧១ ហើយដែលបានកែសម្រួលបោះពុម្ពជាបន្តបន្ទាប់ សម្រាប់បម្រើគោលបំណងពាក់ព័ន្ធនឹងការផ្តល់ និងការចុះផ្សាយប្រកាសនីយបត្រតក្កកម្ម និងវិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ ដើម្បីងាយស្រួលក្នុងការស្រាវជ្រាវរកឯកសារ ដែលបានរក្សាទុកតាមចំណាត់ថ្នាក់ ។

ប្រការ ៥.- សំណុំលិខិតស្នើសុំប្រកាសនីយបត្រតក្កកម្ម និងវិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍

អនុលោមតាមមាត្រា ១៦ នៃច្បាប់ សំណុំលិខិតស្នើសុំប្រកាសនីយបត្រតក្កកម្ម និងវិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ដែលរួមមាន ពាក្យសុំ សេចក្តីអធិប្បាយអំពីតក្កកម្ម សេចក្តីអះអាងមួយឬច្រើន គំនូសបង្ហាញមួយឬច្រើន ប្រសិនបើគម្រូវ និងខ្លឹមសារសង្ខេប ត្រូវដាក់នៅនាយកដ្ឋានទទួលបន្ទុកចុះបញ្ជី ដោយបង់កម្រៃតាមការកំណត់ ។

ប្រការ ៦.- ពាក្យសុំ

ពាក្យសុំ ត្រូវមានលក្ខណៈដូចខាងក្រោម :

១-ពាក្យសុំប្រកាសនីយបត្រតក្កកម្ម និងវិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ ត្រូវបំពេញតាមគំរូពាក្យសុំលេខ **១ប្រក/មយ** ដូចមានភ្ជាប់ក្នុង**ឧបសម្ព័ន្ធ ក** នៃប្រកាសនេះ ។

២-ពាក្យសុំត្រូវបញ្ជាក់ ឈ្មោះ អសយដ្ឋាន សញ្ជាតិ និងទីលំនៅរបស់អ្នកដាក់ពាក្យសុំម្នាក់ៗ និងត្រូវចុះហត្ថលេខាដោយអ្នកដាក់ពាក្យសុំម្នាក់ៗ ។

៣-ក្នុងករណីអ្នកដាក់ពាក្យសុំជាតក្កករ ពាក្យសុំត្រូវតែភ្ជាប់មកជាមួយនូវលិខិតបញ្ជាក់អំពីអានុភាពនោះ ហើយក្នុងករណីដែលអ្នកដាក់ពាក្យសុំមិនមែនជាតក្កករទេនោះ ពាក្យសុំត្រូវបញ្ជាក់ឈ្មោះ និងអសយដ្ឋានរបស់តក្កករម្នាក់ៗ ព្រមទាំងភ្ជាប់មកជាមួយនូវឯកសារបញ្ជាក់អំពីសិទ្ធិ របស់អ្នកដាក់ពាក្យសុំចំពោះប្រកាសនីយបត្រតក្កកម្ម និងវិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ ។

៤-ប្រសិនបើអ្នកដាក់ពាក្យសុំត្រូវបានតំណាងដោយភ្នាក់ងារ ពាក្យសុំត្រូវបញ្ជាក់ និងថ្លែងបញ្ជាក់ផងដែរនូវ ឈ្មោះ និងអសយដ្ឋានរបស់ភ្នាក់ងារនោះ ។/

៥_ចំណងជើងនៃតក្កកម្មត្រូវតែខ្លីហើយច្បាស់លាស់ ។

ប្រការ ៧._ សេចក្តីអធិប្បាយ

សេចក្តីអធិប្បាយ ត្រូវមានលក្ខណៈដូចខាងក្រោម:-

១_សេចក្តីអធិប្បាយត្រូវបញ្ជាក់ជាដំបូងនូវចំណងជើងនៃតក្កកម្ម ដូចមានបង្ហាញនៅក្នុងពាក្យសុំ ហើយត្រូវ:-

ក_រៀបរាប់ឱ្យបានច្បាស់លាស់អំពីផ្នែកបច្ចេកទេស ដែលពាក់ព័ន្ធទៅនឹងតក្កកម្ម ។

ខ_បញ្ជាក់អំពីស្ថានភាពដែលជាមូលដ្ឋាន ដែលបានដឹងចំពោះអ្នកដាក់ពាក្យសុំអាចត្រូវចាត់ទុកថា អាចប្រើប្រាស់សម្រាប់ការយល់ដឹង ការស្រាវជ្រាវ និងការពិនិត្យតក្កកម្ម និងការដកស្រង់ឯកសារដែលឆ្លុះបញ្ចាំងស្ថានភាពនោះ ។

គ_បង្ហាញឱ្យដឹងពីតក្កកម្មនៅក្នុងល័ក្ខខ័ណ្ឌដែលអាចយល់ដឹងបាន និងបញ្ជាក់អានុភាពដ៏មានផលប្រយោជន៍របស់តក្កកម្ម ដោយយោងតាមស្ថានភាពដែលជាមូលដ្ឋាននោះ ប្រសិនបើមាន ។

ឃ_អធិប្បាយយ៉ាងសង្ខេបអំពីរូបគំនូរដែលបង្ហាញនៅក្នុងគំនូសបង្ហាញ ប្រសិនបើមាន ។

ង_កំណត់យកយ៉ាងហោចណាស់វិធីមួយបែបល្អជាងគេបំផុត ដែលបានគិតទុកដោយអ្នកដាក់ពាក្យសុំសម្រាប់អនុវត្តតក្កកម្ម។ ករណីនេះត្រូវធ្វើឡើងក្នុងល័ក្ខខ័ណ្ឌនៃឧទាហរណ៍ ប្រសិនបើសមស្រប ព្រមទាំងយោងទៅគំនូសបង្ហាញ ប្រសិនបើមាន ។

ច_បញ្ជាក់ឱ្យបានជាក់លាក់នូវរបៀប ដែលតក្កកម្មអាចយកទៅអនុវត្តបាននៅក្នុងលក្ខណៈឧស្សាហកម្ម និងរបៀបដែលតក្កកម្មអាចត្រូវយកទៅផលិត និងប្រើប្រាស់ ឬប្រសិនបើតក្កកម្មអាចត្រូវប្រើប្រាស់តែប៉ុណ្ណោះ ត្រូវបញ្ជាក់របៀបដែលអាចយកទៅប្រើប្រាស់នោះ នៅពេលដែលតក្កកម្មមានសភាពខុសប្លែកពីសេចក្តីអធិប្បាយ ឬពីលក្ខណៈរបស់តក្កកម្ម ។

២_របៀបរបប និងសណ្តាប់ធ្នាប់ដែលបានចែងក្នុងចំណុច ១ នៃប្រការនេះ ត្រូវអនុវត្តតាម លើកលែងតែនៅពេលណារបៀបរបបខុសគ្នា ឬសណ្តាប់ធ្នាប់ខុសគ្នានឹងផ្តល់ជាលទ្ធផល ការយល់ដឹងកាន់តែប្រសើរឡើង និងការបង្ហាញកាន់តែសង្ខេបខ្លីថែមទៀត ព្រោះតែប្រភេទនៃតក្កកម្ម ។

ប្រការ ៨._ សេចក្តីអះអាង

សេចក្តីអះអាងត្រូវមានលក្ខណៈដូចខាងក្រោម :

១_ចំនួននៃសេចក្តីអះអាងត្រូវតែមានលក្ខណៈសមស្របទៅតាមលក្ខណៈរបស់តក្កកម្ម។

៦៤

ប្រសិនបើមានសេចក្តីអះអាងច្រើន ត្រូវចុះលេខរៀងតាមលំដាប់លំដោយជាលេខខ្មែរ។

២. សេចក្តីអះអាងត្រូវកំណត់តក្កកម្មទៅតាមលក្ខណៈបច្ចេកទេសរបស់តក្កកម្មនោះ ។

៣. នៅពេលណាដែលសមស្របសេចក្តីអះអាងត្រូវមាន :

ក. សេចក្តីថ្លែងបញ្ជាក់អំពីលក្ខណៈបច្ចេកទេសពិសេសទាំងឡាយរបស់តក្កកម្ម ដែលចាំបាច់សម្រាប់ការកំណត់អត្ថន័យនៃតក្កកម្ម ក៏ប៉ុន្តែក្នុងការផ្សំបញ្ចូលគ្នា វាជាផ្នែកនៃស្នាដៃមុន ។

ខ. បង្ហាញលក្ខណៈផ្នែកដែលនាំមុខដោយពាក្យពេចន៍ **"បានស្តែងនូវលក្ខណៈដែលក្នុងនោះ"** **"បានស្តែងនូវលក្ខណៈដោយ"** **"ដែលនៅក្នុងនោះការធ្វើឱ្យប្រសើរឡើងមាន"** ឬពាក្យពេចន៍ណាមួយផ្សេងទៀតដែលមានអានុភាពដូចគ្នា ដែលថ្លែងយ៉ាងសង្ខេបអំពីលក្ខណៈបច្ចេកទេសដែលផ្សំបញ្ចូលគ្នាជាមួយលក្ខណៈទាំងឡាយ ដែលមានចែងនៅក្នុងចំណុច ក គឺមានបំណងចង់ការពារ ។

៤. លើកលែងតែករណីចាំបាច់ដាច់ខាត សេចក្តីអះអាងមិនត្រូវសំអាងលើលក្ខណៈបច្ចេកទេសរបស់តក្កកម្មអំពីការយោងលើសេចក្តីអធិប្បាយ ឬគំនូសបង្ហាញ ។ ជាពិសេសសេចក្តីអះអាងមិនត្រូវសំអាងលើការយោងទាំងនេះទេ ដូចជា **"ដូចបានពណ៌នានៅក្នុងផ្នែក...នៃសេចក្តីអធិប្បាយ"** ឬ **"ដូចបានបង្ហាញនៅក្នុងរូបគំនូរ...នៃគំនូសបង្ហាញ"** ។

៥. ក្នុងករណីដែលសំណុំលិខិតស្នើសុំមានគំនូសបង្ហាញលក្ខណៈបច្ចេកទេស ដែលបានបញ្ជាក់នៅក្នុងសេចក្តីអះអាង ត្រូវដាក់តាមលំដាប់លំដោយយ៉ាងសមស្រប ដោយសញ្ញាយោងពាក់ព័ន្ធទៅនឹងលក្ខណៈទាំងនោះ ។ នៅពេលដែលប្រើប្រាស់សញ្ញាយោង ត្រូវដាក់យ៉ាងសមស្របនៅក្នុងវង់ក្រចក ។ ប្រសិនបើការបញ្ចូលសញ្ញាយោងមិនជួយសម្រួល ជាពិសេសឱ្យងាយយល់ឆាប់រហ័ស អំពីសេចក្តីអះអាងទេនោះ សញ្ញាយោងនេះមិនត្រូវយកមកប្រើប្រាស់ទេ ។

៦. សេចក្តីអះអាងណាមួយដែលបានយកមកដាក់ក្រោយកាលបរិច្ឆេទសុំចុះបញ្ជីរបស់សំណុំលិខិតស្នើសុំ ហើយដែលមិនបានបញ្ជាក់ប្រាប់ជាមួយនឹងសេចក្តីអះអាងដែលលេចចេញពីមុន នៅក្នុងសំណុំលិខិតស្នើសុំ ត្រូវយកមកដាក់ជាសេចក្តីអះអាងកែសម្រួល ឬជាសេចក្តីអះអាងថ្មីអាស្រ័យលើការជ្រើសរើសយករបស់អ្នកដាក់ពាក្យសុំ ។

៧. ការលុបចោលសេចក្តីអះអាងណាមួយ ដែលលេចចេញពីមុននៅក្នុងសំណុំលិខិតស្នើសុំ ត្រូវតែធ្វើឡើងដោយបញ្ជាក់លេខនៃសេចក្តីអះអាងពីមុននោះ ដោយប្រើពាក្យ **"លុបចោល"**។

ប្រការ ៩.- គំនូសបង្ហាញ

គំនូសបង្ហាញត្រូវមានលក្ខណៈដូចខាងក្រោម :

១. គំនូសបង្ហាញដែលជាផ្នែកមួយនៃសំណុំលិខិតស្នើសុំប្រកាសនីយបត្រតក្កកម្ម និងវិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ ត្រូវគូសនៅលើក្រដាសដែលមានផ្ទៃអាចប្រើប្រាស់បានមាន

ទំហំមិនលើសពី ២៦,២ស.ម.X១៧ស.ម. ។ សន្លឹកក្រដាសមិនត្រូវមានរឹមនៅជុំវិញផ្ទៃដែលអាចប្រើប្រាស់បាន ឬផ្ទៃដែលប្រើរួចហើយ ។ ប្រវែងអប្បបរមាត្រូវមានដូចខាងក្រោមនេះ :

ក-ផ្នែកខាងលើ ប្រវែង ២,៥ ស.ម.

ខ-ផ្នែកខាងឆ្វេង ប្រវែង ២,៥ ស.ម.

គ-ផ្នែកខាងស្តាំ ប្រវែង ១,៥ ស.ម.

ឃ-ផ្នែកខាងក្រោម ប្រវែង ១,០ ស.ម.

២-គំនូសបង្ហាញត្រូវប្រតិបត្តិដូចខាងក្រោម :

ក-គ្មានពណ៌ រក្សាទុកបានយូរ ពណ៌ខ្មៅ ជិតល្មម និងខ្មៅ មានកម្រាស់ដូចៗគ្នា ហើយមានបន្ទាត់ច្បាស់ និងជាប់មិនដាច់ ដើម្បីអនុញ្ញាតឱ្យថតចម្លងឡើងវិញបានសមរម្យ ។

ខ-ផ្នែកដែលពុះត្រូវតែបញ្ជាក់ដោយគំនូសឆ្នូត ដែលមិនរាំងដល់ការអានច្បាស់លាស់នៃសញ្ញាយោង និងបន្ទាត់មេ ។

គ- មាត្រដ្ឋានរបស់គំនូសបង្ហាញ និងការចែកដាច់ពីគ្នានៃក្រាហ្វិចអនុវត្តត្រូវតែអាចថតបាន ព្រមទាំងបង្រួមបានក្នុងទំហំពីរភាគបី(២/៣) ដែលអាចឱ្យសំគាល់ការលំអិតទាំងអស់បានដោយមិនពិបាក ។ ក្នុងករណីលើកលែងមាត្រដ្ឋានដែលបានផ្តល់នៅលើគំនូសបង្ហាញត្រូវតែតំណាងឱ្យគំនូរតាង ។

ឃ-លេខទាំងអស់ អក្សរទាំងអស់ ក្រាហ្វិច និងសញ្ញាយោងទាំងអស់ដែលវិលេចនៅក្នុងគំនូសបង្ហាញ ត្រូវតែធម្មតា និងច្បាស់ ហើយវង់ដង្កៀប រង្វង់មូល សញ្ញាក្បៀសបញ្ច្រាស មិនត្រូវប្រើប្រាស់ជាមួយលេខ និងអក្សរទេ ។

ង-ធាតុនានានៃរូបដូចគ្នា ត្រូវតែសមមាត្រគ្នាទៅវិញទៅមក លុះត្រាតែមានការខុសប្លែកគ្នានៅក្នុងសមមាត្រដែលមិនអាចជៀសវាងបានសម្រាប់បញ្ជាក់រូបនោះ ។

ច-កំពស់របស់លេខ និងអក្សរត្រូវតែមិនតិចជាង ០,៣២ស.ម. ហើយជាទូទៅសម្រាប់ការដាក់អក្សរនៃគំនូសបង្ហាញត្រូវប្រើប្រាស់អក្សរឡាតាំង និងអក្សរក្រិច ។

ឆ-សន្លឹកដូចគ្នានៃគំនូសបង្ហាញអាចមានរូបជាច្រើន ។ ក្នុងករណីរូបបានគូសនៅលើសន្លឹកក្រដាសចំនួនពីរ ឬច្រើនដែលមានចំណងចង់បង្កើតរូបមួយទាំងមូល រូបនៅលើសន្លឹកក្រដាសជាច្រើននោះ ត្រូវតែរៀបចំឱ្យចេញជារូបមួយទាំងមូលអាចផ្គុំបញ្ចូលគ្នាបាន ដោយគ្មានបោះបង់ចោលនូវផ្នែកណាមួយនៃរូបភាពនោះ ។ រូបខុសគ្នាត្រូវតែរៀបចំដោយមិនឱ្យសល់ផ្ទៃទំនេរច្រើន ចែកដាច់ពីគ្នាច្បាស់លាស់ពីមួយទៅមួយ ។ រូបខុសៗគ្នាត្រូវតែដាក់លេខរៀងបន្តបន្ទាប់គ្នា ដោយឡែកពីការដាក់លេខនៃសន្លឹកក្រដាស ។

ង-សញ្ញាយោងដែលមិនបានបញ្ជាក់នៅក្នុងសេចក្តីអធិប្បាយ ឬសេចក្តីអះអាង មិនត្រូវរំលេចនៅក្នុងគំនូសបង្ហាញទេ ផ្ទុយទៅវិញប្រសិនបើសញ្ញាយោង ដែលបានបញ្ជាក់នៅក្នុងសេចក្តីអធិប្បាយ ឬសេចក្តីអះអាងអាចរំលេចនៅក្នុងគំនូសបង្ហាញ ។ កាលណាមានបង្ហាញដោយសញ្ញាយោងលក្ខណៈដូចគ្នា ត្រូវតែបង្ហាញដោយសញ្ញាដូចគ្នានៅក្នុងសំណុំលិខិតស្នើសុំទាំងមូល ។

ឈ-គំនូសបង្ហាញមិនត្រូវមានហេតុផលជាអត្ថបទទេ លើកលែងតែកាលណាតម្រូវឱ្យស្វែងយល់អំពីគំនូសបង្ហាញនូវពាក្យទោល ឬពាក្យពីរបីដូចជា "ទឹក" "ចំហាយ" "បើក" "បិទ" "ផ្នែកទៅលើអេអេ" ហើយក្នុងករណីចរន្តអគ្គីសនី និងប្រអប់គំនូសបំព្រួញ ឬឌីយ៉ាក្រាមនៃដំណើរការអ្វីមួយ ពាក្យសំខាន់ៗខ្លីៗបន្តិចបន្តួច ។

ញ-សន្លឹកក្រដាសនៃគំនូសបង្ហាញត្រូវតែដាក់លេខដោយយោងតាមចំណុច ៧ នៃប្រការ ១៦ នៃប្រកាសនេះ ។

ដ-គំនូសបំព្រួញពីដំណើរការ ឬឌីយ៉ាក្រាមត្រូវបានចាត់ទុកថាជាគំនូសបង្ហាញ ។

ប្រការ ១០.- ខ្លឹមសារសង្ខេប

ខ្លឹមសារសង្ខេប ត្រូវមានលក្ខណៈដូចខាងក្រោម:-

១- ខ្លឹមសារសង្ខេបត្រូវតែបានព្រាងឡើង ដែលអាចយកទៅប្រើដោយប្រសិទ្ធភាពជាឧបករណ៍ស្កេន សម្រាប់គោលបំណងនៃការស្រាវជ្រាវនៅក្នុងស្នាដៃជាក់លាក់ ។

២-ខ្លឹមសារសង្ខេបត្រូវរួមមាន :

ក-សេចក្តីសង្ខេបនៃការបញ្ចេញឱ្យដឹងដូចមានរៀបរាប់នៅក្នុងសេចក្តីអធិប្បាយ សេចក្តីអះអាង និងគំនូសបង្ហាញណាមួយដែលបញ្ជាក់ផ្នែកបច្ចេកទេសពាក់ព័ន្ធទៅនឹងតក្កកម្ម និងត្រូវធ្វើយ៉ាងណាឱ្យងាយយល់អំពីបញ្ហាបច្ចេកទេស សារៈសំខាន់នៃដំណោះស្រាយរបស់បញ្ហានោះ តាមរយៈតក្កកម្ម និងគោលការណ៍ប្រើប្រាស់តក្កកម្ម ឬការប្រើប្រាស់តក្កកម្ម ។

ខ-ក្នុងករណីចាំបាច់ រូបមន្តគីមីដែលស្តែងល្អជាងគេរបស់តក្កកម្មក្នុងចំណោមរូបមន្តទាំងឡាយដែលមាននៅក្នុងសំណុំលិខិតស្នើសុំ ។

៣-ខ្លឹមសារសង្ខេបត្រូវ បរិយាយឱ្យខ្លីមិនឱ្យលើសពីមួយរយហាសិប(១៥០)ពាក្យ ។

៤-ខ្លឹមសារសង្ខេបមិនត្រូវមានសេចក្តីថ្លែងអំពីអត្ថសេចក្តីដែលបានអះអាង ឬតម្លៃនៃតក្កកម្ម ឬអំពីការអនុវត្តន៍ដោយមិនប្រាកដចំពោះតក្កកម្ម ។

៥-លក្ខណៈបច្ចេកទេសសំខាន់នីមួយៗ ដែលរៀបរាប់នៅក្នុងខ្លឹមសារសង្ខេប និងដែលបានពន្យល់ដោយគំនូសបង្ហាញនៅក្នុងសំណុំលិខិតស្នើសុំ ត្រូវតែកត់សំគាល់ដោយសញ្ញាយោង ហើយដាក់នៅក្នុងវង់ក្រចក ។ ៤

៦-ខ្លឹមសារសង្ខេប ត្រូវតែភ្ជាប់មកជាមួយនូវគំនូសបង្ហាញណាមួយដែលពន្យល់ ។

ប្រការ ១១.- ភាសានៃឯកសារ និងការបកប្រែ

ភាសានៃឯកសារ និងការបកប្រែ ត្រូវអនុវត្តដូចខាងក្រោមៈ-

១-សំណុំលិខិតស្នើសុំទាំងឡាយ និងឯកសារណាមួយដែលបង្កើតបានជាផ្នែកមួយនៃសំណុំលិខិតស្នើសុំ ឬឯកសារណាមួយបានដាក់ជូននាយកដ្ឋានទទួលបន្ទុកចុះបញ្ជី ឬមន្ត្រីកាន់កាប់បញ្ជី អនុលោមតាមច្បាប់ ប្រកាសនេះ និងបទបញ្ញាពាក់ព័ន្ធត្រូវធ្វើជាភាសាខ្មែរ ។

២-សម្រាប់គោលបំណងនៃការស្រាវជ្រាវ និងការពិនិត្យ ក្នុងករណីសំណុំលិខិតស្នើសុំ និងឯកសារដូចមានចែងក្នុងចំណុច ១ នៃប្រការនេះ ដែលបានសរសេរជាភាសាខ្មែរ ឬជាភាសាបរទេសក្រៅពីភាសាអង់គ្លេស ត្រូវបកប្រែជាភាសាអង់គ្លេស ហើយត្រូវដាក់ជូនមន្ត្រីកាន់កាប់បញ្ជីក្នុងរយៈពេលប្រាំមួយ (៦) ខែគិតចាប់ពីកាលបរិច្ឆេទនៃការសុំចុះបញ្ជី ។

៣-សម្រាប់គោលបំណងនៃការវិនិច្ឆ័យ ការការពារ និងការអនុវត្តន៍ច្បាប់ ក្នុងករណីសំណុំលិខិតស្នើសុំ និងឯកសារ ដូចមានចែងក្នុងចំណុច ១ នៃប្រការនេះ ដែលសរសេរជាភាសាបរទេស ក្រៅពីភាសាខ្មែរ ត្រូវបកប្រែជាភាសាខ្មែរ ហើយត្រូវដាក់ជូនមន្ត្រីកាន់កាប់បញ្ជីក្នុងរយៈពេលប្រាំមួយ(៦)ខែ គិតចាប់ពីកាលបរិច្ឆេទនៃការសុំចុះបញ្ជី ។

ប្រការ ១២.- ការបញ្ជាក់ឈ្មោះ សញ្ជាតិ អសយដ្ឋាន និងលំនៅដ្ឋាន

ការបញ្ជាក់ឈ្មោះ អសយដ្ឋាន សញ្ជាតិ និងលំនៅដ្ឋាន ត្រូវអនុវត្តដូចខាងក្រោមៈ-

១-ត្រង់ចំណុចឈ្មោះរបស់រូបវន្តបុគ្គលត្រូវបញ្ជាក់ដោយ នាមត្រកូល នាមខ្លួន សញ្ជាតិ និងអសយដ្ឋានរបស់បុគ្គលនោះ ។ ឈ្មោះរបស់នីតិបុគ្គល ត្រូវបញ្ជាក់ដោយឈ្មោះពេញជាផ្លូវការ របស់នីតិបុគ្គលនោះ ។

២-ត្រង់ចំណុចសញ្ជាតិត្រូវបញ្ជាក់ឈ្មោះប្រទេសដែលបុគ្គលនោះជាជនជាតិ ។ នីតិបុគ្គលត្រូវបញ្ជាក់ឈ្មោះប្រទេសដែលនីតិបុគ្គលនោះត្រូវបានបង្កើតនៅក្រោមច្បាប់នៃប្រទេសនោះ ព្រមទាំងការិយាល័យដែលបានចុះបញ្ជីរួចហើយរបស់នីតិបុគ្គលនោះ ។

៣-ត្រង់ចំណុចអសយដ្ឋានរបស់អ្នកដាក់ពាក្យសុំ ត្រូវបញ្ជាក់តាមវិធីណាមួយដើម្បីបំពេញការតម្រូវជាធម្មតា សម្រាប់ការបញ្ជូនតាមប្រៃសណីយ៍បានឆាប់ទៅដល់អសយដ្ឋានដែលបញ្ជាក់នោះ ហើយក្នុងករណីណាមួយក៏ដោយ ក៏ត្រូវបញ្ជាក់ផងដែរនូវអង្គភាពរដ្ឋបាលពាក់ព័ន្ធរួមទាំងលេខផ្ទះ ប្រសិនបើមាន ។ អសយដ្ឋានត្រូវមានបញ្ជាក់ លេខទូរស័ព្ទ លេខទូរសារ និងអសយដ្ឋាន អ៊ីម៉ែលផងដែរ ។

៤-ត្រង់ចំណុចលំនៅដ្ឋានត្រូវបានបញ្ជាក់ឈ្មោះប្រទេស ដែលបុគ្គលនោះជាជនមានលំនៅដ្ឋានជាប់លាប់ ។/៨

៥-គ្រប់អ្នកដាក់ពាក្យសុំ ប្រកាសនីយបត្រតក្កកម្ម វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ ត្រូវផ្តល់ជូនមន្ត្រីកាន់កាប់បញ្ជីនូវអសយដ្ឋាន សម្រាប់ទំនាក់ទំនងនៅក្នុងព្រះរាជាណាចក្រកម្ពុជា សម្រាប់គោលបំណងនៃសំណុំលិខិតស្នើសុំរបស់គាត់ ។

ប្រការ ១៣.- ការប្តូរឈ្មោះ សញ្ជាតិ និងអសយដ្ឋាន

ការប្តូរឈ្មោះ សញ្ជាតិ និងអសយដ្ឋាន ត្រូវអនុវត្តដូចខាងក្រោមៈ-

១-សំណើសុំដោយម្ចាស់ ឬដោយអ្នកដាក់ពាក្យសុំប្រកាសនីយបត្រតក្កកម្ម វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ ដើម្បីប្តូរឈ្មោះ សញ្ជាតិ អសយដ្ឋាន ឬអសយដ្ឋានសម្រាប់ទាក់ទង ដែលបានកត់ត្រាចំពោះប្រកាសនីយបត្រតក្កកម្ម វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ ឬនៅក្នុងសំណុំលិខិតស្នើសុំខាងលើរបស់ខ្លួន ត្រូវធ្វើជាលាយលក្ខណ៍អក្សរ ។

២-មុននឹងអនុវត្តតាមសំណើក្នុងការប្តូរឈ្មោះ ឬសញ្ជាតិ មន្ត្រីកាន់កាប់បញ្ជីអាចតម្រូវឱ្យអ្នកដាក់ពាក្យសុំ ផ្តល់ភស្តុតាងសមស្របពាក់ព័ន្ធទៅនឹងការប្តូរនេះ ។

៣-ប្រសិនបើមន្ត្រីកាន់កាប់បញ្ជីពិនិត្យឃើញថា សំណើនោះសមស្រប មន្ត្រីកាន់កាប់បញ្ជី ត្រូវអនុវត្តការប្តូរនោះលើប្រកាសនីយបត្រតក្កកម្ម វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ ឬក៏លើសំណុំលិខិតស្នើសុំខាងលើ ហើយក្នុងករណីដែលឈ្មោះ សញ្ជាតិ ឬអសយដ្ឋានបានកត់ត្រារួចហើយនៅក្នុងបញ្ជី បញ្ជីនោះក៏ត្រូវតែកត់ត្រាការប្តូរនោះ ឱ្យបានត្រឹមត្រូវ ។

ប្រការ ១៤.- ការចុះហត្ថលេខា

ការចុះហត្ថលេខា ត្រូវអនុវត្តដូចខាងក្រោមៈ-

១-ឯកសារដែលរៀបចំដើម្បីចុះហត្ថលេខាជួសមុខឱ្យ ឬក្នុងនាមក្រុមហ៊ុនសហកម្មសិទ្ធិមួយ ត្រូវមានឈ្មោះរបស់ក្រុមហ៊ុន និងដៃគូទាំងអស់ ជាឈ្មោះពេញ ហើយត្រូវបានចុះហត្ថលេខា ដោយអ្នកទាំងអស់នោះ ឬដោយដៃគូណាមួយ ដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ដើម្បីចុះហត្ថលេខា ដោយបញ្ជាក់ថា ដៃគូនោះចុះហត្ថលេខាក្នុងនាមក្រុមហ៊ុនសហកម្មសិទ្ធិ ឬចុះហត្ថលេខា ដោយបុគ្គលណាម្នាក់ផ្សេងទៀត ដែលមន្ត្រីកាន់កាប់បញ្ជីទទួលស្គាល់ថា បុគ្គលនោះត្រូវបានអនុញ្ញាតឱ្យចុះហត្ថលេខាលើឯកសារ ។ ឯកសារដែលបានរៀបចំដើម្បីចុះហត្ថលេខាជួសមុខឱ្យ ឬក្នុងនាមអង្គភាពសាជីវកម្ម ត្រូវចុះហត្ថលេខាដោយនាយក ឬដោយលេខាធិការ ឬមន្ត្រីសំខាន់ណាមួយផ្សេងទៀត របស់អង្គភាពសាជីវកម្មនោះ ឬដោយបុគ្គលណាមួយផ្សេងទៀត ដែលមន្ត្រីកាន់កាប់បញ្ជីទទួលស្គាល់ថា បុគ្គលនោះត្រូវបានអនុញ្ញាតឱ្យចុះហត្ថលេខាលើឯកសារ និងប្រថាប់ត្រារបស់អង្គភាពសាជីវកម្មនោះ ។ ឯកសារដែលរៀបចំឡើងដើម្បីចុះហត្ថលេខាជួសមុខឱ្យ ឬក្នុងនាមសមាគមនៃបុគ្គលច្រើននាក់ អាចត្រូវចុះហត្ថលេខាដោយបុគ្គលណាម្នាក់ ដែលមន្ត្រីកាន់កាប់បញ្ជីទទួលស្គាល់ថា បុគ្គលនោះបានទទួលសិទ្ធិស្របច្បាប់ ដើម្បីចុះហត្ថលេខា ។

២_ក្នុងករណីដែលយល់ថាចាំបាច់ មន្ត្រីកាន់កាប់បញ្ជីត្រូវស្នើសុំឱ្យផ្តល់ភស្តុតាងនៃការអនុញ្ញាតឱ្យចុះហត្ថលេខា ។

ប្រការ ១៥._ រង្វាស់ សារព័ន្ធស័ព្ទ និងសញ្ញាសំគាល់

រង្វាស់ សារព័ន្ធស័ព្ទ និងសញ្ញាសំគាល់ត្រូវមានលក្ខណៈដូចខាងក្រោម :

១_ឯកតានៃទម្ងន់ និងរង្វាស់ ត្រូវតែបញ្ជាក់ទៅតាមនៃប្រព័ន្ធដែលប្រើប្រាស់ម៉ែត្រជាមូលដ្ឋាន ។

២_សីតុណ្ហភាពត្រូវតែបញ្ជាក់ជាអង្សាសែលស៊ីស ។

៣_ដង់ស៊ីតេត្រូវបញ្ជាក់ជាឯកតានៃប្រពន្ធ័ដែលប្រើប្រាស់ម៉ែត្រជាមូលដ្ឋាន ។

៤_ការប្រើប្រាស់ស្តង់ដារ ជាទូទៅត្រូវតែប្រកាន់យកសម្រាប់ការចង្អុលបង្ហាញ កំដៅ ថាមពល ពន្លឺ សម្លេង និងម៉ាញេទិច ក៏ដូចជារូបមន្តគណិតវិទ្យា និងឯកតាអគ្គីសនី ។ ការប្រើប្រាស់ជាទូទៅត្រូវតែអនុវត្តសម្រាប់រូបមន្តគីមី និមិត្តសញ្ញា ទម្ងន់អាតូម និងរូបមន្ត ម៉ូលេគុល ។

៥_ជាទូទៅមានតែពាក្យ បច្ចេកទេស សញ្ញា និងនិមិត្តសញ្ញាប៉ុណ្ណោះ ដែលត្រូវប្រើប្រាស់តាមការយល់ព្រមជាទូទៅនៅក្នុងស្នាដៃដែលបានសិក្សាស្រាវជ្រាវរកឃើញ ។

៦_សារព័ន្ធស័ព្ទ និងសញ្ញានានា ត្រូវតែស៊ីសង្វាក់គ្នានៅក្នុងសំណុំលិខិតស្នើសុំ ។

ប្រការ ១៦._ ចំនួនឯកសារ និងការតម្រូវរូបសាស្ត្រ

លើកលែងបទប្បញ្ញត្តិនៃចំណុច ៧ នៃប្រការ ២០ នៃប្រកាសនេះ ចំនួនឯកសារ និងការតម្រូវផ្នែករូបសាស្ត្រត្រូវមានដូចខាងក្រោម :

១_សំណុំលិខិតស្នើសុំ និងឯកសារភ្ជាប់ជាមួយ ត្រូវតែដាក់ជូនមន្ត្រីកាន់កាប់បញ្ជីចំនួន បី(៣)ច្បាប់ ។ ក៏ប៉ុន្តែមន្ត្រីកាន់កាប់បញ្ជីអាចស្នើអ្នកដាក់ពាក្យសុំឱ្យផ្តល់សំណុំលិខិតស្នើសុំ និងឯកសារភ្ជាប់ជា មួយចំនួនច្រើនច្បាប់បន្ថែមទៀត តាមការចាំបាច់ ។

២_ឯកសារទាំងអស់នៃសំណុំលិខិតស្នើសុំ ត្រូវតែបង្ហាញផងដែរអំពីការអនុញ្ញាតឱ្យផលិតសារជាថ្មីផ្ទាល់តែម្តងដោយរូបថត ដំណើរការអេឡិចត្រូស្តាទិក បោះពុម្ពតាមរបៀបអូហ្វសិត និងការធ្វើមីក្រូហ្វីល ។

៣_អនុញ្ញាតឱ្យប្រើប្រាស់សន្លឹកក្រដាសតែម្ខាងសម្រាប់រៀបចំសំណុំលិខិតស្នើសុំ ។

៤_ឯកសារទាំងអស់នៃសំណុំលិខិតស្នើសុំ ត្រូវតែសរសេរលើក្រដាសដែលងាយបត់បាន មាំមិនងាយរហែក ពណ៌ស រលោង មិនភ្លឺចាំង និងរក្សាទុកបានយូរ ។

៥_ទំហំនៃសន្លឹកក្រដាស ត្រូវយកទំហំ អា៤ (២៩,៧ស.ម.x២១ស.ម.) ។ ប៉ុន្តែមន្ត្រីកាន់កាប់បញ្ជីអាចយល់ព្រមទទួលសន្លឹកក្រដាស ដែលមានទំហំផ្សេងទៀតបានតាមការចាំបាច់ ។

៦-រឹមនៃសន្លឹកក្រដាសនីមួយៗ ត្រូវមានប្រវែងអប្បបរមាដូចតទៅនេះ :

ក-រឹមខាងលើនៃទំព័រនីមួយៗមានមានប្រវែង ២,០ស.ម. លើកលែងតែទំព័រទីមួយ ។

ខ-រឹមខាងលើនៃទំព័រទីមួយមានប្រវែង ៣,០ស.ម. ។

គ-រឹមជ្រុងម្ខាងដែលទុកសម្រាប់កិប ឬចងជាសៀវភៅមានប្រវែង២,៥ស.ម.។

ឃ-រឹមជ្រុងម្ខាងទៀតមានប្រវែង ២,០ស.ម. ។

ង-រឹមខាងក្រោមមានប្រវែង ២,០ស.ម. ។

៧-ការតម្រូវថែមទៀតនៃសន្លឹកក្រដាស ត្រូវអនុវត្តដូចខាងក្រោម:-

ក-គ្រប់សន្លឹកក្រដាស ត្រូវដាក់លេខទំព័រនៅផ្នែកខាងលើចំកណ្តាល នៃទំព័រ ហើយលេខទំព័រនោះត្រូវដាក់តាមលំដាប់ជាប់គ្នា ។

ខ-ឯកសារទាំងឡាយនៃសំណុំលិខិតស្នើសុំ ត្រូវរៀបដាក់តាមលំដាប់លំដោយលេខរៀងនៃសន្លឹកដូចតទៅ : ពាក្យសុំ សេចក្តីអធិប្បាយ សេចក្តីអះអាង ខ្លឹមសារសង្ខេប គំនូសបង្ហាញ ។

គ-លំដាប់លំដោយលេខរៀងនៃសន្លឹករបស់សំណុំលិខិតស្នើសុំ ត្រូវបែងចែកជាលេខរៀងតៗគ្នាដោយឡែកពីគ្នាចំនួនបី(៣)ប្រភេទ ។ លេខរៀងប្រភេទទីមួយ អនុវត្តចំពោះពាក្យសុំតែប៉ុណ្ណោះ ដែលចាប់ផ្តើមពីសន្លឹកទីមួយនៃពាក្យសុំ ។ លេខរៀងប្រភេទទីពីរ ចាប់ផ្តើមពីទំព័រទីមួយនៃសេចក្តីអធិប្បាយ ហើយបន្តទៅសេចក្តីអះអាង និងរហូតដល់ទំព័រចុងក្រោយនៃខ្លឹមសារសង្ខេប ។ លេខរៀងប្រភេទទីបី អនុវត្តចំពោះសន្លឹកនៃគំនូសបង្ហាញតែប៉ុណ្ណោះ ដែលចាប់ផ្តើមពីសន្លឹកទីមួយនៃគំនូសបង្ហាញ ។

៨-អត្ថបទទាំងឡាយនៃសំណុំលិខិតស្នើសុំ ត្រូវតែវាយអង្គុយលីលេខ ឬកុំព្យូទ័រ។ រីឯនិមិត្តសញ្ញា ក្រាហ្វិក រូបមន្តគីមី ឬរូបមន្តគណិតវិទ្យា និងលក្ខណៈពិសេសផ្សេងទៀត អាចត្រូវបានអនុញ្ញាតឱ្យសរសេរដៃឬគូសបាន ប្រសិនបើចាំបាច់ ។

៩-គំនូសបង្ហាញ ត្រូវគូសបន្ទាត់ឱ្យបានល្អជាប់បានយូរ ពណ៌ខ្មៅ ដិតល្មម និងចាស់ល្មម មានកម្រាស់ស្មើៗគ្នា ច្បាស់ល្អ និងមិនគ្រើម ព្រមទាំងមិនដាក់ពណ៌ធម្មជាតិ ។

ប្រការ ១៧.- ការរួមបញ្ចូលគ្នានៃតក្កកម្ម

យោងតាមមាត្រា ២៣ នៃច្បាប់ត្រូវ:

១-បានបកស្រាយជាការអនុញ្ញាតដោយឡែកចំពោះលទ្ធភាពណាមួយ នៃលទ្ធភាពទាំងបី ដូចខាងក្រោមនេះ :

ក-ក្នុងការបន្ថែមលើសេចក្តីអះអាងដែលមានលក្ខណៈឯករាជ្យសម្រាប់

ផលិតផល ដែលបានផ្តល់ការបញ្ចូលនៅក្នុងសំណុំលិខិតស្នើសុំដូចគ្នា នូវសេចក្តីអះអាងដែលមានលក្ខណៈឯករាជ្យសម្រាប់ដំណើរការផលិតកម្ម ដែលសម្រួលជាពិសេសសម្រាប់ការផលិតនូវផលិតផលដែលបានថែង និងការបញ្ចូលនៅក្នុងសំណុំលិខិតស្នើសុំដូចគ្នា នូវសេចក្តីអះអាងដែលមានលក្ខណៈឯករាជ្យសម្រាប់ការប្រើប្រាស់នៃផលិតផលដែលបានថែង ឬ

ខ-ក្នុងការបន្ថែមទៅលើសេចក្តីអះអាងដែលមានលក្ខណៈឯករាជ្យ សម្រាប់ដំណើរការផលិតកម្មដែលបានផ្តល់ ការបញ្ចូលនៅក្នុងសំណុំលិខិតស្នើសុំដូចគ្នា នូវសេចក្តីអះអាងដែលមានលក្ខណៈឯករាជ្យសម្រាប់បរិក្ខា ឬមធ្យោបាយនានា ដែលបានគ្រោងជាពិសេសសម្រាប់អនុវត្តដំណើរការផលិតកម្មនោះ ឬ

គ-ក្នុងការបន្ថែមទៅលើសេចក្តីអះអាង ដែលមានលក្ខណៈឯករាជ្យសម្រាប់ផលិតផល ដែលបានផ្តល់ការបញ្ចូលនៅក្នុងសំណុំលិខិតស្នើសុំដូចគ្នា នូវសេចក្តីអះអាងដែលមានលក្ខណៈឯករាជ្យ សម្រាប់ដំណើរការផលិតកម្មដែលសម្រួលជាពិសេសសម្រាប់ផលិតនូវផលិតផល និងការបញ្ចូលនៅក្នុងសំណុំលិខិតស្នើសុំដូចគ្នា នូវសេចក្តីអះអាងដែលមានលក្ខណៈឯករាជ្យសម្រាប់បរិក្ខា ឬមធ្យោបាយនានា ដែលបានគ្រោងជាពិសេសសម្រាប់អនុវត្តដំណើរការផលិតកម្ម។

២-បានអនុញ្ញាតឱ្យបញ្ចូលនៅក្នុងសំណុំលិខិតស្នើសុំដូចគ្នា នូវសេចក្តីអះអាង ដែលមានលក្ខណៈឯករាជ្យចំនួនពីរ ឬច្រើន ដែលមានប្រភេទដូចគ្នាដែលមិនអាចគ្របដណ្តប់ទាំងស្រុងដោយសេចក្តីអះអាងទោលតាមប្រភេទមួយ ។

៣-បានអនុញ្ញាតិឱ្យបញ្ចូលនៅក្នុងសំណុំលិខិតស្នើសុំដូចគ្នានូវចំនួនសមស្រប នៃសេចក្តីអះអាងដែលមានលក្ខណៈឯករាជ្យ ដែលអះអាងពីទម្រង់ជាក់លាក់នានារបស់តក្កកម្ម ដែលបានទាមទារនៅក្នុងសេចក្តីអះអាងដែលមានលក្ខណៈឯករាជ្យនោះ ។

ប្រការ ១៨.- ការបំបែកនៃសំណុំលិខិតស្នើសុំ

ការបំបែកនៃសំណុំលិខិតស្នើសុំ ត្រូវអនុវត្តដូចខាងក្រោមៈ-

១-យោងតាមមាត្រា ២៥នៃច្បាប់ សំណុំលិខិតស្នើសុំបំបែក ត្រូវមានសេចក្តីយោងទៅតាមសំណុំលិខិតស្នើសុំពីដំបូង ។

២-ប្រសិនបើអ្នកដាក់ពាក្យសុំចង់ឱ្យសំណុំលិខិតស្នើសុំបំបែក ទទួលផលប្រយោជន៍ពីអាទិភាពណាមួយដែលបានអះអាងសម្រាប់សំណុំលិខិតស្នើសុំពីដំបូង សំណុំលិខិតស្នើសុំបំបែកត្រូវមានការស្នើសុំចំពោះប្រសិទ្ធភាពនោះ ។ ក្នុងករណីនេះ ការប្រកាសអាទិភាព និងឯកសារទាំងឡាយដែលបានផ្តល់ យោងតាមប្រការ ២០ នៃប្រកាសនេះ សម្រាប់សំណុំលិខិតស្នើសុំពីដំបូងត្រូវចាត់ទុកថាមានការពាក់ព័ន្ធទៅនឹងសំណុំលិខិតស្នើសុំបំបែកផងដែរ ។

៣-ក្នុងករណីអាទិភាពនៃសំណុំលិខិតស្នើសុំមុនចំនួនពីរ ឬច្រើន ត្រូវបានអះអាង

សម្រាប់សំណុំលិខិតស្នើសុំពីដំបូង សំណុំលិខិតស្នើសុំបំបែកអាចទទួលបានផលប្រយោជន៍តែពីអាទិភាពមួយ ឬច្រើន ដែលអាចអនុវត្តបានចំពោះខ្លួនតែប៉ុណ្ណោះ ។

ប្រការ ១៩.- ការបញ្ចេញឱ្យដឹង ដែលមិនត្រូវបានចាត់ទុកថាបានការសម្រាប់ស្នាដៃមុន

ការបញ្ចេញឱ្យដឹង ដែលមិនត្រូវបានចាត់ទុកថាបានការសម្រាប់ស្នាដៃមុន ត្រូវមានលក្ខណៈដូចខាងក្រោម:-

១.-យោងតាមមាត្រា ៦នៃច្បាប់ សម្រាប់គោលបំណងនៃស្នាដៃមុន ពោលគឺការរកឃើញពីមុន អ្នកដាក់ពាក្យសុំដែលចង់បានការបញ្ចេញឱ្យដឹងអំពីគត្តកម្មទៅជាការមិនអាចយកជាការបាន ត្រូវបញ្ជាក់នៅលើសំណុំលិខិតស្នើសុំជាលាយលក្ខណ៍អក្សរ និងត្រូវផ្តល់ព្រមជាមួយសំណុំលិខិតស្នើសុំ ឬត្រូវផ្តល់ក្នុងរយៈពេលមួយ(១)ខែ គិតចាប់ពីកាលបរិច្ឆេទសុំចុះបញ្ជីនៃសំណុំលិខិតស្នើសុំ ដោយរៀបរាប់អំពីការបញ្ចេញឱ្យដឹងដ៏ជាក់លាក់ឱ្យបានពេញលេញ ។ ក្នុងករណីដែលការបញ្ចេញឱ្យដឹង ត្រូវបានធ្វើនៅឯកន្លែងតាំងពិពណ៌ អ្នកដាក់ពាក្យសុំត្រូវផ្តល់វិញ្ញាបនបត្រជាទីទុកចិត្តត្រឹមត្រូវ ដែលចេញឱ្យដោយអាជ្ញាធរទទួលខុសត្រូវការតាំងពិពណ៌នោះ រួមមានបញ្ជាក់ជាពិសេស នៃការតាំងពិពណ៌ និងបញ្ជាក់ថាគត្តកម្មនោះត្រូវបានដាក់តាំងពិពណ៌នៅទីនោះពិតប្រាកដមែន ។

២.-ក្នុងគោលបំណងនៃវាក្យខណ្ឌទី ៣ (ខ) នៃមាត្រា ៦នៃច្បាប់ ការដឹងដល់សាធារណជននូវគត្តកម្ម មិនត្រូវបានចាត់ទុកថាយកជាបានការទេ ប្រសិនបើវាកើតឡើងក្នុងរយៈពេលដប់ពីរ(១២)ខែ មុនកាលបរិច្ឆេទសុំចុះបញ្ជី ឬកាលបរិច្ឆេទអាទិភាពនៃសំណុំលិខិតស្នើសុំក្នុងករណីដែលអាចមាន ហើយប្រសិនបើវាកើតឡើងដោយមូលហេតុ ឬជាផលវិបាកនៃអំពើដែលប្រព្រឹត្តដោយអ្នកដាក់ពាក្យសុំ ឬអ្នកស្នងរបស់គាត់ ឬជាការរំលោភដែលប្រព្រឹត្តដោយភាគីទី ៣ ទៅលើអ្នកដាក់ពាក្យសុំ ឬអ្នកស្នងរបស់គាត់ ។

ប្រការ ២០.- ការប្រកាសអាទិភាព

ការប្រកាសអាទិភាព ត្រូវអនុវត្តដូចខាងក្រោម:-

១.-សេចក្តីប្រកាសដែលយោងតាមមាត្រា ២៧នៃច្បាប់ ត្រូវធ្វើឡើងនៅពេលដាក់សំណុំលិខិតស្នើសុំប្រកាសនីយបត្រគត្តកម្ម និងវិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ ហើយត្រូវបញ្ជាក់អំពី :

ក.-កាលបរិច្ឆេទនៃការសុំចុះបញ្ជីរបស់សំណុំលិខិតស្នើសុំដំបូង ។

ខ.-លេខនៃសំណុំលិខិតស្នើសុំដំបូង លើកលែងតែចំណុច២ នៃប្រការនេះ ។

គ.-និមិត្តសញ្ញារបស់ចំណាត់ថ្នាក់អន្តរជាតិនៃប្រកាសនីយបត្រគត្តកម្ម ដែលត្រូវបានដាក់ចំពោះសំណុំលិខិតស្នើសុំដំបូង លើកលែងតែចំណុច ៣ នៃប្រការនេះ។

ឃ-ឈ្មោះប្រទេសដែលបានទទួលការស៊ុំចុះបញ្ជីនៃសំណុំលិខិតស្នើសុំដំបូង ឬ ឈ្មោះប្រទេសមួយឬច្រើន ដែលបានទទួលការស៊ុំចុះបញ្ជីនៃសំណុំលិខិតស្នើសុំនោះ ក្នុងករណីដែលសំណុំលិខិតស្នើសុំដំបូងជាសំណុំលិខិតស្នើសុំថ្នាក់តំបន់ ឬជាសំណុំលិខិតស្នើសុំអន្តរជាតិ ។

ង-ឈ្មោះការិយាល័យដែលបានទទួលការស៊ុំចុះបញ្ជីនៃសំណុំលិខិតស្នើសុំដំបូង ក្នុងករណីសំណុំលិខិតស្នើសុំដំបូង ជាសំណុំលិខិតស្នើសុំថ្នាក់តំបន់ ឬជាសំណុំលិខិតស្នើសុំអន្តរជាតិ ។

២-ក្នុងករណីនាពេលដាក់សេចក្តីប្រកាស ដូចមានចែងនៅក្នុងចំណុច ១ នៃប្រការនេះ លេខនៃសំណុំលិខិតស្នើសុំដំបូង មិនត្រូវបានដឹងទេនោះ លេខនេះ ត្រូវតែផ្តល់ឱ្យក្នុងរយៈពេលដប់ប្រាំមួយ(១៦)ខែ ក្រោយកាលបរិច្ឆេទអាទិភាព ។

៣-ក្នុងករណីនាពេលដាក់សេចក្តីប្រកាសដូចមានចែងនៅក្នុងចំណុច ១ នៃប្រការនេះ និមិត្តសញ្ញារបស់ចំណាត់ថ្នាក់អន្តរជាតិនៃប្រកាសនីយបត្រតក្កកម្ម មិនត្រូវបានកំណត់ឱ្យចំពោះសំណុំលិខិតស្នើសុំដំបូង ឬមិនទាន់បានកំណត់ឱ្យនៅឡើយ អ្នកដាក់ពាក្យសុំ ត្រូវថ្លែងបញ្ជាក់អំពីហេតុករណីនេះនៅក្នុងសេចក្តីប្រកាសនោះ ហើយត្រូវផ្តល់និមិត្តសញ្ញានេះយ៉ាងឆាប់ខណៈដែលវាត្រូវបានកំណត់ ។

៤-អ្នកដាក់ពាក្យសុំអាចកែតម្រូវអត្ថបទនៃសេចក្តីប្រកាសដូចមានចែងនៅក្នុងចំណុច១នៃប្រការនេះ នាពេលណាមួយមុនការផ្តល់ប្រកាសនីយបត្រតក្កកម្ម ឬវិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ ។

៥-យោងតាមមាត្រា ២៨ នៃច្បាប់ រយៈពេលសម្រាប់ការផ្តល់ឯកសារចម្លង ដែលមានការបញ្ជាក់ត្រឹមត្រូវតាមច្បាប់ដើមនៃសំណុំលិខិតស្នើសុំដំបូង ត្រូវមានរយៈពេលបី (៣)ខែ គិតចាប់ពីកាលបរិច្ឆេទនៃការស្នើសុំដោយមន្ត្រីកាន់កាប់បញ្ជី ។ ក្នុងករណីដែលឯកសារចម្លងនៃសំណុំលិខិតស្នើសុំត្រូវបានប្រគល់រួចហើយ សម្រាប់ការដាក់សំណុំលិខិតស្នើសុំផ្សេងទៀត អ្នកដាក់ពាក្យសុំអាចឆ្លើយតប ដោយធ្វើសេចក្តីយោងទៅលើការដាក់សំណុំលិខិតស្នើសុំផ្សេងទៀតនោះ ។

៦-ក្នុងករណីដែលសំណុំលិខិតស្នើដំបូង សរសេរជាភាសាផ្សេងក្រៅពីភាសាខ្មែរ អ្នកដាក់ពាក្យសុំត្រូវផ្តល់សេចក្តីបកប្រែនៃសំណុំលិខិតស្នើសុំនោះជាភាសាខ្មែរ ក្នុងរយៈពេលប្រាំមួយ(៦)ខែ គិតចាប់ពីកាលបរិច្ឆេទនៃ ការស្នើសុំរបស់មន្ត្រីកាន់កាប់បញ្ជី ។

៧-ទោះបីជាគ្មានការស្នើសុំពីមន្ត្រីកាន់កាប់បញ្ជីក៏ដោយ ក៏អ្នកដាក់ពាក្យសុំត្រូវតែដាក់សំណុំលិខិតស្នើសុំដំបូង ចំនួនមួយ(១)ច្បាប់ និងសេចក្តីបកប្រែសំណុំលិខិតស្នើសុំនោះជាភាសាខ្មែរ ចំនួនមួយ(១)ច្បាប់ ។

ប្រការ ២១.- ពេលវេលាសម្រាប់ការផ្តល់ពត៌មាន

ពេលវេលាសម្រាប់ការផ្តល់ការពត៌មាន ពាក់ពន្ធ័នឹងការឆ្លើយឆ្លងនៃសំណុំលិខិតស្នើសុំ បរទេស ត្រូវកំណត់ដូចខាងក្រោម :-

១.-រយៈពេលកម្រិតដែលត្រូវបញ្ជាក់សម្រាប់ផ្តល់ពត៌មានដែលបានស្នើសុំ អនុលោមតាមមាត្រា ៣០ និង មាត្រា ៣១ នៃច្បាប់ ត្រូវមានរយៈពេលមិនលើសពីប្រាំមួយ (៦)ខែ គិតចាប់ពីកាលបរិច្ឆេទនៃការស្នើសុំនេះត្រូវបានធ្វើឡើង ។ មន្ត្រីកាន់កាប់បញ្ជីអាចពន្យាររយៈពេលនេះ បានដោយមានមូលហេតុសមស្របតាមការស្នើសុំពីអ្នកដាក់ពាក្យសុំ ។

២.-ប្រសិនបើអ្នកដាក់ពាក្យសុំឆ្លើយតបមកវិញថា ឯកសារដែលបានស្នើសុំ អនុលោមតាមមាត្រា៣០ និងមាត្រា ៣១ នៃច្បាប់ មិនទាន់មាននៅឡើយទេនោះ មន្ត្រីកាន់កាប់បញ្ជីអាចផ្អាកនីតិវិធីសម្រាប់ការពិនិត្យសំណុំលិខិតស្នើសុំ រហូតដល់ពេលដែលឯកសារទាំងនោះត្រូវបានផ្តល់ឱ្យគ្រប់គ្រាន់ ។

ប្រការ ២២.- ការដកយកទៅវិញ និងការកែតម្រូវសំណុំលិខិតស្នើសុំ

ការដកយកទៅវិញ និងការកែតម្រូវសំណុំលិខិតស្នើសុំ ត្រូវអនុវត្តដូចខាងក្រោមៈ-

១.-សំណុំលិខិតស្នើសុំត្រូវសុំដកយកវិញបាន ដោយសេចក្តីប្រកាសជាលាយលក្ខណ៍អក្សរ ដែលបានដាក់ជូនមន្ត្រីកាន់កាប់បញ្ជី ហើយដែលចុះហត្ថលេខាដោយអ្នកដាក់ពាក្យសុំម្នាក់ៗ។

២.-កម្រៃពាក់ព័ន្ធនឹងការដាក់សំណុំលិខិតស្នើសុំមិនត្រូវបានប្រគល់ឱ្យវិញទេ ប្រសិនបើសំណុំលិខិតស្នើសុំ ត្រូវបានដកយកទៅវិញ ។

៣.-ការកែតម្រូវណាមួយដូចមានចែងក្នុងមាត្រា ២៤នៃច្បាប់ ត្រូវធ្វើជាលាយលក្ខណ៍អក្សរ ។

៤.-សំណុំលិខិតស្នើសុំប្រកាសនីយបត្រតក្កកម្ម និងវិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ ដែលត្រូវបានដកហូតយកទៅវិញ បានបោះបង់ចោល ឬត្រូវបានបដិសេធ ត្រូវអនុវត្តតាមបទប្បញ្ញត្តិនៃមាត្រា ៤(គ)(៤) ស្តីពីសិទ្ធិអាទិភាពនៃអនុសញ្ញាក្រុងប៉ារីស តាមការសមស្រប។

ប្រការ ២៣.- ការចុះលេខ និងការគូសសញ្ញា

ការចុះលេខ និងការគូសសញ្ញាសម្រាប់ផ្តល់ប្រកាសនីយបត្រតក្កកម្ម និងវិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ ត្រូវអនុវត្តដូចខាងក្រោមៈ-

១.-ចំពោះប្រកាសនីយបត្រតក្កកម្ម នៅពេលទទួលសំណុំលិខិតស្នើសុំ មន្ត្រីកាន់កាប់បញ្ជីត្រូវចុះកំណត់សំគាល់នៅលើឯកសារនីមួយៗនៃសំណុំលិខិតស្នើសុំ នូវកាលបរិច្ឆេទជាក់ស្តែងនៃការទទួល និងលេខសំណុំលិខិតស្នើសុំ ដែលផ្តើដោយអក្សរ " គ៥" បន្ទាត់ទ្រេត "/" អក្សរ

"**ប្រូត**" បន្ទាត់ទ្រេត "/" លេខពីរខ្ទង់ចុងក្រោយនៃឆ្នាំដែលឯកសារត្រូវបានទទួល បន្ទាត់ទ្រេត "/" និងលេខចំនួនប្រាំខ្ទង់ ដែលត្រូវដាក់តាមលំដាប់លំដោយនៃសំណុំលិខិតស្នើសុំដែលបានទទួល ។ ក្នុងករណីដែលឯកសារកែតម្រូវណាមួយ ឬឯកសារដែលបានដាក់ក្រោយផ្សេងទៀត ត្រូវបានទទួល នៅលើកាលបរិច្ឆេទខុសគ្នា មន្ត្រីកាន់កាប់បញ្ជីត្រូវចុះកំណត់សំគាល់ផងដែរ នូវកាលបរិច្ឆេទជាក់ស្តែងនៃការទទួលនោះ នៅកន្លែងសមស្របរបស់ពាក្យសុំប្រកាសនីយបត្រតក្កកម្ម (គំរូពាក្យសុំលេខ **១ប្រូត/មយ**) ។

២~ចំពោះវិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ នៅពេលទទួលសំណុំលិខិតស្នើសុំ មន្ត្រីកាន់កាប់បញ្ជី ត្រូវចុះកំណត់សំគាល់នៅលើឯកសារនីមួយៗនៃសំណុំលិខិតស្នើសុំ នូវកាលបរិច្ឆេទជាក់ស្តែងនៃការទទួល និងលេខសំណុំលិខិតស្នើសុំ ដែលផ្តើដោយអក្សរ " **អច** " បន្ទាត់ទ្រេត "/" អក្សរ " **មយ** " បន្ទាត់ទ្រេត "/" លេខពីរខ្ទង់ចុងក្រោយនៃឆ្នាំដែលឯកសារត្រូវបានទទួល បន្ទាត់ទ្រេត "/" និងលេខចំនួនប្រាំខ្ទង់ ដែលត្រូវដាក់តាមលំដាប់លំដោយនៃសំណុំលិខិតស្នើសុំដែលបានទទួល ។ ក្នុងករណីដែលឯកសារកែតម្រូវណាមួយ ឬឯកសារដែលបានដាក់ក្រោយផ្សេងទៀត ត្រូវបានទទួល នៅលើកាលបរិច្ឆេទខុសគ្នា មន្ត្រីកាន់កាប់បញ្ជីត្រូវចុះកំណត់សំគាល់ផងដែរ នូវកាលបរិច្ឆេទជាក់ស្តែងនៃការទទួលនោះ នៅកន្លែងសមស្របរបស់ពាក្យសុំវិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ (គំរូពាក្យសុំលេខ **១ប្រូត/មយ**) ។

៣~លេខសំណុំលិខិតស្នើសុំដែលមានចែងក្នុងចំណុច ១ និង ២ នៃប្រការនេះ ត្រូវស្រង់យកមកដាក់នៅក្នុងការទាក់ទងពត៌មាន តាមលំដាប់លំដោយពាក់ព័ន្ធទៅនឹងសំណុំលិខិតស្នើសុំ ។

ប្រការ ២៤.~ ការពិនិត្យសំណុំលិខិតស្នើសុំ

ការពិនិត្យសំណុំលិខិតស្នើសុំប្រកាសនីយបត្រតក្កកម្ម និងវិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ ត្រូវអនុវត្តដូចខាងក្រោម :

១~មន្ត្រីកាន់កាប់បញ្ជីត្រូវពិនិត្យ ថាតើសំណុំលិខិតស្នើសុំឱ្យបំពេញតាមការតម្រូវនៃវាក្យខណ្ឌទី១ នៃមាត្រា ៣៣ នៃច្បាប់ ឬទេ ។

២~ការអញ្ជើញឱ្យដាក់ការកែតម្រូវណាមួយ យោងតាមមាត្រា ៣៤ នៃច្បាប់ ត្រូវធ្វើជាលាយលក្ខណ៍អក្សរ ហើយត្រូវបញ្ជាក់ឱ្យបានច្បាស់អំពីការកែតម្រូវ ឬការកែតម្រូវដែលបានតម្រូវ និងស្នើឱ្យប្រគល់ការកែតម្រូវនោះ ក្នុងរយៈពេលពីរ (២) ខែ គិតចាប់ពីកាលបរិច្ឆេទនៃការអញ្ជើញ ។

៣~នៅពេលដែលមន្ត្រីកាន់កាប់បញ្ជីយល់ព្រមចំពោះកាលបរិច្ឆេទសុំចុះបញ្ជី មន្ត្រីកាន់កាប់បញ្ជី ត្រូវជូនដំណឹងទៅអ្នកដាក់ពាក្យសុំជាលាយលក្ខណ៍អក្សរ ។ ប្រសិនបើសំណុំលិខិត

ស្នើសុំ ត្រូវបានចាត់ទុកថា មិនបានដាក់ស្របតាមមាត្រា ៣៤ នៃច្បាប់ទេ មន្ត្រីកាន់កាប់បញ្ជី ត្រូវជូនដំណឹងទៅអ្នកដាក់ពាក្យសុំជាលាយលក្ខណ៍អក្សរ ដោយបញ្ជាក់អំពីមូលហេតុផង ។

៤-បន្ថែមលើការតម្រូវទាំងឡាយនៃមាត្រា ១៦ និងមាត្រា ១៧ នៃច្បាប់ និងបទប្បញ្ញត្តិទាំងឡាយដែលពាក់ព័ន្ធនឹងមាត្រាទាំងឡាយនេះ ការតម្រូវនៃមាត្រា ៣០ មាត្រា ៣១ និង មាត្រា ១១៦ នៃច្បាប់ ព្រមទាំងប្រការ ១១ ប្រការ ១២ ប្រការ ១៤ ប្រការ ៣៣ ប្រការ ១៥ និងប្រការ ១៦ នៃប្រកាសនេះ និងបទប្បញ្ញត្តិពាក់ព័ន្ធដែលត្រូវកំណត់ដោយក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល និងដោយនាយកដ្ឋានទទួលបន្ទុកចុះបញ្ជីដែលអាចអនុវត្តបាន ត្រូវបានចាត់ទុកថា ការតម្រូវផ្លូវការ ដើម្បីបម្រើគោលបំណងទាំងឡាយនៃច្បាប់ ។

៥-ក្នុងករណីដែលមន្ត្រីកាន់កាប់បញ្ជីពិនិត្យឃើញថា ល័ក្ខខ័ណ្ឌទាំងឡាយដែលមានចែងក្នុងមាត្រា ៣៦ នៃច្បាប់ មិនត្រូវបានបំពេញទេនោះ មន្ត្រីកាន់កាប់បញ្ជីត្រូវអញ្ជើញអ្នកដាក់ពាក្យសុំជាលាយលក្ខណ៍អក្សរឱ្យមកធ្វើការកែតម្រូវដែលចាំបាច់តម្រូវឱ្យកែ ក្នុងរយៈពេលពីរ(២) ខែ គិតចាប់ពីកាលបរិច្ឆេទនៃការអញ្ជើញ ។ ក្នុងករណីដែលខ្លឹមសារសង្ខេបមិនត្រូវបានផ្តល់ឱ្យទេនោះ មន្ត្រីកាន់កាប់បញ្ជីត្រូវអញ្ជើញអ្នកដាក់ពាក្យសុំឱ្យមកកែតម្រូវការខ្វះខាត ដោយផ្តល់មកឱ្យនូវខ្លឹមសារសង្ខេប ។ ប្រសិនបើអ្នកដាក់ពាក្យសុំមិនបានអនុវត្តតាមការអញ្ជើញឱ្យមកកែតម្រូវការខ្វះខាត ឬថ្វីបើអ្នកដាក់ពាក្យសុំបានផ្តល់ការកែតម្រូវការខ្វះខាតនោះរួចហើយក៏ដោយ ក្នុងករណីដែលមន្ត្រីកាន់កាប់បញ្ជីពិនិត្យឃើញថា ល័ក្ខខ័ណ្ឌទាំងឡាយដែលមានចែងក្នុងមាត្រា ៣៦ នៃច្បាប់ មិនត្រូវបានបំពេញទេនោះ មន្ត្រីកាន់កាប់បញ្ជីត្រូវបដិសេធសំណុំលិខិតស្នើសុំ ហើយជូនដំណឹងទៅអ្នកដាក់ពាក្យសុំជាលាយលក្ខណ៍អក្សរ ដោយបញ្ជាក់អំពីមូលហេតុផង ។

៦-ការបដិសេធនៃសំណុំលិខិតស្នើសុំ មិនជះឥទ្ធិពលលើកាលបរិច្ឆេទសុំចុះនៃបញ្ជីសំណុំលិខិតស្នើសុំឡើយ ។ កាលបរិច្ឆេទសុំចុះបញ្ជីនោះនៅតែមានសុពលភាពដដែល ។

ប្រការ ២៥.- ការពិនិត្យលំអិត

ការពិនិត្យលំអិត ត្រូវអនុវត្តដូចខាងក្រោម:-

១-មន្ត្រីកាន់កាប់បញ្ជី ត្រូវផ្តល់ពត៌មានពីសេចក្តីសម្រេចទៅអ្នកដាក់ពាក្យសុំជាលាយលក្ខណ៍អក្សរ ។

២-អនុលោមតាមមាត្រា ៣៧ នៃច្បាប់ មន្ត្រីកាន់កាប់បញ្ជីត្រូវគិតដល់របាយការណ៍ស្រាវជ្រាវ និងរបាយការណ៍ពិនិត្យដែលត្រូវបានធ្វើឡើងដោយអាជ្ញាធរស្រាវជ្រាវ និងពិនិត្យខាងក្រៅ តាមការស្នើរបស់ខ្លួន ។

៣-ដោយពិនិត្យទៅលើសេចក្តីសន្និដ្ឋាននៃលទ្ធផលនៃរបាយការណ៍ស្រាវជ្រាវ និង

របាយការណ៍ពិនិត្យ យោងតាមចំណុច ២ នៃប្រការនេះ ប្រសិនបើមាន មន្ត្រីកាន់កាប់បញ្ជីពិនិត្យឃើញថាល័ក្ខខ័ណ្ឌទាំងឡាយដែលមានចែងក្នុងមាត្រា ២៣ នៃច្បាប់ មិនត្រូវបានបំពេញទេនោះ មន្ត្រីកាន់កាប់បញ្ជីត្រូវជូនដំណឹងទៅអ្នកដាក់ពាក្យសុំជាលាយលក្ខណ៍អក្សរអញ្ជើញគាត់ឱ្យផ្តល់ការសង្កេតរបស់ខ្លួន ហើយកែប្រែ ឬបំបែកសំណុំលិខិតស្នើសុំ ក្នុងករណីដែល អាចធ្វើទៅបានក្នុងរយៈពេលមិនលើសពីប្រាំ(៥)ខែ គិតចាប់ពីកាលបរិច្ឆេទនៃការអញ្ជើញ ។ ការអញ្ជើញត្រូវធ្វើតាមគំរូលិខិត ដែលត្រូវកំណត់ដោយក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។ ការអញ្ជើញនេះអាចត្រូវធ្វើបានច្រើនដង ប្រសិនបើចាំបាច់ ។

៤.ក្នុងករណីអ្នកដាក់ពាក្យសុំមិនបានអនុវត្តតាមការអញ្ជើញខាងលើនេះទេ ឬក្នុងករណីដែល ទោះបីជាការសង្កេតការកែប្រែ ឬការបំបែកណាមួយដែលដាក់ជូនដោយអ្នកដាក់ពាក្យសុំក៏ដោយ ប្រសិនបើមន្ត្រីកាន់កាប់បញ្ជីពិនិត្យឃើញថា ល័ក្ខខ័ណ្ឌទាំងឡាយដែលមានចែងក្នុងមាត្រា ៣៥ និងមាត្រា ៣៦ នៃច្បាប់ មិនត្រូវបានបំពេញទេនោះ មន្ត្រីកាន់កាប់បញ្ជី ត្រូវបដិសេធការផ្តល់ប្រកាសនីយបត្រតក្កកម្ម និងវិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ ។

៥.ក្នុងករណីដែលមន្ត្រីកាន់កាប់បញ្ជីពិនិត្យឃើញថា ល័ក្ខខ័ណ្ឌទាំងឡាយដែលមានចែងក្នុងមាត្រា ៣៨ នៃច្បាប់ និងប្រកាសនេះ ត្រូវបានបំពេញរួចហើយ មន្ត្រីកាន់កាប់បញ្ជីត្រូវដំណើរការផ្តល់ប្រកាសនីយបត្រតក្កកម្ម និងវិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ យោងតាមមាត្រា ៣៩ នៃច្បាប់ និងប្រការ ២៧ នៃប្រកាសនេះ ។

៦.មន្ត្រីកាន់កាប់បញ្ជីត្រូវជូនដំណឹងទៅអ្នកដាក់ពាក្យសុំជាលាយលក្ខណ៍អក្សរ អំពីការសម្រេចផ្តល់ ឬការសម្រេចបដិសេធការផ្តល់ប្រកាសនីយបត្រតក្កកម្ម និងវិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ ដោយភ្ជាប់ជាមួយនូវច្បាប់ចម្លងនៃរបាយការណ៍ស្រាវជ្រាវ និងរបាយការណ៍ពិនិត្យដែលជាមូលដ្ឋាននៃការសម្រេចនោះប្រសិនបើមាន ហើយក្នុងករណីការសម្រេចផ្តល់ប្រកាសនីយបត្រតក្កកម្ម និងវិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ អ្នកដាក់ពាក្យសុំត្រូវបង់កម្រៃសម្រាប់ការផ្តល់ប្រកាសនីយបត្រតក្កកម្ម និងវិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ ក្នុងរយៈពេលបី(៣)ខែ គិតចាប់ពីកាលបរិច្ឆេទនៃការជូនដំណឹង ។

ប្រការ ២៦.- ការសម្រេចផ្តល់ប្រកាសនីយបត្រតក្កកម្ម និងវិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ ឬការបដិសេធ

ការសម្រេចផ្តល់ប្រកាសនីយបត្រតក្កកម្ម និងវិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ ឬការបដិសេធ ត្រូវអនុវត្តដូចខាងក្រោម:-

១.ក្នុងករណីមានសំណុំលិខិតស្នើសុំប្រកាសនីយបត្រតក្កកម្ម និងវិញ្ញាបនបត្រម៉ូដែល

មានអត្ថប្រយោជន៍ ចំនួនពីរ(២) ឬច្រើន សម្រាប់តក្កកម្មដូចគ្នា ត្រូវបានដាក់ដោយ អ្នកដាក់ពាក្យសុំផ្សេងគ្នា មន្ត្រីកាន់កាប់បញ្ជីត្រូវផ្តល់ប្រកាសនីយបត្រតក្កកម្ម និងវិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ ចំពោះសំណុំលិខិតស្នើសុំណាដែលមានកាលបរិច្ឆេទសុំចុះបញ្ជីមុនគេបង្អស់ ឬកាលបរិច្ឆេទអាទិភាពមុនគេបង្អស់នៅមានសុពលភាព ប្រសិនបើអាទិភាពត្រូវបានអះអាង ក្នុងករណីសំណុំលិខិតស្នើសុំនោះមិនត្រូវបានដកយកទៅវិញ មិនត្រូវបានបោះបង់ចោល ឬមិនត្រូវបានបដិសេធ ។

២-មន្ត្រីកាន់កាប់បញ្ជីត្រូវជូនដំណឹងទៅអ្នកដាក់ពាក្យសុំជាលាយលក្ខណ៍អក្សរ អំពីការសម្រេចផ្តល់ ឬការសម្រេចបដិសេធការផ្តល់ប្រកាសនីយបត្រតក្កកម្ម និងវិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ ។ ក្នុងករណីការសម្រេចបដិសេធការផ្តល់ប្រកាសនីយបត្រតក្កកម្ម និងវិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ មន្ត្រីកាន់កាប់បញ្ជីត្រូវបញ្ជាក់អំពីមូលហេតុនៃការបដិសេធនោះ ។ ក្នុងករណីការសម្រេចផ្តល់ប្រកាសនីយបត្រតក្កកម្ម និងវិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ មន្ត្រីកាន់កាប់បញ្ជីត្រូវស្នើអ្នកដាក់ពាក្យសុំឱ្យបង់កម្រៃសម្រាប់ការផ្តល់ប្រកាសនីយបត្រតក្កកម្ម និងវិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ក្នុងរយៈកំណត់ ដូចមានចែងក្នុងចំណុច ៦ នៃប្រការ ២៥ នៃប្រកាសនេះ ។

ប្រការ ២៧.- ការផ្តល់ប្រកាសនីយបត្រតក្កកម្ម និងវិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ ការបោះពុម្ពផ្សាយ ការចេញវិញ្ញាបនបត្រ

ការផ្តល់ប្រកាសនីយបត្រតក្កកម្ម និងវិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ ការបោះពុម្ពផ្សាយការចេញវិញ្ញាបនបត្រសម្រាប់ការផ្តល់ប្រកាសនីយបត្រតក្កកម្ម និងវិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ ត្រូវអនុវត្តដូចខាងក្រោម :

១-យោងតាមការបង់កម្រៃសម្រាប់ការផ្តល់ប្រកាសនីយបត្រតក្កកម្ម និងវិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ តាមរយៈពេលកំណត់ ដូចមានចែងក្នុងចំណុច ៦ នៃប្រការ ២៥ នៃប្រកាសនេះ មន្ត្រីកាន់កាប់បញ្ជីត្រូវដំណើរការផ្តល់ប្រកាសនីយបត្រតក្កកម្ម និងវិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ ដូចមានចែងក្នុង មាត្រា ៣៩ នៃច្បាប់ និងប្រការនេះ ។

២-មន្ត្រីកាន់កាប់បញ្ជីត្រូវចុះលេខសម្រាប់ប្រកាសនីយបត្រតក្កកម្ម និងវិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍នីមួយៗ ដែលខ្លួនបានផ្តល់ គឺលេខបោះពុម្ពផ្សាយនៃប្រកាសនីយបត្រតក្កកម្ម និងវិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ តាមលំដាប់លំដោយនៃការផ្តល់ប្រកាសនីយបត្រតក្កកម្ម និងវិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ ។

៣-ប្រកាសនីយបត្រតក្កកម្ម និងវិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ ត្រូវបានផ្តល់តាមគំរូវិញ្ញាបនបត្រដែលត្រូវកំណត់ ដោយក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល និងត្រូវ

មានកាលបរិច្ឆេទនៃការបោះពុម្ពផ្សាយ ប្រកាសនីយបត្រតក្កកម្ម និងវិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ និងឯកសារផ្សេងៗ ឬសេចក្តីយោងផ្សេងៗដែលបានដកស្រង់ពីស្នាដៃមុន សេចក្តីអធិប្បាយ សេចក្តីអះអាង និងគំនូសបង្ហាញ ប្រសិនបើមាន បន្ថែមលើពត៌មានដែលបញ្ជាក់ក្នុងចំណុច ៥ នៃប្រការនេះ ។

៤-ប្រកាសនីយបត្រតក្កកម្ម និងវិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ ត្រូវបានចាត់ទុកថាបានផ្តល់ក្នុងកាលបរិច្ឆេទ ដែលមន្ត្រីកាន់កាប់បញ្ជីបានបោះពុម្ពផ្សាយនូវសេចក្តីយោងអំពីការផ្តល់ប្រកាសនីយបត្រតក្កកម្ម និងវិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ ដោយយោងតាមចំណុច ១ នៃមាត្រា ៣៩ នៃច្បាប់ ។

៥-ការបោះពុម្ពផ្សាយសេចក្តីបញ្ជាក់អំពីការផ្តល់ប្រកាសនីយបត្រតក្កកម្ម និងវិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ ត្រូវរួមមាន :

ក-លេខប្រកាសនីយបត្រតក្កកម្ម និងវិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍

ខ-ឈ្មោះ និងអសយដ្ឋានរបស់ម្ចាស់ប្រកាសនីយបត្រតក្កកម្ម និងវិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍

គ-ឈ្មោះ និងអសយដ្ឋានរបស់តក្កករ លើកលែងតែតក្កករនោះបានស្នើសុំមិនឱ្យដាក់ឈ្មោះរបស់ខ្លួននៅក្នុងប្រកាសនីយបត្រតក្កកម្ម និងវិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍

ឃ-ឈ្មោះ និងអសយដ្ឋានរបស់ភ្នាក់ងារ ប្រសិនបើមាន

ង-កាលបរិច្ឆេទសុំចុះបញ្ជី

ច-សេចក្តីប្រកាសអំពីអាទិភាព កាលបរិច្ឆេទអាទិភាព និងឈ្មោះរបស់ប្រទេសទាំងឡាយ ដែលសំណុំលិខិតស្នើសុំដែលបានដាក់មុនគេបានដាក់នៅទីនោះ ប្រសិនបើកាលបរិច្ឆេទអាទិភាពត្រូវបានអះអាង ហើយការអះអាងនោះត្រូវបានយល់ព្រមទទួលស្គាល់

ឆ-កាលបរិច្ឆេទប្រសិទ្ធិភាពនៃការផ្តល់ប្រកាសនីយបត្រតក្កកម្ម និងវិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍

ជ-ចំណងជើងតក្កកម្ម

ឈ-ខ្លឹមសារសង្ខេប

ញ-គំនូសបង្ហាញដែលផ្តល់ការពន្យល់ច្បាស់លាស់ជាងគេ ប្រសិនបើមាន និង

ដ-និមិត្តសញ្ញារបស់ចំណាត់ថ្នាក់អន្តរជាតិនៃប្រកាសនីយបត្រតក្កកម្ម ។

៦-វិញ្ញាបនបត្របញ្ជាក់អំពីការផ្តល់ប្រកាសនីយបត្រតក្កកម្ម និងវិញ្ញាបនបត្រម៉ូដែល

មានអត្ថប្រយោជន៍ ត្រូវបានផ្តល់តាមគំរូ វិញ្ញាបនបត្រ ដែលនឹងត្រូវកំណត់ដោយក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ហើយដែលត្រូវ រួមមាន:-

ក-លេខប្រកាសនីយបត្រតក្កកម្ម និងវិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍

ខ-ឈ្មោះ និងអសយដ្ឋានរបស់ម្ចាស់ប្រកាសនីយបត្រតក្កកម្ម និងវិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍

គ-កាលបរិច្ឆេទសុំចុះបញ្ជី និងកាលបរិច្ឆេទអាទិភាពនៃសំណុំលិខិតស្នើសុំប្រសិនបើមាន

ឃ-កាលបរិច្ឆេទប្រសិទ្ធិភាពនៃការផ្តល់ប្រកាសនីយបត្រតក្កកម្ម និងវិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍និង

ង-ចំណងជើងតក្កកម្ម ។

ប្រការ ២៨.- ការបង់កម្រៃប្រចាំឆ្នាំ

ការបង់កម្រៃប្រចាំឆ្នាំ ត្រូវអនុវត្តដូចខាងក្រោម:-

១-នៅពេលទទួលការបង់កម្រៃប្រចាំឆ្នាំ ស្របតាមមាត្រា ៤៦ នៃច្បាប់ មន្ត្រីកាន់កាប់បញ្ជីត្រូវប្រគល់ ឬផ្ញើវិក័យបត្រនៃការទទួលការបង់កម្រៃប្រចាំឆ្នាំ ជូនអ្នកដាក់ពាក្យសុំ ឬម្ចាស់ប្រកាសនីយបត្រតក្កកម្ម និងវិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ ក្នុងរយៈពេលបី (៣) សប្តាហ៍ គិតចាប់ពីកាលបរិច្ឆេទនៃការទទួលការបង់កម្រៃប្រចាំឆ្នាំ ។

២-មន្ត្រីកាន់កាប់បញ្ជីត្រូវកត់ត្រា និងបោះផ្សាយសេចក្តីជូនដំណឹងអំពីការអស់សុពលភាពរបស់ប្រកាសនីយបត្រតក្កកម្ម និងវិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ ។

៣-កម្រៃប្រចាំឆ្នាំមិនត្រូវបានប្រគល់ជូនវិញទេ ។

ប្រការ ២៩.- ការធ្វើអាជីវកម្មដោយរដ្ឋាភិបាល ឬដោយបុគ្គលដែលទទួលការអនុញ្ញាតិពីរដ្ឋាភិបាល

ការធ្វើអាជីវកម្មដោយរដ្ឋាភិបាល ឬដោយបុគ្គលដែលទទួលការអនុញ្ញាតិពីរដ្ឋាភិបាលនូវតក្កកម្មដែលបានទទួលប្រកាសនីយបត្រតក្កកម្ម និងវិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍រួចហើយ ត្រូវអនុវត្តដូចខាងក្រោម:-

១-មុនធ្វើការសម្រេចតាមខ្លឹមសារដូចមានចែងក្នុងផ្នែកទី ១១ នៃជំពូកទី ២នៃច្បាប់ រដ្ឋមន្ត្រីត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរអំពីកាលបរិច្ឆេទ នៃកិច្ចប្រជុំទៅម្ចាស់ប្រកាសនីយបត្រតក្កកម្ម និងវិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ និងបុគ្គលផ្សេងៗទៀតដែលរដ្ឋមន្ត្រី គិតថាមានសារៈប្រយោជន៍ក្នុងការចូលរួមប្រជុំស្តាប់យោបល់ យ៉ាងហោចណាស់ម្ភៃមួយ(២១)ថ្ងៃ មុនថ្ងៃប្រជុំ ។ ម្ចាស់ប្រកាសនីយបត្រតក្កកម្ម និងវិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរ ទៅអ្នកកាន់អាជ្ញាប័ណ្ណទាំងឡាយ អំពីការប្រជុំស្តាប់យោបល់ ហើយ ៤

អ្នកទាំងអស់នោះមានសិទ្ធិចូលរួមក្នុងការប្រជុំស្តាប់យោបល់នេះ។

២-រដ្ឋមន្ត្រីត្រូវធ្វើសេចក្តីសម្រេចជាលាយលក្ខណ៍អក្សរ បន្ទាប់ពីបានស្តាប់យោបល់ការប្រជុំដោយបញ្ជាក់អំពីហេតុផលជាមូលដ្ឋាន និងដោយបញ្ជាក់អំពីល័ក្ខខ័ណ្ឌនានានៃការធ្វើអាជីវកម្ម ប្រសិនបើរដ្ឋមន្ត្រីសម្រេចថាតក្កកម្មត្រូវតែធ្វើអាជីវកម្ម អនុលោមតាមវាក្យខណ្ឌទី ១ នៃមាត្រា ៤៧ នៃច្បាប់ ហើយបញ្ជូនសេចក្តីសម្រេចនេះទៅឱ្យមន្ត្រីកាន់កាប់បញ្ជី ។

៣-មន្ត្រីកាន់កាប់បញ្ជីត្រូវកត់ត្រា និងបោះពុម្ពផ្សាយខ្លឹមសារនៃសេចក្តីសម្រេចរបស់រដ្ឋមន្ត្រី ហើយជូនដំណឹងជាលាយលក្ខណ៍អក្សរ អំពីហេតុការណ៍នេះទៅម្ចាស់ប្រកាសនីយបត្រតក្កកម្ម និងវិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ និងអ្នកផ្សេងទៀតដែលបានចូលរួមក្នុងការប្រជុំស្តាប់យោបល់នេះ ។

៤-ប្រសិនបើសេចក្តីសម្រេចរបស់រដ្ឋមន្ត្រី ជាកម្មវត្ថុសម្រាប់ប្តឹងត៍វ៉ាទៅតុលាការមានសមត្ថកិច្ចតុលាការមានសមត្ថកិច្ចត្រូវជូនដំណឹងដល់មន្ត្រីកាន់កាប់បញ្ជីអំពីសេចក្តីសម្រេចស្ថាពររបស់តុលាការមានសមត្ថកិច្ច ហើយមន្ត្រីកាន់កាប់បញ្ជីត្រូវកត់ត្រា និងបោះពុម្ពផ្សាយសេចក្តីសម្រេចនោះ ។

ប្រការ ៣០.- អាជ្ញាប័ណ្ណបញ្ជា

អាជ្ញាប័ណ្ណបញ្ជា ត្រូវបំពេញតាមលក្ខខណ្ឌដូចខាងក្រោម:-

១-សំណុំលិខិតស្នើសុំអាជ្ញាប័ណ្ណបញ្ជាដូចមានចែងក្នុងផ្នែកទី ១២ នៃជំពូកទី ២ នៃច្បាប់ ត្រូវបំពេញតាមគំរូកំណត់ និងត្រូវភ្ជាប់មកជាមួយនូវសេចក្តីបញ្ជាក់អំពីហេតុផលដែលអ្នកដាក់ពាក្យសុំយកមកធ្វើជាការអះអាង ចំនួន ពីរ(២) ច្បាប់ និងភស្តុតាងសម្រាប់ផ្ទៀងផ្ទាត់អំពីសេចក្តីបញ្ជាក់នោះចំនួន ពីរ(២)ច្បាប់ ។

២-ក្នុងរយៈពេលបី(៣)ខែ គិតចាប់ពីកាលបរិច្ឆេទនៃការសុំអាជ្ញាប័ណ្ណបញ្ជា រដ្ឋមន្ត្រីត្រូវពិនិត្យថាតើការតម្រូវនានានៃមាត្រា ៥៦ ឬ មាត្រា ៥៩ នៃច្បាប់ និងចំណុច ១ នៃប្រការនេះ ត្រូវបានបំពេញត្រឹមត្រូវហើយឬនៅ ។ ប្រសិនបើរដ្ឋមន្ត្រីពិនិត្យឃើញថាការតម្រូវនានា មិនបានបំពេញត្រឹមត្រូវទេនោះ រដ្ឋមន្ត្រីត្រូវបដិសេធពាក្យសុំនោះ ហើយជូនដំណឹងជាលាយលក្ខណ៍អក្សរ ដោយបញ្ជាក់អំពីមូលហេតុនៃការបដិសេធទៅឱ្យបុគ្គលដែលស្នើសុំអាជ្ញាប័ណ្ណបញ្ជានោះ ។ ប្រសិនបើរដ្ឋមន្ត្រីពិនិត្យឃើញថា ការតម្រូវនានាត្រូវបានបំពេញត្រឹមត្រូវរួចហើយ រដ្ឋមន្ត្រីត្រូវផ្ញើច្បាប់ចម្លងនៃពាក្យសុំអាជ្ញាប័ណ្ណបញ្ជា ទៅម្ចាស់ប្រកាសនីយបត្រតក្កកម្ម និងវិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ ទៅអ្នកដែលទទួលផលប្រយោជន៍នៃអាជ្ញាប័ណ្ណបញ្ជា និងទៅបុគ្គលដែលធ្វើអាជីវកម្មលើតក្កកម្ម ដែលបានទទួលប្រកាសនីយបត្រតក្កកម្ម និងវិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍រួចហើយនោះ ដូចមានចែងក្នុងមាត្រា ៥៩ នៃច្បាប់ និង

អញ្ជើញបុគ្គលទាំងឡាយខាងលើ ឱ្យផ្តល់ការសង្កេតអំពីការស្នើសុំអាជ្ញាប័ណ្ណបញ្ជានេះ ជាលាយលក្ខណ៍អក្សរមករដ្ឋមន្ត្រី ក្នុងរយៈពេលបី(៣)ខែ គិតចាប់ពីកាលបរិច្ឆេទនៃការអញ្ជើញ ។

៣~ម្ចាស់ប្រកាសនីយបត្រតក្កកម្ម និងវិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ ត្រូវជូនដំណឹងឱ្យបានឆាប់ជាលាយលក្ខណ៍អក្សរ ដល់អ្នកកាន់អាជ្ញាប័ណ្ណទាំងអស់អំពីសំណើនោះ ហើយអ្នកកាន់អាជ្ញាប័ណ្ណទាំងអស់មានសិទ្ធិផ្តល់ការសង្កេតអំពីបញ្ហាខាងលើនេះ ជាលាយលក្ខណ៍អក្សរជូនរដ្ឋមន្ត្រីក្នុងរយៈពេលបី(៣)ខែ គិតចាប់ពីកាលបរិច្ឆេទ នៃការអញ្ជើញដែលធ្វើឡើងអនុលោមតាមចំណុច ២ នៃប្រការនេះ ។

៤~រដ្ឋមន្ត្រីត្រូវជូនដំណឹងឱ្យបានឆាប់ទៅបុគ្គលដែលស្នើសុំអាជ្ញាប័ណ្ណបញ្ជា អំពីការសង្កេតនានាដែលបានដាក់ជូន ដូចមានចែងក្នុងចំណុច ២ និងចំណុច ៣ នៃប្រការនេះ។

៥~បន្ទាប់មករដ្ឋមន្ត្រីត្រូវរៀបចំកិច្ចប្រជុំស្តាប់យោបល់ ហើយត្រូវអញ្ជើញបុគ្គលដែលស្នើសុំ អាជ្ញាប័ណ្ណបញ្ជា ម្ចាស់ប្រកាសនីយបត្រតក្កកម្ម និងវិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ និងបុគ្គលដែលបានផ្តល់ការសង្កេត ដូចមានចែងក្នុងចំណុច ២ និងចំណុច ៣ នៃប្រការនេះ ឱ្យចូលរួមដោយជូនដំណឹងជាលាយលក្ខណ៍អក្សរដល់អ្នកដែលត្រូវចូលរួមប្រជុំទាំងនោះ ក្នុងរយៈពេលយ៉ាងតិចមួយ(១)ខែ មុនកាលបរិច្ឆេទដែលបានកំណត់សម្រាប់កិច្ចប្រជុំស្តាប់យោបល់ ។

៦~ក្រោយពីស្តាប់យោបល់នៃកិច្ចប្រជុំ ប្រសិនបើរដ្ឋមន្ត្រីពិនិត្យឃើញថា លក្ខខណ្ឌនានា សម្រាប់ការផ្តល់អាជ្ញាប័ណ្ណបញ្ជាត្រូវបានបំពេញត្រឹមត្រូវរួចហើយ រដ្ឋមន្ត្រីត្រូវផ្តល់អាជ្ញាប័ណ្ណបញ្ជា ។ បើមិនដូច្នោះទេ រដ្ឋមន្ត្រីត្រូវបដិសេធការផ្តល់អាជ្ញាប័ណ្ណបញ្ជា ។

៧~ការសម្រេចផ្តល់ ឬការសម្រេចបដិសេធការផ្តល់អាជ្ញាប័ណ្ណបញ្ជា ត្រូវធ្វើជាលាយលក្ខណ៍អក្សរ ហើយត្រូវបញ្ជាក់អំពីមូលហេតុជាមូលដ្ឋាននៃការសម្រេចខាងលើ ។ ក្នុងករណីការសម្រេចផ្តល់អាជ្ញាប័ណ្ណបញ្ជា ត្រូវបញ្ជាក់ជាពិសេសនូវចំណុចដូចខាងក្រោម :

ក- រយៈពេលដែលអាជ្ញាប័ណ្ណត្រូវបានផ្តល់

ខ- សកម្មភាពដូចមានចែងក្នុងមាត្រា ៤២ នៃច្បាប់ ដែលអាជ្ញាប័ណ្ណត្រូវបន្ត

គ- ពេលវេលាកម្រិតដែលអ្នកទទួលផលប្រយោជន៍ពីអាជ្ញាប័ណ្ណត្រូវចាប់ផ្តើមធ្វើអាជីវកម្មលើតក្កកម្មដែលបានទទួលប្រកាសនីយបត្រតក្កកម្ម និងវិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍រួចហើយ

ឃ- លក្ខខណ្ឌនៃការបង់កម្រៃជូនម្ចាស់ប្រកាសនីយបត្រតក្កកម្ម និងវិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ ។

៨~មន្ត្រីកាន់កាប់បញ្ជីត្រូវកត់ត្រា និងបោះពុម្ពផ្សាយខ្លឹមសារនៃសេចក្តីសម្រេចផ្តល់ ឬសេចក្តីសម្រេចបដិសេធផ្តល់អាជ្ញាប័ណ្ណបញ្ជា ហើយបញ្ជូនឯកសារចម្លងនៃសេចក្តីសម្រេចនេះ

ទៅបុគ្គល ដែលស្នើសុំអាជ្ញាប័ណ្ណបញ្ជា ទៅឱ្យម្ចាស់ប្រកាសនីយបត្រតក្កកម្ម និងវិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ និងទៅឱ្យបុគ្គលដែលបានផ្តល់ការសង្កេត ដូចមានចែងក្នុងចំណុច ២ និងចំណុច ៣ នៃប្រការនេះ ។

ប្រការ ៣១.- មោឃភាព

មោឃភាព ត្រូវអនុវត្តដូចខាងក្រោមៈ-

១-ក្នុងករណីដែលបទប្បញ្ញត្តិនៃផ្នែកទី ១៣ នៃជំពូកទី ២ នៃច្បាប់ ដែលអនុវត្តចំពោះតែសេចក្តីអះអាងមួយចំនួន ឬផ្នែកខ្លះនៃសេចក្តីអះអាងនោះទេ សេចក្តីអះអាងមួយចំនួន ឬផ្នែកខ្លះនៃសេចក្តីអះអាងនោះ ត្រូវចាត់ទុកជាមោឃៈ ។

២-ម្ចាស់ប្រកាសនីយបត្រតក្កកម្ម និងវិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរ ទៅអ្នកកាន់អាជ្ញាប័ណ្ណណាមួយអំពីដំណើរការកាត់ក្តីនៃតុលាការណាមួយ សម្រាប់ការចាត់ទុកជាមោឃៈនៃ ប្រកាសនីយបត្រតក្កកម្ម និងវិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍។ ក្នុងករណីមូលហេតុនៃមោឃភាពដែលបានស្នើសុំបង្ហាញថាម្ចាស់ប្រកាសនីយបត្រតក្កកម្ម និងវិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ មិនមែនជាតក្កករ ឬមិនមែនជាអ្នកស្នងរបស់តក្កករនោះទេ បុគ្គលដែលស្នើសុំមោឃភាព ត្រូវជូនដំណឹងទៅអ្នកទទួលផលប្រយោជន៍ណាមួយ ពីការផ្តល់សេចក្តីអនុញ្ញាត ដូចមានចែងក្នុងផ្នែកទី ១១ នៃជំពូកទី ២ នៃច្បាប់ និងទៅបុគ្គលដែលត្រូវបានអះអាងថាមានសិទ្ធិលើប្រកាសនីយបត្រតក្កកម្ម និងវិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ ។

ប្រការ ៣២.- ការប្តូរម្ចាស់កម្មសិទ្ធិ និងកិច្ចសន្យាអាជ្ញាប័ណ្ណ

ការប្តូរម្ចាស់កម្មសិទ្ធិ និងកិច្ចសន្យាអាជ្ញាប័ណ្ណ ត្រូវអនុវត្តដូចខាងក្រោមៈ-

១-អនុលោមតាមមាត្រា ១១៤ នៃច្បាប់ សំណើសុំធ្វើការកត់ត្រា ការប្តូរម្ចាស់កម្មសិទ្ធិនៃប្រកាសនីយបត្រតក្កកម្ម និងវិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ ដែលបានផ្តល់ស្របតាមច្បាប់ ឬធ្វើការកត់ត្រាការប្តូរម្ចាស់កម្មសិទ្ធិនៃ សំណុំលិខិតស្នើសុំប្រកាសនីយបត្រតក្កកម្ម និងវិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ ត្រូវបំពេញតាមគំរូពាក្យសុំតាមការកំណត់ រួចដាក់ជូនមន្ត្រីកាន់កាប់បញ្ជី ។

២-ការបោះពុម្ពផ្សាយស្តីពីការប្តូរម្ចាស់កម្មសិទ្ធិត្រូវបញ្ជាក់អំពីៈ

ក-ចំណងជើងនៃតក្កកម្ម ដែលបានការពារ

ខ-កាលបរិច្ឆេទសុំចុះបញ្ជី កាលបរិច្ឆេទអាទិភាពប្រសិនបើមាន និងកាលបរិច្ឆេទនៃការចុះបញ្ជី ឬកាលបរិច្ឆេទនៃការផ្តល់

គ-ម្ចាស់កម្មសិទ្ធិ និងម្ចាស់កម្មសិទ្ធិថ្មី និង

ឃ-លក្ខណៈនៃការប្តូរម្ចាស់កម្មសិទ្ធិ ។

៣~កិច្ចសន្យាអាជ្ញាប័ណ្ណដែលបានដាក់ជូនដើម្បីកត់ត្រាយោងតាមមាត្រា ១១៥ នៃច្បាប់ ម្ចាស់កម្មសិទ្ធិត្រូវបង់កម្រៃតាមការកំណត់ ។

ប្រការ ៣៣.~ ភ្នាក់ងារ

ភ្នាក់ងារ ត្រូវអនុវត្តដូចខាងក្រោមៈ-

១~អនុលោមតាមមាត្រា ១១៦ នៃច្បាប់ ការចាត់តាំងភ្នាក់ងារតំណាងត្រូវធ្វើឡើងតាមរយៈលិខិតប្រគល់សិទ្ធិដែលត្រូវចុះហត្ថលេខាដោយអ្នកដាក់ពាក្យសុំ ឬដោយអ្នកដាក់ពាក្យសុំម្នាក់ៗ ប្រសិនបើមានអ្នកដាក់ពាក្យសុំលើសពីមួយនាក់ ។ អសយដ្ឋានរបស់ភ្នាក់ងារតំណាងត្រូវចាត់ទុកថាជាអសយដ្ឋានទាក់ទងដើម្បីបញ្ជូនដំណឹងទៅបុគ្គលម្នាក់ ឬបុគ្គលច្រើននាក់ ដែលបានចាត់តាំងភ្នាក់ងារនោះ សម្រាប់គោលបំណងទាំងឡាយដែលពាក់ព័ន្ធទៅនឹងច្បាប់ និងប្រកាសនេះ ។

២~លិខិតប្រគល់សិទ្ធិឱ្យភ្នាក់ងារដូចមានចែងក្នុងចំណុច ១ នៃប្រការនេះ ត្រូវដាក់ភ្ជាប់ជាមួយសំណុំលិខិតស្នើសុំ ឬដែលអាចត្រូវប្រគល់ក្នុងរយៈពេលពីរ(២)ខែ គិតចាប់ពីកាលបរិច្ឆេទសុំចុះបញ្ជីនៃសំណុំលិខិតស្នើសុំនោះ ។

៣~ប្រសិនបើការចាត់តាំងភ្នាក់ងារ មិនត្រូវបានអនុវត្តដូចមានចែងក្នុងចំណុច ២ នៃប្រការនេះទេ ហើយមិនស្របតាមមាត្រា ១១៦ នៃច្បាប់ ចំណាត់ការជានីតិវិធីណាមួយដែលធ្វើដោយភ្នាក់ងារ ក្រៅពីការដាក់សំណុំលិខិតស្នើសុំចុះបញ្ជី ត្រូវចាត់ទុកថាមិនបានធ្វើឡើយ ។

៤~ការតម្រូវនានាពាក់ព័ន្ធភ្នាក់ងារតំណាងរបស់អ្នកដាក់ពាក្យសុំ ដូចមានចែងក្នុងចំណុច ១ នៃប្រការនេះ ត្រូវចែងដោយបទប្បញ្ញត្តិដោយឡែក ដែលកំណត់ដោយក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។

ប្រការ ៣៤.~ ថ្ងៃលើកលែង

កាលណាថ្ងៃចុងក្រោយសម្រាប់អនុវត្តអំពើណាមួយ ឬដំណើរចំណាត់ការណាមួយធ្លាក់ចំថ្ងៃដែលក្រុមហ៊ុន និងនាយកដ្ឋានទទួលបន្ទុកចុះបញ្ជីមិនធ្វើការបំរើសាធារណជន ត្រូវចាត់ទុកថាស្របច្បាប់ចំពោះការអនុវត្តនីអំពើ ឬដំណើរការនៅថ្ងៃដែលក្រុមហ៊ុន ឬនាយកដ្ឋានទទួលបន្ទុកចុះបញ្ជីដំណើរការបំរើសាធារណជន នៅថ្ងៃបន្ទាប់ពីថ្ងៃឈប់នោះ ។

ប្រការ ៣៥.~ ការដកស្រង់ពត៌មានពីបញ្ជី និងការកែតម្រូវកំហុស

ការដកស្រង់ពត៌មាន និងការកែតម្រូវកំហុស ត្រូវអនុវត្តដូចខាងក្រោមៈ-

១~ការស្នើសុំច្បាប់ចម្លងដែលមាន បញ្ជាក់ថាត្រឹមត្រូវតាមច្បាប់ដើមនៃការដកស្រង់ពត៌មានពីបញ្ជី ឬការស្នើសុំថតចម្លងឯកសារផ្សេងៗ ត្រូវធ្វើជាលាយល័ក្ខណ៍អក្សរ ហើយត្រូវ

ដាក់ជូនមន្ត្រីកាន់កាប់បញ្ជី ។

២_ការកែតម្រូវកំហុស យោងតាមមាត្រា ១២០ នៃច្បាប់ អាចត្រូវបានធ្វើឡើងដោយមន្ត្រីកាន់កាប់បញ្ជី នៅពេលបានទទួលសំណើជាលាយលក្ខណ៍អក្សរ ហើយបានបំពេញល័ក្ខខ័ណ្ឌទាំងឡាយ ដែលមន្ត្រីកាន់កាប់បញ្ជីពិនិត្យឃើញថាសមស្រប ឬតាមគំនិតផ្តួចផ្តើមផ្ទាល់របស់មន្ត្រីកាន់កាប់បញ្ជី ។ ការកែតម្រូវទាំងឡាយដែលបានធ្វើឡើងត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរទៅបុគ្គលពាក់ព័ន្ធទាំងឡាយ ហើយក្នុងករណីចាំបាច់ត្រូវបោះផ្សាយដោយមន្ត្រីកាន់កាប់បញ្ជី ។

ប្រការ ៣៦._ សវនាការ

សវនាការ ត្រូវអនុវត្តដូចខាងក្រោម:-

១_មុនពេលអនុវត្ត អំណាចឆន្ទានុសិទ្ធិណាមួយ ដែលបានផ្តល់ឱ្យមន្ត្រីកាន់កាប់បញ្ជីដោយច្បាប់ ឬដោយប្រកាសនេះ ចំពោះបុគ្គលណាម្នាក់ដោយមិនអនុគ្រោះ មន្ត្រីកាន់កាប់បញ្ជីត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរទៅបុគ្គលនោះ អំពីនិកាលសម្រាប់សវនាការ ហើយបញ្ជាក់អំពីពេលវេលាកម្រិតមិនតិចជាងមួយ(១)ខែ សម្រាប់ការដាក់ពាក្យសុំធ្វើ សវនាការនោះ ។

២_ពាក្យសុំធ្វើសវនាការត្រូវធ្វើជាលាយលក្ខណ៍អក្សរ ។

៣_នៅពេលទទួលពាក្យសុំធ្វើសវនាការ មន្ត្រីកាន់កាប់បញ្ជីត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរអំពីកាលបរិច្ឆេទ និងពេលវេលាធ្វើសវនាការ មិនតិចជាងរយៈពេលពីរ(២)សប្តាហ៍មុនកាលបរិច្ឆេទកំណត់ធ្វើសវនាការ ទៅបុគ្គលដែលបានដាក់ពាក្យសុំ និងបុគ្គលពាក់ព័ន្ធផ្សេងៗទៀត ។

ប្រការ ៣៧._ សេវាកម្មដោយសំបុត្រ

សេវាកម្មដោយសំបុត្រ ត្រូវអនុវត្តដូចខាងក្រោម:-

១_សេចក្តីជូនដំណឹងណាមួយ សំណុំលិខិតស្នើសុំ ឬឯកសារផ្សេងៗទៀត ដែលបានផ្ញើតាមប្រៃសណីយ៍ជូនមន្ត្រីកាន់កាប់បញ្ជី ត្រូវចាត់ទុកថាបានប្រគល់ បានផ្តល់ បានផ្ញើ ឬបានដាក់សំណុំលិខិតស្នើសុំនៅពេលដែលឯកសារទាំងនោះ ត្រូវបានប្រគល់តាមរបៀបធម្មតានៃប្រៃសណីយ៍ ។ ដើម្បីបញ្ជាក់ជាភស្តុតាងអំពីការបញ្ជូននេះ ត្រូវតែបង្ហាញភស្តុតាងគ្រប់គ្រាន់ថាលិខិតដែលរួមមានសេចក្តីជូនដំណឹង សំណុំលិខិតស្នើសុំ ឬឯកសារផ្សេងៗខាងលើនោះ បានដាក់អាសយដ្ឋានយ៉ាងត្រឹមត្រូវ និងបានផ្ញើតាមលិខិតអនុសិដ្ឋ ។

២_ចំណុច ១ នៃប្រការនេះ មិនត្រូវបានយកមកអនុវត្តចំពោះការយល់ព្រមទទួលស្គាល់កាលបរិច្ឆេទសុំចុះបញ្ជីឡើយ ។/៥

ប្រការ ៣៨.- ភស្តុតាង

ភស្តុតាង ត្រូវអនុវត្តដូចខាងក្រោមៈ-

១-អនុលោមតាមប្រកាសនេះ ភស្តុតាងដែលត្រូវដាក់ជូនពិនិត្យ ត្រូវធ្វើឡើងតាមរយៈលិខិតប្រកាសស្របច្បាប់ ឬតាមរយៈលិខិតសច្ចាប្រណិធាន ។

២-ក្នុងករណីដោយឡែកណាមួយ ប្រសិនបើពិនិត្យឃើញថាជាការសមស្រប មន្ត្រីកាន់កាប់បញ្ជីអាចទទួលយកភស្តុតាងផ្ទាល់មាត់ជំនួស ឬបន្ថែមលើភស្តុតាងខាងលើ និងត្រូវអនុញ្ញាតឱ្យ សាក្សីណាមួយអាចចូលរួមធ្វើការចោទសួរឆ្លើយឆ្លង អំពីលិខិតសច្ចាប្រណិធាន ឬលិខិតប្រកាសរបស់គេ ។

ប្រការ ៣៩.- លិខិតប្រកាសស្របច្បាប់

លិខិតប្រកាសស្របច្បាប់ ត្រូវអនុវត្តដូចខាងក្រោមៈ-

១-លិខិតប្រកាសស្របច្បាប់ ឬលិខិតសច្ចាប្រណិធានណាមួយ ដែលដាក់ជូនសម្រាប់ពិនិត្យស្របតាមច្បាប់ និងប្រកាសនេះ ត្រូវធ្វើឡើងនៅចំពោះមុខមន្ត្រីណាម្នាក់ដែលបានទទួលសិទ្ធិតាមច្បាប់នៅទីកន្លែងណាមួយនៃព្រះរាជាណាចក្រកម្ពុជា ដើម្បីចាត់ចែងការធ្វើសច្ចាប្រណិធានសម្រាប់គោលបំណងនៃដំណើរការស្របច្បាប់ណាមួយខាងផ្លូវច្បាប់ ។

២-លិខិតប្រកាសស្របច្បាប់ ឬលិខិតសច្ចាប្រណិធានដែលធ្វើនៅក្រៅព្រះរាជាណាចក្រកម្ពុជាត្រូវធ្វើឡើងនៅចំពោះមុខមន្ត្រីស្ថានកុងស៊ុល ឬមន្ត្រីស្ថានទូតនៃព្រះរាជាណាចក្រកម្ពុជាប្រចាំនៅប្រទេសនោះ ។

ប្រការ ៤០.- ព្រឹត្តិបត្រផ្លូវការ

ចំណុចពិសេសទាំងឡាយរបស់ប្រកាសនីយបត្រតក្កកម្ម វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ និងដំណើរការដទៃទៀត អនុលោមតាមច្បាប់ និងពត៌មានណាមួយផ្សេងទៀតដែលតម្រូវឱ្យបោះពុម្ពផ្សាយ អនុលោមតាមច្បាប់ ឬប្រកាសនេះ និងបទប្បញ្ញត្តិពាក់ព័ន្ធ ត្រូវបោះពុម្ពផ្សាយតាមការណែនាំរបស់មន្ត្រីកាន់កាប់បញ្ជី នៅក្នុងព្រឹត្តិបត្រផ្លូវការដែលនឹងត្រូវរៀបចំឡើង។

ប្រការ ៤១.- ការបង់កម្រៃ

កម្រៃដែលត្រូវបង់សម្រាប់ការផ្តល់ប្រកាសនីយបត្រតក្កកម្ម និងវិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ ដូចមានចែងក្នុងប្រកាសនេះ ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។

ប្រការ ៤២.- ការដោះស្រាយវិវាទ

នាយកដ្ឋានកម្មសិទ្ធិឧស្សាហកម្ម មានសមត្ថកិច្ចបង្កើតយន្តការដោះស្រាយវិវាទពាក់ព័ន្ធនឹងប្រពន្ធ័ផ្តល់ប្រកាសនីយបត្រតក្កកម្ម និងវិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ តាមការចាំបាច់។

ប្រការ ៤៣.- កិច្ចសហការ

នាយកដ្ឋានកម្មសិទ្ធិឧស្សាហកម្ម ត្រូវសហការជាមួយអង្គការជាតិ និងអន្តរជាតិ និងស្ថាប័នពាក់ព័ន្ធ ដើម្បីជំរុញការការពារកម្មសិទ្ធិឧស្សាហកម្ម និងអភិវឌ្ឍប្រព័ន្ធប្រកាសនីយបត្រតក្កកម្ម និងវិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ ។

ផ្នែកទី ៣

តក្កកម្មពាក់ព័ន្ធកុំព្យូទ័រសូហ្វវែរ

ប្រការ ៤៤.- តក្កកម្មពាក់ព័ន្ធកុំព្យូទ័រសូហ្វវែរ

តក្កកម្មពាក់ព័ន្ធទៅនឹងកុំព្យូទ័រសូហ្វវែរ ត្រូវអនុវត្តដូចខាងក្រោម:-

១-អនុលោមតាមវាក្យខណ្ឌទី ៣ នៃមាត្រា ៣ នៃច្បាប់ ដែលចែងថា "តក្កកម្មអាចជាការរកឃើញផលិតផល ឬដំណើរការផលិតកម្ម ឬអាចជាការរកឃើញអ្វីមួយដែលទាក់ទងទៅនឹងផលិតផល ឬដំណើរការផលិតកម្ម" ត្រូវរាប់បញ្ចូលនូវ :

ក-តក្កកម្មជាដំណើរការផលិតកម្ម ដែលផ្នែកទាំងមូល ឬផ្នែកខ្លះ មានជំហានជាច្រើនដែលត្រូវអនុវត្តដោយកុំព្យូទ័រ និងត្រូវបញ្ជាដោយកម្មវិធីកុំព្យូទ័រ និង

ខ-តក្កកម្មជាផលិតផល ដែលមានជាតុនៃតក្កកម្មដែលអនុវត្តដោយកុំព្យូទ័ររួមមានជាពិសេស:-

-រូបកម្មវិធីកម្មកុំព្យូទ័រដែលម៉ាស៊ីនអាចអានបានដែលអាចស្តុកទុកនៅក្នុងឧបករណ៍មានរូបរាងជាក់ស្តែង ដូចជា ហ្វ្លូពីឌីស កុំព្យូទ័រហាដដ្រាយ្វ ឬកុំព្យូទ័រម៉េម័រី និង

-កុំព្យូទ័រសម្រាប់គោលបំណងទូទៅ ដែលភាពថ្មីរបស់វា លើស្នាដៃមុន លេចចេញជាបឋមដោយការផ្តុំបញ្ចូលវាជាមួយកម្មវិធីកុំព្យូទ័រជាក់លាក់មួយ ។

២-អ្នកដាក់ពាក្យសុំដែលបានដាក់សំណុំលិខិតស្នើសុំប្រកាសនីយបត្រតក្កកម្មសម្រាប់កម្មវិធីកុំព្យូទ័រ និងតក្កកម្មដែលពាក់ព័ន្ធទៅនឹងកុំព្យូទ័រ ដូចមានចែងក្នុងចំណុច ១ នៃប្រការនេះ ត្រូវបានចាត់ទុកថាបានបោះបង់ចោលសិទ្ធិរបស់ខ្លួនក្នុងការស្វែងរកការការពារសិទ្ធិអ្នកនិពន្ធ ប្រសិនបើមាន អនុលោមតាមមាត្រា ១០(១) នៃកិច្ចព្រមព្រៀងស្តីពីទិដ្ឋភាពពាណិជ្ជកម្ម ពាក់ព័ន្ធនឹងកម្មសិទ្ធិបញ្ញា (TRIPS) ។ /K

ផ្នែកទី ៤

អន្តរប្បញ្ញត្តិ

ប្រការ ៤៥.- តក្កកម្ម ពាក់ពន្ធ័នឹងផលិតផលឱសថ

ចំពោះតក្កកម្មពាក់ពន្ធ័នឹងផលិតផលឱសថ ត្រូវអនុវត្តដូចខាងក្រោម:-

១.-ត្រូវមានសំណុំលិខិតស្នើសុំប្រកាសនីយបត្រតក្កកម្មដែលអះអាងអំពីតក្កកម្មផលិតឱសថ យោងតាម មាត្រា ១៣៦ នៃច្បាប់ អាចត្រូវបានដាក់ជូននាយកដ្ឋានទទួលបន្ទុកចុះបញ្ជី ចាប់ពីថ្ងៃចេញប្រកាសនេះ អនុលោមតាមមាត្រា ១៦ នៃច្បាប់ ព្រមទាំងបទប្បញ្ញត្តិពាក់ពន្ធ័នឹងច្បាប់ និងប្រកាសនេះ ។

២.-ចំពោះសំណុំលិខិតស្នើសុំដែលបញ្ជាក់ក្នុងចំណុច ១ នៃប្រការនេះ ត្រូវពិនិត្យស្របតាមបទប្បញ្ញត្តិនៃផ្នែកទី ៦ និងផ្នែកទី ៧ នៃជំពូកទី ២ នៃច្បាប់ ក្រោយពីផុតរយៈពេលអន្តរកាល ដែលមានចែងក្នុងមាត្រា ១៣៦ នៃច្បាប់ ។

៣.-តាមការចូលជាធរមាននៃច្បាប់ លក្ខណៈវិនិច្ឆ័យនៃភាពទទួលបានប្រកាសនីយបត្រតក្កកម្មដូចមានចែងក្នុងមាត្រា ៤ មាត្រា ៥ មាត្រា ៦ មាត្រា ៧ មាត្រា ៨ និងមាត្រា ៩ នៃច្បាប់ ត្រូវអនុវត្តចំពោះសំណុំលិខិតដែលបានចែងក្នុងចំណុច ១ និងចំណុច ២ នៃប្រការនេះ ថ្វីបើលក្ខណៈវិនិច្ឆ័យខាងលើត្រូវបានអនុវត្តលើកាលបរិច្ឆេទសុំចុះបញ្ជី ក្នុងព្រះរាជាណាចក្រកម្ពុជា ឬកាលបរិច្ឆេទអាទិភាពនៃសំណុំលិខិតស្នើសុំ ក្នុងករណីកាលបរិច្ឆេទ អាទិភាពមាន និងត្រូវបានអះអាង ។

៤.-សំណុំលិខិតស្នើសុំដែលមានចែងក្នុងចំណុច ១ និងចំណុច ២ នៃប្រការនេះ ត្រូវផ្តល់ការការពារតក្កកម្ម ដោយយោងតាមច្បាប់ ចាប់ពីពេលផ្តល់ប្រកាសនីយបត្រតក្កកម្ម និងចំពោះរយៈពេលដែលនៅសេសសល់នៃរយៈពេលប្រកាសនីយបត្រតក្កកម្ម ដោយចាប់ផ្តើមរាប់ពីកាលបរិច្ឆេទសុំចុះបញ្ជី អនុលោមតាមមាត្រា ៤៥ នៃច្បាប់ សម្រាប់សំណុំលិខិតស្នើសុំប្រកាសនីយបត្រតក្កកម្មទាំងឡាយណា ដែលបំពេញតាមលក្ខណៈវិនិច្ឆ័យ ដើម្បីទទួលបានការការពារ ដូចមានចែងក្នុងចំណុច ៣ នៃប្រការនេះ ។

ផ្នែកទី ៥

អវសានប្បញ្ញត្តិ

ប្រការ ៤៦.- សមត្ថកិច្ចកិច្ចអនុវត្ត

អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន អគ្គនាយកនៃអគ្គនាយកដ្ឋានឧស្សាហកម្ម នាយខុទ្ទកាល័យ ប្រធាននាយកដ្ឋានរដ្ឋបាល ប្រធាននាយកដ្ឋានបុគ្គលិក ប្រធាននាយកដ្ឋានគណនេយ្យ និងហិរញ្ញ

វត្ថុ និងប្រធាននាយកដ្ឋានកម្មសិទ្ធិឧស្សាហកម្ម មានភារកិច្ចអនុវត្តក្នុងក្របខ័ណ្ឌសមត្ថកិច្ចរៀងៗខ្លួន ។

ប្រការ ៤៧.- ប្រសិទ្ធិភាព

ប្រកាសនេះមានប្រសិទ្ធភាពអនុវត្ត ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ស៊ុយ សែម

<u>កន្លែងទទួល</u> :

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រុមប្រឹក្សាអភិវឌ្ឍកម្ពុជា
- ក្រសួងពាណិជ្ជកម្ម
- ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- ក្រសួងព័ត៌មាន
- ក្រសួងអប់រំ យុវជន និងកីឡា
- ក្រសួងសុខាភិបាល
- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- ក្រសួងយុត្តិធម៌
- រាជបណ្ឌិត្យសភាកម្ពុជា
- គ្រប់អគ្គនាយកដ្ឋាន
- គ្រប់នាយកដ្ឋានសេនាធិការក្រសួង
- គ្រប់មន្ទីរឧស្សាហកម្ម រ៉ែ និងថាមពល ខេត្ត-ក្រុង
  " ដើម្បីជូនជ្រាបជាព័ត៌មាន "
- ដូចប្រការ ៤៦ "ដើម្បីអនុវត្ត "
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ឧបសម្ព័ន្ធ ក
(គំរូលេខ ១ ប្រក/មយ)

ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
អគ្គនាយកដ្ឋានឧស្សាហកម្ម
នាយកដ្ឋានកម្មសិទ្ធិឧស្សាហកម្ម

ពាក្យសុំប្រកាសនីយបត្រតក្កកម្មកម្ពុជា
ឬ វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍កម្ពុជា

យោងលេខ

សាម៉ីជនដែលបានចុះហត្ថលេខានេះ ស្នើសុំ ☐ប្រកាសនីយបត្រតក្កកម្ម/☐វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍កម្ពុជា ចំពោះកម្មវត្ថុដូចខាងក្រោមនេះ:	**សម្រាប់មន្ត្រីកាន់កាប់បញ្ជី**
	កាលបរិច្ឆេទទទួល :
	លេខរបស់សំណុំលិខិតស្នើសុំ :
	កាលបរិច្ឆេទសុំចុះបញ្ជី :

ប្រអប់លេខ ១

ចំណងជើងនៃតក្កកម្ម :..

....

ប្រអប់លេខ ២

អ្នកដាក់ពាក្យសុំ(ទោះបីមិនមែនជាតក្កករក៏ដោយ)សូមប្រើប្រអប់នេះសម្រាប់បញ្ជាក់ប្រាប់ពីអ្នកដាក់ពាក្យសុំ ឬអ្នកណាម្នាក់ក៏បាន នៅក្នុងចំណោមអ្នកទាំងនោះ ប្រសិនបើអ្នកដាក់ពាក្យសុំមានគ្នាច្រើន ។ ប្រសិនបើមានគ្នាលើសពីមួយនាក់ (ឬអង្គភាពស្របច្បាប់លើសពីមួយឡើងទៅ) ដែលជាប់ពាក់ព័ន្ធសូមបន្តទៅប្រអប់បន្ថែម ។

បុគ្គលក្នុងប្រអប់នេះគឺជា (គូសតែមួយប៉ុណ្ណោះ) : ☐ អ្នកដាក់ពាក្យសុំ និងតក្កករ ☐ អ្នកដាក់ពាក្យសុំតែប៉ុណ្ណោះ

ឈ្មោះ និង អាសយដ្ឋាន ....

....

លេខទូរស័ព្ទ (រួមទាំងលេខកូដតំបន់) :..

លេខទូរសារ:.. អាសយដ្ឋានអ៊ីម៉ែល:..

សញ្ជាតិ :.. ប្រទេសស្នាក់នៅ:..

បុគ្គលក្នុងប្រអប់នេះគឺជា (គូសតែមួយប៉ុណ្ណោះ) : ☐ អ្នកដាក់ពាក្យសុំ និងតក្កករ ☐ អ្នកដាក់ពាក្យសុំតែប៉ុណ្ណោះ

ឈ្មោះ និង អាសយដ្ឋាន:..

....

លេខទូរស័ព្ទ (រួមទាំងលេខកូដតំបន់): ....

លេខទូរសារ:.. អាសយដ្ឋានអ៊ីម៉ែល:..

សញ្ជាតិ :.. ប្រទេសស្នាក់នៅ: ....

ប្រអប់លេខ ៣

ចំណាំ ត្រូវបំពេញក្នុងប្រអប់តូចដាច់ពីគ្នាទៅតាមបុគ្គលនីមួយៗ ។ ប្រសិនបើប្រអប់តូចទាំងពីរនោះពុំមានកន្លែងគ្រប់គ្រាន់ទេ សូមបន្តទៅ "ប្រអប់បន្ថែម" (បំពេញទៅទីនេះសម្រាប់បុគ្គលបន្ថែមម្នាក់ៗដូចគ្នា និងការបញ្ជាក់នៃសំណើទាំងនោះ ក្នុងប្រអប់តូចទាំងពីរខាងក្រោម) ឬប្រើ "សន្លឹកបន្ត"

បុគ្គលក្នុងប្រអប់នេះគឺជា (គូសតែមួយប៉ុណ្ណោះ) : ☐ អ្នកដាក់ពាក្យសុំ និងតក្កករ ☐ អ្នកដាក់ពាក្យសុំតែប៉ុណ្ណោះ

ឈ្មោះ និង អសយដ្ឋាន :..

....

ប្រសិនបើបុគ្គលដែលបានបញ្ជាក់ក្នុងប្រអប់តូចនេះគឺជាអ្នកដាក់ពាក្យសុំ (ឬ អ្នកដាក់ពាក្យសុំ និងអ្នកបង្កើតស្នាដៃ) ចូរបញ្ជាក់ផងដែរនូវ :

សញ្ជាតិ :.. ប្រទេសស្នាក់នៅ:..

បុគ្គលក្នុងប្រអប់នេះគឺជា (គូសតែមួយប៉ុណ្ណោះ) : ☐ អ្នកដាក់ពាក្យសុំ និងតក្កករ ☐ អ្នកដាក់ពាក្យសុំតែប៉ុណ្ណោះ

ឈ្មោះ និង អសយដ្ឋាន:..

....

ប្រសិនបើបុគ្គលដែលបានបញ្ជាក់ក្នុងប្រអប់តូចនេះគឺជាអ្នកដាក់ពាក្យសុំ (ឬ អ្នកដាក់ពាក្យសុំ និងតក្កករ) ចូរបញ្ជាក់ផងដែរនូវ :

សញ្ជាតិ :.. ប្រទេសស្នាក់នៅ:..

ប្រអប់លេខ ៤

ភ្នាក់ងារ (ប្រសិនបើមាន) ឬតំណាងរួម (ប្រសិនបើមាន) ៖ អសយដ្ឋានសម្រាប់ជូនដំណឹង (ក្នុងករណីចាំបាច់) ៖

អ្នកតំណាងរួមអាចត្រូវបានគេចាត់តាំងឡើងចំពោះតែក្នុងករណី ប្រសិនបើមានអ្នកដាក់ពាក្យសុំច្រើននាក់ និងប្រសិនបើពុំមានចាត់តាំងភ្នាក់ងារ : អ្នកតំណាងរួមត្រូវតែជាអ្នកណាម្នាក់នៃអ្នកដាក់ពាក្យសុំទាំងនោះ ។ បុគ្គលខាងក្រោមនេះ (អាចរួមមានអង្គភាពស្របច្បាប់ណាមួយ) ត្រូវបានចាត់តាំងជាភ្នាក់ងារ ឬ ជាតំណាងរួមដើម្បីអនុវត្ត ក្នុងនាមជាអ្នកដាក់ពាក្យសុំ (ម្នាក់ ឬ ច្រើននាក់) នៅចំពោះមុខមន្ត្រីកាន់កាប់បញ្ជី ។

ឈ្មោះ និង អសយដ្ឋានរួមទាំងលេខកូដប្រៃសណីយ៍របស់ភ្នាក់ងារ :..

....

លេខទូរស័ព្ទ (រួមទាំងលេខកូដតំបន់) :..

លេខទូរសារ :.. អសយដ្ឋានអ៊ីម៉ែល:..

ប្រអប់លេខ ៥

សំណុំលិខិតស្នើសុំបំបែក

សំណុំលិខិតស្នើសុំនេះ គឺជាសំណុំលិខិតស្នើសុំបំបែក ។ គុណប្រយោជន៍នៃកាលបរិច្ឆេទសុំចុះបញ្ជី កាលបរិច្ឆេទអាទិភាពនៃសំណុំលិខិតស្នើសុំពីដំបូងត្រូវបានអះអាងដោយហេតុថា កម្មវត្ថុនៃសំណុំលិខិតស្នើសុំបំបែកនេះ រួមមាននៅក្នុងសំណុំលិខិតស្នើសុំពីមុន ដែលត្រូវបានបញ្ជាក់ដូចខាងក្រោម :

លេខនៃសំណុំលិខិតស្នើសុំពីមុន :..

កាលបរិច្ឆេទនៃសំណុំលិខិតស្នើសុំពីមុន :..

ប្រអប់លេខ ៦

ការបញ្ចេញឱ្យដឹង ដែលមិនយកជាបានការសម្រាប់គោលបំណងនៃស្នាដៃថ្មី ៖ ការបញ្ចេញឱ្យដឹងដែលកើតឡើងក្នុងអំឡុងមិនលើសពីដប់ពីរ (១២) ខែ មុនកាលបរិច្ឆេទសុំចុះបញ្ជី ឬកាលបរិច្ឆេទអាទិភាពនៃសំណុំលិខិតស្នើសុំនេះ :

☐ ដោយមូលហេតុ ឬជាផលវិបាកនៃសកម្មភាពរបស់អ្នកដាក់ពាក្យសុំ ឬអ្នកស្នងរបស់បុព្វជននៃអ្នកដាក់ពាក្យសុំ ។

☐ ដោយមូលហេតុ ឬជាផលវិបាកនៃការរំលោភបំពានដែលប្រព្រឹត្តឡើងដោយភាគីទីបីលើសិទ្ធិរបស់អ្នកដាក់ពាក្យសុំ ឬអ្នកស្នងរបស់បុព្វជននៃអ្នកដាក់ពាក្យសុំ ។

ប្រអប់លេខ ៧

សេចក្តីអះអាងអំពីអាទិភាព (ប្រសិនបើមាន) ។ សូមអះអាងអំពីអាទិភាពនៃសំណុំលិខិតស្នើសុំដែលបានដាក់មុនដូចតទៅ :

ប្រទេស ឬការិយាល័យដែលបានដាក់សំណុំលិខិតស្នើសុំ : (ប្រសិនបើសំណុំលិខិតស្នើសុំដែលបានដាក់មុន ជាសំណុំលិខិតស្នើសុំថ្នាក់តំបន់ ឬសំណុំលិខិតស្នើសុំអន្តរជាតិ ត្រូវបញ្ជាក់អំពីឈ្មោះការិយាល័យ និង ឈ្មោះប្រទេសដែលសំណុំលិខិតស្នើសុំនោះបានដាក់) :	កាលបរិច្ឆេទសុំចុះបញ្ជី (ថ្ងៃ,ខែ,ឆ្នាំ)	លេខសំណុំលិខិតស្នើសុំ	និមិត្តសញ្ញានៃចំណាត់ថ្នាក់អន្តរជាតិរបស់ប្រកាសនីយបត្រតក្កកម្ម
១			
២			
៣			
៤			
៥			

លិខិតបញ្ជាក់អំពីសំណុំលិខិតស្នើសុំដែលបានដាក់មុន

☐ ត្រូវបានភ្ជាប់មកជាមួយសំណុំលិខិតស្នើសុំនេះ ☐ ត្រូវបានផ្តល់ជូនក្នុងរយៈពេលបួន(៤)ខែ គិតចាប់ពីកាលបរិច្ឆេទសុំចុះបញ្ជីនៃសំណុំលិខិតស្នើសុំ

ប្រអប់លេខ ៨

ការត្រួតពិនិត្យឯកសារ(ត្រូវបំពេញដោយអ្នកដាក់ពាក្យសុំ)

សំណុំលិខិតស្នើសុំនេះរួមមាន :	សំណុំលិខិតស្នើសុំត្រូវមានឯកសារភ្ជាប់មកជាមួយដូចខាងក្រោម :
១. ពាក្យសុំ .... សន្លឹក	១. ☐ លិខិតប្រគល់សិទ្ធិដោយឡែក / ចាត់តាំងភ្នាក់ងារតំណាង
២. សេចក្តីអធិប្បាយ .... សន្លឹក	២. ☐ លិខិតចតម្លងនៃការប្រគល់សិទ្ធិទូទៅ
៣. សេចក្តីអះអាង .... សន្លឹក	៣. ☐ សេចក្តីថ្លែងបញ្ជាក់អំពីសិទ្ធិរបស់អ្នកដាក់ពាក្យសុំ
៤. ខ្លឹមសារសង្ខេប .... សន្លឹក	៤. ☐ សេចក្តីថ្លែងបញ្ជាក់អំពីការបង្ហាញឱ្យគេដឹងមួយចំនួនដែលមិនយកជាបានការ
៥. គំនូសបង្ហាញ .... សន្លឹក	៥. ☐ ឯកសារអាទិភាព (សូមមើលប្រអប់លេខ ៧)
	៦. ☐ លិខិតបញ្ជាក់នៃសំណុំលិខិតស្នើសុំដំបូង
សរុប : .... សន្លឹក	៧. ☐ សេចក្តីបកប្រែជាភាសាអង់គ្លេសនៃសំណុំលិខិតស្នើសុំដែលបានដាក់មុនគេ ដែលការអះអាងអាទិភាពត្រូវបានយកធ្វើជាមូលដ្ឋាន
គំនូរលេខ....................................នៃគំនូសបង្ហាញ (ប្រសិនបើមាន) ត្រូវបានស្នើសុំភ្ជាប់ទៅនឹងខ្លឹមសារសង្ខេប ដើម្បីធ្វើការផ្សព្វផ្សាយ ។	៨. ☐ វិក័យបត្រនៃការបង់ប្រាក់
	៩. ☐ ឯកសារផ្សេងៗ (សូមបញ្ជាក់)

ប្រអប់លេខ ៩

ការសុំពន្យារការចោះពុម្ពផ្សាយ

តើអ្នកដាក់ពាក្យស្នើសុំពន្យារការចុះផ្សាយឬទេ? ☐ មាន ☐ គ្មានទេ

ប្រសិនបើមានរយៈពេលពន្យារគឺ :...................................ខែ

ប្រអប់លេខ ១០

ហត្ថលេខាអ្នកដាក់ពាក្យសុំ ឬភ្នាក់ងារ ត្រាមានចិត្រា ឈ្មោះ

ហត្ថលេខា *... ....

(កាលបរិច្ឆេទ)

*ដាក់ឈ្មោះនៅក្រោមហត្ថលេខា

ប្រសិនបើពាក្យសុំនាពេលបច្ចុប្បន្នត្រូវបានចុះហត្ថលេខាដោយភ្នាក់ងារម្នាក់ តំណាងឱ្យអ្នកដាក់ពាក្យសុំ នោះចាំបាច់ត្រូវមានលិខិតបញ្ជាក់ប្រគល់សិទ្ធិដោយឡែកមួយក្នុងការចាត់តាំងភ្នាក់ងារនោះ ដែលចុះហត្ថលេខាដោយអ្នកដាក់ពាក្យសុំ ។ ប្រសិនបើមានដូចករណីនេះ សំណូមពរឱ្យប្រើលិខិតប្រគល់សិទ្ធិទូទៅមួយ(ដែលតំកល់ទុកនៅនាយកដ្ឋានកម្មសិទ្ធិឧស្សាហកម្ម) លិខិតថតចម្លងនៃលិខិតប្រគល់សិទ្ធិត្រូវតែភ្ជាប់មកជាមួយសំណុំលិខិតស្នើសុំនេះ ។

ត្រូវបំពេញដោយមន្ត្រីកាន់កាប់បញ្ជី

១. កាលបរិច្ឆេទនៃការទទួលការកែតម្រូវ ឬកាលបរិច្ឆេទនៃការទទួលឯកសារដែលបានដាក់ក្រោយគេសម្រាប់ការបំពេញឱ្យគ្រប់គ្រាន់នូវសំណុំលិខិតស្នើសុំ :

២. កាលបរិច្ឆេទទទួលកម្រៃ :..

ប្រអប់បន្ថែម ចូរប្រើប្រអប់នេះក្នុងករណីដូចតទៅ :

(១) ប្រសិនបើមានគ្នាច្រើនជាងចំនួនបីនាក់ ត្រូវបានជាប់ពាក់ព័ន្ធនឹងអ្នកដាក់ពាក្យសុំនិង / ឬតក្កករ : ក្នុងករណីនេះចូរសរសេរប្រអប់បន្ថែមលេខ 3 និង បញ្ជាក់ឱ្យដឹងសម្រាប់បុគ្គលបន្ថែមម្នាក់ៗនូវប្រភេទពត៌មានដូចគ្នា ដូចដែលបានស្នើសុំឱ្យបំពេញនៅក្នុងប្រអប់លេខ ៣។

(២) ប្រសិនបើមានសំណុំលិខិតស្នើសុំអះអាងអាទិភាពលើសពីប្រាំឡើងទៅ : ក្នុងករណីនេះចូរបញ្ជាក់ក្នុងការបន្តរបស់ប្រអប់លេខ ៧ និងបញ្ជាក់បន្ថែមលើសំណុំលិខិតស្នើសុំដែលបានដាក់មុនគេនីមួយៗនោះនូវប្រភេទពត៌មានដូចគ្នា ដូចដែលបានតម្រូវឱ្យបំពេញនៅក្នុងប្រអប់លេខ ៧ ។

(៣) ប្រសិនបើនៅក្នុងប្រអប់ទាំងនោះគ្មានប្រអប់ទំនេរគ្រប់គ្រាន់សម្រាប់ផ្តល់ពត៌មាន ក្នុងករណីដូចនេះសូមសរសេរប្រអប់បន្តលេខ (ចូរសរសេរដាក់លេខនៃប្រអប់) ហើយសូមផ្តល់ពត៌មានក្នុងរបៀបដូចគ្នាដែលបានតម្រូវឱ្យបំពេញ ដោយយោងទៅតាមបញ្ហាដែលត្រូវអធិប្បាយនៅក្នុងប្រអប់ដែលពុំមានកន្លែងគ្រប់គ្រាន់នោះ។

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
Ministry of Industry, Mines and Energy
N° ៧១៥ ឧ.ក.ក.រ-ប្រក.

រាជធានីភ្នំពេញ, ថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០០៦

លិខិតចូល
ថ្ងៃទី១២...ខែ... 2006

ប្រកាស

រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/ រកត / ០៧០៤/ ១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/ ០១៩៦/ ០៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើត ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
- បានឃើញអនុក្រឹត្យលេខ ៣៥ អនក្រ.បក ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
- បានឃើញលិខិតលេខ ១៦៥៨/០៦ គ.វ.ក ចុះថ្ងៃទី២៨.០៤.២០០៦ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- យោងពាក្យស្នើរបស់ក្រុមហ៊ុន ផានថេសសា ហ្គាមេន (ខេមបូឌា) ចុះថ្ងៃទី១២.០៤.២០០៦

សំរេច

ប្រការ១: អនុញ្ញាតឱ្យក្រុមហ៊ុន ផានថេសសា ហ្គាមេន (ខេមបូឌា) (PANTESSA GARMENT (CAMBODIA) CO., LTD.) តំណាងដោយ លោក HSIEH MING-DER សញ្ជាតិចិន(តៃវ៉ាន់) អាយុ៤៦ឆ្នាំ កាន់លិខិតឆ្លងដែនលេខ 132889916 ចុះថ្ងៃទី២៩.០១.២០០២ បង្កើតរោងចក្រ “កាត់ដេរសម្លៀកបំពាក់” ដែលមានឈ្មោះថា “ផានថេសសា ហ្គាមេន (ខេមបូឌា) (PANTESSA GARMENT (CAMBODIA))”មានទីតាំងស្ថិតនៅ ភូមិម៉ែល សង្កាត់ដង្កោ ខណ្ឌដង្កោ រាជធានីភ្នំពេញ ។

<u>ប្រការ២</u>: ក្នុងកិច្ចដំណើរការ ក្រុមហ៊ុនត្រូវផ្តល់ប្លង់គ្រឿងចក្រ-ម៉ាស៊ីន មកក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ក្នុងរយៈពេលយ៉ាងយូរ ពីរខែ ។

<u>ប្រការ៣</u>: រោងចក្រនេះ ត្រូវបានអនុញ្ញាតឱ្យ "កាត់ដេរសម្លៀកបំពាក់" ហើយត្រូវធ្វើរបាយការណ៍ប្រចាំខែអំពីស្ថានភាពផលិតកម្មរបស់រោងចក្រ ជូនក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

<u>ប្រការ៤</u>: ក្រុមហ៊ុនត្រូវលើកបង្ហាញ "ផ្លាកឈ្មោះរោងចក្រ " របស់ខ្លួនជាអក្សរខ្មែរមានទំហំធំជាង និងនៅពីលើអក្សរផ្សេងទៀត នៅកន្លែងដែលងាយមើលឃើញនៅខាងមុខរោងចក្រ ។

<u>ប្រការ៥</u>: ការពង្រីកផលិតកម្ម ផ្លាស់ប្តូរមុខផលិតផល ផ្លាស់ប្តូរទីតាំងរោងចក្រ ឬ បង្កើតសាខារោងចក្រ ក្រុមហ៊ុនត្រូវសុំការអនុញ្ញាត ពីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

<u>ប្រការ៦</u>: ក្រុមហ៊ុន ត្រូវធានាសុវត្ថិភាពឧស្សាហកម្ម និង គុណភាពផលិតផល ព្រមទាំងត្រូវគោរពឱ្យបានម៉ឺងម៉ាត់ នូវច្បាប់ និងបទប្បញ្ញត្តិនានា ដែលពាក់ព័ន្ធនឹងផលិតកម្ម អាជីវកម្ម របស់ក្រុមហ៊ុន ។

<u>ប្រការ៧</u>: ក្រុមហ៊ុន ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ចនៃក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ក្នុងគោលបំណងអនុវត្តប្រកាសនេះ ឱ្យមានប្រសិទ្ធភាព ។

<u>ប្រការ៨</u>: ក្នុងករណីរោងចក្រផ្អាកដំណើរការជាប់ៗគ្នាក្នុងរយៈពេល១២ខែ ឬ ប្រព្រឹត្តល្មើសច្បាប់ ឬ ល្មើសធ្ងន់ធ្ងរនឹងប្រការណាមួយ ដែលបានចែងខាងលើ ប្រកាសនេះនឹងត្រូវដកហូត ដោយគ្មានសំណងអ្វីឡើយ ។

<u>ប្រការ៩</u>: អគ្គនាយកឧស្សាហកម្ម ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរឧស្សាហកម្ម រ៉ែ និង ថាមពល រាជធានីភ្នំពេញ និងប្រធានក្រុមហ៊ុន ផានថៃសសា ហ្គាមេន (ខេមបូឌា) ត្រូវអនុវត្តប្រកាសនេះ តាមមុខការរៀង១ខ្លួន ។

<u>ប្រការ១០</u>: ប្រកាសនេះ មានអនុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខា តទៅ ។

រដ្ឋមន្ត្រី

ស៊ុយ_សែម

<u>ចម្លងជូន</u> :
-ទីស្តីការគណៈរដ្ឋមន្ត្រី
-រាជកិច្ច
-ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
-ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
-ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ
-ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់
-ក្រសួងបរិស្ថាន
-ក្រសួងពាណិជ្ជកម្ម
-សាលាក្រុងភ្នំពេញ
" ដើម្បីជូនជ្រាប "
-ដូចប្រការ ៩ " ដើម្បីអនុវត្ត"
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
Ministry of Industry, Mines and Energy
N° ៧៦៩ ១.២ ក.ក.ប្រក.

រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៦

លិខិតចូល
ថ្ងៃទី ១៤ ខែ កក្កដា ឆ្នាំ 2006

ប្រកាស

រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/ រកត / ០៧០៤/ ១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/ ០១៩៦/ ០៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើត ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
- បានឃើញអនុក្រឹត្យលេខ ៣៥ អនក្រ.បក ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
- បានឃើញលិខិតលេខ ២៣៥៨/០៦ ត.វ.ក ចុះថ្ងៃទី២២.០៦.២០០៦ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- យោងពាក្យស្នើរបស់ក្រុមហ៊ុន អ៊ីយ៉ុន (ខេមបូឌា) ហ្គាមេន ចុះថ្ងៃទី១៥.០៦.២០០៦

សំរេច

ប្រការ១: អនុញ្ញាតឱ្យក្រុមហ៊ុន អ៊ីយ៉ុន (ខេមបូឌា) ហ្គាមេន (EAYUAN (CAMBODIA) GARMENT CO., LTD.) តំណាងដោយ លោក PENG KE សញ្ជាតិចិន អាយុ៣២ឆ្នាំ កាន់លិខិតឆ្លងដែនលេខ G10011604 ចុះថ្ងៃទី ១១.១០.២០០៥ បង្កើតរោងចក្រ "កាត់ដេរសម្លៀកបំពាក់" ដែលមានឈ្មោះថា "អ៊ីយ៉ុន (ខេមបូឌា) ហ្គាមេន (EAYUAN (CAMBODIA) GARMENT)" មានទីតាំងស្ថិតនៅ ភូមិត្រពាំងថ្លឹង សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ ។

៤៥ មហាវិថីព្រះនរោត្តម ខណ្ឌដូនពេញ ភ្នំពេញ ទូរស័ព្ទ : (៨៥៥) ២៣.២១១១៤១ . ទូរសារ : ៨៥៥.២៣.៤២៨២៦៣
45 Preah Norodom Boulevard, Khan Daun Penh, Phnom Penh, Phone : 855.23.211141 , Fax : 855.23.428263

ប្រការ២: ក្នុងកិច្ចដំណើរការ ក្រុមហ៊ុនត្រូវរៀបចំរោងចក្រ ទៅតាមប្លង់ដែលបានតម្កល់ទុកនៅ ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

ប្រការ៣: រោងចក្រនេះ ត្រូវបានអនុញ្ញាតឱ្យ "កាត់ដេរសម្លៀកបំពាក់" ហើយត្រូវធ្វើរបាយការណ៍ប្រចាំខែអំពីស្ថានភាពផលិតកម្មរបស់រោងចក្រ ជូនក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

ប្រការ៤: ក្រុមហ៊ុនត្រូវលើកបង្ហាញ "ផ្លាកឈ្មោះរោងចក្រ" របស់ខ្លួនជាអក្សរខ្មែរមានទំហំធំជាង និងនៅពីលើអក្សរផ្សេងទៀត នៅកន្លែងដែលងាយមើលឃើញនៅខាងមុខរោងចក្រ ។

ប្រការ៥: ការពង្រីកផលិតកម្ម ផ្លាស់ប្តូរមុខផលិតផល ផ្លាស់ប្តូរទីតាំងរោងចក្រ ឬ បង្កើតសាខារោងចក្រ ក្រុមហ៊ុនត្រូវសុំការអនុញ្ញាត ពីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

ប្រការ៦: ក្រុមហ៊ុន ត្រូវធានាសុវត្ថិភាពឧស្សាហកម្ម និង គុណភាពផលិតផល ព្រមទាំងត្រូវគោរពឱ្យបានម៉ឺងម៉ាត់ នូវច្បាប់ និងបទប្បញ្ញត្តិនានា ដែលពាក់ព័ន្ធនឹងផលិតកម្ម អាជីវកម្ម របស់ក្រុមហ៊ុន ។

ប្រការ៧: ក្រុមហ៊ុន ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ចនៃក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ក្នុងគោលបំណងអនុវត្តប្រកាសនេះ ឱ្យមានប្រសិទ្ធភាព ។

ប្រការ៨: ក្នុងករណីរោងចក្រផ្អាកដំណើរការជាប់១ឆ្នាំក្នុងរយៈពេល១២ខែ ឬ ប្រព្រឹត្តល្មើសច្បាប់ ឬ ល្មើសចំពោះប្រការណាមួយ ដែលបានចែងខាងលើ ប្រកាសនេះនឹងត្រូវដកហូត ដោយគ្មានសំណងអ្វីឡើយ ។

ប្រការ៩: ប្រកាសលេខ១០២ កកឧ.ប្រក ចុះថ្ងៃទី១០.០២.២០០០ របស់ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ស្តីពីការបង្កើតរោងចក្រកាត់ដេរ និង ចាក់សម្លៀកបំពាក់ របស់ក្រុមហ៊ុន (FULL VALUE (CAMBODIA) TEXTILES LTD.) ត្រូវចាត់ទុកជានិរាករណ៍។

ប្រការ១០: អគ្គនាយកឧស្សាហកម្ម ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរឧស្សាហកម្ម រ៉ែ និង ថាមពល រាជធានីភ្នំពេញ និងប្រធានក្រុមហ៊ុន អ៊ីយ៉ុន (ខេមបូឌា) ហ្គាមេន ត្រូវអនុវត្តប្រកាសនេះ តាមមុខការរៀងៗខ្លួន ។

ប្រការ១១: ប្រកាសនេះ មានអនុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខា តទៅ ។

រដ្ឋមន្ត្រី

ស៊ុយ សែម

ចម្លងជូន :
-ទីស្តីការគណៈរដ្ឋមន្ត្រី
-រាជកិច្ច
-ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
-ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
-ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ
-ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់
-ក្រសួងបរិស្ថាន
-ក្រសួងពាណិជ្ជកម្ម
-សាលាក្រុងភ្នំពេញ
" ដើម្បីជូនជ្រាប "
-ដូចប្រការ ១០" ដើម្បីអនុវត្ត"
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
Ministry of Industry, Mines and Energy
N° ៣៧៧០ ឧ.ស.ក.រ.ប្រក.

រាជធានីភ្នំពេញ, ថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៥

លិខិតចូល
ថ្ងៃទី ១៤ ខែ កក្កដា ឆ្នាំ 2005

ប្រកាស

រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/ រកត / ០៧០៤/ ១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/ ០១៩៦/ ០៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើត ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
- បានឃើញអនុក្រឹត្យលេខ ៣៥ អនក្រ.បក ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
- បានឃើញលិខិតលេខ ៣២០៩/០៥ គ.វ.ក ចុះថ្ងៃទី ១៩.០៥.២០០៥ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- យោងពាក្យស្នើរបស់ក្រុមហ៊ុន ហ្យុន់ជីន (ខេមបូឌា) ខប ចុះថ្ងៃទី២៥.០៧.២០០៥

សំរេច

ប្រការ១: អនុញ្ញាតឱ្យក្រុមហ៊ុន ហ្យុន់ជីន (ខេមបូឌា) ខប (HYUNJIN (CAMB0DAI) CORP.) តំណាងដោយលោក KIM CHUL សញ្ជាតិកូរ៉េ អាយុ៤៣ឆ្នាំ កាន់លិខិតឆ្លងដែនលេខ TJ0452718 ចុះថ្ងៃទី១៨.០២.២០០៣ បង្កើតរោងចក្រ "កាត់ដេរសម្លៀកបំពាក់" ដែលមានឈ្មោះថា " **ហ្យុន់ជីន (ខេមបូឌា) ខប** (HYUNJIN (CAMBODIA) CORP.)" មានទីតាំងស្ថិតនៅ ភូមិកែវឧត្តម ឃុំត្រពាំងគង ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ ។

ប្រការ២: ក្នុងកិច្ចដំណើរការ ក្រុមហ៊ុនត្រូវផ្តល់ប្លង់គ្រឿងចក្រ-ម៉ាស៊ីន មកក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ក្នុងរយៈពេល ២ខែ យ៉ាងយូរ ហើយរៀបចំរោងចក្រទៅតាមប្លង់ ដែលនឹងតំកល់ទុកនៅក្រសួង ។

៤៥ មហាវិថីព្រះនរោត្តម ខ័ណ្ឌដូនពេញ ភ្នំពេញ ទូរស័ព្ទ : (៨៥៥) ២៣.២១១១៤១ , ទូរសារ : ៨៥៥.២៣.៤២៨២៦៣
45 Preah Norodom Boulevard, Khan Daun Penh, Phnom Penh, Phone : 855.23.211141 , Fax : 855.23.428263

ប្រការ៣: រោងចក្រនេះត្រូវបានអនុញ្ញាតឱ្យ "កាត់ដេរសម្លៀកបំពាក់" ហើយត្រូវធ្វើរបាយការណ៍ប្រចាំខែអំពីស្ថានភាពផលិតកម្មរបស់រោងចក្រ ជូនក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

ប្រការ៤: ក្រុមហ៊ុនត្រូវលើកបង្ហាញ "ផ្លាកឈ្មោះរោងចក្រ " របស់ខ្លួនជាអក្សរខ្មែរមានទំហំធំជាង និងនៅពីលើអក្សរផ្សេងទៀត នៅកន្លែងដែលងាយមើលឃើញនៅខាងមុខរោងចក្រ ។

ប្រការ៥: ការពង្រីកផលិតកម្ម ផ្លាស់ប្តូរមុខផលិតផល ផ្លាស់ប្តូរទីតាំងរោងចក្រ ឬ បង្កើតសាខារោងចក្រ ក្រុមហ៊ុនត្រូវសុំការអនុញ្ញាត ពីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

ប្រការ៦: ក្រុមហ៊ុន ត្រូវធានាសុវត្ថិភាពឧស្សាហកម្ម និង គុណភាពផលិតផល ព្រមទាំងត្រូវគោរពឱ្យបានម៉ឺងម៉ាត់ នូវច្បាប់ និងបទប្បញ្ញត្តិនានា ដែលពាក់ព័ន្ធនឹងផលិតកម្ម អាជីវកម្ម របស់ក្រុមហ៊ុន ។

ប្រការ៧: ក្រុមហ៊ុន ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ចនៃក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ក្នុងគោលបំណងអនុវត្តប្រកាសនេះ ឱ្យមានប្រសិទ្ធភាព ។

ប្រការ៨: ក្នុងករណីរោងចក្រផ្អាកដំណើរការជាប់ៗគ្នាក្នុងរយៈពេល១២ខែ ឬ ប្រព្រឹត្តល្មើសច្បាប់ ឬ ល្មើសធ្ងន់ធ្ងរនឹងប្រការណាមួយ ដែលបានចែងខាងលើ ប្រកាសនេះនឹងត្រូវដកហូត ដោយគ្មានសំណងអ្វីឡើយ ។

ប្រការ៩: អគ្គនាយកឧស្សាហកម្ម ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរឧស្សាហកម្ម រ៉ែ និង ថាមពល ខេត្តកំពង់ស្ពឺ និងប្រធានក្រុមហ៊ុន ហ្សន់ជីន (ខេមបូឌា) ខប ត្រូវអនុវត្តប្រកាសនេះ តាមមុខការរៀងៗខ្លួន ។

ប្រការ១០: ប្រកាសនេះមានអនុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខា តទៅ ។

រដ្ឋមន្ត្រី

ស៊ុយ_សែម

ចម្លងជូន :
- ទីស្តីការគណៈរដ្ឋមន្ត្រី
- រាជកិច្ច
- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់
- ក្រសួងបរិស្ថាន
- ក្រសួងពាណិជ្ជកម្ម
- សាលាខេត្តកំពង់ស្ពឺ

" ដើម្បីជូនជ្រាប "

- ដូចប្រការ ៩ " ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
Ministry of Industry, Mines and Energy
N° ៣៧៦១ ឧរថ.កវ.ប្រក

រាជធានីភ្នំពេញ, ថ្ងៃទី ០៥ ខែ កក្កដា ឆ្នាំ ២០០៦

លិខិតចូល
ថ្ងៃទី...ខែ...ឆ្នាំ20...

ប្រកាស

រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/ រកត / ០៧០៤/ ១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/ ០១៩៦/ ០៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើត ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
- បានឃើញអនុក្រឹត្យលេខ ៣៥ អនក្រ.បក ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ១៩៩៩ ស្ដីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
- បានឃើញលិខិតលេខ ០០៩ ស ជ ណ ចុះថ្ងៃទី ០៩.១២.២០០៥ របស់អនុគណៈកម្មាធិការវិនិយោគក្រុងព្រះសីហនុ
- បានឃើញលិខិតលេខ ១៦២ ឧសក រថ. កសន ចុះថ្ងៃទី១៦.០៦.២០០៦ របស់មន្ទីរឧស្សាហកម្ម រ៉ែ និង ថាមពល ក្រុងព្រះសីហនុ
- យោងពាក្យស្នើរបស់ក្រុមហ៊ុន អឺរូហ្គេត ហ្គាមេន ចុះថ្ងៃទី២៨.១០.២០០៥

សំរេច

ប្រការ១: អនុញ្ញាតឱ្យក្រុមហ៊ុន អឺរូហ្គេត ហ្គាមេន (EUROGATE GARMENT LIMITED) តំណាងដោយលោក PARK SANG HO សញ្ជាតិកូរ៉េ អាយុ៥៣ឆ្នាំ កាន់លិខិតឆ្លងដែនលេខ DJ0021377 ចុះថ្ងៃទី៣០.០៩.២០០៥ បង្កើតរោងចក្រ “កាត់ដេរសម្លៀកបំពាក់” ដែលមានឈ្មោះថា “អឺរូហ្គេត ហ្គាមេន (EUROGATE GARMENT)” មានទីតាំងស្ថិតនៅ មណ្ឌល១ សង្កាត់១ ខណ្ឌមិត្តភាព ក្រុងព្រះសីហនុ ។

៤៥ មហាវិថីព្រះនរោត្តម ខ័ណ្ឌដូនពេញ ភ្នំពេញ ទូរស័ព្ទ : (៨៥៥) ២៣.២១១១៤១ . ទូរសារ : ៨៥៥.២៣.៤២៨២៦៣
45 Preah Norodom Boulevard, Khan Daun Penh, Phnom Penh, Phone : 855.23 211141 , Fax : 855.23.428263

ប្រការ២: ក្នុងកិច្ចដំណើរការ ក្រុមហ៊ុនត្រូវរៀបចំរោងចក្រទៅតាមប្លង់ ដែលបានតំកល់ទុកនៅក្នុងក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

ប្រការ៣: រោងចក្រនេះត្រូវបានអនុញ្ញាតឱ្យ "កាត់ដេរសម្លៀកបំពាក់" ហើយត្រូវធ្វើរបាយការណ៍ប្រចាំខែអំពីស្ថានភាពផលិតកម្មរបស់រោងចក្រ ជូនក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

ប្រការ៤: ក្រុមហ៊ុនត្រូវលើកបង្ហាញ "ផ្លាកឈ្មោះរោងចក្រ " របស់ខ្លួនជាអក្សរខ្មែរមានទំហំធំជាង និងនៅពីលើអក្សរផ្សេងទៀត នៅកន្លែងដែលងាយមើលឃើញនៅខាងមុខរោងចក្រ ។

ប្រការ៥: ការពង្រីកផលិតកម្ម ផ្លាស់ប្តូរមុខផលិតផល ផ្លាស់ប្តូរទីតាំងរោងចក្រ ឬ បង្កើតសាខារោងចក្រ ក្រុមហ៊ុនត្រូវសុំការអនុញ្ញាត ពីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

ប្រការ៦: ក្រុមហ៊ុន ត្រូវធានាសុវត្ថិភាពឧស្សាហកម្ម និង គុណភាពផលិតផល ព្រមទាំងត្រូវគោរពឱ្យបានម៉ឺងម៉ាត់ នូវច្បាប់ និងបទប្បញ្ញត្តិនានា ដែលពាក់ព័ន្ធនឹងផលិតកម្ម អាជីវកម្ម របស់ក្រុមហ៊ុន ។

ប្រការ៧: ក្រុមហ៊ុន ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ចនៃក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ក្នុងគោលបំណងអនុវត្តប្រកាសនេះ ឱ្យមានប្រសិទ្ធភាព ។

ប្រការ៨: ក្នុងករណីរោងចក្រផ្អាកដំណើរការជាប់ៗគ្នាក្នុងរយៈពេល១២ខែ ឬ ប្រព្រឹត្តល្មើសច្បាប់ ឬ ល្មើសធ្ងន់ធ្ងរនឹងប្រការណាមួយ ដែលបានចែងខាងលើ ប្រកាសនេះនឹងត្រូវដកហូត ដោយគ្មានសំណងអ្វីឡើយ ។

ប្រការ៩: ប្រកាសលេខ៣៧៥ ផក.ប្រក ចុះថ្ងៃទី១០.០៦.១៩៩៦ របស់ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ស្តីពីការបង្កើតរោងចក្រស្បែកជើង ដុងដា របស់ក្រុមហ៊ុន (DONG DA SHOES CAMBODIA COMPANY LTD.) ត្រូវចាត់ទុកជានិរាករណ៍ ។

ប្រការ១០: អគ្គនាយកឧស្សាហកម្ម ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរឧស្សាហកម្ម រ៉ែ និង ថាមពល ក្រុងព្រះសីហនុ និងប្រធានក្រុមហ៊ុន អឺរូហ្គេត ហ្គាមេន ត្រូវអនុវត្តប្រកាសនេះ តាមមុខការរៀង១ខ្លួន ។

ប្រការ១១: ប្រកាសនេះមានអនុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខា តទៅ ។

រដ្ឋមន្ត្រី

ស៊ុយ_សែម

ចម្លងជូន :
-ទីស្តីការគណៈរដ្ឋមន្ត្រី
-រាជកិច្ច
-ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
-ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ
-ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់
-ក្រសួងបរិស្ថាន
-ក្រសួងពាណិជ្ជកម្ម
-អនុគណៈកម្មាធិការវិនិយោគក្រុងព្រះសីហនុ
" ដើម្បីជូនជ្រាប "
-ដូចប្រការ ១០ " ដើម្បីអនុវត្ត"
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
Ministry of Industry, Mines and Energy
N° ៣៧៦ ឧ.ជ.គ.ប្រក.

រាជធានីភ្នំពេញ. ថ្ងៃទី ០៥ ខែ កក្កដា ឆ្នាំ ២០០៦

លិខិតចូល
ថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ 2006

ប្រកាស

រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/ រកត / ០៧០៤/ ១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/ ០១៩៦/ ០៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើត ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
- បានឃើញអនុក្រឹត្យលេខ ៣៥ អនក្រ.បក ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
- បានឃើញលិខិតលេខ ១៩២៨/០៦ គ.វ.ក ចុះថ្ងៃទី ២២.០៥.២០០៦ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- យោងពាក្យស្នើរបស់ក្រុមហ៊ុន ញូ មីងដា (ខេមបូឌា) ចុះថ្ងៃទី ២៤.០៤.២០០៦

សម្រេច

ប្រការ១: អនុញ្ញាតឱ្យក្រុមហ៊ុន ញូ មីងដា (ខេមបូឌា) (NEW MINGDA (CAMBODIA) CO., LTD.) តំណាងដោយលោក DONG AIKANG សញ្ជាតិចិន អាយុ៤១ឆ្នាំ កាន់លិខិតឆ្លងដែនលេខ G 15336424 ចុះថ្ងៃទី ១២.១២. ២០០៥ បង្កើតរោងចក្រ "កាត់ដេរសម្លៀកបំពាក់ " ដែលមានឈ្មោះថា "ញូ មីងដា (ខេមបូឌា) (NEW MINGDA (CAMBODIA))" មានទីតាំងស្ថិតនៅ ភូមិទួលពង្រ សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ ។

៤៥ មហាវិថីព្រះនរោត្តម ខ័ណ្ឌដូនពេញ ភ្នំពេញ ទូរស័ព្ទ : (៨៥៥) ២៣.២១១១៤១ , ទូរសារ : ៨៥៥.២៣.៤២៨២៦៣
45 Preah Norodom Boulevard, Khan Daun Penh, Phnom Penh, Phone : 855.23.211141 Fax . 855.23.428263

ប្រការ២: ក្នុងកិច្ចដំណើរការ ក្រុមហ៊ុនត្រូវផ្តល់ប្លង់ និងលិខិតអនុញ្ញាតសាងសង់ មកក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ក្នុងរយៈពេល ២ខែ យ៉ាងយូរ ។

ប្រការ៣: រោងចក្រនេះ ត្រូវបានអនុញ្ញាតឱ្យ "កាត់ដេរសម្លៀកបំពាក់"ហើយត្រូវធ្វើរបាយការណ៍ប្រចាំខែ អំពីស្ថានភាពផលិតកម្ម របស់រោងចក្រ ជូនក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

ប្រការ៤: ក្រុមហ៊ុនត្រូវលើកបង្ហាញ "ផ្លាកឈ្មោះរោងចក្រ " របស់ខ្លួនជាអក្សរខ្មែរមានទំហំធំជាង និងនៅពីលើអក្សរផ្សេងទៀត នៅកន្លែងដែលងាយមើលឃើញនៅខាងមុខរោងចក្រ ។

ប្រការ៥: ការពង្រីកផលិតកម្ម ផ្លាស់ប្តូរមុខផលិតផល ផ្លាស់ប្តូរទីតាំងរោងចក្រ ឬ បង្កើតសាខារោងចក្រ ក្រុមហ៊ុនត្រូវសុំការអនុញ្ញាត ពីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

ប្រការ៦: ក្រុមហ៊ុន ត្រូវធានាសុវត្ថិភាពឧស្សាហកម្ម និង គុណភាពផលិតផល ព្រមទាំងត្រូវគោរពឱ្យបានម៉ឺងម៉ាត់ នូវច្បាប់ និងបទប្បញ្ញត្តិនានា ដែលពាក់ព័ន្ធនឹងផលិតកម្ម អាជីវកម្ម របស់ក្រុមហ៊ុន ។

ប្រការ៧: ក្រុមហ៊ុន ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ចនៃក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ក្នុងគោលបំណងអនុវត្តប្រកាសនេះ ឱ្យមានប្រសិទ្ធភាព ។

ប្រការ៨: ក្នុងករណីរោងចក្រផ្អាកដំណើរការជាប់ៗគ្នាក្នុងរយៈពេល១២ខែ ឬ ប្រព្រឹត្តល្មើសច្បាប់ ឬ ល្មើសធ្ងន់ធ្ងរនឹងប្រការណាមួយ ដែលបានចែងខាងលើ ប្រកាសនេះនឹងត្រូវដកហូត ដោយគ្មានសំណងអ្វីឡើយ ។

ប្រការ៩: អគ្គនាយកឧស្សាហកម្ម ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរឧស្សាហកម្ម រ៉ែ និង ថាមពល រាជធានីភ្នំពេញ និងប្រធានក្រុមហ៊ុន ញូ មីងដា (ខេមបូឌា) ត្រូវអនុវត្តប្រកាសនេះ តាមមុខការរៀងៗខ្លួន ។

ប្រការ១០: ប្រកាសនេះមានអនុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខា តទៅ ។

រដ្ឋមន្ត្រី

ស៊ុយ សែម

ចម្លងជូន :
- ទីស្តីការគណៈរដ្ឋមន្ត្រី
- រាជកិច្ច
- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់
- ក្រសួងបរិស្ថាន
- ក្រសួងពាណិជ្ជកម្ម
- សាលាក្រុងភ្នំពេញ

" ដើម្បីជូនជ្រាប "

- ដូចប្រការ ៩ " ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
Ministry of Industry, Mines and Energy
N° ៧៦៣ ឧស្សា.កន-ប្រក

រាជធានីភ្នំពេញ, ថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០..

លិខិតចូល
ថ្ងៃទី ១៧ ខែ ... ឆ្នាំ 200..

ប្រកាស

រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/ រកត / ០៧០៤/ ១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/ ០១៩៦/ ០៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើត ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
- បានឃើញអនុក្រឹត្យលេខ ៣៥ អនក្រ.បក ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
- បានឃើញលិខិតលេខ ៥១៩៥/០៥ ត.រ.ក ចុះថ្ងៃទី ៣០.១២.២០០៥ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- យោងពាក្យស្នើរបស់ក្រុមហ៊ុន យ៉ាកជីន (ខេមបូឌា) អ៊ីន ចុះថ្ងៃទី ១៨.១០.២០០៥

សំរេច

ប្រការ១: អនុញ្ញាតឱ្យក្រុមហ៊ុន យ៉ាកជីន (ខេមបូឌា) អ៊ីន (YAKJIN (CAMBODIA) INC.) តំណាងដោយ លោក KIM JAE JUNG សញ្ជាតិកូរ៉េ អាយុ៥៨ឆ្នាំ កាន់លិខិតឆ្លងដែនលេខ 7042907 ចុះថ្ងៃទី២៣.០៨.២០០៤ បង្កើតរោងចក្រ "កាត់ដេរសម្លៀកបំពាក់ " ដែលមានឈ្មោះថា "យ៉ាកជីន (ខេមបូឌា) អ៊ីន (YAKJIN (CAMBODIA) INC.)" មានទីតាំងស្ថិតនៅ ភូមិតាកេរ្តិ៍-ភូមិផ្សារកំបូល-ភូមិព្រៃកុជី ឃុំកំបូល ស្រុកអង្គស្នួល ខេត្តកណ្តាល ។

៤៥ មហាវិថីព្រះនរោត្តម ខ័ណ្ឌដូនពេញ ភ្នំពេញ ទូរស័ព្ទ : (៨៥៥) ២៣.២១១១៤១ . ទូរសារ : ៨៥៥.២៣.៤២៨២៦៣
45 Preah Norodom Boulevard, Khan Daun Penh, Phnom Penh, Phone : 855.23.211141 , Fax : 855.23.428263

ប្រការ២: ក្នុងកិច្ចដំណើរការ ក្រុមហ៊ុនត្រូវផ្តល់ប្លង់គ្រឿងចក្រ-គ្រឿងម៉ាស៊ីន មកក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ក្នុងរយៈពេល ២ខែ យ៉ាងយូរ ។

ប្រការ៣: រោងចក្រនេះ ត្រូវបានអនុញ្ញាតឱ្យ "កាត់ដេរសម្លៀកបំពាក់" ហើយត្រូវធ្វើរបាយការណ៍ប្រចាំខែអំពីស្ថានភាពផលិតកម្ម របស់រោងចក្រ ជូនក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

ប្រការ៤: ក្រុមហ៊ុនត្រូវលើកបង្ហាញ "ផ្លាកឈ្មោះរោងចក្រ " របស់ខ្លួនជាអក្សរខ្មែរមានទំហំធំជាង និងនៅពីលើអក្សរផ្សេងទៀត នៅកន្លែងដែលងាយមើលឃើញនៅខាងមុខរោងចក្រ ។

ប្រការ៥: ការពង្រីកផលិតកម្ម ផ្លាស់ប្តូរមុខផលិតផល ផ្លាស់ប្តូរទីតាំងរោងចក្រ ឬ បង្កើតសាខារោងចក្រ ក្រុមហ៊ុនត្រូវសុំការអនុញ្ញាត ពីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

ប្រការ៦: ក្រុមហ៊ុន ត្រូវធានាសុវត្ថិភាពឧស្សាហកម្ម និង គុណភាពផលិតផល ព្រមទាំងត្រូវគោរពឱ្យបានម៉ឺងម៉ាត់ នូវច្បាប់ និងបទប្បញ្ញត្តិនានា ដែលពាក់ព័ន្ធនឹងផលិតកម្ម អាជីវកម្ម របស់ក្រុមហ៊ុន ។

ប្រការ៧: ក្រុមហ៊ុន ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ចនៃក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ក្នុងគោលបំណងអនុវត្តប្រកាសនេះ ឱ្យមានប្រសិទ្ធភាព ។

ប្រការ៨: ក្នុងករណីរោងចក្រផ្អាកដំណើរការជាប់១ឆ្នាំក្នុងរយៈពេល១២ខែ ឬ ប្រព្រឹត្តល្មើសច្បាប់ ឬ ល្មើសធ្ងន់ធ្ងរនឹងប្រការណាមួយ ដែលបានចែងខាងលើ ប្រកាសនេះនឹងត្រូវដកហូត ដោយគ្មានសំណងអ្វីឡើយ ។

ប្រការ៩: អគ្គនាយកឧស្សាហកម្ម ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរឧស្សាហកម្ម រ៉ែ និង ថាមពល ខេត្តកណ្តាល និងប្រធានក្រុមហ៊ុន យ៉ាកជីន (ខេមបូឌា) អ៊ិន ត្រូវអនុវត្តប្រកាសនេះ តាមមុខការរៀង១ខ្លួន ។

ប្រការ១០: ប្រកាសនេះមានអនុភាពតតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខា តទៅ ។ ភ្នំពេញ

រដ្ឋមន្ត្រី

ស៊ុយ_សែម

ចម្លងជូន :
-ទីស្តីការគណៈរដ្ឋមន្ត្រី
-រាជកិច្ច
-ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
-ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
-ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ
-ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់
-ក្រសួងបរិស្ថាន
-ក្រសួងពាណិជ្ជកម្ម
-សាលាខេត្តកណ្តាល
" ដើម្បីជូនជ្រាប "
-ដូចប្រការ ៩ " ដើម្បីអនុវត្ត"
-ឯកសារ-កាលប្បវត្តិ